
អាន អធិស្ឋាន ចម្រើនជំនឿ
កក្កដា - កញ្ញា ២០២២
ដំណឹងល្អ
នៃជីវិត
បណ្ឌិត ធីម៉ូធី ចូវ
“នៅក្នុងទ្រង់មានជីវិត ហើយ
ជីវិតនោះជាពន្លឺនៃមនុស្សលោក”
(យ៉ូហាន ១:៤)

# ពន្ធ័កិច្ច អាន អធិស្ឋាន រីកចម្រើន

កូនសៀវភៅសម្រាប់អាននាពេលស្ងៀមស្ងាត់ **អាន អធិស្ឋាន រីកចម្រើន** (RPG) ជាព័ន្ធកិច្ចបោះពុម្ពផ្សព្វផ្សាយរបស់ព្រះវិហារ**កាល់វ៉ារី ផាន់ដិន ព្រះគម្ពីរប្រេ៊សប៊ីធីរាន**។ ការប្រែសម្រួលជាភាសាខ្មែរក្រោមពន្ធ័កិច្ចនៃ **ព្រះវិហារ ប៊ីភី ដំណឹងល្អពិត** ខេត្តកំពត ប្រទេសកម្ពុជា។

**អាន អធិស្ឋាន រីកចម្រើន** (អ.អ.រ) **មគ្គុទេសក៍សម្រាប់ការអានព្រះគម្ពីរប្រចាំថ្ងៃ** គឺត្រូវបោះពុម្ពជារៀងរាល់ ត្រីមាសម្តង ដោយរោងពុម្ព **ថៃបឺណាខល ប៊ុកស៍** (Tabernacle Books) ប្រទេសសឹង្ហបូរី។

បច្ចុប្បន្ន ដោយសារព្រះគុណនៃព្រះ **អ.អ.រ** កំពុងជួយគ្រីស្ទបរិស័ទទូទាំងពិភពលោកអានព្រះបន្ទូលយ៉ាងទៀតទាត់និងប្រកបដោយអត្ថន័យ។ អ្នកនិពន្ធសៀវភៅនេះគឺសុទ្ធតែជាគ្រូគង្វាលនិងសាស្រ្តាចារ្យព្រះគម្ពីរដែលប្រកាន់ខ្ជាប់ខ្ជួនតាម គោលជំនឿគ្រីស្ទបរិស័ទបែបអភិរក្សនិយម និងជាអ្នកលើកកំពស់ព្រះគម្ពីរផងដែរ។ **អ.អ.រ** ភាសាអង់គ្លេសប្រើព្រះគម្ពីរឃីង ចែមស៍ (King James Version) សម្រាប់អាន ជាព្រះគម្ពីរនៃចលនាកែទម្រង់ និងភាសាខ្មែរប្រើព្រះគម្ពីរខ្មែរបរិសុទ្ធ ១៩៥៤។ ការទ្រទ្រង់សម្រាប់បោះគឺបានមកតាមរយៈដង្វាយក្តីស្រឡាញ់និងដង្វាយស្ម័គ្រពីចិត្តរបស់រាស្រ្តនៃព្រះ។ យើងខ្ញុំអរព្រះគុណព្រះជាអនេកដោយបានបង្កើតពន្ធ័កិច្ចនេះឡើងហើយរក្សាវាជានិរន្តតាំងពីឆ្នាំ ១៩៨២។

**អ.អ.រ** បោះពុម្ពជាភាសាអង់គ្លេស។ ក្រុមអ្នកបកប្រែដែលមានឆន្ទះខ្ពស់សម្រាប់កូនសៀវភៅនេះបានខិតខំព្យាយាមប្រែសម្រួល**មគ្គុទេសក៍សម្រាប់ការអានព្រះគម្ពីរប្រចាំថ្ងៃ**ពីភាសាអង់គ្លេសមកភាសាខ្មែរប្រយោជន៍ឲ្យគ្រីស្ទបរិស័ទកម្ពុជាមានធុនធានជំនួយសម្រាប់ការសិក្សាព្រះបន្ទូលផ្ទាល់ខ្លួន។ យើងខ្ញុំសូមលើកទឹកចិត្តលោកអ្នក បងប្អូនចុះឈ្មោះសម្រាប់កូនសៀវភៅ ក៏ដូចជាជួយណែនាំមិត្តភក្តិឲ្យបានស្គាល់សៀវភៅនេះផងដែរ។ បើព្រះទ្រង់សព្វព្រះហឫទ័យ យើងខ្ញុំនឹងផ្ញើ **អ.អ.រ** ជូនសម្រាប់អ្នកដែលចង់ប្រើប្រាស់វា។ សូមឲ្យយើងជួយអធិស្ឋានសម្រាប់ពន្ធ័កិច្ចពាក្យបន្ទូលនេះបន្តទៀត។

**អ.អ.រ** ក៏ត្រូវបានបកប្រែជាច្រើនភាសា មានដូចជា ភាសាចិន ភាសាឥណ្ឌូនេស៊ី ភាសាភូមា ជាដើម ។ល។ សូមផ្ញើសាអេឡិចត្រូនិក មកយើងខ្ញុំ ប្រសិនបើលោកអ្នកចង់ចុះឈ្មោះទិញសម្រាប់មិត្តភក្តិ ឬ ក្នុងបំណងផ្សេងៗ។

**អ.អ.រ** ភាសាអង់គ្លេស តាមប្រពន្ធ័អ៊ីធឺណែតមាននៅលើគេហទំព័រ www.calvarypandan.sg/rpg

**អ.អ.រ** ក៏មានជាឯកសារដែលអាចទាយយកសម្រាប់ប្រើប្រាស់តាមប្រពន្ធ័កុំព្យូទ័រ ទូរសព្ទ័ដៃ ឬ ឧបករណ៍អេឡិចត្រូនិកផ្សេងៗទៀតពីគេហទំព័រ www.truthbpc.com/rpg.html

ភាសាអង់គ្លេស៖ សូមទាក់ទងយើងខ្ញុំតាមសាអេឡិចត្រូនិក៖ rpg@calvarypandan.sg (ភាសាអង់គ្លេស)
ភាសាខ្មែរ៖ 012383513/016 960040។

**ខែ កក្កដា-កញ្ញា ២០២២**

# «*ដំណឹងល្អនៃជីវិត*»

***The Gospel of Life***

*ការអត្ថាធិប្បាយបែបអនុវត្តន៍ពីដំណឹងល្អយ៉ូហាន*

**ដោយ**

**បណ្ឌិត ធីម៉ូធី ថូវ**

( *Rev Dr. Timothy Tow* )

**និង**

# «*ដោយមូលហេតុតែ*»

***The Reason Why***

ដោយ **រ៉ូបឺត អេ លេដឡ**

( **Robert A Laidlaw** )

---

## *អំពីអ្នកនិពន្ធៈ*



បណ្ឌិត **ធីម៉ូធី ថូវ** (១៩២០-២០០៩) ជាបិតាស្ថាបនិកចលនាគណៈនិកាយ ព្រះគម្ពីរប្រេ៊ស ប៊ីធីរាន នៅអាស៊ីអាគ្នេយ៍បន្ទាប់ពីលោកបានវិលត្រឡប់មកប្រទេសសិង្ហបុរីក្នុងឆ្នាំ១៩៥០ ដោយសារលោកប្រកាន់តាមចលនាកែទម្រង់សតវត្សទី២០ នៅពេលទទួលការសិក្សានា សាកលវិទ្យាល័យទេវសាស្រ្តជាន់ខ្ពស់ហ្វៀត (*Faith Theological Seminary*)។ បណ្ឌិត ថូវ ជាអតីតគ្រូគង្វាលពួកជំនុំព្រះគម្ពីរប្រេ៊ស ប៊ីធីរានជីវិត (*Life BPC*, ១៩៥០-២០០៣) និងពួកជំនុំព្រះគម្ពីរប្រេ៊សប៊ីធីរានជីវិតពិត (*True Life BPC*, ២០០៣-២០០៩) ហើយជានាយកមហាវិទ្យាល័យព្រះគម្ពីរ ហ្វាអ៊ីស្ទើន (*Far Eastern Bible College*, ១៩៦២-២០០៩)។ ក្នុងនាម ជាអ្នកផ្តត់ផ្គង់អត្ថបទដ៏ទៀងទាត់សម្រាប់ការបោះពុម្ព អធិស្ឋាន និង រីករាយចម្រើន (RPG) លោកក៏បាននិពន្ធសៀវភៅ ជាង៣៥ក្បាល។ «**ដំណឹងល្អនៃជីវិត**» គឺជាស្នាដៃនិពន្ធរបស់លោកដែលបានបោះពុម្ពក្នុងឆ្នាំ ១៩៨៣ បច្ចុប្បន្នត្រូវបានប្រែសម្រួលជាភាសាខ្មែរដោយសង្ឃឹមថាមិត្តអាននឹងស្វែងរកដំណោះស្រាយសម្រាប់បញ្ហាជាច្រើនក្នុងជីវិតក៏ដូច ជាការរកឃើញនូវសេចក្តីអំណរក្នុងជីវិតដ៏ពេញបរិបូរដែរ។ សូមឲ្យព្រះនាមនៃព្រះយេស៊ូវគ្រីស្ទបានដំកើងឡើងតាមរយៈជីវិតគ្រីស្ទបរិស័ទកម្ពុជា។ អាម៉ែន!

# **បុព្វកថា**

**អៈអៈរ** ឬ **អាន អធិស្ឋាន រីកចម្រើន**! កូនព្រះគ្រប់រូបត្រូវរីកចម្រើន។ រីកចម្រើនទាល់តែអ្នកញ៉ាំអាហារ! លុះត្រាលោកអ្នកញ៉ាំទឹកដោះដែលជាពាក្យបន្ទូល អ្នកនឹងមិនរីកចម្រើនដូចបំណងឡើយ។

ចំណង់ស្រេកឃ្លានខាងផ្នែកព្រលឹងវិញ្ញាណមិនមែនជាធម្មតាកើតឡើងទេ តែដោយការខិតខំលត់ដំនិងការអប់រំដ៏អត់ធ្មត់ប៉ុណ្ណោះ។ គ្រីស្ទបរិស័ទជាច្រើនបានបរាជ័យព្រោះតែពួកគាត់គ្មានវិធីសាស្ត្រ។ ចេតនាល្អគឺមិនទាន់គ្រប់គ្រាន់ឡើយ។ ប្រពន្ធ័និងវិធីសាស្ត្រជួយឲ្យមានការលត់ដំនិងចំណង់ស្រេកឃ្លាន (ផ្នែកព្រលឹងវិញ្ញាណ)។

អត្ថបទ **អៈអៈរ** បង្កើតឲ្យមានការអានព្រះគម្ពីរប្រចាំថ្ងៃតាមវិធីសាស្ត្រនិងបែបជាប្រពន្ធ័។ រយៈពេលដប់ប្រាំនាទីក្នុងមួយថ្ងៃនឹងធ្វើឲ្យអ្នកអានស្ថិតនៅលើដងវិថីដ៏មានសុខមាលល្អនិងព្រលឹងវិញ្ញាណរីកចម្រើនយ៉ាងរស់រវើក។ ជាគ្រូគង្វាល គ្រូបង្រៀនពាក្យបន្ទូល និងជាអ្នកទេវសាស្ត្រ បណ្ឌិត ធីម៉ូធី ថូវ មានបទពិសោធន៍និពន្ធជាងសាមសិបឆ្នាំ។ ដូចជាចុងភៅចិនចម្អិនអាហារសម្រាប់ភោជនីដ្ឋានដ៏ល្បីម្នាក់ គាត់ផ្ដល់អាហារដ៏ឱជារសដែលមានរសជាតិប្លែកៗគ្នាគួរឲ្យចង់បរិភោគជាច្រើនដល់ផ្នែកព្រលឹងវិញ្ញាណរបស់យើង។ សូមអញ្ជើញលោកអ្នកក្រេបរសជាតិពីទំព័រទាំងឡាយនៃកូនសៀវភៅនេះចុះ។

ពាក្យក្នុងបុព្វកថាមុខនេះបោះពុម្ពជាមួយការអធិស្ឋានសូមឲ្យព្រះវិញ្ញាណបរិសុទ្ធនៃព្រះចិញ្ចឹមបីបាច់និង ចម្រើនកម្លាំងជីវិតជាគ្រីស្ទបរិស័ទរបស់អ្នកនៅពេលលោកអ្នកអានសៀវភៅ **អៈអៈរ** នេះ!

**បណ្ឌិត ថូវ ស៊ាង ហ៊** (Rev. Dr. Tow Siang Hwa)

# **អារម្ភកថា**

កម្រងអត្ថាធិប្បាយបែបអនុវត្តន៍ពីដំណឹងល្អនិងសំបុត្ររបស់យ៉ូហានគឺជាការងារដោយក្តីស្រឡាញ់រយៈ ពេលប្រាំខែសម្រាប់សៀវភៅ **អាន អធិស្ឋាន រីកចម្រើន** (**អ.អ.រ**) ជាសៀវភៅលំហាត់នៃ**ការអាន ព្រះគម្ពីរប្រចាំថ្ងៃ**សម្រាប់មនុស្សគ្រប់រូប បោះពុម្ពលេខ ៨-១៣។

គោលបំណងចម្បងនៃសៀវភៅនេះគឺដើម្បីបញ្ជ្រាបទឹកចិត្តគ្រីស្ទបរិស័ទឲ្យអានព្រះគម្ពីររបស់ខ្លួនជាប្រចាំថ្ងៃ។ តាមរយៈការពន្យល់បកស្រាយពាក្យពីជំពូកមួយទៅជំពូកមួយ ពីផ្នែកមួយទៅផ្នែកមួយ ជាពិសេសនូវខគម្ពីរពិបាកៗប្រយោជន៍ឲ្យបានយល់និងប្រតិបត្តិតាមក្នុងជីវិតប្រចាំថ្ងៃរបស់យើង មេរៀនពន្យល់បកស្រាយទាំងនេះនឹងក្លាយជាអាហារផ្នែកព្រលឹងវិញ្ញាណដែលមនុស្សជាច្រើនបានបរិភោគដោយអំណររីករាយ។

ភ្ជាប់ជានឹងមូលហេតុដែលដំណឹងល្អនិងសំបុត្រយ៉ូហានត្រូវបានក្លាយជាកំណប់គឺក្នុងសេចក្តីផ្តើមរបស់វាដែល ប៊ីហ្សប ជេ ស៊ី រ៉ៃល (Bishop J.C. Ryle) បានផ្តល់ចំណាប់អារម្មណ៍ថាជាសៀវភៅដ៏វិសេសនៅក្នុងព្រះគម្ពីរទាំងមូល។ ពីព្រោះនៅក្នុងដំណឹងល្អនិងនៅក្នុងបណ្តាសំបុត្រនេះសាវ័កនៃសេក្តីស្រឡាញ់បានដឹកនាំយើងចូលទៅក្នុងការប្រកបគ្នាដ៏ជិតស្និទ្ធនឹងព្រះដ៏ជាម្ចាស់ដែលគ្មានសាវ័ក ឬហោរាណាម្នាក់ពីមុនធ្លាប់បានដឹកនាំយើងយ៉ាងដូច្នេះឡើយ។ ហើយការប្រកបគ្នាដ៏ស្និទ្ធស្នាលនេះគឺអាចកើតឡើងបានលុះត្រាតែបន្ទាប់ពីលោកអ្នកបានជ្រួតជ្រាបនឹងពាក្យបន្ទូលជីវិត ព្រមទាំងបានទទួលជីវិតដ៏អស់កល្បតាមរយៈការជឿប៉ុណ្ណោះ។ តើអ្នកជឿព្រះយេស៊ូវជាព្រះគ្រីស្ទជាព្រះរាជបុត្រានៃព្រះ ?

នេះគឺជា**សៀវភៅនៃជីវិត**ប្រទានដល់មនុស្សជាតិដែលកំពុងស្លាប់។ បើមានការរួមចំណែករបស់អ្នកតាមរយៈការណែនាំវាដល់ព្រលឹងវិញ្ញាណដែលបាត់ នោះគេនឹងស្វែងរកជីវិតដ៏អស់កល្បឃើញដូចលោកអ្នកដែរ ហើយការចងក្រងអត្ថបទ **អ.អ.រ** ជាសៀវភៅមួយក្បាលនេះនឹងមិនជាអសារឥតការឡើយ។ អាម៉ែន!

**ធីម៉ូធី ថូវ** (T.T)

# ១. ដំណើរយាងមកជាលើកទីពីររបស់ទ្រង់

តាមរយៈការមានបន្ទូលប្រាប់ដល់សិស្សពីដំណើរយាងមកជាលើកទីពីរ ព្រះយេស៊ូវផ្តល់ការបង្រៀនដល់គេដែលពួកជំនុំហៅថាក្តីសង្ឃឹមដ៏មានពរ។ ព្រះយេស៊ូវគឺជាផ្លូវតែមួយទៅកាន់ព្រះ ប៉ុន្តែផ្លូវនេះមិនមែនជាផ្លូវសម្រាប់តែទ្រង់ផ្ទាល់យាងត្រឡប់ទៅឯដំណាក់ព្រះវរបិតាជារៀងរហូតឡើយ។ វាគឺជាផ្លូវធ្វើចរាចរណ៍ទៅមកបាន ដូចនេះព្រះអង្គនឹងយាងត្រឡប់មកទទួលយើងទៅជាមួយទ្រង់។ ដូច្នេះទើបទ្រង់បានផ្តើមបង្រៀនថា «កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភឡើយ» (១៤:១)។

ជំពូកដ៏ល្អប្រសើរពិពណ៌នាពីដំណើរយាងមករបស់ទ្រង់គឺ ១ ថែស្សាឡូនីច ៤:១៣-១៨។ ការយាងមកជាលើកទី២របស់ព្រះយេស៊ូវនឹងមិនដូចជាការយាងមកលើកទី១របស់ទ្រង់ឡើយ។ ដំណើរយាងមកនោះនឹងមិនបន្ទាបខ្លួនគង់នៅក្នុងស្នូកសត្វទៀតទេ តែនឹងមានសម្លេងត្រែផ្លុំដោយពួកទេវតាឮសូរដូចជាសម្លេងគ្រាប់បរម៉ាណូនិងសិរីល្អនៃពួកទេវតាសម្តែងមកឲ្យឃើញនៅក្នុងពពកដល់ផែនដីទាំងមូលវិញ។

នាដំណើរយាងមកជាលើកទីពីរពួកអ្នកស្លាប់ក្នុងព្រះគ្រីស្ទនឹងប្រោសឲ្យរស់ឡើងវិញជាមួយនឹងរូបកាយថ្មីជារូបកាយឧត្តម។ ពួកគេនឹងត្រូវបានលើកភ្លាមៗដែលមានគ្រីស្ទបរិស័ទនៅមានជីវិតលើកឡើងឬស្រង់ឡើងយ៉ាងលឿនដូចជាផ្លេកបន្ទោរតាមក្រោយគេ។ ព្រឹត្តិការណ៍មហាភ័យនៃផ្នែកដ៏គួរឲ្យអស្ចារ្យបែបនេះបង្កឲ្យនឹកស្មានមិនដល់។

គ្រីស្ទបរិស័ទខ្លះដែលសិក្សាសៀវភៅវិវរណៈនិងបំណែកនៃបទទំនាយផ្សេងៗទៀតនៃព្រះគម្ពីរស្តីពីថ្ងៃចុងក្រោយ ជជែកវែកញែកជាច្រើនអំពីពេលជាក់លាក់របស់ព្រឹត្តិការណ៍លើកឡើង (*Rapture*)។ នេះគឺប្រៀប ដូចជាការទៅជិះរថភ្លើងមានតែកាលវិភាគធ្វើដំណើរដូច្នោះដែរ។ ព្រះយេស៊ូវមិនបានសង្កត់ធ្ងន់ទៅលើពេលវេលានៃដំណើរយាងមករបស់ទ្រង់ទេ តែអំពីការត្រៀមលក្ខណៈរបស់យើងដើម្បីជួបនឹងទ្រង់វិញ។ ពួកអ្នកដែលមានសេចក្តីពិតរបស់ទ្រង់និងជីវិតរបស់ទ្រង់នឹងទៅជាមួយព្រះអង្គដែលទ្រង់គឺជាផ្លូវ។ សំណួរស្មោះពីចិត្តនៃជំនឿដ៏គ្មានបទពិសោធន៍របស់សាវ័កថូម៉ាសនាំយើងគ្រប់រូបដែលបានអានជំពូកនេះព្រមទាំងបានជឿទ្រង់ទៅក្នុងជំនឿមួយដែលមិនត្រូវការនូវបទពិសោធន៍។ បើយើងទុកចិត្តលើព្រះអម្ចាស់ ទ្រង់នឹងទទួលយើងត្រឡប់ទៅនៅជាមួយទ្រង់ដែរ។ ព្រះអង្គជាមគ្គុទេសចង្អុលប្រាប់ផ្លូវដល់យើង។ តើអ្នកអាចនិយាយថាអ្នកនឹងទៅជាមួយទ្រង់នាដំណើរយាងមកជាលើកទីពីររបស់ទ្រង់ដែរឬទេ? បើព្រះអង្គពន្យាពេលយូរបន្តិចទៀត តើអ្នកនឹងជួបទ្រង់នៅពេលអ្នកស្លាប់? បើទ្រង់ពុំទាន់យាងមករកយើង យើងត្រូវតែត្រៀមខ្លួនជាស្រេចដើម្បីទៅជួបទ្រង់! តើអ្នកត្រៀមខ្លួនរួចហើយឬនៅ?

**ការពិចារណា៖** តើខ្ញុំបានត្រៀមខ្លួនដើម្បីជួបព្រះយេស៊ូវជារៀងរាល់ថ្ងៃ?

**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមឲ្យខ្ញុំកុំកន្តើយនឹងដំណើរយាងមករបស់ទ្រង់ឡើយ។

## ២. ផ្លូវតែមួយគត់ទៅកាន់ព្រះជាម្ចាស់

ថ្វីត្បិតយើងបានសិក្សារហូតដល់ខទី៦នៅក្នុងមេរៀនមុន យើងក៏ត្រូវយកចិត្តទុកដាក់យ៉ាងពិសេសទៅលើខមួយនេះទៀតដែរ ព្រោះវាទាក់ទងលើផ្នែកមួយដ៏សំខាន់នៃសេចក្ដីពិត។ សូមកត់សម្គាល់ព្រះយេស៊ូវមានបន្ទូលថា៖ «..នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ»។ គ្មានបុគ្គលណាម្នាក់ទៅស្ថានសួគ៌ដោយមិនតាមរយៈព្រះយេស៊ូវគ្រីស្ទឡើយ។ ការអះអាងរបស់ព្រះយេស៊ូវគឺពិតជា ខុសប្លែកស្រឡះពីទស្សនវិជ្ជារបស់ពិភពលោកីយ៍។

នេះមានន័យថាលទ្ធិរបស់និកាយរ៉ូម៉ាំងកាតូលិកអំពីការតាំងនាងម៉ារាជាសហព្រះសង្គ្រោះ គឺជាការភូតកុហក់ដ៏ធំមួយ បើទោះបីជាពួកគេទទួលស្គាល់ព្រះគ្រីស្ទបានសុគតជំនួសអំពើបាបរបស់គេក៏ដោយ។ តើអ្នកគឺជាអ្នកកាន់សាសនារ៉ូម៉ាំងកាតូលិក? អ្នកត្រូវបានគេបង្រៀនលទ្ធិខុសឆ្គងដល់អ្នកហើយ។

នេះមានន័យថារាល់សាសនារបស់មនុស្សជាតិ ទោះបីជានៅលោកខាងកើតឬខាងលិចគឺនឹងគ្មានប្រយោជន៍ដើម្បីនាំមកនូវសេចក្ដីសង្គ្រោះយើងបានឡើយ។ មានសាសនាមួយដែលយកមនុស្សជំនួសអ្នកសង្រ្គបសម្រួមដល់ព្រះជាម្ចាស់។ បុគ្គលនោះគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ! ពីព្រោះបើគ្មានព្រះរាជបុត្រានោះនឹងគ្មានផ្លូវទៅឯព្រះវរបិតាឡើយ។ ដូច្នេះយើងត្រូវតែអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវ «..ហើយដោយគ្មានសេចក្ដីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ» (កិច្ចការ ៤:១២)។

ជនជាតិយូដាដែលប្រតិបត្តិតាមតែលោកម៉ូសេនិងសៀវភៅទាំង៣៩នៃព្រះគម្ពីរសញ្ញាចាស់ក៏គ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែរ។ ពួកគេនឹងបានសង្គ្រោះលក្ខណៈជាប្រជាជាតិនៅពេលគេថ្វាយបង្គំព្រះយេស៊ូវជាព្រះមែស៊ីរបស់ពួកគេនាដំណើរយាងមកជាលើកទីពីររបស់ទ្រង់ (សូមអាន សាការី ១២:១០)។

ចំពោះពួកអ្នកប្រតិបត្តិតាមលោកកុងជឺ (*Confucius*) ជាអ្នកមិនដឹងអំពីជីវិតបន្ទាប់ពីសេចក្ដីស្លាប់ក៏មិនខុសប្លែកគ្នាដែរ។ ឯសិស្សរបស់ព្រះពុទ្ធ ឬឡៅស៊ី (*Laotse*) ក៏មិនខុសគ្នាប៉ុន្មានដែរ។ ជាការមួយដ៏គួរឲ្យអាសូរនៅពេលឃើញជនជាតិរួមជាតិនៃយើងថ្វាយបង្គំរូបសំណាកនិងអារក្សអ្នកតាផ្សេងៗហើយនិងបណ្ដាអាទិទេពក៏ដូចជាទេវតាទាំងឡាយរួមមាន គន យិន (Kwan Yin) និង គន កុង (Kwan Kong) ជាដើម។ ទោះបីពួកគេជាវីរៈបុរសនិងវីរៈនារី ក៏ប៉ុន្តែពួកអ្នកដែលយើងបានលើកឈ្មោះឡើងខាងលើរួមទាំងពួកព្យាការីផងនោះ ពួកគេមិនអាចសង្គ្រោះខ្លួនឯងគេឲ្យមានជីវិតជាថ្មីម្ដងទៀតបានឡើយ។ តើដូច្នេះធ្វើដូចម្ដេចនឹងឲ្យគេអាចជួយសង្គ្រោះយើងបាន?

អ្នកដែលនិយាយថា៖ «ដរាបណាយើងរស់នៅដោយជំនឿ» ដោយមិនសំដៅជំនឿលើព្រះយេស៊ូវ គឺបានវង្វេង ដូចជានាវាគ្មានយុថ្កា ឬចង្កូតនៅក្នុងព្យុះមហាសាគរ។ ព្រះយេស៊ូវជាផ្លូវតែ១គត់ទៅព្រះជាម្ចាស់! នេះហើយជាដំណឹងយើងត្រូវប្រាប់អ្នកដទៃដែលមិនទាន់ស្គាល់ទ្រង់។ តើអ្នកនឹងធ្វើកិច្ចការនេះទេ? លោកគ្រូគង្វាល ស៊ី ធី ហ្សូ (Rev. C. T. Hsu) ជាសមាជិកស្ថាបនិកពួកជំនុំ ប៊ី ភី (B.P Church) បច្ចុប្បន្នរស់នៅក្នុង

ទីក្រុងញូវយ៉កប្រាប់ដល់ពិភពលោកថា «មានតែព្រះយេស៊ូវសង្គ្រោះ (ONLY JESUS SAVES)» ដោយពាក់ស្លាកនេះនៅលើអាវរងាររបស់គាត់ទៅគ្រប់ទីកន្លែងដែលគាត់ទៅ! ស្លាកនេះបង្កជាការជជែកវែកញែកជាច្រើនជាមួយនឹងអ្នកកាន់សាសនារ៉ូម៉ាំងកាតូលិក តែនោះជាការល្អ!

**ការពិចារណា៖** ចូរបន្លឺ..សរសើរដំកើង ព្រះយេស៊ូវទ្រង់សង្គ្រោះ (ចម្រៀងទំនុកតម្កើង ១៨៩)។
**ការអធិស្ឋាន៖** សូមទ្រង់ប្រទានសេចក្តីក្លាហានប្រកាសថាមានតែព្រះយេស៊ូវសង្គ្រោះ។

*« ...ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ»*

## ៣. ព្រះយេស៊ូវនិងព្រះវរបិតាគឺតែមួយ

គោលលទ្ធិអំពីសមភាពនៃព្រះបុត្រាជាមួយនឹងព្រះវរបិតាត្រូវបានសម្តែងប្រាប់ដល់សាសន៍យូដានាឱកាសជាច្រើនដងនៅពេលដែលអំណាចរបស់ព្រះយេស៊ូវត្រូវបានគេជំទាស់។ (សូមអានឡើងវិញនូវមេរៀនដើមដំបូងពីដំណឹងយ៉ូហានរបស់អ្នក)។ លោកភីលីពដឹងពីចំណុចអ្វីមួយអំពីគោលលទ្ធិនេះ តែមិនសូវច្បាស់លាស់ ហេតុនេះទើបគាត់ចង់ដឹងបន្ថែមទៀត (ខ ៨)។ ដូច្នេះ វាក៏ជាចំណូលចិត្តរបស់សាវ័កដទៃទៀតហើយយើងទាំងអស់គ្នាដែរ។

ព្រះយេស៊ូវនិងព្រះវរបិតាគឺតែ១ព្រោះព្រះអង្គគឺជាព្រះរាជបុត្រាតែមួយនៃព្រះ។ នៅក្នុងការណែនាំយើងពីព្រះដ៏ពិតទាស់នឹងព្រះមិនពិតនិងរូបអាទិទេពទាំងឡាយ ដំណឹងល្អយ៉ូហាន ១:១ និង១២ចែងថា៖ « កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ។ ទ្រង់គង់នៅជាមួយនឹងព្រះ តាំងពីដើមមក»។ តាមរយៈសេចក្តីបង្រៀនទាំងនេះណែនាំយើងឲ្យដឹងពីអាថ៌កំបាំងអំពីភាពដ៏អស់កល្បរបស់ព្រះ មានដូចជាពីឯកភាពនៃព្រះជាម្ចាស់ និងពីត្រៃឯកភាពរបស់ទ្រង់ ហើយនិងពីព្រះយេស៊ូវជាព្រះរាជបុត្រា ជាអង្គបុគ្គលទីពី ព្រមទាំងពីព្រះដ៏ជាជំនួយ (ខ១៦) ជាអង្គបុគ្គលទីបី។

ព្រះយេស៊ូវជាពន្លឺដ៏ភ្លឺត្រចង់នៃសិរីរុងរឿងរបស់ព្រះនិងជាអង្គសម្តែងពីអង្គទ្រង់ផ្ទាល់ (ហេព្រើរ ១:៣) ដូចនេះវាគឺជាការត្រឹមត្រូវក្នុងការនិយាយថាពេលយើងឃើញទ្រង់យើងក៏ព្រះវរបិតា។ តើនោះមិនមែនជាបទពិសោធន៍របស់យើងនាពេលយើងឃើញកូនប្រុសម្នាក់ដែលមានរូបរាងនិងពាក្យសម្តីហើយនិងកាយវិកាស្រដៀងគ្នានឹងឪពុករបស់គាត់? ព្រះយេស៊ូវគឺទ្រង់តែមួយនឹងព្រះវរបិតាក្នុងនិស្ស័យជាព្រះ ក្នុងព្រះចេស្តានិងសិរីរុងរឿង (គោលជំនឿវេស្នមិនស្ទឺរសំណួរនិងចម្លើយខ្នាតខ្លី៖ ចម្លើយទី៦)។ ការបញ្ជាក់ថាព្រះយេស៊ូវគឺជាព្រះ គឺការអស្ចារ្យទាំងឡាយរបស់ទ្រង់។ សូមអាន ខ ១០ និង ១១។

គំនិតមួយដ៏កក់ក្តៅបំផុតគឺពួកសាវ័កដែលជាអ្នកនឹងក្លាយជាអវយវះរបស់ព្រះយេស៊ូវនៅពេលក្បាលនឹងឡើងទៅឯស្ថានដ៏ខ្ពស់ ពួកគេបានទទួលសេចក្តីសន្យាពីព្រះចេស្តាដើម្បីធ្វើកិច្ចការរបស់ព្រះដូចជាព្រះបុត្រា ហើយនិងធ្វើបានច្រើនជាងទ្រង់ទៀត! នៅក្នុងខ ១២-១៥នេះ ព្រះយេស៊ូវប្រទានតម្រុយប្រាប់ពីព្រះចេស្តានាថ្ងៃបុណ្យថ្ងៃទី៥០ដែលនឹងប្រទានដល់ពួកជំនុំ។ យើងអាចធ្វើកិច្ចការដដែលដូចគ្នាសព្វថ្ងៃនេះដោយសេចក្តីជំនឿ! «បើអ្នករាល់គ្នានឹងសូមអ្វីដោយនូវឈ្មោះខ្ញុំ នោះខ្ញុំនឹងសំរេចឲ្យ» (ខ ១៤)។

**ការពិចារណា៖** ខ្ញុំជឿថាព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធជាព្រះតែ១។
**ការអធិស្ឋាន៖** យើងខ្ញុំសូមអរព្រះគុណសម្រាប់អំណោយទាននៃសេចក្តីជំនឿលើទ្រង់។

# ៤. ការបញ្ជូនព្រះវិញ្ញាណបរិសុទ្ធ

ដូចជាព្រះអម្ចាស់បានមានបន្ទូលប្រាប់គ្រួសៗពីព្រះចេស្ដានឹងចាក់បំពេញលើពួកសាវ័ក ពេលនេះទ្រង់បើកសម្ដែងកាន់តែច្បាស់ពីអង្គបុគ្គលទីបីនៃព្រះត្រៃឯក ដែលតាមរយៈអង្គបុគ្គលនេះហើយព្រះចេស្ដានៃទ្រង់នឹងបានប្រទានមក។ ព្រះវិញ្ញាណបរិសុទ្ធ (ភាសាអង់គ្លេសពីបុរាណគឺ «*Holy Ghost*» និងបច្ចុប្បន្នគឺ «*Holy Spirit*» ) ត្រូវបានហៅថាព្រះដ៏ជាជំនួយ ឬព្រះដ៏ជួយគំនិតនៅក្នុងកំណែនៃព្រះគម្ពីរផ្សេងទៀត។ ជាភាសាក្រិក ប៉ារ៉ាក្លិតូស (*Paracletos*) ដែលន័យត្រង់គឺអ្នកដែលហៅមកជាជំនួយ ឬមេធាវី (១ យ៉ូហាន ២: ១)។ ព្រះវិញ្ញាណបរិសុទ្ធជាអង្គបុគ្គលនៃព្រះនៅចំណុចនេះគឺត្រូវបានបើកសម្ដែងច្បាស់ជាងនៅក្នុងព្រះគម្ពីរសញ្ញាចាស់។

នៅក្នុងប្រវត្តិសាស្ត្រនៃការប្រោសលោះ មានការបើកសម្ដែងជាហូរហែរអំពីកិច្ចការប្រកបដោយព្រះគុណនៃព្រះដែលក្នុងការបែងចែកមានបីដំណាក់កាល (១) នៅក្នុងសម័យសញ្ញាចាស់ព្រះជាម្ចាស់ត្រូវបានសម្ដែងប្រាប់ដូចជា «អង្គបុគ្គលដ៏ខ្ពស់ឧត្ដមដែលមានព្រះជន្មដ៏អស់កល្បជានិច្ច»។ (២) នៅក្នុងសម័យសញ្ញាថ្មីអង្គព្រះជាម្ចាស់ត្រូវបានគេឃើញតាមរយៈព្រះរាជបុត្រាតែ១របស់ទ្រង់។ (៣) នាដំណើរយាងត្រឡប់ទៅឋានសួគ៌នៃព្រះអម្ចាស់របស់យើង «ព្រះដ៏ជាជំនួយ១អង្គទៀត» ត្រូវបានបញ្ជូនមកក្នុងកិច្ចការរបស់ទ្រង់ ហើយព្រះអង្គនេះនឹងបន្តពន្ធកិច្ចនៃអង្គព្រះសង្គ្រោះដែលបានយកនិស្ស័យជាមនុស្សរហូតមកដល់សព្វថ្ងៃនេះ ដោយការនាំឲ្យអ្នកមានបាបចូលមកព្រះគ្រីស្ទ។

ព្រះវិញ្ញាណបរិសុទ្ធគឺជាអង្គបុគ្គលនាំឲ្យយើងបានកើតជាថ្មីតាមរយៈការនាំយើងទៅកាន់ព្រះសង្គ្រោះដែលបានជាប់ឆ្កាងហើយបានរស់ពីការសុគត។ គឺជាព្រះវិញ្ញាណបរិសុទ្ធដែលបើកសម្ដែងសេចក្ដីពិតនៃបទគម្ពីរដល់យើងក្រោយពីយើងបានកើតជាថ្មី។ ព្រះវិញ្ញាណបរិសុទ្ធមិនត្រឹមបាននាំយើងទៅកាន់ព្រះរាជបុត្រាទេ តែក៏នាំយើងទៅព្រះវរបិតាផងដែរ (ឧ២០)។ រ៉ូម ៨:១៤-១៥ សម្ដែងប្រាប់ថា «ហើយអស់អ្នកណាដែលព្រះវិញ្ញាណនៃព្រះទ្រង់នាំ អ្នកទាំងនោះហើយជាពួកកូនរបស់ព្រះ។ អ្នករាល់គ្នាមិនបានទទួលនិស្ស័យជាបាវបំរើ ឲ្យត្រូវភ័យខ្លាចទៀតឡើយ គឺបានទទួលនិស្ស័យជាកូនចិញ្ចឹមវិញ ដោយហេតុនោះបានជាយើងស្រែកឡើងថា ឱអ័ប្បា ព្រះវរបិតាអើយ »។ បើអ្នកមានព្រះវិញ្ញាណនៃព្រះនៅក្នុងជីវិត នោះអ្នកអាចយល់ពីបណ្ដាបញ្ហា ដែលមនុស្សធម្មតាមិនអាចយល់បាន គឺពីសេចក្ដីពិតបែបព្រលឹងវិញ្ញាណនិងបែបស្ថានសួគ៌ ជាសេចក្ដីល្ងង់ខ្លៅចំពោះមនុស្សលោកីយ (១ កូរិនថូស ២)។

នៅក្នុងខ ២៦ ព្រះយេស៊ូវមានបន្ទូលថាព្រះវិញ្ញាណបរិសុទ្ធ «ទ្រង់នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្ដីទាំងអស់ ក៏នឹងរំឭកពីគ្រប់ទាំងសេចក្ដី ដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាដែរ»។ កាល់វិន លោកផ្ដល់អត្ថាធិប្បាយថាយើងត្រូវអត់ធ្មត់ដើម្បីរៀននូវមេរៀនអំពីព្រះគ្រីស្ទរហូតទាល់តែព្រះវិញ្ញាណធ្វើឲ្យងាយយល់នូវសេចក្ដីដែលយើងជារឿងៗហាក់ដូចជាអានឬស្ដាប់ទៅគ្មានន័យ។ ការអធិប្បាយពាក្យបន្ទូលដ៏ឮៗនឹងទៅជាឥតប្រយោជន៍បើគ្មានការបង្រៀននៃព្រះវិញ្ញាណបន្ថែម។ នេះជាសេចក្ដីបន្ថែមនូវអ្វីដែលព្រះគ្រីស្ទមាន

បន្ទូលទៅកាន់យូដាស (មិនមែនអ៊ីស្ការីយ៉ុត) ក្នុងល័ក្ខខ័ណ្ឌ ដែលព្រះជាម្ចាស់នឹងបើកបង្ហាញពីអង្គទ្រង់ដល់មនុស្សនៅពេលយើងស្រឡាញ់ទ្រង់ហើយរក្សាតាមបញ្ញតរបស់ព្រះអង្គ (ខ ២១)។

**ការពិចារណា៖** ខ្ញុំមានព្រះវិញ្ញាណបរិសុទ្ធគង់ក្នុងជីវិត?

**ការអធិស្ឋាន៖** សូមព្រះអង្គយាងមកសណ្ឋិត គង់នៅពោរពេញក្នុងចិត្ត...។

ថ្ងៃទី ៥ កក្កដា

យ៉ូហាន ១៤:២៧,៣០

*«ដ្បិតចៅហ្វាយរបស់លោកីយនេះ ជិតមកដល់ហើយ តែវាគ្មានអ្វីនៅក្នុងខ្ញុំទេ»*

## ៥. សេចក្ដីសុខសាន្តមិនមែនដូចជាលោកីយឲ្យ (ខ ២៧)

សូមទន្ទេញចងចាំអត្ថបទមាសនៃខគម្ពីរនេះ ព្រោះយើងត្រូវការសេចក្ដីសុខសាន្តយ៉ាងខ្លាំងនៅក្នុងពិភពលោកដ៏មានបញ្ហាស្មុកស្មាញនេះ!

លោកប៊ីហ្សព ដេ ស៊ី រ៉ៃឡ៍ ធ្វើសេចក្ដីអត្ថាធិប្បាយថា៖ «សេចក្ដីសុខសាន្តគឺជាអំណោយទានដ៏ពិសេសរបស់ព្រះគ្រីស្ទ វាមិនមែនជាមាសប្រាក់ ជាសេចក្ដីសុខសាន្តត្រាណបែបលោកីយ និងជាវិបុលសុខជាបណ្ដោះអាសន្នឡើយ។ សេចក្ដីទាំងនេះគឺជាទ្រព្យសម្បត្តិងាយនឹងចោទជាបញ្ហា។ ទ្រព្យទាំងនេះជារឿយៗនាំមកនូវគ្រោះថ្នាក់ជាជាងសុវត្ថិភាពដល់ផ្នែកព្រលឹងវិញ្ញាណ។ សេចក្ដីទាំងនេះមានតួនាទីជាឧបសគ្គនិងជាបន្ទុកដល់ជីវិតខាងផ្នែកព្រលឹងវិញ្ញាណរបស់យើង។ សេចក្ដីសុខសាន្តផ្នែកខាងក្នុងបញ្ញាចិត្ត កើតមកពីវិញ្ញាណដែលទទួលបានការអត់ទោសបាបនិងការផ្សះផ្សានឹងព្រះជាម្ចាស់ដ៏មានពរ។ សេចក្ដីសុខសាន្តនេះគឺទ្រព្យរបស់អ្នកជឿទាំងអស់គ្នា ទោះជាមានឋានៈខ្ពង់ខ្ពស់ឬតូចទាបក្ដី»។

សេចក្ដីសុខសាន្តដែលព្រះគ្រីស្ទប្រទានទ្រង់ហៅថា «សេចក្ដីសុខសាន្តរបស់ខ្ញុំ»។ វាគឺជាសេចក្ដីសុខសាន្តដ៏ពិសេសរបស់ទ្រង់សម្រាប់ប្រទានឲ្យយើង ព្រោះទ្រង់បានទិញវាមកដោយព្រះលោហិតទ្រង់ ជាសេចក្ដីបានលោះមកដោយការជំនួសនៃអង្គទ្រង់ ហើយព្រះវរបិតាបានតម្រូវទុកសម្រាប់ចែកដល់លោកីយដែលបាត់បង់។ ដូចជាយ៉ូសែបត្រូវបានតម្រូវទុកនិងតាំងឡើងដើម្បីផ្គត់ផ្គង់គ្រាប់ស្រូវដល់សាសន៍អេស៊ីបដែលអត់ឃ្លានយ៉ាងណា នោះព្រះគ្រីស្ទក៏ត្រូវបានតែងតាំងយ៉ាងពិសេសនៅក្នុងព្រះតំរិះនៃព្រះត្រៃឯកដើម្បីប្រទានសេចក្ដីសុខសាន្តដល់មនុស្សដូច្នោះដែរ។

សេចក្ដីសុខសាន្តដែលព្រះគ្រីស្ទប្រទានឲ្យគឺមិនមែនដូចជាលោកីយឲ្យឡើយ។ សេចក្ដីដែលទ្រង់ប្រទានឲ្យលោកីយមិនអាចផ្ដល់ឲ្យបានទេ ហើយសេចក្ដីដែលទ្រង់ប្រទានឲ្យគ្មានភាពស្ទះស្ទើរ ឬដោយភាពអសទ្ធា ឬក៏ក្នុងរយៈពេលខ្លីដែរ។ ព្រះគ្រីស្ទស្ម័គ្រព្រះទ័យប្រទានឲ្យជាជាងលោកីយនឹងទទួល។ សេចក្ដីដែលទ្រង់ប្រទានមកនឹងប្រទានឲ្យជារៀងរហូតនិងមិនដែលដកយកវិញឡើយ។ ព្រះអង្គត្រៀមជាស្រេចនឹងប្រទានឲ្យដ៏ហូរហៀរជាងដែលយើងនឹងអាចទូលសុំ ឬគិតទៅទៀត។ ទ្រង់មានបន្ទូលថា «ចូរឯងហាមាត់ឲ្យធំ អញនឹងបំពេញឲ្យ» (ទំនុកដំកើង ៨១:១០)។

**ការពិចារណា៖** «ចូរឯងហាមាត់ឲ្យធំ អញនឹងបំពេញឲ្យ» (ទំនុកដំកើង ៨១:១០)។

**ការអធិស្ឋាន៖** សូមព្រះនៃសេចក្ដីសុខសាន្តប្រទានសេចក្ដីសាន្តដល់ព្រលឹងនិងកាយដល់យើង។

ថ្ងៃទី ៦ កក្កដា

យ៉ូហាន ១៤:៣០ «...តែវាគ្មានអ្វីនៅក្នុងខ្ញុំទេ»

## *សេចក្ដីសុខសាន្តដែលឈ្នះអារក្សសាតាំង* (ខ៣០)

«ដ្បិតចៅហ្វាយរបស់លោកីយនេះ ជិតមកដល់ហើយ តែវាគ្មានអ្វីនៅក្នុងខ្ញុំទេ»។ លោកជេ ស៊ី រ៉ៃឡ៍ អត្ថាធិប្បាយបន្ថែមទៀតថា៖«ព្រះអម្ចាស់នៃយើងមានបំណងចង់ឲ្យសិស្សទ្រង់ដឹងថាសាតាំង «ជាចៅហ្វាយនៃលោកីយនេះ» រៀបនឹងវាយប្រហារដោយហឹង្សាជាចុងក្រោយនឹងធ្ងន់ធ្ងរមកលើទ្រង់។ ព្រះអង្គកំពុងដាស់តឿនយ៉ាងអស់ពីព្រះហឫទ័យរបស់ទ្រង់សម្រាប់ការចាប់ផ្ដើមដ៏អស្ចារ្យមួយ។ សាតាំងនឹងមកជាមួយនឹងការព្យាបាទដ៏ពិសពុលរបស់វាដើម្បីល្បងលអ័ដាមទីពីរនៅក្នុងសួនកេតសេម៉ានី និងនៅលើឈើឆ្កាងនៃភ្នំកាល់វ៉ារី។ ប៉ុន្តែចៅហ្វាយដ៏មានព្រះពរនៃយើងទ្រង់ប្រកាសថា «តែវាគ្មានអ្វីនៅក្នុងខ្ញុំទេ»។ «សាតាំងនឹងមិនអាចតស៊ូឈ្នះបានទេ។ គ្មានចំណុចទន់ខ្សោយនិងខ្វះខាតអ្វីនៅក្នុងខ្ញុំឡើយ។ ខ្ញុំបានរក្សាបញ្ញត្តរបស់ព្រះវរបិតាខ្ញុំ និងបានបញ្ចប់កិច្ចការដែលទ្រង់បានប្រទានអោយខ្ញុំសំរេចធ្វើ។ អារក្សសាតាំង ដូចនេះមិនអាចផ្ដួលរំលំខ្ញុំបានឡើយ។ គាត់ក៏មិនអាចធ្វើការចោទប្រកាន់អ្វីដល់ខ្ញុំបានទេ។ គាត់មិនអាចផ្ដន្ទាទោសខ្ញុំបានទេ។ ខ្ញុំនឹងត្រឡប់មកពីការល្បួងល្បងដូចជាអ្នកឈ្នះសង្គ្រាម»។

**ការពិចារណា**៖ ព្រះគ្រីស្ទជាមេទ័ពធំនៃយើង។

**ការអធិស្ឋាន**៖ សូមឲ្យយើងខ្ញុំលើទង់ឈើឆ្កាងនៃទ្រង់សម្រាប់ឈ្នះរាល់ល្បិចកលអារក្ស។

## ៦. ការចុះចូលរបស់ទ្រង់ចំពោះព្រះវរបិតា

«ពីព្រោះព្រះវរបិតារបស់ខ្ញុំធំជាងខ្ញុំ» គឺជាប្រយោគចំណូលចិត្តនៃក្រុមស្មរបន្ទាល់ព្រះយេហូវ៉ាបានដកស្រង់មកខុសបរិបទ ដោយអះអាងថាព្រះអម្ចាស់នៃយើងគឺជាព្រះតូច។ ដូចជាក្រុមអេរាន (Arians)នៃសតវត្សទី៤ដែរ ក្រុមស្មរបន្ទាល់ព្រះយេហូវ៉ាបដិសេធភាពស្មើគ្នាជាព្រះនៃព្រះគ្រីស្ទនឹងព្រះវរបិតា។ ខណៈពេលព្រះយេស៊ូវទទួលស្គាល់នូវការចុះចូល របស់ទ្រង់ចំពោះព្រះវរបិតានៅក្នុងខនេះ តើនៅខឯទៀតទ្រង់មិនបានថ្លែងប្រាប់ពីអង្គទ្រង់ពីភាពស្មើគ្នា ជាមួយនឹងព្រះវរបិតា? សូមចងចាំពីការដែលសាសន៍យូដាសព្យាយាមសម្លាប់ទ្រង់រឹតតែខ្លាំងឡើង ពីព្រោះទ្រង់មិនត្រឹមតែរំលងច្បាប់នៃថ្ងៃឈប់សំរាកប៉ុណ្ណោះទេគឺបានទាំងហៅព្រះថាជាព្រះវរបិតានៃទ្រង់ថែមទៀត ហើយលើកអង្គទ្រង់ស្មើនឹងព្រះផង។ (យ៉ូហាន ៥:១៨)។

ក្នុងយ៉ូហាន១០:៣៣ ព្រះយេស៊ូវថ្លែងថា៖ «ខ្ញុំហើយនឹងព្រះវរបិតាគឺតែ១ព្រះអង្គទេ»។ នោះពួកសាសន៍យូដាក៏រើសថ្មម្តងទៀតដើម្បីនឹងចោលទ្រង់ ហើយខ៣៣ ចែងប្រាប់ថា «យើងចោលអ្នកនឹងថ្ម មិនមែនដោយព្រោះការល្អណាទេ គឺដោយព្រោះពាក្យប្រមាថដល់ព្រះ ហើយពីព្រោះអ្នកដែលជាមនុស្សបានតាំងខ្លួនឡើងជាព្រះវិញប៉ុណ្ណោះ»។ ខគម្ពីរគំរូអំពីភាពស្មើគ្នានៃព្រះយេស៊ូវនឹងព្រះវរបិតាក្នុងន័យចុះចូលគឺត្រូវបានប៉ុលកត់ត្រាក្នុងភីលីព២:៦-៨ «ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីដែលស្មើនឹងព្រះនោះទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នោះនោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់លើឈើឆ្កាងផង»។

ដូចនេះតើមានន័យដូចម្តេចនៅពេលព្រះយេស៊ូវមានបន្ទូល «ដ្បិតព្រះវរបិតាទ្រង់ធំលើសជាងខ្ញុំ?» បណ្ឌិត បាស្វែល មានប្រសាសន៍ថា «វាគឺជាការសំខាន់បំផុតដែលយើងបែងចែកនូវសេដ្ឋកិច្ចនិងមុខងារនៃការចុះចូលនិងពីសារៈសំខាន់នៃភាពស្មើភាពគ្នា។ ពេលព្រះយេស៊ូវមានបន្ទូលថា «ព្រះវរបិតាទ្រង់ធំលើសជាងខ្ញុំ» ហើយ «ខ្ញុំពុំអាចនឹងធ្វើការអ្វីដោយខ្លួនខ្ញុំបានទេ» (យ៉ូហាន ៥:៣០) យើងត្រូវតែយល់ពាក្យទាំងនេះទុកដូចជាការសំដៅអំពីសេដ្ឋកិច្ចនៃការចុះចូល «កាលទ្រង់គង់នៅក្នុងសាច់ឈាមនៅឡើយ» ព្រះគ្រីស្ទគឺប្រៀបដូចជាបុត្រាស្តេចបម្រុងនឹងឡើងគ្រងរាជ្យមានជីវិតឯកជនបម្រើក្នុងកងទ័ពដែលនឹងមានថ្ងៃមកដល់ទ្រង់នឹងក្លាយជានាយទាហានជាតិជាន់ខ្ពស់។ ការងារនេះទ្រង់ធ្វើក្នុងបំណងដើម្បីសម្រេចកាតព្វកិច្ចជាតិ។

បណ្ឌិត ដេវីឌ ស្មីត មានប្រសាសន៍ថា «ព្រះអង្គមានឋានៈទាបជាងព្រះវរបិតានៅក្នុងលក្ខខ័ណ្ឌនៃការបន្ទាបខ្លួនរបស់ទ្រង់ សម្រាប់យើងគ្រប់គ្នា ដើម្បីការប្រោសលោះរបស់យើង ទ្រង់បានត្រឡប់ជាមនុស្សដោយការទុកសិរីរុងរបស់ទ្រង់ផ្ទាល់នៅដោយឡែកសិន..»។

**ការពិចារណា៖** ព្រះយេស៊ូវជាគំរូនៃការចុះចូលនឹងអំណាចដែលព្រះជាម្ចាស់តែងតាំង។
**ការអធិស្ឋាន៖** សូមឲ្យខ្ញុំចុះចូលនឹងអំណាចដែលទ្រង់តែងតាំងតាមគំរូព្រះយេស៊ូវ។

## ព្រះយេស៊ូវគឺជាដើមទំពាំងបាយជូរជីវិត ទ្រង់បណ្តាលឲ្យកិច្ចបម្រើរបស់យើងកាន់ប្រសើរ

បើអ្នកអានប្រយោគចុងក្រោយម្តងទៀតនៅខគម្ពីរចុងក្រោយនៃជំពូកមុន នោះវានឹងបានដឹងនូវតំរុយពីទីកន្លែងនិងបរិបទនៃការអធិប្បាយនេះជាពុំខាន។ ការអធិប្បាយនេះគឺមិនមែននៅក្នុងបន្ទប់រៀបចំពិធីបុណ្យរំលងទៀតទេ តែដូចជា លោក ស្កហ្វីល ផ្តល់ជាមតិគឺនាពេលកំពុងធ្វើដំណើរទៅសួនគែតសេម៉ានី ខាងក្រៅទីក្រុងយេរូសាឡឹមទល់មុខទីជ្រោះកេដ្រុន នាភ្នំដើមភ្នំអូលីវ។

ព្រះយេស៊ូវប្រើរូបភាពដើមទំពាំងបាយជូរដើម្បីបង្រៀនពីសារៈសំខាន់នៃទំនាក់ទំនងរវាងអង្គទ្រង់នឹងពួកជំនុំ ដោយសារផ្លែទំពាំងបាយជូរ ទឹកទំពាំងបាយជូរ គឺទើបតែបានប្រើប្រាស់មុននោះបន្តិចសម្រាប់ពិធីលៀងព្រះអម្ចាស់។ ផ្លែទំពាំងបាយជូរជាផ្លែឈើបរិសុទ្ធក្នុងចំណោមផ្លែឈើទាំងប្រាំពីរប្រភេទទៀត (ចោទិយកថា ៨:៨) ជាផ្លែឈើរបស់ប្រជាជាតិនៃដែនដីបរិសុទ្ធ ដូចជាពីផ្លែអូលីវនិងផ្លែល្វាផងដែរ។ ផ្លែឈើទាំងបីប្រភេទនេះគឺត្រូវបានប្រើជានិមិត្តសញ្ញារបស់ប្រទេសអ៊ីស្រាអែល។ តើរូបភាពផ្លែឈើពីរប្រភេទទៀតឃើញនៅទីណា? អ៊ីស្រាអែលគឺត្រូវបានហៅថាចំការទំពាំងបាយជូររបស់ព្រះជាម្ចាស់និងស្រុកយូដា (មេកុលសម្ពន្ធ័នៃប្រទេសអ៊ីស្រាអែលដែលព្រះអម្ចាស់នៃយើងបានប្រសូត្រមក) គឺត្រូវបានហៅថាជាដើមទំពាំងបាយជូរយ៉ាងល្អឯក (អេសាយ ៥:១-៧)។ ទំនុកដំកើង ៨០ ពិពណ៌នារាស្ត្ររបស់ព្រះឲ្យដូចដើមទំពាំងបាយជូរចាស់ដែលបាននាំចេញពីស្រុកអេស៊ីព្ទ។ ដូច្នេះវាគឺជាការត្រឹមត្រូវសម្រាប់ព្រះអម្ចាស់នៃយើងរូបភាពដើមទំពាំងបាយជូរសម្រាប់អង្គទ្រង់និងពួកជំនុំគ្រីស្ទបរិសទ័នៅក្នុងន័យដ៏ធំទូលាយ។

ឥឡូវនៅពេលដើមទំពាំងបាយជូរជារូបភាពដែលសាសន៍យូដាស្គាល់គ្រប់គ្នា ចំពោះពួកយើងដែលរស់នៅក្នុងទឹកដីមានតែដើមសាវម៉ៅជុះ គឺត្រូវការពន្យល់ខ្លះៗ៖ វចនានុក្រមព្រះគម្ពីរថ្មី ពន្យល់ថា ដើមទំពាំងបាយជូរទូទៅ គឺជាប្រភេទដើមធ្នារតូចដែលវារនៅលើដីឬ វារឡើងទ្រើងដោយដៃវល្លិ៍។ នៅពេលមានផ្លែមែកទាំងឡាយរបស់វាបានលូតវែងខ្ពស់ពីដីទៅលើ ទ្រើងតែមិនខ្ពស់ជាងជំហរមនុស្សទេ។ បទគម្ពីរឯទៀតដែលកត់ត្រាពីដើមទំពាំងបាយមានដូចជា លូកា ១៣:៦៩ ម៉ាថាយ ២០:១-៦ ម៉ាកុស ៩:១៧ ម៉ាថាយ ២១:២៨-៣២ ម៉ាថាយ ២១:៣៣ ម៉ាកុស ១២:១-១១ លូកា ២០:៩-១៨។

**ការពិចារណា**៖ បើព្រះយេស៊ូវជាដើមទំពាំងបាយជូរដ៏ពិត នោះខ្ញុំជាខ្នែងដ៏ពិត!

**ការអធិស្ឋាន**៖ព្រះអម្ចាស់អើយ សូមឲ្យខ្ញុំជាខ្នែងនៅជាប់នឹងទ្រង់ជាដើមទំពាំងបាយជូរដ៏ពិតផង។

ថ្ងៃទី ៩ កក្កដា
យ៉ូហាន ១៥:១-៨

*"...តែអស់ទាំងខ្នែងណា ដែលបង្កើតផលផ្លែ នោះទ្រង់លួសខ្នែងនោះវិញ ដើម្បីឲ្យបានផលផ្លែជាច្រើនឡើង"*

## ពួកជំនុំគឺជាដើមទំពាំងបាយជូរមានផលផ្លែ

សូមចាំថាជំពូកនេះគឺការអធិប្បាយមួយក្នុងបណ្តាការអធិប្បាយចុងក្រោយរបស់ព្រះអម្ចាស់នៃយើង ដែលបានប្រកាសប្រាប់ដល់ពួកសិស្សរបស់ទ្រង់មុនពេលព្រះអង្គត្រូវបានលើកឡើងទៅស្ថានសួគ៌។ ថ្វីដ្បិតតែខាងផ្នែករូបកាយទ្រង់នឹងត្រូវលើកយកពីផែនដីនេះ ក៏ព្រះអង្គត្រូវតែបន្តនៅលើផែនដីតាមរយៈពួកជំនុំនៃទ្រង់ដែរ។ ពួកជំនុំរបស់ទ្រង់ត្រូវតែតាំងឡើងហើយរីកដុះដាលរហូតដល់ចុងបំផុតនៃផែនដី។

ព្រះវរបិតារបស់ទ្រង់ ជាព្រះដ៏មានអំណាចចេស្តា គឺជាអ្នកដាំ ឬជាម្ចាស់ចំការទំពាំងបាយជូរ ដែលជាពិភពលោក។ ព្រះយេស៊ូវគឺជាដើមទំពាំងបាយដែលព្រះវរបិតាបានដាំ។ ដើមទំពាំងបាយជូរពិត ព្រោះទ្រង់គឺជាគំនិតដ៏ល្អឯក ជាដើមទំពាំងបាយជូរខាងព្រលឹងវិញ្ញាណដែលបន្តនៅអស់កល្បជានិច្ច។ ខណៈពេលព្រះសិរសា (ក្បាល) បានយាងឡើងទៅស្ថានសួគ៌ យើងរាល់គ្នាគឺជាខ្នែង ដែលជាដៃនិងជាជើងនៅលើផែនដីបន្តបេសកកម្មរបស់ទ្រង់។ គោលបំណងរបស់យើងខណៈពេលរស់នៅលើផែនដីគឺត្រូវបង្កើនផលថ្វាយទ្រង់ ដើម្បីបង្កើតផលផ្លែជាច្រើន ហើយនឹងពង្រីកពួកជំនុំរបស់ព្រះអង្គ។ នេះគឺត្រូវបានធ្វើពន្យល់ជារូបភាពតាមរយៈចង្កោមផ្លែទំពាំងបាយជូរធ្ងន់ធ្លាក់សំយ៉ុងចុះដ៏រលោងនិងប្រកបដោយឱជារសទុំនៅដើមទំពាំងបាយជូរ។ នៅពេលអ្នកបេះវាមកបរិភោគវាមានសុទ្ធតែទឹកយ៉ាងផ្អែមជាប់មាត់ តើអ្នកនឹងមិននិយាយពាក្យអរគុណដល់ម្ចាស់ចំការដែលអញ្ជើញអ្នកមកចំការរបស់គាត់? ចូរបង្កើតផ្លែឲ្យច្រើន ព្រះអម្ចាស់នៃយើងបង្គាប់ ដើម្បីឲ្យព្រះវរបិតាបានលើកដំកើង! មិត្តអ្នកអានអើយ លោកអ្នកអាចនឹងទទួលបានសង្គ្រោះរយៈពេលជាច្រើនឆ្នាំមួយទសវត្ស ពីរទសវត្ស មួយជីវិតដែលជិតនឹងបញ្ចប់! សូមពិនិត្យមើលខ្លួនឯងអ្នក។ តើផលផ្លែអ្វីខ្លះអ្នកបានបង្កើតថ្វាយដល់ព្រះគ្រីស្ទដែលអាចជាការសរសើរតំកើងថ្វាយព្រះវរបិតា? ឬក៏គ្មានផលផ្លែដូចជាព្រះអម្ចាស់នៃយើងបានមានបន្ទូល? ឬជាផ្លែជូរ ជាជីវភាពគ្រីស្ទបរិស័ទជូរចត់ ដូចនេះទើបអ្នកមិនចុះសម្រុងនឹងគ្រីស្ទបរិស័ទឯទៀត? មិនត្រឹមតែគ្មានផលផ្លែ តែថែមទាំងរារាំងមិនឲ្យគេបង្កើតផលផ្លែទៀត?

ខ្នែងក្រៀមស្វិត ធ្លាក់ចុះដោយគ្មានភាពលំបាក គឺនឹងយកទៅដុតចោល។ គ្រីស្ទបរិស័ទតែឈ្មោះ មិនទាន់បានកើតជាថ្មី នឹងចាកចេញពីពួកជំនុំដោយគ្មានវិប្បតិសារី ហើយនឹងរសាត់ត្រឡប់ទៅក្នុងលោកីយវិញ។ គាត់បរាជ័យក្នុងការមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងព្រះនេត្រនៃព្រះវរបិតានានគរស្ថានសួគ៌។ មនុស្សបែបនេះគឺមិនបានសង្គ្រោះឡើយ។ គ្រីស្ទបរិស័ទតែឈ្មោះជាច្រើននាក់បញ្ចប់យ៉ាងវេទនាក្នុងស្ថាននរកដូចជាលោកគ្រូ ចន ស៊ុងមានប្រសាសន៍អំពីបុរសអ្នកមាននៅក្នុងលូកា ១៦។ នៅពេលពួកជំនុំគឺជាដើមទំពាំងបាយជូរមានផលផ្លែ នោះសូមឲ្យសមាជិកម្នាក់ៗបង្កើតផលផ្លែល្អថ្វាយដល់ព្រះអម្ចាស់របស់ខ្លួនចុះ។

**ការពិចារណា៖** តើខ្ញុំជាគ្រីស្ទបរិស័ទតែឈ្មោះ?

**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ សូមជួយឲ្យយើងខ្ញុំបង្កើតផលផ្លែថ្វាយទ្រង់ផង។

*«អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើតផលឡើងជាច្រើន»*

## ដំណាក់កាលនៃការបង្កបង្កើនផល

១. ត្រូវរក្សានៅជាប់នឹងព្រះអម្ចាស់ «អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើតផលឡើងជាច្រើន»(ខ៥)។ តើអ្នកស្វែងរកសិរីរុងរឿងរបស់ព្រះអម្ចាស់នូវក្នុងគ្រប់កិច្ចការដែលអ្នកធ្វើ? តើអ្នកអធិស្ឋានសុំការយល់ព្រមនឹងការដឹកនាំពីទ្រង់។ តើអ្នកស្រឡាញ់ទ្រង់អស់ពីចិត្តអ្នក? តើអ្នកចូលរួមកម្មវិធីថ្វាយបង្គំនៅព្រះវិហារនិងការប្រជុំអធិស្ឋានហើយនឹងចូលរួមពិធីលៀងព្រះអម្ចាស់ទៀងទាត់? តើអ្នកព្រមទាំងបានទទួលបុណ្យជ្រមុជ? ទាំងនេះគឺជាមធ្យោបាយនៃព្រះគុណដែលជួយឲ្យយើងបានរីកចម្រើនក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

២. ត្រូវអនុញ្ញាតឲ្យពាក្យបន្ទូលទ្រង់តាមរយៈការអានព្រះគម្ពីរប្រចាំថ្ងៃធ្វើឲ្យជីវិតអ្នកបានបរិសុទ្ធ។ «ឯអ្នករាល់គ្នាបានស្អាតហើយ ដោយសារពាក្យដែលខ្ញុំបានប្រាប់» (ខ ៣)។ លោកប៉ុលជាអ្នកបរិសុទ្ធបានប្រដូចព្រះគម្ពីរទៅនឹងទឹកដែលមានថាមពលសម្អាត។ គាត់បានបង្រៀនថា «ដើម្បីឲ្យទ្រង់បានញែកពួកជំនុំចេញជាបរិសុទ្ធ ដោយបានលាងសំអាតនឹងទឹក គឺជាព្រះបន្ទូល» (អេភេសូរ ៥:២៦)។ ហេតុនេះការខិតខំព្យាយាមដ៏ខ្ជាតខ្ជីនៅក្នុងមេរៀននៃកូនសៀវភៅសម្រាប់ពេលស្ងៀមស្ងាត់ទាំងនេះ (RPG)ដើម្បីជម្រុញនូវការអានព្រះគម្ពីរប្រចាំថ្ងៃដើម្បីសុខមាលភាពខាងផ្នែកជីវិតនៃគំនិតរបស់អ្នក។

៣. ត្រូវស៊ូទ្រាំនឹងវិធានការកែតម្រូវដែលព្រះជាម្ចាស់បានធ្វើដើម្បីកែទម្រង់ជីវិតរបស់អ្នក។ ខ្នែងងាប់គឺបានបាក់ធ្លាក់ចេញដោយគ្មានឈឺចាប់ ពីព្រោះវាគ្មានអារម្មណ៍បែបនោះ។ គ្រីស្ទបរិសទ្ធតែឈ្មោះនឹងចាកចេញពីក្រុមជំនុំទៅលោកីយដោយគ្មានការសោកស្ដាយ ព្រោះគាត់មិនធ្លាប់ក្លាយជាសមាជិកនៃពួកជំនុំ។ សាក្ខីភាពនេះគឺយើងបានឃើញនៅក្នុងមេរៀនមុន។ ប៉ុន្តែកូនប្រុសនិងកូនស្រីពិតប្រាកដរបស់ព្រះនឹងត្រូវស៊ូទ្រាំនឹងការផ្ចាញ់ផ្ចាល (ហេព្រើរ ១៦:៦-៨)។ ការបៀតបៀនទាំងឡាយដែលបានធ្លាក់មកលើពួកសាវ័កកាលពីសម័យមុនគឺព្រះអម្ចាស់បានអនុញ្ញាតដើម្បីបង្កើននូវកម្លាំងដល់ពួកជំនុំ។ ការជំនុំជំរះលោកអន៉្ញានាសនិងសាភីរ៉ា រំដោះពួកជំនុំសម័យដើមចេញពីភាពមិនស្មោះត្រង់និងកិត្តិសព្ទ័ឥតន័យ។ នៅពេលយើងឈឺ ឬរងការបាត់បង់ទ្រព្យសម្បត្តិ ឬក៏ជួបការបរាជ័យអ្វីមួយ សូមចងចាំថាការទាំងនេះបានមកពីព្រះវរបិតានៃយើងដើម្បីនាំយើងត្រឡប់មកអង្គទ្រង់វិញ។ សេចក្ដីទាំងនេះគឺការលួសខ្នែងដើម្បីឲ្យជីវិតអាចបង្កើនផលផ្លែកាន់តែច្រើនឡើង។

ហើយនៅរាល់ការរីកចម្រើនដែលស្ថិតក្នុងដំណាក់កាលនៃការបង្កបង្កើនផល ទឹកចិត្តស៊ូទ្រាំត្រូវតែជាសេចក្ដីស្រឡាញ់។ យើងបន្តនៅក្នុងសេចក្ដីស្រឡាញ់នៃទ្រង់ រក្សាបញ្ញត្តិទ្រង់ ឲ្យសម្អាតដោយពាក្យបន្ទូលទ្រង់ នឹងដើម្បីឲ្យព្រះវរបិតាបានលួស(យើង)!

**ការពិចារណា៖** «ឯអ្នករាល់គ្នាបានស្អាតហើយ ដោយសារពាក្យដែលខ្ញុំបានប្រាប់» (១៥:៣)

**ការអធិស្ឋាន៖** ព្រះយេស៊ូវអើយ សូមឲ្យខ្ញុំជាប់នៅ ដោយចិត្តជឿមាំឥតរាថយទៅ...។

ថ្ងៃទី ១១ កក្កដា
យ៉ូហាន ១៥:១១-១៤

*«...ហើយឲ្យសេចក្ដីអំណររបស់អ្នករាល់គ្នាបានពោរពេញផង»*

# ព្រះយេស៊ូវមិនត្រឹមប្រទានសេចក្ដីសុខសាន្តទេ តែសេចក្ដីអំណរដែរ

នៅក្នុងយ៉ូហាន១៤:២៧ ព្រះយេស៊ូវប្រទានសេចក្ដីសុខសាន្តដល់ពួកជំនុំរបស់ទ្រង់ **សាឡូម** នៅក្នុងភាសាហេព្រើរ និងភីង អាន នៅក្នុងភាសាចិនកុកងឺ។ អត្ថន័យរបស់ពាក្យសេចក្ដីអំណរពីព្រះជាម្ចាស់ គឺត្រូវបានបរិយាយយ៉ាងក្បោះក្បាយដោយ បណ្ឌិត ជេ ស៊ី រ៉ៃល៍ដូចតទៅនេះថា៖

សេចក្ដីអំណរយកមកសម្ដែងប្រាប់គឺជាសេចក្ដីអំណរពីព្រះគ្រីស្ទផ្ទាល់ដែលទ្រង់មានចេតនានៅក្នុងសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះព្រះវរបិតាហើយនិងសេចក្ដីស្រឡាញ់នៃព្រះវរបិតាមានចំពោះទ្រង់វិញ។ ពន្លឺភ្លឺថ្លានៃសេចក្ដីអំណរនោះបានអុជបំភ្លឺនាវេលាដ៏ខ្មៅងងឹតក្នុងជីវិតជាមនុស្សរបស់ទ្រង់ផ្ទាល់ ហើយទ្រង់មានបំណងឲ្យវាបំភ្លឺជីវិតរបស់ពួកសាវ័កដែរ។ នៅក្នុងចេតនានៃសេចក្ដីស្រឡាញ់របស់ពួកគេចំពោះព្រះជាម្ចាស់ ហើយនិងសេចក្ដីស្រឡាញ់របស់ព្រះចំពោះពួកគេនឹងស្ថិតមាននៅគេ ជាផ្នែកនៃជីវិតដ៏ពិតប្រាកដជាសេចក្ដីអំណរដែលគ្មានទុក្ខសោកណាអាចឈ្នះបាន។ ពួកគេជាមនុស្សដែលមានទុក្ខលំបាកក្នុងចិត្ត។ ព្រះអង្គមានបន្ទូលប្រាប់ពួកគេអំពីប្រភពនៃសេចក្ដីអំណរពិត។ សេចក្ដីអំណររបស់ទ្រង់ផ្ទាល់ដែលបានប្រទានដល់ពួកគេ។ ពេលនេះទ្រង់មានបន្ទូលប្រាប់ពួកគេពីប្រភពនៃសេចក្ដីអំណរ ហើយមានបន្ទូលពាក្យដែលគេនឹងអាចទទួលជាកម្មសិទ្ធនូវសេចក្ដីអំណរដែលជាពន្លឺនៃព្រះហឫទ័យទ្រង់ផ្ទាល់។

ស្ថានភាពដែលទ្រង់មានបន្ទូលទៅកាន់ពួកគឺជាស្ថានភាពនៃការស្រឡាញ់និងការទទួលនូវសេចក្ដីស្រឡាញ់ពីព្រះជាម្ចាស់ គឺជាជីវិតដ៏ប្រសើរប្រកបដោយឧត្តមគតិខ្ពង់ខ្ពស់។ សេចក្ដីអំណរនេះផ្ដល់នូវភាពស្កប់ស្កល់ចិត្តសម្រាប់អស់ទាំងសេចក្ដីប៉ងប្រាថ្នាជ្រាលជ្រៅរបស់ខ្លួនយើង។ ចំណុះទាំងមូលរបស់មនុស្សគឺពេញដោយសេចក្ដីអំណរនេះ ហើយជាលទ្ធផលគឺពោរពេញដោយសេចក្ដីអំណរ។ ពួកគេបានដឹងតិចតួចពីទឹកចិត្តពិតប្រាកដនៃជំនឿគ្រីស្ទបរិស័ទដែលមានសាសនាដែលមិនផ្ដល់នូវសេចក្ដីអំណរដើពួកគេដែលចាំងពន្លឺរបស់វាលើជីវិតរបស់គេទាំងមូល។

ដូចខ្ញុំធ្លាប់បានកត់សម្គាល់ឃើញ សេចក្ដីអំណររបស់គ្រីស្ទរិស័ទ គឺត្រូវបានមកពីសេចក្ដីស្រឡាញ់នៃព្រះ គឺឃើញកំពុងរះបំភ្លឺលើគ្រីស្ទបរិស័ទដែលមានទុក្ខព្រួយជាប់ក្នុងចិត្តរបស់ពួកគេ។ ហើយសេចក្ដីអំណរនោះនឹងនាំមកនូវក្ដីទំនុកចិត្ត ហេតុនេះគ្រីស្ទបរិស័ទ «មានព្រះគង់ក្នុងទូកយើងអាចញញឹមពេលមានព្យុះ» ។ នេះគឺជាជំនឿរបស់និកាយប្រូតេស្តង់ មិនមែនជាសាសនារបស់រ៉ូម៉ាំងកាតូលិក!

**ការពិចារណា៖** «មានព្រះគង់ក្នុងទូកយើងអាចញញឹមពេលមានព្យុះ» ។
**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ យើងខ្ញុំត្រូវការ «**សាឡូម**» របស់ទ្រង់

*«ខ្ញុំមិនហៅជាអ្នកបំរើទៀត..គឺខ្ញុំហៅអ្នករាល់គ្នាថាជាសំឡាញ់វិញ...»*

# ដោយការតែងតាំងដ៏ខ្ពស់

មកដល់ខគម្ពីរនេះ ឋានៈទន់ទាបនៃភាពជាសាវ៉កត្រូវបានលើកមកសង្កត់ធ្ងន់ ទុកជាតម្រូវការជាមុននៃការស្តាប់បង្គាប់និងការចុះចូល។ «សិស្សមិនមែនលើសជាងគ្រូទេ ហើយបាវក៏មិនលើសជាងចៅហ្វាយខ្លួនដែរ» (ម៉ាថាយ ១០:២៤)។ហើយ យ៉ូហាន ១៥:២០ «ចូរនឹកចាំពីពាក្យដែលខ្ញុំបានប្រាប់រួចហើយថា បាវមិនមែនធំជាងចៅហ្វាយទេ»។ តវិយាបថនៃកិច្ចម្រើដ៏បន្ទាបខ្លួននេះបានរៀននាអំឡុងបីឆ្នាំកន្លះចុងក្រោយ ពួកអ្នក១១នាក់(យូដាសជាសិស្សក្បត់បានចាកចេញ) ពេលនេះត្រូវបានលើកដំកើងជាមិត្ត សម្លាញ់។ «ខ្ញុំមិនហៅជាអ្នកបំរើទៀត ពីព្រោះអ្នកបំរើគេមិនដឹងជាចៅហ្វាយធ្វើអ្វីទេ គឺខ្ញុំហៅអ្នករាល់គ្នាថាជាសំឡាញ់វិញ...» (យ៉ូហាន ១៥:១៥)។ បែបបទឆ្ពោះទៅរកឧត្តមភាពក្នុងកិច្ចបម្រើព្រះគឺត្រូវផ្តើមពីជំហ៊ុងបង្អស់ មួយជំហានម្តង មួយជំហានម្តង! បណ្ឌិត កាល់វីនមានប្រសាសន៍ថាច្បាប់ទីមួយ ច្បាប់ទីពីរ និងច្បាប់ទីបីក្នុងការរៀនមេរៀនអំពីព្រះជាម្ចាស់គឺ ការបន្ទាបខ្លួន ការបន្ទាបខ្លួន និងការបន្ទាបខ្លួន។

ពិតជាកិត្តិយសខ្លាំងណាស់ដែលត្រូវបានផ្តល់កិត្តិយសជាមិត្តរបស់ព្រះអម្ចាស់។ តើនោះមិនមែនជាតួនាទីប្រទានដល់លោកអ័ប្រាហាំ ជាសំឡាញ់នៃព្រះទេឬអី? (យ៉ាកុប ២:២៣, ២ របាក្សត្រ ២:៧ អេសាយ៤:១៨)។ បាវបម្រើទទួលតែបញ្ជាពីចៅហ្វាយប៉ុណ្ណោះ។ មិត្តសំឡាញ់ទទួលយោបលពីគ្នាទៅវិញទៅមក! តែសូមកុំឲ្យយើងភ្លេចនូវក្រិត្យក្រមអំពីភក្តីភាពនិងស្វាមីភក្តិហើយនិងការចុះចូលដោយក្តីស្រឡាញ់គ្រប់គ្រងចំណងមិត្តភាពឡើយ (ខ១២-១៤)។ ពីការដំកើងកិត្តិយសក្នុងចំណងមិត្តភាពដែលបានផ្តល់ឲ្យសាវ៉ករបស់ព្រះអម្ចាស់នៃយើងដឹកនាំពួកគេឆ្ពោះទៅរកការតែងតាំងដ៏ខ្ពង់ខ្ពស់របស់ពួកគេ «មិនមែនអ្នករាល់គ្នាដែលបានរើសខ្ញុំទេ គឺខ្ញុំទេតើ ដែលរើសអ្នករាល់គ្នាវិញ ទាំងតែងតាំងអ្នករាល់គ្នា...»(ខ១៦)។ នេះនាំយើងមកដល់គោលលទ្ធិនៃការជ្រើសរើស (doctrine of election)។

នៅពេលព្រះអង្គមានបន្ទូលថាពួកគេមិនបានជ្រើសរើសទ្រង់ ពាក្យនោះមានន័យថាពួកគេគ្មានគុណសម្បត្តិ ឬសគុណអ្វីមួយដើម្បីធ្វើជាសាវ៉ក ឬជាសំឡាញ់ឡើយ។ វាគឺជាការសព្វព្រះហឫទ័យនិងគោលបំណងសុទ្ធសាធរបស់ព្រះជាម្ចាស់ ហើយនិងដើម្បីសិរីរុងរឿងរបស់ទ្រង់ផ្ទាល់ដែលព្រះអង្គបានជ្រើសរើសអ្នកទាំងដប់១១នាក់ធ្វើជាសាវ៉ក។ នេះគឺជាការជ្រើសតាំងដ៏ខ្ពង់ខ្ពស់ហួសពីដំណើរផ្តើមជ្រើសរើសឲ្យបានសេចក្តីសង្គ្រោះរបស់ពួកគេទៅទៀត។ ពួកសាវ៉កគឺត្រូវបានជ្រើសរើសយ៉ាងពិសេសពីចំណោមអ្នកបានសង្គ្រោះដោយព្រះគុណដ៏ពិសេសរបស់ព្រះជាម្ចាស់។ នៅក្នុងការបើកសម្តែងដល់ពួកសាវ៉កនូវការតែងតាំងដ៏ខ្ពង់ខ្ពស់បែបនេះ ការតាក់តែងរបស់ព្រះគ្រីស្ទគឺដើម្បីជំរុញឲ្យពួកគេបំពេញភារៈកិច្ចរបស់គេយ៉ាងសកម្ម (បណ្ឌិតកាល់វីន)។ នេះក៏ផ្តល់ឲ្យពួកគេនូវកម្លាំងសម្រាប់កិច្ចបម្រើ ដូចជាពួកគេបានដឹងរួចមកហើយថាគឺជាព្រះជាម្ចាស់ទេដែលធ្វើការនៅក្នុងពួកគេ «ដ្បិតគឺជាព្រះហើយ ដែលបណ្តាលចិត្តអ្នករាល់គ្នា ឲ្យមានទាំងចំណង់ចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ» (ភីលីព ២:១៣)។

តើអ្នកត្រូវបានហៅមកធ្វើជាបាវបម្រើ ជាអ្នកបម្រើរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ? នៅក្នុងការបម្រើពេញម៉ោង? តើធ្លាប់បានសង្ស័យនិងធ្លាក់ចិត្តខាងផ្នែកព្រលឹងវិញ្ញាណរបស់អ្នកពេលពន្ធ័កិច្ចហាក់ដូចជាទាញអ្នកឡើងទីទូលខ្ពស់តាមផ្លូវលំបាករដិបរដុប? ជាផ្លូវនៃឈើឆ្កាង! សូមចងចាំថាអ្នកត្រូវបានជ្រើសតាំងយ៉ាងពិសេសដោយព្រះជាម្ចាស់សម្រាប់កិច្ចការដែលទ្រង់បានហៅអ្នក។ ដូច្នេះអ្នកមិនអាចបរាជ័យ និងមិនត្រូវបរាជ័យបានទេ ព្រោះព្រះយេស៊ូវគ្រីស្ទជាប្រភពធន់ធានដ៏ធំនៃកិច្ចបម្រើរបស់អ្នក។ សូមឲ្យការតែងតាំងដ៏ខ្ពង់ខ្ពស់របស់ទ្រង់បំបាត់ចោលនូវអារម្មណ៍តូចទាបស្មុកស្មាញចេញចុះ។

**ការពិចារណា៖** គ្មានភាពជោគជ័យណាដែលគ្មានការលំបាកពុះពារឡើយ។
**ការអធិស្ឋាន៖** សូមអរព្រះគុណដែលទ្រង់សន្យាផ្តល់ព្រះគុណដល់អ្នករាបសា (យ៉ាកុប ៤:៦)។

ថ្ងៃទី ១៣ កក្កដា
យ៉ូហាន ១៥:១៨-២៥

*«តែបើរងទុក្ខ ដោយព្រោះជាពួកគ្រីស្ទានវិញ នោះកុំឲ្យខ្មាសឲ្យសោះ ចូរសរសើរដំកើងដល់ព្រះ ដោយព្រោះនាមនោះវិញ»។*

## ការបញ្ជាក់ទ្វេរដងសម្រាប់គ្រាលំបាកវេទនា

«បេតុងពង្រឹង (*reinforced concrete*)» ជាពាក្យបច្ចេកទេសប្រើក្នុងឧស្សាហកម្មសំណង់។ វចនានុក្រមវិបស្ទឺរ ពន្យល់ឃ្លានេះថា «កំបោរបេតុងដែលបន្ទះដែក ឬស្ពឺដែលបានបង្កប់ចូលគ្នាបណ្ដាលឲ្យសារជាតុទាំងពីរស៊ីគ្នានៅក្នុងកំឡាំងទប់ដ៏រឹងមាំ»។

មុនពេលព្រះអម្ចាស់នៃយើងយាងចាកចេញពីសិស្សទ្រង់ផ្ទាល់ ព្រះអង្គត្រូវតែជ្រាបដឹងពីការត្រៀមលក្ខណៈដើម្បីប្រឈមមុខនឹងបញ្ហាលំបាកវេទនាជាមុនសិន។ តើយើងបានត្រៀមខ្លួនរួចរាល់ឬនៅ?

នៅក្នុងផ្នែកមុនៗនៃមេរៀនយើងបានឃើញពីរបៀបដែលព្រះអម្ចាស់នៃយើងបានបញ្ជាក់ពួកសាវ័កតាមរយៈការបណ្ដុះនូវក្ដីស្រឡាញ់ គឺជាសេចក្ដីស្រឡាញ់សម្រាប់គ្រូ និងសេចក្ដីស្រឡាញ់សម្រាប់គ្នាទៅវិញទៅមក។ នៅពេលយើងឈរក្នុងជំហររួបរួមក្នុងចំណងក្ដីស្រឡាញ់នៃគ្រីស្ទបរិស័ទ យើងនឹងអាចប្រឈមមុខនឹងលោកីយ៍ជាបច្ចាមិត្តបាន។

ពិតមែនហើយ លោកីយដ៏ជាសត្រូវគឺជាទីកន្លែងដែលពួកសិស្សនឹងធ្វើដំណើរឆ្ពោះទៅ។ ពួកគេនឹងជួបនឹងសេចក្ដីសំអប់ (ខ១៨) ការបៀតបៀន (ខ២០) ការប្រកាន់ពូជសាសន៍ (ខ២៥)។ សេចក្ដីទាំងនេះគឺជាឥទ្ធិពលប្រឈមមុខនឹងពួកសិស្សស្មោះត្រង់គ្រប់រូប ពីព្រោះសិស្សស្មោះត្រង់ម្នាក់ៗត្រូវតែឆ្លងកាត់ដូចជាគ្រូបានឆ្លងកាត់ដែរ។ ព្រះសង្គ្រោះនៃយើងក្នុងការធ្វើបន្ទាល់ពីសេចក្ដីពិតបានបញ្ចប់ដោយនូវក្នុងសេចក្ដីស្លាប់។ ដូចនេះសេចក្ដីស្លាប់ មរណៈស្សបន្ទាល់ គឺជាការព្រៀងទុកជាមុនសម្រាប់សិស្សស្មោះត្រង់គ្រប់រូបនៅក្នុងលោកីយដ៏ជាសត្រូវនេះ។

តើយើងត្រៀមលក្ខណៈដើម្បីលីឈើឆ្កាងនៅថ្ងៃចុងក្រោយទាំងនេះឬនៅ?

ដើម្បីទុកជាការបញ្ជាក់ទ្វេរដងបន្ថែមទៀតឲ្យសាវ័កត្រូវតែឈរមាំមួនក្នុងគ្រាអាក្រក់ ព្រះអម្ចាស់នៃយើងបានរំឭកពួកគេពីការជំទាស់ទាំងឡាយដែលនឹងកើតមានឡើងដោយយល់ដល់ទ្រង់ថា «គេនឹងប្រព្រឹត្តការទាំងនោះដល់អ្នករាល់គ្នា ដោយយល់ដល់ឈ្មោះខ្ញុំ ... អ្នកណាដែលស្អប់ខ្ញុំ នោះក៏ស្អប់ដល់ព្រះវរបិតាខ្ញុំដែរ» (ខ ២១,២៣)។ ដូច្នេះព្រោះតែយល់ដល់ព្រះវរបិតាផងដែរ។ ការយល់ដឹងរបស់គ្រីស្ទបរិស័ទ នៅពេលត្រូវបៀតបៀនព្រោះសេចក្ដីសុចរិត ការបៀតបៀនបែបនេះនឹងបានត្រូវត្រឡប់ជាព្រះពរបញ្ជាក់ដល់គាត់ដើម្បីអាចបន្តឆ្លងកាត់ក្នុងសេចក្ដីទុក្ខលំបាក។

ហេតុនេះ ទើបសាវ័កពេត្រុសបានដាស់តឿនដល់ពួកអ្នកដែលត្រូវបានគេបៀតបៀន ដោយទីបន្ទាល់ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ថា «ត្រូវអរសប្បាយវិញ ដោយព្រោះមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាបានត្រេកអររីករាយជាខ្លាំង ក្នុងកាលដែលសិរីល្អទ្រង់លេចមក។ បើសិនជាគេតិះដៀលអ្នករាល់គ្នា ដោយព្រោះព្រះគ្រីស្ទ នោះមានពរហើយ ពីព្រោះព្រះវិញ្ញាណដ៏មានសិរីល្អ គឺជាព្រះវិញ្ញាណនៃព្រះ ទ្រង់សណ្ឋិតលើអ្នករាល់គ្នាហើយ...។ តែបើរងទុក្ខ ដោយព្រោះជាពួកគ្រីស្ទានវិញ នោះកុំឲ្យខ្មាសឲ្យសោះ ចូរសរសើរដំកើងដល់ព្រះ ដោយព្រោះនាមនោះវិញ» (១ ពេត្រុស ៤:១៣-១៦)។

ការបញ្ជាក់ទ្វេរដងសម្រាប់គ្រាលំបាកវេទនារួមមានសេចក្ដីស្រឡាញ់ និងកក្ដីភាពដើម្បីរងនូវការឈឺចាប់ដោយព្រោះយល់ដល់ព្រះយេស៊ូវប្រៀបដូចជាបេតុងនិងដែកដែលបានប្រើប្រាស់នៅក្នុងសំណង់គេហដ្ឋានដូច្នោះដែរ។

**ការពិចារណា៖** តើខ្ញុំត្រៀមលក្ខណៈដើម្បីលីឈើឆ្កាងនៅថ្ងៃចុងក្រោយទាំងនេះឬនៅ?
**ការអធិស្ឋាន៖** ឱសូមកុំឲ្យខ្ញុំខ្មាស់នឹងដោយព្រោះជាគ្រីស្ទានឡើយ។

ថ្ងៃទី ១៤ កក្កដា
យ៉ូហាន ១៥:២២, ២៤-២៧ *«..ព្រះអង្គនោះ ទ្រង់នឹងធ្វើបន្ទាល់ពីខ្ញុំ» ។*

## ព្រះគ្រីស្ទដាក់ទោស ព្រះដ៏ជំនួយនាំឲ្យជឿ

ព្រះគ្រីស្ទបានបង្រៀនគោលលទ្ធិដ៏សន្តោសប្រណីអំពីសេចក្តីពិតជាពិសេសដល់សាសន៍យូដា។ ដើម្បីបញ្ជាក់ថាការបង្រៀនរបស់ទ្រង់មកពីព្រះ ព្រះអង្គបានសម្តែងនូវការអស្ចារ្យដ៏ខ្លាំងក្លាជាច្រើននៅចំណោមពួកគេ «ដែលគ្មានអ្នកណាទៀតបានធ្វើឡើយ» (ខ២៤)។ ពិតជាឯកសិទ្ធិដែលសាសន៍យូដាជារាស្ត្រព្រះប្រទានដល់គេនូវពិធីជប់លៀងផ្នែកព្រលឹងវិញ្ញាណដ៏អស្ចារ្យជាច្រើន ពីអាហារមួយមុខហើយមួយមុខទៀត។ ជំនួសនូវការអរព្រះគុណសម្រាប់ព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ សាសន៍យូដាប្រៀបដូចជាកូនមិនល្អ បានប្រមាថមើលងាយអ្នកដែលបានផ្តល់អាហារដល់គេ។ ដោយសារបានប្រព្រឹត្តិទង្វើបែបនេះ ពួកគេបានដាក់ទោសដល់ខ្លួនឯងគេ។ ពួកគេជាប់មានទោសព្រោះបានបដិសេធន៍សេចក្តីពិត។ ពួកគេគ្មានអ្វីគ្របបាំង និងពាក្យដោះសារ ចំពោះអំពើបាបរបស់គេឡើយ។

សាសន៍យូដាទាំងនោះបានសម្រេចពាក្យរបស់ស្តេចដាវីឌបានមានបន្ទូលបែបជារូបតាំងរបស់ព្រះគ្រីស្ទ ហើយត្រូវបានមនុស្សជំនាន់ទ្រង់ស្អប់ព្រះអង្គដោយគ្មានមូលហេតុ។ មានសាសន៍យូដាជាច្រើនមិនត្រឹមតែនៅខាងក្នុងទេ តែក៏នៅខាងក្រៅផងដែរ គឺមានចំនួនមនុស្សបែបនោះច្រើនណាស់។

ប៉ុន្តែព្រះទ្រង់នឹងមិនទុកឲ្យអ្នកមានបាបចេញទៅដោយឥតបន្តកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធឡើយ។ ដូច្នេះទើបព្រះយេស៊ូវបានលើកទឹកចិត្តពួកសាវ័កថាទ្រង់នឹងបញ្ជូនព្រះដ៏ជាជំនួយមកពីព្រះវរបិតាដើម្បីបន្តធ្វើបន្ទាល់ពីព្រះអង្គ។ ការងារនៃព្រះវិញ្ញាណបរិសុទ្ធគឺដើម្បីប្រទាននូវភាពជោគជ័យដល់ពន្ធ័កិច្ចដំណឹងល្អ។ ព្រះអង្គនឹងធ្វើកិច្ចការនៅក្នុងចិត្តរបស់មនុស្សរឹងមានះប្រយោជន៍ឲ្យគេបានជឿថាព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់។

លោកម៉ាតជូ ហិនរី (Matthew Henry) មានប្រសាសន៍ថា «ព្រះវិញ្ញាណដ៏ប្រទានពរគឺជាពន្លឺភាយចុះមក ហើយជាអំណាចនៃព្រះចេស្តានៃព្រះ។ កាំរស្មីព្រះអាទិត្យ ជារស្មីចែកនិងបញ្ចេញនូវពន្លឺ និងកំដៅ ហើយជាឥទ្ធិពលចេញមកពីព្រះអាទិត្យ ក៏ប៉ុន្តែវាជាពន្លឺរួមគ្នាមួយ។ សាវ័កក៏ត្រូវបានបង្រៀននិងលើកទឹកចិត្តតាមរយៈឥទ្ធិពលរបស់ទ្រង់ គេនឹងធ្វើទីបន្ទាល់ដល់ទ្រង់ហើយនិងពីសេចក្តីសង្គ្រោះរបស់ទ្រង់ដែរ។ ពួកគេនឹងមានសមត្ថភាពដ៏ពិសេសក្នុងកិច្ចការនេះ ព្រោះបាននៅជាមួយព្រះអង្គតាំងពីគ្រាដំបូងនៃព័ន្ធកិច្ចរបស់ទ្រង់»។

នៅពេលព្រះគ្រីស្ទត្រូវបានគេបដិសេធព្រោះតែទីបន្ទាល់ដំបូងរបស់យើង ព្រះវិញ្ញាណបរិសុទ្ធត្រូវតែធ្វើការដើម្បីបណ្តាលឲ្យអ្នកបដិសេធព្រះគ្រីស្ទបានជឿនិងក្លាយជាអ្នកទទួលទ្រង់។ តើនោះមិនមែនជាបទពិសោធន៍របស់យើងមួយចំនួនជាអ្នករឹងមានះកាលពីដើមដំបូង? ឥឡូវនេះដែលយើងបានទទួលព្រះគ្រីស្ទវាគឺជាកិច្ចការពីខាងក្នុងរបស់អង្គព្រះវិញ្ញាណបរិសុទ្ធ។

**ការពិចារណា៖** បើព្រះមិនបើកភ្នែកខាងព្រលឹងវិញ្ញាណទេ នោះគឺគ្មានព្រះវិញ្ញាណគង់ក្នុងយើងដែរ។
**ការអធិស្ឋាន៖** អរព្រះគុណព្រះអម្ចាស់អើយ ដែលប្រទានសេចក្តីជំនឿឲ្យយើងខ្ញុំជឿព្រះយេស៊ូវ។

*« ខ្ញុំបាននិយាយសេចក្តីទាំងនេះ ប្រាប់ដល់អ្នករាល់គ្នា ដើម្បីកុំឲ្យអ្នករាល់គ្នារវាតចិត្តឡើយកុំឲ្យ» ។*

# ពាក្យបណ្តាំលានៃព្រះយេស៊ូវដល់សិស្សរបស់ទ្រង់

ហេតុផលមួយដែលអតីតនាយករដ្ឋមន្ត្រីអង់គ្លេស វិនស្តុន ធឺឆៀល (Winston Churchill) អាចប្រមូលផ្តុំប្រជាជាតិមួយដែលពុំបានត្រៀមលក្ខណៈទប់ទល់នឹងជនជាតិអាល្លឺម៉ង់ឆ្ពោះរកជ័យជំនះនាសង្គ្រាមចុងក្រោយ (the Last War) គឺដោយសារការបើកចំហរបស់គាត់។ ផ្ទុយពីពាក្យនិយាយចំហរបស់លោក ណេវីល ឆាំប៊ឺលេន (Neville Chamberlain) លោកធឺឆៀលបានប្រាប់បណ្តាប្រជាជាតិទាំងឡាយថាការប្រឈមមុខនឹងការអាក្រក់ដ៏ធ្ងន់ធ្ងរគឺពិតប្រាកដមែន។

ព្រះអង្គដ៏ជាសេចក្តីពិត នៅក្នុងពាក្យបណ្តាំលារបស់ទ្រង់បានមានបន្ទូលប្រាប់ពួកសិស្សពីការសាកល្បងផ្សេងៗដែលនៅគ្រាឥឡូវនេះនឹងកើតមានឡើងដល់គេដូចជាផ្គររន្ទះ។ ដូច្នេះ ជំពូក១៦ចាប់ផ្តើមយ៉ាងហ័ស តែប្រកបដោយសេចក្តីពិត៖ «ខ្ញុំបាននិយាយសេចក្តីទាំងនេះប្រាប់ដល់អ្នករាល់គ្នា ដើម្បីកុំឱ្យអ្នករាល់គ្នារវាតចិត្តឡើយ។ គេនឹងកាត់អ្នករាល់គ្នាចេញពីពួកជំនុំរបស់គេ ក៏នឹងមានពេលវេលាមកនោះអ្នកណាដែលសំឡាប់អ្នករាល់គ្នានឹងគិតស្មានថាខ្លួនបំរើដល់ព្រះដែរ (អធិមុត្តិនិយមនៃសង្គ្រាមបរិសុទ្ធជនជាតិជ្វីប» )។

ក្រោយមកព្រះយេស៊ូវគាំទ្រពាក្យអះអាងរបស់ទ្រង់អំពីការចាកចេញពីពួកសិស្សជាមួយនឹងលទ្ធផលល្អដែលនឹងកើតមានឡើង គឺជាការបញ្ជូនមកនៃព្រះដ៏ជាជំនួយ ជាព្រះវិញ្ញាណបរិសុទ្ធដែលទ្រង់នឹងទទួលជំនួសនូវតួនាទីរបស់ទ្រង់ដោយក្នុងមធ្យោបាយដ៏វិសេសមួយ (ខ៧)! ម៉្យាងវិញទៀតព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើឱ្យលោកីយស្គាល់ពីអំពើបាបនិងពីសេចក្តីសុចរិត ហើយនិងពីសេចក្តីជំនុំជំរះ បន្ថែមលើនោះទៀតព្រះអង្គនឹងនាំពួកសាវកចូលក្នុងគ្រប់ទាំងសេចក្តីពិតព្រោះតែគេមិនអាចទទួលនូវសេចក្តីគ្រប់លក្ខណៈនៅឡើយខណៈពេលនោះ។

ព្រះយេស៊ូវសម្រាលនូវការព្រួយបារម្ភនិងការភិតភ័យរបស់គេដោយការធានាពីជ័យជំនះលើសេចក្តីស្លាប់។ ការព្រួយចិត្តរបស់សាវកនឹងមានត្រឹមតែ «មួយរយៈពេលខ្លី» ប៉ុណ្ណោះ តែវានឹងប្រែទៅជាក្តីអំណរវិញ (ខ២០)។ ព្រះអម្ចាស់នៃយើងប្រដូចទុក្ខវេទនារបស់ទ្រង់ទៅនឹងស្ត្រីឈឺពោះសម្រាលកូន «តែកាលណាសំរាលរួចមក នោះលែងនឹកពីសេចក្តីវេទនានោះហើយ ពីព្រោះមានសេចក្តីអំណរដោយព្រោះមានកូនមួយកើតមកក្នុងលោក» (ខ ២១)។

លើសជាងនោះទៅទៀតព្រះអម្ចាស់នៃយើងសន្យានឹងពួកគេសុវត្ថិភាពពីការផ្គត់ផ្គង់ដោយសេចក្តីស្រឡាញ់នៃព្រះវរបិតានានគរស្ថានសួគ៌ បើគេទូលសុំដោយនូវក្នុងព្រះនាមទ្រង់។

ទទួលបាននូវការលើកទឹកចិត្តតាមរយៈពាក្យបន្ទូលដ៏ច្បាស់របស់ទ្រង់ គេក៏បានបង្ហាញនូវក្តីទំនុកចិត្តរបស់គេយ៉ាងមុតមាំ (ខ ២៩, ៣០)។

ព្រះយេស៊ូវមានបន្ទូលនាពេលចុងក្រោយអំពីពួកសិស្សថាគេនឹងបែកខ្ញែកគ្នាដោយសារការសាកល្បងដែលកើតឡើង ប៉ុន្តែទ្រង់នឹងអាចទ្រាំទ្រនឹងការសាកល្បងដោយសារព្រះវរបិតាជាមួយនឹងទ្រង់។ សូមទន្ទេញចងចាំខទី៣៣រួចហើយធ្វើតេសការចងចាំរបស់អ្នក យ៉ូហាន ១៤:១៧ ដែលចែងពីសេចក្តីសុខសាន្តលោកីយ៍ត្រូវការជាចាំបាច់។

**ការពិចារណា៖** តើពាក្យបន្ទូលដែលខ្ញុំបានអាននិងស្តាប់បានកំសាន្តចិត្ត?
**ការអធិស្ឋាន៖** សូមទ្រង់ជាកម្លាំងដល់យើងខ្ញុំនៅក្នុងគ្រាល្បួងផ្សេងៗដែលកើតមានក្នុងជីវិតនេះផង។

# ការព្រមានទុកជាមុនគឺដើម្បីប្រុងប្រៀបខ្លួនទុកជាមុន

នៅពេលព្រះយេស៊ូវត្រាស់ហៅសាវ័កទាំង១២នាក់ តើទ្រង់មិនបានមានបន្ទូលប្រាប់ពីល័ក្ខខ័ណ្ឌព្រមព្រៀងអំពីភាពជាសាវ័ក? ប្រាកដណាស់ ទ្រង់បានធ្វើកិច្ចការនោះ។ ថ្វីដ្បិតម៉ាកុសនិងលូកាផ្តល់ការពិពណ៌នាដ៏ស្ដួចស្ដើងដល់យើង លោកម៉ាថាយពិព៌ណនាបំពេញយ៉ាងលម្អិត ក្នុងជំពូក១០ទាំងមូលដែលមាន៤២ខ។ បណ្តាពាក្យព្រមានដែលទ្រង់ផ្ដល់ឲ្យនៅក្នុងខនោះគឺដូចគ្នានឹងពាក្យនៅក្នុងអត្ថបទ (ព្រះគម្ពីរ) នេះ គឺចំៗនិងតឹងរឹង ហើយតម្រូវការនៃភាពជាសាវ័កក៏ច្បាស់លាស់ដែរ។

ទោះជាយ៉ាងណា នៅក្នុងដំណឹងល្អម៉ាថាយ ពួកសាវ័កគឺត្រូវបានបញ្ជាក់ប្រាប់ឲ្យដឹងច្បាស់ពីការការពារនៃព្រះវរបិតាតាមរយៈការគាំពាររបស់ព្រះជាម្ចាស់យ៉ាងពិសេសមួយ។ ពួកគេទទួលបាននូវសេចក្តីសន្យានៃគតិបណ្ឌិតរបស់ព្រះវិញ្ញាណបរិសុទ្ធសម្រាប់បបូរមាត់របស់ពួកគេដើម្បីរំដោះគេចេញពីអន្ទាក់ចោទប្រកាន់របស់អ្នកចោទប្រកាន់របស់គេ។ តើហេតុអ្វីបានជាព្រះអម្ចាស់នៃយើងមានបន្ទូលថា «ខ្ញុំមិនបានប្រាប់កាលពីដើមទេ ពីព្រោះខ្ញុំកំពុងនៅជាមួយនឹងអ្នករាល់គ្នានៅឡើយ?» ។

ការយល់ដឹងរបស់យើងគឺថាទោះបីទ្រង់បានថ្លែងពីល័ក្ខខ័ណ្ឌព្រមព្រៀងអំពីភាពជាសាវ័ក ព្រះអង្គមិនបានមានបន្ទូលប្រាំដែលអំពីការនោះទេ ពីព្រោះពេលល្បងលពុំទាន់មកដល់នៅឡើយ។ ដោយហេតុតែព្រះអម្ចាស់តែងមានវត្តមាននឹងពួកសាវ័ក ដូចនេះគេមានអារម្មណ៍សុវត្ថិភាព។

ពេលដែលគ្រោងទុកឥឡូវនេះនឹងរំកិលមកដល់យ៉ាងរហ័ស ព្រះអម្ចាស់ត្រូវឲ្យសាវ័កទ្រង់ត្រៀមខ្លួនសម្រាប់ការល្បងល។ ការព្រមានទុកជាមុនគឺដើម្បីប្រុងប្រៀបខ្លួនទុកជាមុន៖ «ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នានឹងយំ ហើយសោកសង្រេង តែលោកីយនឹងអរសប្បាយឡើង អ្នករាល់គ្នានឹងព្រួយចិត្ត តែសេចក្តីព្រួយរបស់អ្នករាល់គ្នានឹងប្រែទៅជាសេចក្តីអំណរវិញ» (ខ ២០)។ សេចក្តីវេទនាប្រាកដជានឹងកើតមានឡើង តែការរំដោះលោះក៏នឹងមានដែរ!

តើមេរៀនអ្វីយើងអាចរៀនពីសេចក្តីបង្រៀនដ៏ច្បាស់លាស់នេះ? យើងក៏ត្រូវតែប្រុងប្រយ័ត្នដែរ។ ដូចជាសាវ័កត្រូវតែឆ្លងកាត់ទុក្ខលំបាកវេទនានៅក្នុងមាគ៌ានៃឈើឆ្កាង យើងក៏ត្រូវតែត្រៀមលក្ខណៈដើម្បីឆ្លងកាត់ចលាចលនិងការបៀតបៀននៅជាន់ក្រោយបង្អស់មុនយើងឃើញមង្កុត គឺជាការយាងមកវិញរបស់ទ្រង់! ថ្វីដ្បិតការល្បងលនាពេលបច្ចុប្បន្នរបស់យើង យ៉ាងណាក៏ដោយ យើងក៏ទុក្ខព្រួយរបស់យើងនឹងក្លាយជាសេចក្តីអំណរដែរនាពេលទ្រង់យាងមកក្នុងពពកនាអាកាសនឹងកើតមានឡើង។ តើនេះមិនមែនជាក្តីសង្ឃឹមនៅក្នុងនៅលោកីយដ៏មានបញ្ហាទេឬអី?

**ការពិចារណា៖** សូមទន្ទេញ ១ កូរិនថូស ១០:១៣។
**ការអធិស្ឋាន៖** យើងខ្ញុំជឿថាទ្រង់នឹងព្រះអង្គគង់ជាមួយនឹងយើងដូចជានឹងពួកសាវ័កទ្រង់ដែរ។

ថ្ងៃទី ១៧ កក្កដា
យ៉ូហាន ១៦:៥-៨

*« ដ្បិតបើខ្ញុំមិនទៅទេ នោះព្រះដ៏ជាជំនួយក៏មិនមកឯអ្នករាល់គ្នាដែរ.. »*

# ផែនការរបស់ព្រះ សម្រាប់វិបុលភាពរបស់យើង

ពេលព្រះអម្ចាស់នៃយើងមានបន្ទូលយ៉ាងច្បាស់ពីទុក្ខវេទនាដែលគ្រូនិងសិស្សត្រូវតែឆ្លងកាត់ ហើយនិងអំពីដំណើរយាងត្រឡប់ទៅឯព្រះវរបិតានានគរស្ថានសួគ៌ បរិយាកាសស្រងូតស្រងាត់ដ៏ស្ងប់ស្ងាត់មួយបក់មកគ្របដណ្តប់លើសាវ័កទាំងដប់មួយនាក់។ ដូចជាសុភាសិតចិនមួយពោលថា តើមានទុក្ខព្រួយដ៏ធំអ្វីជាជាងទុក្ខព្រួយនៃការឃ្លាតចេញពីមនុស្សជាទីស្រឡាញ់ ទោះជានៅមានជីវិត ឬស្លាប់? ជាធម្មតាសាវ័កមិនចង់ឲ្យព្រះអម្ចាស់របស់ខ្លួនគេចាកចេញដូចជាកុមារតូចៗមិនអាចទ្រាំទ្រនឹងឃើញឪពុកម្តាយរបស់ខ្លួនចាកចេញពីពួកគេសម្រាប់រយៈពេលណាមួយដូច្នោះដែរ។ បើអ្នកជាសាវ័កភីលីព ឬថូម៉ាសវិញ តើអ្នកនឹងមានអារម្មណ៍យ៉ាងដូចម្តេច?

ទោះជាយ៉ាងណា នៅក្នុងផែនការណ៍នៃកិច្ចការសម្រេចលទ្ធផលសេចក្តីសង្គ្រោះរបស់ព្រះ ដើម្បីប្រយោជន៍របស់យើង ព្រះសង្គ្រោះត្រូវតែយាងចាកចេញពីផែនដីនេះ។ បើទ្រង់បន្តគង់នៅផែនដី ព្រះដ៏ជាជំនួយ ព្រះវិញ្ញាណបរិសុទ្ធ ជាអង្គបុគ្គលទីបីនៃព្រះត្រៃឯកនឹងមិនត្រូវបានបញ្ជូនមកឡើយ។ ប៉ុន្តែនៅពេលព្រះអម្ចាស់នៃយើងយាងទៅឋានសួគ៌ស្របតាមផែនការណ៍នៃកិច្ចការសម្រេចលទ្ធផលសេចក្តីសង្គ្រោះរបស់ព្រះព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកហើយបន្តការងារដែលនៅសេសសល់ដើម្បីបញ្ចប់នូវកិច្ចការទាំងនោះ។ នៅក្នុងការរៀបចំនេះ យើងជាពួកជំនុំជាទូទៅនឹងត្រូវបានប្រទានពរ។ ដោយហេតុតែកិច្ចការនៃព្រះសង្គ្រោះនៃយើងគឺត្រឹមតែដែនដីរបស់សាសន៍យូដាការងារនៃព្រះវិញ្ញាណបរិសុទ្ធនឹងពង្រីកទៅទូទាំងពិភពលោក។

រូបភាពពន្យល់ត្រង់ចំណុចនេះប្រហែលនឹងផ្តល់នូវភាពងាយស្រួលយល់។ តើអ្នកបំភ្លឺផ្ទះរបស់អ្នកដោយរបៀបណា? តាមរយៈការដាក់អំពូលភ្លើងឲ្យកាន់តែខិតជិតនឹងកម្រាលឥដ្ឋដូចជាអ្នកអាចធ្វើទៅបាន? បើអ្នកធ្វើដូចនេះនឹងមានពន្លឺខ្សោយបំភ្លឺដល់គេហដ្ឋានរបស់អ្នក។ ទេ នឹងធ្វើមិនដូច្នោះឡើយ។ អ្នកនឹងដាក់អំពូលភ្លើងកាន់ខ្ពស់ទៅតាមលទ្ធភាពដែលអ្នកអាចធ្វើទៅបាន ដែលធម្មតាដោយការចាប់អំពូលទាំងនោះភ្ជាប់ទៅនឹងពិដាន។ បន្ទាប់មកពន្លឺភ្លើងនឹងបំភ្លឺជះទៅគ្រប់ជ្រុងជ្រោយនៃលំនៅដ្ឋានរបស់អ្នក។ ដូចជាព្រះគ្រីស្ទបានយាងទៅឋានដ៏ខ្ពស់នោះពន្លឺរបស់ទ្រង់ ព្រះវិញ្ញាណបរិសុទ្ធនឹងចាំងពន្លឺច្បាស់នៅក្នុងចិត្តរបស់យើងរាល់គ្នារហូតដល់ទីបំផុតនៃផែនដី។ ផែនការណ៍របស់ព្រះជាម្ចាស់គឺសម្រាប់វិបុលភាពរបស់យើង!

**ការពិចារណា៖** ផែនការរបស់ព្រះគឺខ្ពង់ខ្ពស់ជាងអស់ទាំងគំនិតរបស់យើង។
**ការអធិស្ឋាន៖** សូមឲ្យយើងខ្ញុំជឿថារាល់ទាំងផែនការរបស់ទ្រង់គឺសម្រាប់ការល្អរបស់យើងខ្ញុំ។

ថ្ងៃទី ១៨ កក្កដា
យ៉ូហាន ១៦:៨-១១

*«ទ្រង់នឹងសំដែងពី..អំពីអំពើបាប ពីសេចក្តីសុចរិត ហើយពីសេចក្តីជំនុំជំរះ» ។*

## បេសកកម្មបីផ្នែករបស់ព្រះវិញ្ញាណ

១. ព្រះអង្គនឹងសម្តែងឲ្យលោកីយដឹង**ពីអំពើបាប**។ «គឺអំពីអំពើបាបដោយព្រោះគេមិនជឿដល់ខ្ញុំ» (ខ ៩)។ ការសម្តែងឲ្យដឹងគឺជាការបណ្តាលឲ្យជឿ។ វាគឺជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធដើម្បីធ្វើឲ្យជឿ ហើយទ្រង់អាចធ្វើការនេះយ៉ាងប្រសិទ្ធិភាព។ លុះត្រាតែព្រះវិញ្ញាណបរិសុទ្ធរួមចំណែកក្នុងការអធិប្បាយរបស់យើងទើបវានឹងមិនធ្លាក់លើប្រចៀកថ្លង់។ តើព្រះវិញ្ញាណបរិសុទ្ធនឹងសម្តែងឲ្យដឹងពីអ្នកណា? លោកីយ គឺទាំងសាសន៍យូដានិងសាសន៍ដទៃ។ លោកម៉ាតជូ ហិនរី បានបន្ថែមថា «ពីមនុស្សខ្លះ នៅគ្រប់ជំនាន់និងគ្រប់ទីកន្លែង ប្រយោជន៍ដើម្បីឱ្យមានការកើតជាថ្មីមកក្នុងជំនឿរបស់ព្រះគ្រីស្ទ។ បច្ចុប្បន្ននេះវាគឺជា ការលើកទឹកចិត្តឲ្យបង្កើតសិស្សទាក់ទងនឹងការលំបាកទាំងឡាយដែលពួកគេប្រឈមមុខ។ សូម្បីតែគពផែនដីអាក្រក់ក៏ព្រះវិញ្ញាណនឹងធ្វើកិច្ចការនោះចំពោះវាដែរ ហើយការនាំឲ្យអ្នកមានបាបជឿគឺជាភាពកក់ក្តៅមួយរបស់អ្នកបម្រើស្មោះត្រង់» ។ តើបាបគឺជាអ្វី? បាបជាការគ្មានជំនឿ។ ការបដិសេធព្រះគ្រីស្ទគឺជាអំពើបាបដ៏ធ្ងន់ធ្ងរ!

២. **ពីសេចក្តីសុចរិត**។ ព្រះអង្គនឹងបណ្តាលឲ្យលោកីយជឿព្រះយេស៊ូវជាអ្នកស្រុកណាសារ៉ែតថាជាព្រះគ្រីស្ទគឺជាព្រះដ៏សុចរិត ទោះបីសាសន៍យូដាមិនអាចទទួលនូវការពិតនេះ ដោយហេតុនេះទើបពួកគេស្ថិតក្នុងបញ្ហាជាច្រើននាសព្វថ្ងៃនេះ។ ព្រះគ្រីស្ទគឺត្រូវបានបញ្ជាក់ឲ្យដឹងថាជាមនុស្សដ៏សុចរិតហើយទ្រង់មិនមែនជាអ្នកបោកបញ្ឆោតទេ និងលើសជាងនោះទៅទៀតទ្រង់គឺជាអ្នកប្រោសលោះរបស់មនុស្សជាតិ។

៣. **ពីការជំនុំជំរះ**។ តាមរយៈការជំនុំជំរះស្តេចនៃលោកីយ គឺជាអារក្សសាតាំង ព្រះគ្រីស្ទគឺត្រូវបានបញ្ជាក់ឲ្យដឹងថាទ្រង់ជាអង្គដ៏មានអំណាចខ្លាំងជាងគេ។ ព្រះវិញ្ញាណបរិសុទ្ធនឹងសម្តែងប្រាប់ឲ្យដឹងថាដំណើរបេសកកម្មរបស់ព្រះគ្រីស្ទនៅផែនដីគឺដើម្បីណែនាំពីពេលវេលានៃការកែទម្រង់និងការផ្លាស់ប្រែ។ ហើយលើសពីការជំនុំជំរះនាថ្ងៃចុងក្រោយ អស់ទាំងសត្រូវរឹងរូសទាស់នឹងដំណឹងល្អនៃព្រះគ្រីស្ទនិងនគររបស់ទ្រង់ពួកគេនឹងត្រូវរាប់បញ្ចូលក្នុងការជំនុំជំរះដែរ ព្រោះអារក្សនឹងត្រូវបានជំនុំជំរះ។ ដូច្នេះពួកអ្នកមានបាបគឺត្រូវបានបណ្តាលឲ្យដឹងពីកំហុសនិងនាំមកនូវការជំនុំជំរះខ្លួនឯងគេ ហើយទទួលស្គាល់ពីទោសកំហុសនៅចំពោះព្រះជាម្ចាស់» (ម៉ាតជូ ហិនរី)។

**ការពិចារណា៖** ដរាបណាខ្ញុំនៅមានជីវិត ឱកាសនៃការរួចពីការជំនុំរះមានដែនកំណត់។
**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ សូមអរព្រះគុណសម្រាប់ការរំដោះយើងខ្ញុំរួចពីការជំនុំជំរះ។

## ព្រះវិញ្ញាណបរិសុទ្ធជាគ្រូបន្តរបស់សាវ័ក

ការបង្រៀនពីសេចក្តីពិតត្រូវបានប្រទានមកជាលំដាប់។ ពីក្រិត្យវិន័យរបស់លោកម៉ូសេដល់ ប្រវត្តិសាស្ត្រនៃរាស្ត្ររបស់ព្រះជាម្ចាស់ ដល់កណ្ឌបទទំនាយ ដល់កណ្ឌកំណាព្យ ដូចជាទំនុក ដំកើងនិងប្រាជ្ញា អក្សសាស្ត្រ ដូច ជាសុភាសិតជាដើម។ ក្រោយមកកណ្ឌសញ្ញាថ្មី ដំណឹងល្អ កិច្ចការ បណ្តាសំបុត្រ និងកណ្ឌវិវរណៈ។ សាវ័កប៉ុល មានប្រសាសន៍ទៅអ្នកស្រុកកូរិនថា «ខ្ញុំបានឲ្យទឹកដោះមកអ្នករាល់គ្នាផឹក មិនបានឲ្យសាច់បរិភោគទេ ដ្បិតកាល ណាអ្នករាល់គ្នាពុំអាចនឹង បរិភោគបាន ហើយឥឡូវនេះ ក៏មិនទាន់បានដែរ» (១ កូរិនថូស ៣:២)។

ព្រះអម្ចាស់នៃយើងមានបន្ទូលទៅពួកសិស្សថា« ខ្ញុំនៅមានសេចក្តីជាច្រើនទៀតនឹងប្រាប់ដល់អ្នករាល់គ្នា តែឥឡូវនេះ អ្នករាល់គ្នាពុំអាចនឹងទទួលបានទេ» (ខ ១២)។ ឧទាហរណ៍ សេចក្តីពិតអំពីការរស់ឡើងវិញ និងការ យាងត្រឡប់ទៅឋានសួគ៌ហើយនិងដំណើរយាងមកនៃអង្គព្រះវិញ្ញាណ ដោយនូវក្នុងអំណាចបេស្តានាបុណ្យថ្ងៃទី ៥០ សេចក្តីពិតទាំងនេះមិនទាន់កើតឡើងនៅឡើយ។ វាជាមូលហេតុដ៏ត្រឹមត្រូវ បន្ទាប់ពីព្រឹត្តិការណ៍ ទាំងនេះ បានកើតមានឡើង មេរៀនទាំងនោះត្រូវបានប្រទានដល់ពួកគេ។ ព្រះវិញ្ញាណបរិសុទ្ធគឺជាគ្រូបង្រៀនបន្តដែលទ្រង់ «នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំងសេចក្តីពិត» (ខ ១៣)។ លោកម៉ាតជូ ហិនរី មានប្រសាសន៍ថា៖ «ដើម្បីដឹក នាំពួកសាវ័ក ព្រះអង្គនឹងថែរក្សាគេមិនឲ្យពួកគេវង្វេងផ្លូវ។ ព្រះវិញ្ញាណបរិសុទ្ធបានតម្រង់អណ្តាតរបស់ពួកគេក្នុង ការនិយាយនិងប៊ិចក្នុងការសរសេរ ដើម្បីរក្សាពួកគេពីកំហុសឆ្គងទាំងឡាយ។ ព្រះវិញ្ញាណបរិសុទ្ធគឺជាមគ្គុទេសក៏របស់យើង រ៉ូម ៨:១៤ ដែលទ្រង់នឹងយាងទៅជាមួយយើងតាមរយៈជំនួយការនិងអនុភាពរបស់ទ្រង់» ។

លោកម៉ាធិន (Machen) មានប្រសាសន៍ថាសាវ័កទទួលអំណាចរបស់គេមកពីការប្រទានអំណាចរបស់ព្រះយេស៊ូវ ដែលទ្រង់នឹងបញ្ជូនព្រះវិញ្ញាណបរិសុទ្ធមកដឹកនាំគេចូលក្នុងគ្រប់ទាំងសេចក្តីពិត (យ៉ូហាន ១៦:១៣)។ ហើយដោយសារអត្ថប្រយោជន៍នៃអំណាចនេះ សាវ័កបានបន្ថែមទៅព្រះគម្ពីរនាសម័យកាលរបស់គេ នូវសៀវភៅជាច្រើនទៀតដែលមាននៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ បណ្តាខ (គម្ពីរ)នៅក្នុងមេរៀនផ្នែកនេះប្រទានមកយ៉ាងពិសេសដល់សាវ័កនូវអំណាចដើម្បីសរសេរកណ្ឌសញ្ញាថ្មីព្រោះព្រះវិញ្ញាណបរិសុទ្ធគឺជាគ្រូបន្តរបស់ពួក គេ។ សៀវភៅសញ្ញាថ្មីគឺត្រូវបានព្រះបណ្តាលឲ្យតែងដូចជាបណ្តាសៀវភៅព្រះគម្ពីរសញ្ញាចាស់ដែរ កណ្ឌនោះគ្មានកំហុស គ្មានការភាន់ច្រឡំដូចគ្នា។ មិនត្រឹមតែការសរសេររបស់សាវ័កជាពាក្យបន្ទូលនៃព្រះប៉ុណ្ណោះទេ ឯការអធិប្បាយរបស់គេក៏ជាព្រះបន្ទូលដែរ! លោកម៉ាធិនណែនាំយើងទៅ ១ ថែស្សាឡូនីច ២:១៣ ជាខដែលសាវ័កប៉ុលបង្រៀនថា «ដោយហេតុនេះទៀត បានជាយើងខ្ញុំអរព្រះគុណដល់ព្រះ ឥតមានដាច់ គឺដោយព្រោះកាលអ្នករាល់គ្នាបានទទួលព្រះបន្ទូល ជាដំណឹងពីព្រះ ដោយសារយើងខ្ញុំ នោះមិនបានទទួល ទុកដូចជាពាក្យរបស់មនុស្សទេ បានទទួលតាមភាពដ៏ពិតនៃដំណឹងនោះវិញ គឺជាព្រះបន្ទូលនៃព្រះដែលបណ្តាលមកក្នុងអ្នករាល់គ្នា ជាពួកអ្នកជឿ» ។ បើអ្នកណាម្នាក់គួរិះគន់សាវ័ក តាមរយៈពាក្យសម្តីឬទង្វើណាមួយ សូមអ្នកនោះគួរប្រុងប្រយ័ត្ន!

**ការពិចារណា៖** តើខ្ញុំបានស្គាល់សេចក្តីពិតរួចហើយ?

**ការអធិស្ឋាន៖** ឱសូមឲ្យខ្ញុំឃ្លាតឆ្ងាយពីការមន្ទិលសង្ស័យនឹងពាក្យបន្ទូលទ្រង់។

ថ្ងៃទី ២០ កក្កដា
យ៉ូហាន ១៦:១៦-២២,២៧-៣៣

*« ទឹកភ្នែកនឹងមាននៅជាប់អស់មួយយប់ក៏បាន តែព្រឹកឡើងគង់នឹងមានសេចក្តីអំណរឡើងដែរ» ។*

# «នៅបន្តិចទៀត»

ឃ្លានេះព្រះអម្ចាស់នៃយើងប្រើដើម្បីពិពណ៌នានូវព្រឹត្តិការណ៍ដែលនឹងកើតឡើងនាពេលដ៏ខ្លីខាងមុខ គឺរយៈពេលប៉ុន្មានម៉ោងទៀតប៉ុណ្ណោះ ហើយរយៈពេលប៉ុន្មានថ្ងៃភ្លាមៗទៀតដែលនឹងមកដល់បានក្លាយជាប្រស្នាមួយចំពោះក្រុមសាវ័ក។ ពេលយើងយល់នូវឃ្លានោះកាន់តែច្បាស់ពីចម្ងាយ «បន្តិចទៀត» ថាព្រះអម្ចាស់នៃយើងបង្រៀនអំពីការឃ្លាតចេញទៅវាងពួកគេក្នុងការចាប់ខ្លួន ការឆ្កាង ការបញ្ចុះ (ក្នុងផ្នូរ) និងការរស់ឡើងវិញ។ តើសាវ័កបានភិតភ័យចេញពីភាពទល់តម្រិះរបស់ពួកគេ? តើពួកគេមិនរងទុក្ខធ្ងន់ធ្ងរ? សិស្សខ្លះអាចនឹងលះបង់ចោលអស់រាល់ក្តីសង្ឃឹម ព្រោះតែស្ពឹកថ្លង់នឹងការបង្រៀននិងការអធិប្បាយពីបទទំនាយរបស់ព្រះអម្ចាស់នៃយើង។ ការបាត់បង់នូវក្តីសង្ឃឹមដ៏ស្រគត់ស្រគុំគឺមានសភាពធ្ងន់ធ្ងរ តែសម្រាប់ «រយៈពេលបន្តិច» ប៉ុណ្ណោះ។ «ទឹកភ្នែកនឹងមាននៅជាប់អស់មួយយប់ក៏បាន តែព្រឹកឡើងគង់នឹងមានសេចក្តីអំណរឡើងដែរ» (ទំនុកដំកើង ៣០:៥)។

ព្រោះបន្ទាប់ពីការសុគតរបស់ទ្រង់នឹងមានការរស់ឡើងវិញ និងបន្ទាប់ពីការរស់ឡើងវិញ គឺការយាងត្រឡប់ទៅស្ថានសួគ៌ (ខ២៨) ហើយនៅក្នុងសេចក្តីពិតនៃការយាងត្រឡប់ទៅស្ថានសួគ៌នាំមកនូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធជាដំណើរយាងមកនិងព្រះវត្តមានអចិន្ត្រៃយ៍បែបព្រលឹងវិញ្ញាណរបស់ព្រះគ្រីស្ទនៅក្នុងពួកជំនុំ។

លោកបណ្ឌិតកាល់វិនយល់ឃើញលើសពីការបង្ហាញរបស់ព្រះគ្រីស្ទអំពីអង្គទ្រង់ដល់ពួកសាវ័កក្នុងឃ្លា «បន្តិចទៀត»។ គាត់ក៏យល់ដឹងពីព្រះវត្តមានរបស់ព្រះគ្រីស្ទនៅក្នុងការសណ្ឋិតនៅនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងចិត្តរបស់ពួកគេផងដែរ។ ថ្វីដ្បិតតែគាត់មិនបានឃើញទ្រង់ផ្ទាល់នឹងភ្នែករបស់គាត់ក៏ដោយ ប៉ុន្តែព្រះវត្តមានរបស់ទ្រង់គឺអាចដឹងបានតាមរយៈវត្តមាននៃសេចក្តីជំនឿដូចគ្នាដែរ។ ព្រះគ្រីស្ទចង់ឲ្យពួកសាវ័កដឹងពីអ្វីដែលនឹងជាស្ថានភាពបន្ទាប់ពីការស្លាប់ដើម្បីឲ្យពួកគេអាចនឹងស្គាល់នឹងព្រះវត្តមានបែបព្រលឹងវិញ្ញាណរបស់ទ្រង់ និងមិនចាត់ទុកវាដូចជាការបាត់បង់ចំពោះពួកគេ ហើយថាទ្រង់ឈប់គង់នៅជាមួយនឹងពួកគេដូចជាមនុស្សខាងផ្នែកសាច់ឈាមឡើយ។

តើពួកសាវ័កស្រឡាញ់ព្រះអម្ចាស់របស់ខ្លួនហើយកើតមានសេចក្តីទុក្ខព្រួយព្រោះតែនឹកព្រះសង្គ្រោះរបស់គេ «តែបន្តិច» យ៉ាងណាទៅ! តើអ្នកនឹកព្រះអម្ចាស់របស់អ្នក នៅពេលគេបង្ខាំងអ្នកពីការចូលរួមថ្វាយបង្គំព្រោះតែជម្ងឺ? តើទ្រង់យាងមកអ្នកនៅថ្ងៃបង្ខាំងទាំងនោះ? តើទ្រង់គង់នៅជាមួយអ្នកគ្រប់ពេលវេលា?

**ការពិចារណា៖** ដ្បិត១ថ្ងៃក្នុងព្រះលាននៃទ្រង់ នោះវិសេសជាង១ពាន់ថ្ងៃណាទៀត (ទំនុក. ៨៤:១០)
**ការអធិស្ឋាន៖** យើងខ្ញុំត្រូវការវត្តមានទ្រង់គ្រប់វេលា និងគ្រប់ខ្យល់ដង្ហើមចេញចូលរបស់យើងខ្ញុំ។

## ១. នៅថ្ងៃនោះអ្នករាល់គ្នានឹងមិនសូមអ្វីពីខ្ញុំទៀត (ខ២៣)
## ២. នៅថ្ងៃនោះ អ្នករាល់គ្នានឹងសូមដោយនូវឈ្មោះខ្ញុំ (ខ២៦)

ប្រយោគទាំងពីរនេះហាក់ដូចជាផ្ទុយគ្នា!

១. **នៅថ្ងៃនោះ** (ខ ២៣) សំដៅទៅការយាងមកនៃព្រះវិញ្ញាណបរិសុទ្ធដែលទ្រង់នឹងបំភ្លឺគំនិតពួកគេយ៉ាងពេញលេញប្រយោជន៍ឲ្យ**គេនឹងពុំចាំបាច់ទូលសួរ**ពីអត្ថន័យនៃគំនិតនិងការបង្រៀនថ្មីៗទាំងឡាយដូចជាគេតែងធ្លាប់ទូលសួររហូតមកដល់ពេលនេះឡើយ។ សូមអាន ១យ៉ូហាន ២:២៧ «រីឯដំណើរដែលទ្រង់ចាក់លាបឲ្យ នោះក៏នៅជាប់នឹងអ្នករាល់គ្នាពិត ហើយអ្នករាល់គ្នាមិនត្រូវការ ឲ្យអ្នកណាបង្រៀនពីការអ្វីទេ ប៉ុន្តែដូចជាដំណើរចាក់លាបនោះ បានបង្រៀនពីគ្រប់ការទាំងអស់ ហើយមិនមែនជាសេចក្តីកំភូតទេគឺជាសេចក្តីពិតវិញ នោះត្រូវឲ្យអ្នករាល់គ្នានៅជាប់ក្នុងទ្រង់ចុះ តាមដែលដំណើរនោះបានបង្រៀនមក»។ «រីឯអ្នករាល់គ្នា បានព្រះដ៏បរិសុទ្ធចាក់លាបឲ្យហើយក៏ចេះគ្រប់ទាំងអស់ផង» (១ យ៉ូហាន ២:២០)។

២. នៅថ្ងៃនោះអ្នករាល់គ្នានឹង**សូមដោយនូវឈ្មោះខ្ញុំ** (ខ.២៦)។ បណ្ឌិតកាល់វិនធ្វើអត្ថាធិប្បាយថា៖ តើព្រះជាម្ចាស់អធិស្ឋានជាដំបូងដោយនូវព្រះនាមព្រះគ្រីស្ទនាពេលនោះ? ព្រះគ្រីស្ទទ្រង់កំពុងតែពិពណ៌នាប្រាប់ពីអនាគតដែលព្រះវរបិតានឹងប្រទានដល់សាវ័កនូវសំណូមពួកគេទូលសូមដោយ**នូវព្រះនាមរបស់ទ្រង់**។

«តាំងពីដើមមក អ្នករាល់គ្នាមិនបានសូមអ្វីដោយនូវឈ្មោះខ្ញុំទេ» (ខ.២៤)។ តើសាវ័កជាអ្នកប្រតិបត្តិតាមក្រិត្យវិន័យចាស់ គ្មានសេចក្តីក្លាហាននឹងចូលមកចំពោះព្រះជាម្ចាស់ លុះត្រាតែអ្នកសង្រ្គោះម្នាក់? ព្រោះវាំងននព្រះវិហារនៅបិទជិត សម្តេចសង្ឃដ៏ពិតមិនទាន់យាងចូលទៅពីខាងក្នុងទីដ៏បរិសុទ្ធនៃស្ថានសួគ៌ដើម្បីអធិស្ឋានជំនួសរាស្រ្តរបស់ទ្រង់ ឬញែកផ្លូវជាបរិសុទ្ធដោយព្រះលោហិតរបស់ទ្រង់នៅឡើយ។ ក៏ប៉ុន្តែពេលនេះព្រះគ្រីស្ទបានធ្វើការលោះបាបកម្ម ហើយព្រះជាម្ចាស់ទ្រង់ទទួលព្រះអង្គទៅក្នុងនគរស្ថានសួគ៌នាពេលដ៏ឆាប់ខាងមុខ។ ទ្រង់បានសម្តែងអង្គទ្រង់ផ្ទាល់ធ្វើជាអ្នកសង្គ្រោះសង្រ្គោះ) ហើយនូវព្រះនាមទ្រង់ការអធិស្ឋានរបស់យើងចំពោះព្រះវរបិតានឹងបានឆ្លើយតប។

សូមសរសើរព្រះជាម្ចាស់សម្រាប់ផ្លូវថ្មីហើយរស់ (ហេព្រើរ ១០:២០) ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ផ្លូវនេះបានបើកចំហរដល់អ្នកជឿទាំងអស់។ ដោយពុំចាំបាច់សង្ឃជាមនុស្ស ជាជនជាតិជ្វីប ឬជាសង្ឃរ៉ូម៉ាំងកាតូលិកឡើយ។ ចូរមកឯទ្រង់ចុះ។ ចូរទូលដល់ទ្រង់នូវរាល់តម្រូវការរបស់អ្នក។ នៅក្នុងព្រះនាមទ្រង់គ្រប់ការអធិស្ឋានរបស់អ្នក ទ្រង់នឹងឆ្លើយតបស្របតាមបំណងព្រះហឫទ័យនៃព្រះវរបិតា ហើយនឹងមិនមែនដោយសារនាមបុគ្គលណាម្នាក់ ឬដោយសារអ្នកសង្រ្គោះសង្រ្គោះជាមនុស្សណាទៀតឡើយ។ ដូច្នេះជានិច្ចកាលយើងត្រូវបញ្ចប់ការអធិស្ឋានរបស់យើងចំពោះព្រះជាម្ចាស់ដោយនូវ «ក្នុងព្រះនាមព្រះយេស៊ូវ»។ អាម៉ែន»។

**ការពិចារណា៖** តើខ្ញុំបញ្ចប់ការអធិស្ឋានដោយនូវ «ក្នុងព្រះនាមព្រះយេស៊ូវ» ?

**ការអធិស្ឋាន៖** ព្រះយេស៊ូវជានាមដ៏ពិរោះនិងជាព្រះនាមដ៏ជួយប្រោសលោះ។

## ចំពោះអ្នកជ្រើសរើសរបស់ព្រះវរបិតា ព្រះយេស៊ូវគ្រីស្ទធ្វើជាអ្នកសង្រួបសង្រួមនៃជីវិត

ជំពូកនេះទាំងមូលគឺត្រូវបានគេស្គាល់ថាជាសេចក្តីអធិស្ឋានជាសម្តេចសង្ឃរបស់ព្រះអម្ចាស់។ («ព្រះវរបិតា» នៅក្នុងម៉ាថាយ ៦:៩-១៣ ជាធម្មតាហៅថា «សេចក្តីអធិស្ឋាននៃព្រះអម្ចាស់»)។ លោកគ្រូគង្វាល ជេ ស៊ី រ៉ៃល៍ មានប្រសាសន៍ពីការអធិស្ឋានដ៏វែងនេះថា៖ «វាគឺជាអស្ចារ្យណាស់នូវការប្រកបគ្នាជាគំរូដែលបានរក្សាជាប់ជានិច្ចរវាងព្រះវរបិតានិងព្រះបុត្រានាអំឡុងពេលបំពេញព័ន្ធកិច្ចនៅលើផែនដីរបស់ព្រះរាជបុត្រា។ វាជាលំនាំនៃការអធិស្ឋានជំនួសដ៏ល្អអស្ចារ្យមួយដែលព្រះបុត្រា ជាសម្តេចសង្ឃនៅបន្តធ្វើសម្រាប់យើងនៅនានគរស្ថានសួគ៌។ លើសជាងនេះទៅទៀតវាជាគំរូដ៏អស្ចារ្យពីកិច្ចការផ្សេងៗទៀតដែលអ្នកជឿគួរមានក្នុងការអធិស្ឋាន។ សេចក្តីដែលព្រះគ្រីស្ទទូលសូមសម្រាប់រាស្ត្រទ្រង់ រាស្ត្ររបស់ទ្រង់គួរទូលសូមសម្រាប់ខ្លួនគេផ្ទាល់ដែរ។ ពាក្យដែលធ្លាប់និយាយដ៏ត្រឹមត្រូវនិងជាពាក្យពិតដោយអ្នកបម្រើព្រះពីបុរាណគឺ «ការអធិប្បាយដ៏ល្អនិងឥតខ្ចោះដែលបានអធិប្បាយគឺត្រូវតែតភ្ជាប់នឹងការអធិស្ឋានដ៏ល្អដែរ»។ (ដ្បិតសេចក្តីទូលអង្វរដ៏អស់ពីចិត្តរបស់មនុស្សសុចរិត នោះពូកែណាស់។ យ៉ាកុប ៥:១៦)។

លោក ស្ទហ្វីលវិភាគលើសេចក្តីអធិស្ឋាននេះថាជាការទូលអង្វរចំនួនប្រាំពីរផ្នែក៖

(១). ដើម្បីឲ្យព្រះយេស៊ូវនឹងបានដំកើងដូចជាព្រះរាជបុត្រាបានដំកើងព្រះវរបិតា (ខ ១ ភីលីព ២:៩-១១)។

(២). សម្រាប់តាំងឡើងវិញនូវសិរីល្អដ៏អស់កល្ប (ខ ៥)។

(៣). សម្រាប់សុវត្ថិភាពរបស់អ្នកជឿពី (ក)លោកីយ (ខ១១) និង (ខ) សេចក្តីអាក្រក់ (ខ១៥)។

(៤). សម្រាប់ញែកអ្នកជឿជាបរិសុទ្ធ (ខ ១៧)។

(៥). សម្រាប់សាមគ្គីភាពផ្នែកព្រលឹងវិញ្ញាណរបស់អ្នកជឿ (ខ ២១)។

(៦). ដើម្បីឲ្យលោកីយបានជឿ (ខ ២១)។

(៧).ដើម្បីអោយអ្នកជឿនៅជាមួយទ្រង់នាស្ថានសួគ៌ឃើញនិងទទួលចំណែកសិរីល្អរបស់ទ្រង់។

ជំពូកនេះមានការបង្រៀនដ៏ជ្រាលជ្រៅជាច្រើន។ លោកគ្រូ ជេ ស៊ី រ៉ៃល បានធ្វើសេចក្តីអត្ថាធិប្បាយបន្ថែមទៀតថា «មានប្រយោគ ពាក្យពេចន៍ និងវិញ្ញត្តិ(ការសម្តែងមនោសញ្ចេតនា) ជាច្រើននៅក្នុងខទាំង២៦នៃជំពូកនេះប្រហែលជាគ្មានអ្នកណាម្នាក់នឹងអាចបើកសម្តែងន័យទាំងស្រុងបានឡើយ។ បើយើងអាចមានសមត្ថភាព ក៏យើងគ្មានគំនិតអ្វីដើម្បីបកស្រាយនូវការនេះ ឬនឹងយល់ពីបញ្ហាដែលជំពូកនេះមានដែរ។ ក៏ប៉ុន្តែមានសេចក្តីពិតសំខាន់ៗជាច្រើននៅក្នុងជំពូក (នេះ) ដែលលេចធ្លោនិងច្បាស់លាស់តាមការប្រមើលមើល ហើយជាការល្អយើងគួរតែផ្តោតចិត្តទុកដាក់របស់យើងចំពោះសេចក្តីពិតទាំងនេះ»។

ទោះជាយ៉ាងណាបន្ទុកនៃសេចក្តីអធិស្ឋាននេះគឺជាព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះអម្ចាស់នៃយើងចំពោះអ្នកជ្រើសតាំង គឺជារូបអ្នកនិងខ្ញុំដែលបានជឿលើទ្រង់និងស្រឡាញ់ព្រះអង្គ។ អ្នកគឺជាមនុស្សក្នុងបណ្តាអ្នកដែលបានជ្រើសតាំងបើអ្នកបានភ្លក់នូវព្រះគុណប្រោសលោះដ៏ផ្អែមល្ហែមរបស់ព្រះយេស៊ូវ!

**ការពិចារណា៖** ពេលអធិស្ឋានជាពេលត្រេកអរ..។
**ការអធិស្ឋាន៖** សូមអរព្រះគុណសម្រាប់ព្រះយេស៊ូវជាសម្តេចសង្ឃនៃយើងខ្ញុំ។

## ១. ដើម្បីឲ្យព្រះយេស៊ូវបានដំកើងដូចជាព្រះរាជបុត្រា បានលើកដំកើងព្រះវរបិតា (ខ ១ ភីលីព ២:៩-១១)

នៅក្នុងការទូលអង្វរទី១ដើម្បីឲ្យព្រះគ្រីស្ទនឹងបានលើកតំកើង ការអធិស្ឋាននេះមានន័យថាជាការថ្វាយនូវសេចក្តីតំកើងដល់ព្រះបុត្រាដោយសារការដឹកនាំទ្រង់ឆ្លងកាត់ការជាប់លើឈើឆ្កាង និងការសុគតក្នុងផ្នូរ។ ដើម្បីឲ្យព្រះអង្គអាចសម្រេចកិច្ចការដែលទ្រង់ត្រូវបានចាត់មកបំពេញប្រយោជន៍ឲ្យទ្រង់អាចទទួលបាននូវការលើកតំកើងនៅឯព្រះហស្តស្តាំនៃព្រះជាម្ចាស់និងទទួលនូវកិត្តិនាមដ៏ខ្ពស់អស់ទាំងនាម។

លោកស្ទីអឺ (Stier) បានផ្តល់មតិថា «ពាក្យទាំងនេះបញ្ជាក់ថាព្រះបុត្រាស្មើនឹងព្រះវរបិតា ទាក់ទងទៅនឹងភាពជាព្រះ។ ការបង្កបង្កើតដែលមានជីវិតអាចឈរចំពោះព្រះអាទិកររបស់ខ្លួន ព្រមទាំងបន្លឺថា «ចូរដំកើងខ្ញុំ ដើម្បីអោយខ្ញុំអាចលើកតំកើងទ្រង់» ? សិរីរុងរឿងរបស់ព្រះជាម្ចាស់គឺជាគោលបំណងដ៏ចម្បងនៃការបង្កើតរបស់ទ្រង់ (គោលជំនឿសំណួរនិងចម្លើយខ្នាតខ្លី ចម្លើយទី១)។ ប៉ុន្តែគ្មានអ្វីនាំមកនូវសិរីរុងរឿងដូចជាកិច្ចការសម្រេចជោគជ័យនៃការប្រោសលោះរបស់ព្រះគ្រីស្ទតាមរយៈការសុគត ការមានព្រះជន្មរស់ឡើងវិញ និងការយាងឡើងទៅឋានសួគ៌ឡើយ» ។

យើងដឹងពីដំណើរនៃការមានព្រះជន្មរស់និងការយាងទៅឋានសួគ៌ជាផ្នែកដ៏សំខាន់អំពីកិច្ចការប្រោសលោះរបស់ទ្រង់។ តើ (យើង) អាចនឹងថ្លែងពីការសុគតរបស់ទ្រង់ជាមួយនឹងចោរពីរនាក់ដែល ជាប់ដែកគោលក្បែរទ្រង់ហើយនិងពីព្រះអង្គផ្ទាល់ដែលជាប់ព្យួរឈើឆ្កាងឥតមានសំលៀកបំពាក់? លោកជេ អឹម នៀល (J. M. Neale) មានប្រសាសន៍ថា «តែដូចជាយើងគិតពីសិរីរុងទូទៅបែបលោកីយនៅគ្រាទ្រង់ស្ថិតក្នុងសង្គ្រាមដ៏ក្តៅគគក់ គ្របដណ្តប់ដោយព្រះលោហិត និងញើសនិងធូលីដី ជាជាងពេលទ្រង់គ្របដណ្តប់ដោយសំលៀកបំពាក់ពណ៌ស្វាយនិងសំពតនីឡុងសុទ្ធ ហើយនិងនៅក្នុង អំឡុងពេលជ័យជំនះ ហេតុដូចនេះព្រះអម្ចាស់នៃយើង នៅក្នុងគំនិតមួយ (ទ្រង់) គឺពោរពេញដោយសិរីរុងរឿងនៅពេលទ្រង់ត្រូវបានគេលើកឡើងលើឈើឆ្កាង ហើយខ្ញុំកោតសរសើរបំផុតគឺនៅពេលទ្រង់មានព្រះជន្មរស់ឡើង។ (សូមអាន ភីលីព ២:៩-១១)។

ដូច្នេះចូរយើងលើកតំកើងព្រះគ្រីស្ទឲ្យកាន់តែខ្លាំងឡើងនៅក្នុងការសុគតរបស់ទ្រង់ហើយនឹកចាំពី ទ្រង់នាពេលចូលរួមពិធីលៀងព្រះអម្ចាស់ដែលនៅក្នុងពិធីនោះសិរីរុងរឿងរបស់ទ្រង់ចាំងភ្លឺច្បាស់។ ប្រហែលវាគឺមកពីសិរីរុងនៃការសុគតដែលជាសទិភាពមួយធ្វើឡើងដោយរដ្ឋាភិបាលអាណានិគមអង់គ្លេសដែលបានកសាងវិមានរំឭកវិញ្ញាណក្ខ័ន្ធវីរៈជននៅ ស៊ីងហ្គាពួរ ផាដែង (Singapore Padang) ដើម្បីផ្តល់ «កិត្តិយសដល់មរណៈជន»។ បើពួកអ្នកបានស្លាប់នៅក្នុងសង្គ្រាមលោកលើកទីពីរគឺជាកិត្តិយសដោយសារតែបុព្វហេតុនៃសេចក្តីសុចរិត ព្រះអម្ចាស់នៃយើងគឺរុងរឿងថ្លៃថ្លាជាងពួកអ្នកដែលបានស្លាប់ទៅទៀតព្រោះទ្រង់ប្រគល់សេចក្តីសុចរិតនិងជីវិតដល់មនុស្សដ៏មានបាបដែលកំពុងស្លាប់!(ខ ២៤)។

**ការពិចារណា៖** ឯខ្ញុំ កុំបីឲ្យខ្ញុំអួតខ្លួនឡើយ អួតបានតែពីឈើឆ្កាងនៃព្រះយេស៊ូវគ្រីស្ទ (កាឡាទី ៦:១៤)
**ការអធិស្ឋាន៖** ព្រះអម្ចាស់ សូមឲ្យយើងខ្ញុំបានដំកើងទ្រង់ឡើងក្នុងជីវភាពប្រចាំថ្ងៃផង។

## ២. សម្រាប់តាំងឡើងវិញនូវសិរីល្អដ៏អស់កល្ប

«ឥឡូវនេះ ឱព្រះវរបិតាអើយ សូមដំកើងទូលបង្គំឡើងជាមួយនឹងទ្រង់ផង ដោយសិរីល្អដែលទូលបង្គំមានជាមួយនឹងទ្រង់ ក្នុងកាលដែលលោកីយមិនទាន់បានកើតនៅឡើយ» (ខ ៥)។

«អត្ថន័យរបស់ខនេះ ខ្ញុំកាត់ស្រាយក្នុងន័យយ៉ាងដូច្នេះ « ឱព្រះវរបិតាអើយ កិច្ចការនាលោកីយរបស់ទូលបង្គំពេលនេះនឹងបានបញ្ចប់ ទូលបង្គំសូមឲ្យតាំងឡើងវិញនូវសិរីល្អនៃស្ថានសួគ៌ដ៏ពុំអាចនឹងថ្លែងឲ្យសាកសមបានដែលទូលបង្គំមានជាមួយនឹងទ្រង់ ជាសហការីជាមួយនឹងទ្រង់ក្នុងព្រះត្រៃឯកដ៏ពុំអាចផ្តាច់ចេញបាន គឺមុនដែលពិភពលោកនេះបង្កើតមកម្ល៉េះ។ អំឡុងពេលនៃការបន្ទាបខ្លួននិងការដាក់ជាភាពកំសោយរបស់ទូលបង្គំនឹងបានសម្រេច សូមអនុញ្ញាតឲ្យទូលបង្គំចែករំលែកសិរីល្អរបស់ទ្រង់ម្តងទៀត ហើយគង់ជាមួយនឹងទ្រង់នាបល្ល័ងរបស់ព្រះអង្គដូចជាទូលបង្គំធ្លាប់គង់មុនពេលការយកនិស្ស័យជាមនុស្សរបស់ទូលបង្គំ» ។ ដែលស្ទើរតែមិនបាច់បរិយាយពីសេចក្តី សំណូមដែលបានទូលសូមទាំងនៅក្នុងការអធិស្ឋាននេះនិងការអធិស្ឋានក្នុងអត្ថបទព្រះគម្ពីរឯទៀតគឺមានអត្ថន័យយ៉ាងស៊ីជម្រៅ និងជ្រាលជ្រៅហួសពីការយល់ដឹងរបស់មនុស្ស។ សិរីល្អដែលព្រះបុត្រា មានជាមួយនឹងព្រះវរបិតា នាមុនពេលការបង្កបង្កើតពិភពលោកគឺជារឿងរ៉ាវដ៏ហួសកម្រិតយល់ដឹងរបស់យើង។ ក៏ប៉ុន្តែការមានព្រះជន្មរស់ពីបុព្វរបស់ព្រះគ្រីស្ទ គោលលទ្ធិដែលព្រះវរបិតានិងព្រះរាជបុត្រា គឺជាអង្គបុគ្គលដោយឡែកពីគ្នា និងការមានសិរីល្អស្មើគ្នារវាងព្រះវរបិតានិងព្រះរាជបុត្រា យ៉ាងណាក៏ដោយគឺត្រូវបានបង្រៀននៅក្នុងខនេះយ៉ាងជាក់ច្បាស់។ វាហាក់ដូចជាមិនអាចផ្សះផ្សាគ្នាបាន ទាល់តែសោះនូវខគម្ពីជាមួយនឹងទ្រឹស្តីសូស៊ីនាន (Socinian theory) ដែលបង្រៀនថាព្រះគ្រីស្ទគឺជាមនុស្សធម្មតាដូចជាស្តេចដាវីឌ ឬសាវ័កប៉ុល ហើយទ្រង់គ្មានព្រះជន្មរស់នៅមុនពេលទ្រង់ប្រសូត្រនាភូមិបេថ្លេហិម។ ចូរយើងរៀននូវមេរៀនអនុវត្តន៍ផងដែរថា ការអធិស្ឋាន សម្រាប់សិរីល្អនឹងទទួលបានមក យ៉ាងប្រសើរពីពួកអ្នកដែលបានធ្វើកិច្ចការនៅលើផែនដីថ្វាយដល់ព្រះជាម្ចាស់។ ការប្រាថ្នាចង់បាន បែបខ្ជិលច្រអូសឆ្ពោះទៅរកសិរីល្អ ដោយឥតបានបម្រើការគឺមិនស្របតាមគំរូរបស់ព្រះគ្រីស្ទឡើយ» ។ --លោក ជេ ស៊ី រ៉ៃល (លទ្ធិសូស៊ីនាននាំឆ្ពោះទៅរកលទ្ធិយូនីតារាន Socinianism leads to Unitarianism)។

« ពិតប្រាកដជាសេចក្តីអាថ៌កំបាំងរបស់សាសនានៃយើង នោះជ្រាជ្រៅណាស់ គឺដែលព្រះបានលេចមកក្នុងសាច់ឈាមបានរាប់ជាសុចរិតដោយព្រះវិញ្ញាណ ពួកទេវតាបានឃើញទ្រង់ មនុស្សបានប្រកាសប្រាប់ពីទ្រង់ដល់ពួកសាសន៍ដទៃ មានគេជឿដល់ទ្រង់ក្នុងលោកីយនេះ រួចព្រះបានលើកទ្រង់ឡើងទៅក្នុងសិរីល្អវិញ» (១ ធីម៉ូថេ ៣:១៦)។ នៅក្នុងគោលលទ្ធិនៃការសរសើរតំកើងដែលសាវ័កប៉ុលបានបង្រៀននៅក្នុង ១ ធីម៉ូថេ ៣:១៦ យើងឃើញថាព្រះគ្រីស្ទយាងមកពីសិរីល្អក៏យាងទៅក្នុងសិរីល្អវិញ! លុះត្រាតែព្រះគ្រីស្ទគឺជាព្រះជាម្ចាស់ បើមិនដូច្នោះទេគ្មានសិរីល្អអ្វីទ្រង់ត្រូវយាងទៅបានឡើយ។

**ការពិចារណា៖** ព្រះយេស៊ូវគ្រីស្ទគឺជាព្រះតាំងពីអស់កល្បរហូតដល់អស់កល្បជានិច្ច។
**ការអធិស្ឋាន៖** សូមឲ្យគ្រប់ទាំងចង្គង់លុតចុះហើយថ្លែងថាព្រះយេស៊ូវគ្រីស្ទគឺជាព្រះ។

*« ទូលបង្គំបានរក្សាទុកនូវអស់អ្នក ដែលទ្រង់ប្រទានមកទូលបង្គំ» ។*

## ៣. សម្រាប់សុវត្ថិភាពរបស់អ្នកជឿពី (ក) លោកីយ និង (ខ) សេចក្តីអាក្រក់

នៅក្នុងវគ្គបន្តនេះព្រះយេស៊ូវសម្តែងនូវដំណើរយកព្រះទ័យទុកដាក់ចំពោះពួកសិស្សរបស់ទ្រង់ដូចជាអ្នកម្តាយជាទីស្រឡាញ់យកចិត្តទុកដាក់ចំពោះកូនៗរបស់ខ្លួនដែរ។ ដូចជាម្តាយថែរក្សាកូនដែលនាងបង្កើតមកតាំងពីពេលចាប់កំណើត ពីពេលប្រសូតរហូតដល់ទារកភាព ពីទារកភាពដល់ធំពេញវ័យ ដូចនេះព្រះអម្ចាស់នៃយើងយកព្រះទ័យទុកដាក់ចំពោះកូនៗរបស់ទ្រង់ដែលជាអ្នកជ្រើសតាំងនៃព្រះជាម្ចាស់ (ឯពួកអ្នកដែលទ្រង់បានប្រទានមកទូលបង្គំអំពីមនុស្សលោក (ខ៦)) ជាអ្នកបានទទួលរាជសារទ្រង់បានប្រកាសប្រាប់និងបុគ្គលភាពនៃទ្រង់ជាអង្គមកពីព្រះវរបិតានានៃឋានដ៏ខ្ពស់។ អ្នកជ្រើសតាំងទាំងនេះស្ថិតនៅក្នុងការអធិស្ឋាននៃភាពជាសម្តេចសង្ឃរបស់ព្រះគ្រីស្ទ មិនមែនជាពួកអ្នកខាងក្រៅនៅក្នុងលោកីយឡើយ។

ដោយឥឡូវនេះវត្តមានរបស់ទ្រង់នឹងចាកចេញពីពួកគេ ទ្រង់មិនទុកឲ្យគេការពារខ្លួនគេដោយផ្ទាល់ឡើយ។ ទ្រង់បានអធិស្ឋានសម្រាប់សុវត្ថិភាពរបស់ពួកគេ ដោយហេតុថានឹង «គ្មានអ្នកណាមួយត្រូវវិនាសឡើយ បានវិនាសតែ១នាក់នោះ ដែលបានដំរូវឲ្យត្រូវវិនាសប៉ុណ្ណោះ» (ខ១២)។ នេះគឺជាគំនិតដ៏ជួយសំរាលទុក្ខចំពោះអ្នកនិងខ្ញុំដែលកំពុងទុកចិត្តព្រះអង្គ។ យើងមាន «ការធានាដ៏អស់កល្ប» ជាការធានានៃព្រះជាម្ចាស់ពីសេចក្តីសង្គ្រោះរបស់យើង លើកលែងតែយើងក្លាយជាជនក្បត់ដូចយូដាស ដែលបានតម្រូវឲ្យត្រូវវិនាសប៉ុណ្ណោះ។ («ដំរូវឲ្យវិនាស» មានន័យថា «ត្រូវខូចវិនាសទាំងស្រុង»។ ពិតមែនហើយ ការធានាដ៏អស់កល្បយើងមានក្នុងព្រះគ្រីស្ទគឺជាគំនិតដ៏ជួយសំរាលទុក្ខដែលព្រះអម្ចាស់នៃយើងទ្រង់ទន្ទឹងចង់បាន «ដើម្បីឲ្យគេ(សិស្សរបស់ទ្រង់) បានសេចក្តីអំណររបស់ទូលបង្គំ ឲ្យនៅពោរពេញក្នុងខ្លួនគេ» (ខ ១៣)។

ព្រះគ្រីស្ទរក្សាពួកយើងឱ្យមានសុវត្ថិភាពមិនមែនដោយសារការយកយើងចេញពីលោកីយនេះទេ ប៉ុន្តែដើម្បីឲ្យយើងទទួលបានការពាររួចពីសត្រូវនៃលោកីយនិងឧបាយទុច្ចរិតរបស់អារក្សវិញ។ ហេតុអ្វី? ពីព្រោះពួកយើងគឺជាព្រះហស្ត (ដៃ) និងជា (ព្រះបាត)ជើងរបស់ទ្រង់ដើម្បីបន្តធ្វើបន្ទាល់សម្រាប់សេចក្តីពិតខណៈពេលទ្រង់បានយាងឡើងទៅឋានដ៏ខ្ពស់ (សូមអាន ខ១៨)។

មានរឿងមួយដំណាលប្រាប់ពីទេវតាមួយអង្គទូលសួរព្រះអម្ចាស់នៃយើងនាពេលយាងមករបស់ទ្រង់ក្បែរខ្លោងទ្វារធំនៃនគរឋានសួគ៌ថា «មុនពេលព្រះអង្គយាងឡើងមកទីនេះ ទ្រង់បានបង្គាប់ឲ្យពួកសិស្សរបស់ទ្រង់ចេញទៅក្នុងលោកីយដើម្បីប្រកាសដំណឹងល្អដល់មនុស្សគ្រប់ជាតិសាសន៍។ ចុះប្រសិនបើពួកសិស្សរបស់ទ្រង់មិនទៅវិញ?» ព្រះសង្គ្រោះដ៏រស់បានមានបន្ទូលឆ្លើយតបវិញថា «ខ្ញុំគ្មានមធ្យោបាយណាទៀតឡើយ។ ខ្ញុំពឹងផ្អែកលើពួកគេ ដែលជាដៃនិងជាជើងរបស់ខ្ញុំនៅលើផែនដី»។ យើងជាអ្នកមានអំណរនិងសេចក្តីសុខសាន្តហើយនិងការការពារពីលោកីយនិងអារក្សមិនត្រូវរំលោភបំពាននឹងសេចក្តីសុខសាន្តនោះដោយឥតបម្រើកិច្ចការអ្វីមួយថ្វាយដល់ព្រះអម្ចាស់ឡើយ។

**ការពិចារណា៖** តើខ្ញុំនឹងជួបព្រះអង្គសង្គ្រោះដោយដៃទទេ?
**ការអធិស្ឋាន៖** សូមឲ្យជីវិតខ្ញុំបង្កើតនូវផលផ្លែថ្វាយដល់ទ្រង់ផង ឱព្រះអង្គអើយ!

ថ្ងៃទី ២៦ កក្កដា
យ៉ូហាន ១៧:១៦-២១

*« ទូលបង្គំមិនអធិស្ឋានឲ្យអ្នកទាំងនេះតែប៉ុណ្ណោះ
គឺឲ្យដល់ទាំងអ្នកណាដែលនឹងជឿងដល់ទូលបង្គំ..»*

## ៤. សម្រាប់ញែកអ្នកជឿជាបរិសុទ្ធ
## ៥. សម្រាប់សាមគ្គីភាពផ្នែកព្រលឹងវិញ្ញាណរបស់អ្នកជឿ

ខណៈពេលព្រះយេស៊ូវទូលសូមព្រះវរបិតាឲ្យការពារកូនៗរបស់ទ្រង់ពីការវាយប្រហាររបស់លោកីយ និងអារក្ស ទ្រង់ជ្រាបដឹងពីលទ្ធផលអាក្រក់ពីខាងក្នុង (រង្វង់អ្នកជឿ)។ នោះគឺថាពួកគេនឹងអាចបើកច្រកឲ្យខ្លួនគេទៅក្នុងផ្លូវនៃលោកីយនិងសាតាំង។ បញ្ជាក់៖ ការផ្លាស់ប្តូរដ៏ធំតាមបណ្តាព្រះវិហារជាច្រើនអំពីអ្នកបោះបង់ចោលជំនឿ និងអ្នកត្រឡប់ទៅរកជីវិតចាស់។ តើអ្នកអាចប្រាប់ឈ្មោះសមាជិកខ្លះនៅក្នុងព្រះវិហារតាមបែបសាវ័កដែរឬទេ? តើត្រូវធ្វើដូចម្តេចដើម្បីការពារពួកគេពីក្នុង(ពួកជំនុំ)? សូមញែកគេជាបរិសុទ្ធ! នោះគឺជាការថ្វាយខ្លួន ឬការថ្វាយកក្តីភាព ជាការញែកពួកគេទុកជាពិសេសសម្រាប់អង្គទ្រង់ផ្ទាល់ហើយរក្សាពួកគេទុកដូចជាទ្រព្យសម្បត្តិដ៏បរិសុទ្ធផ្ទាល់ខ្លួនរបស់ព្រះអង្គ (បណ្ឌិត កាល់វិន)។ ហើយរបៀបនៃដំណាក់កាលញែកពួកគេទុកជាពិសេសនេះគឺដោយនូវសេចក្តីពិតរបស់ទ្រង់។ សេចក្តីពិតមិនមែនតែក្នុងគំនិតបែបទ្រឹស្តីបទទេ តែអាស្រ័យទៅតាម «ព្រះបន្ទូលរបស់ទ្រង់» វិញ។

ព្រះបន្ទូលនៅក្នុងខនេះមានន័យថាជាសេចក្តីបង្រៀននៃដំណឹងល្អដែលពួកសាវ័កបានឮពីព្រះឱស្ឋរបស់ព្រះអម្ចាស់។ នៅក្នុងន័យដ៏បរិបូរវាត្រូវ តែជាព្រះគម្ពីរទាំងមូល ដោយហេតុថាសាវ័កបានប្រកាសថាពួកជំនុំគឺត្រូវបានលាងសម្អាតដោយទឹកតាមរយៈព្រះបន្ទូល (អេភេសូរ ៥:៦)។ ពិតជាសំខាន់ខ្លាំងណាស់ក្នុងការអាននិងសញ្ជឹងគិតអំពីព្រះគម្ពីរជារៀងរាល់ថ្ងៃ។ ពាក្យបន្ទូលព្រះគឺជាអំណោយទាននៃព្រះគុណដ៏អស្ចារ្យសម្រាប់ការពារយើងពីសេចក្តីល្បួងនិងពីអារក្សសាតាំង។ នាអំឡុងសម័យមុនដំបូងនៃចលនាកែទម្រង់នាសតវត្សទី១៦មានពួកអ្នកជ្រុលនិយមក្នុងចំណោមក្រុមអាណាបាទីស្ទ ដែលពឹងផ្អែកលើការជាក់ស្តែងនិងការស្រមើស្រមៃ ជាវិធីព្រះជាម្ចាស់ទាក់ទងនឹងពួកគេ សំខាន់ជាងពាក្យន្ទូលទ្រង់។ ពួកអ្នកទាំងនេះត្រូវបានបណ្ឌិតកាល់វិនជាអ្នកប្រកាន់ខ្ជាប់ខ្ជួនតាមព្រះគម្ពីរថ្កោលទោស។ សព្វថ្ងៃមានការកកើតឡើងនូវពួកដែលជឿប្រហាក់ប្រហែលគ្នានោះដែរជាពួកអ្នកផ្តោតទៅលើការយល់សប្តិថាជាការបើកសម្តែងបែបឯកជននិងការជាក់ស្តែងជាជាងលើពាក្យបន្ទូលព្រះ។ នេះគឺជាផ្លូវនាំឆ្ពោះទៅរកការជំរុវឲ្យត្រូវវិនាស។

ក្រៅពីការញែកពួកគេជាបរិសុទ្ធដោយសារពាក្យបន្ទូល ព្រះយេស៊ូវអធិស្ឋានសម្រាប់សាមគ្គីភាពរបស់អ្នកជឿនាជំនាន់ក្រោយ សម្រាប់ប្រសិទ្ធិភាពដ៏មានសន្ទុះខ្លាំងក្នុងការធ្វើបន្ទាល់ដល់លោកីយ។ ចំណុចនេះជាចលនារួបរួមបែបព្រះម្ពីរនៃពួកជំនុំគ្រីស្ទបរិស័ទជាមួយអ្នកប្រតិបត្តិតាមសេចក្តីពិត ជាពួកអ្នកមាន គោលជំហររួមគ្នាលើពាក្យបន្ទូលបរិសុទ្ធ។ ប៉ុន្តែខនេះ (ខ ២១) ត្រូវបានពួកអ្នកលើកកំពស់ចលនារួបរួមព្រះ ពួកជំនុំគ្រីស្ទបរិស័ទ (*Ecumenical Movement*) ប្រើដើម្បីដឹកនាំឆ្ពោះទៅរកព្រះវិហារលំដាប់ពិភពលោកថ្នាក់កំពូល សម្រាប់ផ្សះផ្សាជាមួយព្រះវិហាររ៉ូម៉ាំង (កាតូលិក) និងជាជំនឿលើព្រះជាម្ចាស់លាយនឹងជំនឿលើរូបព្រះជាមួយ (*syncretism*) នឹងសាសនារបស់មនុស្សផ្សេងៗទៀត។ សាមគ្គីភាពដែលព្រះយេស៊ូវអធិស្ឋានគឺពីបែបព្រលឹងវិញ្ញាណ ដូចជាចំណងភ្ជាប់មែកឈើនឹងដើម ហើយមិនមែនជាសាមគ្គីភាព ដែលមនុស្សរៀបចំ

បណ្តុំគ្នាឡើយ។ ការបោកបញ្ឆោតដ៏អស្ចារ្យរបស់សាតាំងចំពោះព្រះវិហារនៅថ្ងៃចុងក្រោយ។ បើអ្នកជាសមាជិកនៃព្រះវិហារគេដែលទាក់ទងនឹងក្រុមប្រឹក្សាពួកជំនុំពិភពលោក តើអ្នកគួរត្រូវធ្វើអ្វីដែរ?

**ការពិចារណា៖** តើយើងត្រូវរួបរួមនឹងព្រះវិហារដទៃទៀតទោះបីមានគោលជំនឿខុសគ្នា?

**ការអធិស្ឋាន៖** ឪសូមញែកជីវិតយើងខ្ញុំជាបរិសុទ្ធសម្រាប់ប្រសិទ្ធិភាពនៃបម្រើទ្រង់ផង។

*« គឺឲ្យអ្នកទាំងនោះបានរួមគ្នាតែមួយ នៅក្នុងយើង ប្រយោជន៍ឲ្យលោកីយបានជឿថា ទ្រង់ចាត់ឲ្យទូលបង្គំមកពិត» ។*

## ៦. ដើម្បីអោយលោកីយបានជឿ
## ៧. ដើម្បីអោយអ្នកជឿនៅជាមួយទ្រង់នាស្ថានសួគ៌ឃើញនិងទទួលចំណែកសិរីល្អរបស់ទ្រង់

ដូចជាយើងបានលើកឡើងរួចមកហើយថា មានពួកជំនុំរួមតែមួយតាមបែបព្រះគម្ពីរ ជាសាមគ្គីភាពរវាងអ្នកជឿទាស់នឹងការបាក់បែកគ្នានៃពួកជំនុំដែលធ្វើការប្រកបដោយប្រសិទ្ធិភាពជាទីបន្ទាល់ដល់លោកីយ (ខ ២៣)។ សេចក្តីដែលព្រះគ្រីស្ទកំពុងមានបន្ទូលគឺមិនមែនជាការញែកចេញពីការគ្មានជំនឿដែលជា ការបែបតាមព្រះគម្ពីរនិងស្រមតាមផ្លូវច្បាស់ទេ។ សេចក្តីដែលព្រះយេស៊ូវ កំពុងមានបន្ទូលគឺអំពីការចែក មតិនិយម ដែលវចនានុក្រមឆាំបឺរ (Chamber) ពន្យល់ន័យថាជា «ការបែកបាក់សាមគ្គីភាព ដោយគ្មានបុព្វហេតុត្រឹមត្រូវ» ។. ការបែកចែកមតិគ្នានៅក្នុងពួកជំនុំស្រុកកូរិន ក្នុងនាមឈ្មោះសាវ៉កប៉ូល និងអាប៉ូឡូស ក្នុងនាមឈ្មោះកេផាស និងថែមទាំងក្នុងព្រះនាមព្រះគ្រីស្ទ ជាដើម! (១ កូរិនថូស ១:១២)។ សូមប្រយត្ន័ក្រុមសាសនាលក្ខណៈបុគ្គលក្នុងព្រះវិហារ!

នៅពេលក្រុមជំនុំបានសាមគ្គីគ្នា ទីបន្ទាល់របស់នាងនឹងខ្លាំងក្លា។ «សាមគ្គីយើងឈរ បាក់បែកគ្នាយើងនឹងដួល» ។ ដូច្នេះចូរយើងប្រុងប្រយត្ន័នឹងបណ្តុះសាមគ្គីភាពបែបព្រលឹងវិញ្ញាណនេះដែលមានពីដើមរៀងមកនៅក្នុងពួកជំនុំ គឺប្រៀបដូចជាមែកដែលជាប់នឹងដើមឈើ។ វាច្បាស់ជានៅទីនោះ មិនមែនសាងសង់ឡើងមួយបំណែកម្តងៗដូចជាប៉មបាបិលទេ គឺដូចជាសាមគ្គីភាពរួមគ្នាមួយដែលក្រុមជំនុំក្រុមប្រឹក្សាពិភពលោកកំពុងតែព្យាយាមធ្វើដូច្នោះដែរ។ ចូរយើងយកដកល្បិចកលនៃភាពអត្តានិយមដែលមានបន្តិចបន្តួចចេញ ការឈ្លោះទាស់ទែងគ្នា ការច្រណែនឈ្នានីស ការសង្ស័យ ការនិយាអេចអូច ការនិយាយដើមគ្នា ឃាដកម្មអត្តចរឹក និងទង្វើទាំងឡាយដែលអ្នកហៅថា «ដែលបំផ្លាញចំការទំពាំងបាយជូរទៅ ដ្បិតទំពាំងបាយជូររបស់យើងកំពុងតែផ្កាហើយ» (បទចំរៀងសាឡូម៉ូន២:១៥)។ ចូរប្រយត្ន័ក្រុមមនុស្សនៅក្នុងពួកជំនុំ!

រួចហើយនៅពេលយើងទៅដល់ស្ថានសួគ៌នោះយើងនឹងមិនមែនជាម្នាក់ដែលនៅជាមួយនឹងទ្រង់ឃើញសិរីល្អរបស់ព្រះអង្គ និងចំណុចដ៏សំខាន់នៃសិរីល្អនោះគឺជាសេចក្តីស្រឡាញ់! សាមគ្គីភាពរបស់យើងនៅក្នុងចំណងនៃក្តីស្រឡាញ់ជាគ្រីស្ទបរិស័ទនៅលើផែនដីគឺគ្រាន់តែជាការសមនិងជាការភ្លក់រសជាតិអំពីសិរីល្អដែលនឹងមកដល់មិនត្រឹមតែនឹងនៅពេលយើងនៅជាមួយនឹងព្រះរាជបុត្រាទេ ក៏ប៉ុន្តែនៅជាមួយនឹងព្រះវរបិតា ដែលជាប្រភពនៃសេចក្តីស្រឡាញ់ដ៏អស់កល្បផងដែរ។ សាមគ្គីភាពមិនអាចស្ថិតនៅគង់វង្សដោយគ្មានខ្យល់ដ៏ស្រស់បស់នៃសេចក្តីស្រឡាញ់ឡើយ!

មិត្តភក្តិនាលោកីយភក្តីមិនទៀតទាត់ សាកលនឹងកញ្ចក់
នោះឃើញជម្រៅចិត្តនឹងមុខមាត់ច្បាស់ តែមានអារម្មណ៍ដូចគ្នា
មុខទល់នឹងមុខជួបនាគ្រាចុងក្រោយ ប្រជុំគ្នានាព្រះបាទានៃព្រះវរបិតា
ក្នុងក្តីស្មោះស្ម័គ្រនិងក្តីពិត ភាពខុសគ្នានឹងដកចេញបាត់។ ជេសុន លីន-Jason Linn

**ការពិចារណា៖** តើគ្រីស្ទបរិស័ទត្រូវរួមគ្នាដោយក្នុងសេចក្តីស្រឡាញ់ទោះបីផ្ទុយពីសេចក្តីពិត?
**ការអធិស្ឋាន៖** សូមឲ្យទង់នៃសេចក្តីពិតរបស់ព្រះបានខ្ពស់ត្រដែតក្នុងការរួបរួមភាពរបស់យើង!

*« កាលទ្រង់មានបន្ទូលទៅគេថា គឺខ្ញុំនេះហើយ នោះគេក៏ថយក្រោយ ដួលផ្ងារទាំងអស់គ្នា» ។*

## ចំពោះសាវ័កអស់ក្ដីសង្ឃឹមដែលបានការពារទ្រង់ ព្រះយេស៊ូវគ្រីស្ទបន្ដនៅជាខែលនៃជីវិតរបស់ពួកគេ

តើអ្នកបានម្ដាល់ឃើញទេថារវាង យ៉ូហាន ១៤:៣១ និង យ៉ូហាន ១៨:១ រវាងការចាកចេញពីបន្ទប់ប្រារព្ធពិធីបុណ្យរំលង (ក្នុងទីក្រុងយេរូសាឡឹម) និងការចូលទៅក្នុងសួនកេតសេម៉ានី (ខាងក្រៅទីក្រុង) ចន្លោះអត្ថបទព្រះគម្ពីរទាំងពីរនេះមានបីជំពូកអំពីការអធិប្បាយនិងការអធិស្ឋានដែរឬទេ? ពិតជាឧត្ដមភាពដ៏អស្ចារ្យនៃព្រះបន្ទូលជីវិតដែលបណ្ដាលឲ្យសុភាសិតកម្រកឃើញរបស់លោកកុងជឺបង្រៀនដល់សិស្សរបស់គាត់ប្រែជាឥតន័យ! តើហេតុអ្វីបានជានិស្សិតទស្សនវិជ្ជាមិនព្រមអានពាក្យបន្ទូលរបស់ព្រះយេស៊ូវ ព្រោះគេប្រាកដជានិយាយថារសជាតិពីស្រាទំពាំងបាយជូរជីវិតគឺពិតជាមានរសផ្អែមជាងមែន! ហើយចុះចំណែកសុភាសិតរបស់លោកម៉ៅ (សេទុង) វិញ?

ទីបំផុត ពេលប្រយុទ្ធបានមកដល់។ សាវ័កយ៉ូហានទុក (កំណត់ត្រា)ឈឺចាប់នាសួនកេតសេម៉ានីនៃព្រះអម្ចាស់របស់គាត់ទៅអ្នកប្រកាសដំណឹងល្អឯទៀត។ គាត់ប្រាប់រឿងរបស់គាត់ជាលក្ខណៈសង្ខេបជាមួយនឹងយូដាសជាសិស្សក្បត់និងនគរបាលសម្ងាត់ជនជាតិយូដាដែលបានលេចមកនាកន្លែងកើតហេតុ។ ដោយរំពេចភ្លាមនោះ ព្រះអម្ចាស់បានប្រទានពួកអ្នកវាយប្រហារដោយពាក្យគំហកថា «គឺខ្ញុំនេះហើយ (I AM)»។ ពាក្យនោះ ទាហានដ៏ខ្លាំងជាងគេ «ក៏ថយក្រោយផ្ងារទាំងអស់គ្នា(*ទៅដី*)» (ខ ៦)។ ហើយតើទ្រង់មិនបានធ្វើកិច្ចការនេះ ដូចជាមេសត្វតោកំពុងការពារកូនរបស់វា ដើម្បីរក្សាសុវត្ថិភាពរបស់ពួកសាវ័ក? «ដូច្នេះ បើអ្នករាល់គ្នារកខ្ញុំ នោះចូរបើកឲ្យអ្នកទាំងនេះទៅចុះ» (ខ ៨)។ ព្រះអម្ចាស់នៃយើងពិតជាយកព្រះទ័យទុកដាក់ចំពោះសិស្សរបស់ទ្រង់មែន! តើអ្នកដឹងទេ ព្រះអង្គគឺកំពុងថែរក្សាអ្នកសូម្បីតែពេលឥឡូវនេះ ជារៀងរាលម៉ោង រៀងរាល់នាទី ដើម្បីការពារអ្នកពីរាល់សេចក្ដីអាក្រក់គ្រប់យ៉ាង?

ពេត្រុសដែលជាសាវ័កធ្វើតាមឆន្ទៈផ្ទាល់ខ្លួន ដោយឮសូរតែមួយខ្ទាប់ កាត់ត្រចៀករបស់ម៉ាលកុសដាច់! ប៉ុន្តែព្រះយេស៊ូវបានបញ្ឈប់គាត់ពីសកម្មភាពប្រើអាវុធតាមបែបសាច់ឈាមរបស់គាត់បន្តទៀត។ ព្រះយេស៊ូវ ដោយបានជ្រាបដឹងនូវវេលាបានមកដល់ ទ្រង់ក៏បានប្រគល់អង្គទ្រង់ទៅកងទ័ពតិរិច្ឆាន។

ឥឡូវនេះអភិបាលសាសន៍រ៉ូម៉ាំងបានផ្ដល់សេរីភាពបែបសាសនាដោយលែកមួយដល់សាសន៍យូដាប្រយោជន៍ឲ្យគេអាចកាត់ក្ដីតាមប្រព័ន្ធតុលាការរបស់ពួកគេ ដូចជាចក្រភពអង់គ្លេសផ្ដល់ ឲ្យជនជាតិអ៊ីស្លាមក្នុងប្រទេសម៉ាឡេស៊ីមានប្រពន្ធ័តុលាការរបស់ខ្លួន ដើម្បីកំណត់យកបញ្ហាបែបសាសនា។ ហេតុនេះទើបយើងឃើញថានគរបាលរ៉ូម៉ាំងមិនបានចាប់ព្រះយេស៊ូវទេ តែជានគរបាលសម្ងាត់ជនជាតិយូដាវិញ។ នាពេលពេលចោទប្រកាន់នៃព្រះអម្ចាស់របស់យើងចំពោះមុខសម្ដេចសង្ឃ សាវ័កពេត្រុសដែលទៅតាមយ៉ាងអៀនខ្មាស់ឈរ «នៅឯមាត់ទ្វារខាងក្រៅ» ព្រះលានសម្ដេចសង្ឃ (ខ ១៦) ហើយបានបដិសេធមិនស្គាល់ទ្រង់ចំនួនបីដង «ស្រាប់តែមាន់រងាវឡើង» (ខ ២៧)។

សាវ័កយ៉ូហាន ប្រហែលជាសិស្សម្នាក់ដែលនៅជាមួយនឹងពេត្រុស បានកត់សម្គាល់ពីមាន់រងាវនេះ ដែលព្រះអម្ចាស់បានព្យាករណ៍ទុកពីដំបូងរួចមក។ សូម្បីមាន់ (គក) ក៏រក្សាពេលវេលាសម្រាប់ព្រះអម្ចាស់ដែរ!

ពីទីតុលាការសែនហិឌ្រិននៃសាសន៍យូដា (Jewi sh Sandhedr i n) ទៅអភិបាលសាសន៍រ៉ូម៉ាំង តែព្រះសង្គ្រោះនៃយើងទ្រង់បែរជាត្រូវបានកាត់ទោសប្រហារជីវិតដោយសំរែកហ្វូងមហាជនដែលតាំងខ្លួនជាតុលាការវិញ។ អូ ចិត្តសាស្ត្ររបស់ហ្វូងមនុស្សបះបោរពិតជាគួរអោយភ័យខ្លាចមែន! សូមប្រយ័ត្នក្រែងលោអ្នកចូលរួមជានឹងហ្វូងមហាជនដើម្បីប្រព្រឹត្តិការអាក្រក់ ដោយមិនដឹងថាខ្លួនអ្នកនៅក្នុងសេចក្តីអាក្រក់!

**ការពិចារណា៖** មិនមែនយើងការពារព្រះទេ តែព្រះការពារយើងវិញទេតើ!

**ការអធិស្ឋាន៖** យើងខ្ញុំដឹងថាវត្តមានរបស់ទ្រង់គឺប្រសើរជាកម្លាំងទព័ទូទាំងសាកលលោក។

# អ្នកត្រៀមខ្លួនដើម្បីស្លាប់នឹងមិនខ្លាចការស្លាប់ឡើយ

យើងបានកត់សម្គាល់កាលពីដើមដំបូងរួចហើយថាអ្នកដែលខ្លាចស្លាប់នឹងស្លាប់មួយរយដង។ ផ្ទុយទៅវិញ អ្នកដែលត្រៀមខ្លួនដើម្បីស្លាប់នឹងមិនខ្លាចការស្លាប់នោះឡើយ។ ព្រះអម្ចាស់នៃយើងដែលបានឈ្នះនូវការនេះដើម្បីអនុញ្ញាតឲ្យគេក្បត់ទ្រង់មិនដែលសុគតឡើយ! ក្រុមសាវ័កមិនបានរៀនឲ្យខ្លួនគេរឹងមាំនឹងធន្ទះនៃអំណាចនេះនៅឡើយ តែពួកគេបានរៀននៅពេលគេគ្រាប់តាមជំហានព្រះអម្ចាស់នាគ្រាចុងក្រោយនៃជីវិតរបស់គេ។ សូមអានបណ្តាំលារបស់សាវ័កពេត្រុសនិងប៉ុល!ពាក្យនិយាយតៗគ្នាប្រាប់យើងថាសាវ័កទាំងអស់បានរងមរណៈស្មរបន្ទាល់ លើកលែងតែសាវ័កយ៉ូហានប៉ុណ្ណោះ។

ការដាក់ពន្ធនាគារនិងមរណៈស្មរបន្ទាល់បានកើតមានឡើងចំពោះពួកជំនុំជនជាតិចិន។ លោកគ្រូ វ៉ចម៉ែន នី (Wathman Nee) នៅល្ងាចនៃការដោះលែងរបស់គាត់ បានឆ្លងកាត់នូវការនោះ បន្ទាប់ពីលោកបានចំណាយពេលម្ភៃឆ្នាំក្នុងពន្ធនាគារ។ លោកគ្រូ វ៉ាំងមីង តៅ (Wang Ming-Toa) មានជីវិតពីការទទួលរងនូវទារុណកម្មជាច្រើនដង សព្វថ្ងៃគឺត្រូវបានគេដោះលែង កំពុងរស់នៅជាទីបន្ទាល់ក្នុងវ័យប៉ែតសិបឆ្នាំរបស់គាត់។ ការឆ្លងកាត់សួនគេតសេម៉ានីជាមួយនឹងព្រះអម្ចាស់នៃយើង ចូរយើងជាអ្នកជំនាន់ក្រោយអធិស្ឋានដើម្បីឲ្យយើងអាចមានជំហរស្មោះត្រង់សម្រាប់បុព្វហេតុរបស់ទ្រង់រហូតដល់ទីបំផុត។

តើខគម្ពីរអ្វីខ្លះសម្តែងប្រាប់យើងពីការត្រៀមលក្ខណៈជាស្រេចរបស់ព្រះអម្ចាស់នៃយើង? ខ៤ ចែងថា «ព្រះយេស៊ូវទ្រង់ជ្រាបការទាំងអស់ ដែលត្រូវមកដល់ទ្រង់ បានជាទ្រង់យាងចេញទៅ..»។ ព្រះអង្គមិនបានរត់គេចចេញទេ តែប្រឈមនឹងពួកអ្នកចាប់ទ្រង់ដោយផ្ទាល់វិញ។ តើអ្នកហ៊ានប្រឈមផ្ទាល់មុខនឹងអ្នកមានអំណាចខ្លាំងជាងគេដែរឬទេ? ចូរបង្កើនអំណាចសីលធម៌! លោក ហ្គាឡាហាដ (Sir Gallahad) មានប្រសាសន៍ថា «កម្លាំងរបស់ខ្ញុំគឺដូចជាកម្លាំងមនុស្សដប់នាក់ ពីព្រោះចិត្តរបស់ខ្ញុំគឺបរិសុទ្ធ»។ ហោរាដានីយ៉ែលអាចប្រឈមមុខនឹងហ្វូងតោព្រោះគាត់បានត្រៀមខ្លួនក្នុងបញ្ញាចិត្តរបស់គាត់ដើម្បីជួបនឹងខ្មាំងសត្រូវ។ មានការកត់សម្គាល់ថាសត្វកណ្តុរអាចនឹងសម្លាប់គាត់បានប្រសិនបើចិត្តរបស់គាត់មិនបរិសុទ្ធតែបន្តិច។

មានរឿងមួយដំណាលប្រាប់អំពីរបៀបដែលលោក ជាង ខៃ សឹក (Chiang Kai-shek) ដែលត្រូវបានគេពួនស្ទាក់វាយប្រហារដោយកងទ័ពឧទ្ទាមឆាង ហ្សួលាង (*Rebel Chang Hsuehliang*)។ អំណាចខាងផ្នែកសីលធម៌ដ៏រឹងមាំរបស់មេបញ្ជាការកងទ័ពជើងគោកបានវាយប្រានសត្រូវរបស់គាត់។ បច្ចុប្បន្នលោក ជាង ខៃ សឹក ជាគ្រីស្ទបរិស័ទដ៏ស្មោះត្រង់ហើយលោកស្រីជាងក៏នៅជាមួយគាត់ដែរ។ «មានព្រះ (គ្រីស្ទ) គង់ក្នុងទូកយើងអាចញញឹមពេលមានព្យុះ»។

តើក្រុមសាវ័កមិនបានធូរស្រាលក្នុងចិត្តដោយសារចរិកលក្ខណៈដ៏មានអំណាចនៃព្រះសង្គ្រោះរបស់គេ? ពួកគេបានរួចផុតចេញពីការចាប់ខ្លួនដោយសុវត្ថិភាព។ «នោះគឺដើម្បីឲ្យបានសំរេចពាក្យ ដែលទ្រង់មានបន្ទូលថា 'ក្នុងពួកអ្នកដែលទ្រង់បានប្រទានមកទូលបង្គំ នោះសូម្បីម្នាក់ ក៏មិនបាត់ផង'» (ខ៩ ប្រៀបធៀបនឹង យ៉ូហាន ១៧:១២)។

សូមទន្ទេញខគម្ពីរនេះ «ព្រោះអ្នកណាដែលចង់ឲ្យរួចជីវិត នោះនឹងបាត់ជីវិតទៅវិញ តែអ្នកណាដែលបាត់ជីវិត ដោយព្រោះខ្ញុំ នោះនឹងបានវិញ» (ម៉ាថាយ ១៦:២៥)។

**ការពិចារណា៖** តើអ្នកត្រៀមខ្លួនដើម្បីបុព្វហេតុដំណឹងល្អ?
**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមឲ្យយើងខ្ញុំមានកម្លាំងក្រោកឈរដើម្បីព្រះនាមទ្រង់ផង។

យ៉ូហាន ១៨:១០-១១ (ម៉ាថាយ ២៦:៤៧-៥៦ ម៉ាកុស ១៤:៤៣-៥០ លូកា ២២:៤៧-៥៣)

## «អាវុធខាងផ្នែកសាច់ឈាមនឹងធ្វើអោយអ្នកបរាជ័យ»

តើយើងនឹងធ្វើអ្វីនាយប់គេចាប់ខ្លួន(ព្រះយេស៊ូវ)? អ្នកនឹងខ្ញុំប្រាកដជានឹងគេចខ្លួនចេញពីការប្រឈមមុខនឹងសត្រូវដ៏មានអំណាចជាមិនខាន។ ក្រៅពីសាវ័កពេត្រុស សាវ័កទាំងអស់ក៏បានធ្វើដូច្នោះដែរ (ម៉ាថាយ ១៥:៥០)។

ពេត្រុសគឺជាសិស្សតែម្នាក់គត់ដែលហ៊ានក្រោកឈរដើម្បីព្រះអម្ចាស់នៃយើង។ គាត់នេះហើយដែលបានព្យាយាមការពារព្រះយេស៊ូវ ជាសាវ័កស្មោះត្រង់និងហ៊ានប្រព្រឹត្តតាមភាពជាក់ស្តែង។ ស្នូរសម្លេងឮស្មៀបគាត់បានកាត់ស្លឹកត្រចៀកម៉ាលកុសជាអ្នកបម្រើសម្តេចសង្ឃដាច់ចេញពីត្រចៀក។ លោកប្រ៊េវី (Sir Bravery) សរសើរថា ជាការស្មោះត្រង់! ពិតមែនហើយព្រះអម្ចាស់នៃយើងបានកោតសរសើរពីភក្តីភាពដ៏ពោរពេញរបស់លោកពេត្រុស។ សូមចាំថាគ្មានខគម្ពីរណាមួយចែងពីព្រះអម្ចាស់នៃយើងបន្ទោសសាវ័កពេត្រុសចំពោះការព្យាយាមរបស់គាត់ឡើយ។ ពេត្រុសបានប្រព្រឹត្តក្នុងដែនកំណត់នៃសេចក្តីសុចរិតស្វ័យការពារខ្លួន។

មានរបាយការណ៍ពីករណីនៅទីក្រុងឡុងដ៏មួយអំពីកុមារជនជាតិចិនម្នាក់ដែលបានចាក់មិត្តរួមថ្នាក់ជនជាតិអង់គ្លេសដ៏ធាត់ធំម្នាក់ដែលបង្ករឿងក្នុងបំណងការពារខ្លួន។ នៅពេលមានភស្តុតាង បញ្ជាក់ថាកុមារាតូចរូបនេះទទួលរងការប្រមាថមើលងាយជាច្រើនដងមុនគ្រោះចាក់សម្លាប់នេះកើតឡើង ក្រុមប្រឹក្សាតុលាការក៏បានដោះលែងគាត់ឲ្យមានសេរីភាព។ វាគឺជាមូលហេតុនៃកិច្ចការពារខ្លួនព្រោះពេលមុនព្រឹត្តិការណ៍សួនគេតសេម៉ានីព្រះយេស៊ូវបានមានបន្ទូលប្រាប់ក្រុមសាវ័កថា «..អ្នកណាដែលគ្មានដាវ ក៏ឲ្យអ្នកនោះលក់អាវខ្លួនទៅទិញមួយមក» (លូកា ២២:៣៦)។ ក្រោយពីពេលពួកគេរកបានដាវពីររួចហើយ ទ្រង់ក៏បានមានបន្ទូលថា «អើ ល្មមហើយ» (លូកា ២២:៣៨)។

នៅពេលពេត្រុសបានប្រព្រឹត្តក្នុងគោលបំណងជាភក្តីភាពដ៏ស្មោះត្រង់ នោះជាចរឹកលក្ខណៈភ្លាហានជ្រុលហួសក្នុងខ្លួនគាត់ដែលជាចាំបាច់ត្រូវទប់ស្កាត់។ ហេតុនេះដំបូន្មាននៅក្នុងម៉ាថាយ ២៦:៥២ គឺ «ចូរស៊កដាវអ្នកទៅក្នុងស្រោមវិញទៅ ដ្បិតអស់អ្នកដែលយកដាវ នោះត្រូវស្លាប់ដោយដាវដែរ»។ មានឱកាសសម្រាប់សុចរិតស្វ័យការពារខ្លួននៅក្នុងជីវភាពគ្រីស្ទបរិស័ទ តែដាវដែលគ្រីស្ទបរិស័ទត្រូវកាន់ជាប់ជានិច្ចនោះគឺជាដាវនៃព្រះវិញ្ញាណវិញ។ នៅពេលបុព្វបុរសជំនាន់ដើមមកដល់ដែនដីអាមេរិកពួកគាត់ត្រូវតែកាន់កាំភ្លើងដើម្បីការពារខ្លួនពីពួកចោរប្លន់ជនជាតិឥណ្ឌា (ស្បែកក្រហម)។ ទីបំផុត វាគឺជាដំណឹងល្អដែលឈ្នះជនជាតិដើម។ ជម្លោះរវាងជនជាតិអារ៉ាប់និងជនជាតិជ្វីហ្វនៅមជ្ឈឹមបូព៌ាបញ្ជាក់នូវការពិតនៃសេចក្តីបង្រៀនរបស់ព្រះយេស៊ូវ។ នៅគ្រាស្វ័យការពារខ្លួនអាចនឹងតម្រូវឲ្យយើងកាន់ដាវ ចូរយើងកុំទុកចិត្តលើអាវុធខាងផ្នែកសាច់ឈាមឡើយ។

**ការពិចារណា៖** ដំណឹងល្អជាព្រះចេស្តានៃព្រះ។

**ការអធិស្ឋាន៖** សូមឲ្យយើងខ្ញុំទុកចិត្តលើទ្រង់ និងអំណាចនៃព្រះម្ចាស់គ្រប់វេលា។

## ពីកន្លែងមួយទៅកន្លែងមួយទៀត

វាគឺជារាត្រីដ៏អាក្រក់បំផុតមួយនៅពេលគេចាប់ព្រះយេស៊ូវក្នុងសួនគេតសេម៉ានី។ នៅពេលគ្រូផ្សាយដំណឹងល្អដទៃទៀតផ្ដោតលើការកាត់ក្តីនៅកន្លែងសម្ដេចសង្ឃកៃផានិងក្រុមជំនុំសែនហិដ្រិនអ្នកដែលផ្ដល់ព័ត៌មានលម្អិតបន្ថែមអំពីការសួរចម្លើយដំបូងគេចំពោះមុខលោកអាណ (Annas) ជាសម្ដេចសង្ឃកិត្តិយសគឺជាសាវ័កយ៉ូហាន។ សំណាក់របស់គាត់ប្រហែលជាមានទីតាំងលើជំរាលភ្នំអូលីវមិនជាឆ្ងាយពីសួនគេតសេម៉ានី។ យ៉ូហានក៏ជាអ្នកបានបង្ហាញប្រាប់ពីលោកកៃផាថាជាសម្ដេចសង្ឃនៅឆ្នាំនោះ ជាអ្នកបានទូន្មានដោយអចេតនាពីការព្យាករណ៍ថា «មានប្រយោជន៍ឲ្យមានមនុស្សម្នាក់ស្លាប់ជំនួសបណ្តាជន» ដែលនៅពេលនេះកំពុងស្ថិតក្នុងដំណាក់ការនឹងបានសម្រេចយ៉ាងជ្រួលច្រាលក្នុងចិត្ត។

ក្រោយពីទទួលការជំនុំជំរះនាសម្ដេចសង្ឃនិងអ្នកដឹកនាំសាសន៍យូដា ព្រះយេស៊ូវត្រូវបានគេនាំទៅឯលោកពីឡាត់។ ប៉ុន្តែវាគឺជាលោកលូកាដែលផ្ដល់ពត៌មានលម្អិតមួយផ្សេងទៀត(លូកា ២៣:៦-១២) ដែលយ៉ូហាន សាវ័កម៉ាថាយ ឬម៉ាកុសឥតបានកត់ត្រា អំពីអន្តរាគមន៍នៃការកាត់ក្ដីនៅចំពោះស្ដេចហេរ៉ូឌ។

ពួកជនជាតិយូដាបានទទួលមរតកពីលោកម៉ូសេនូវ «ច្បាប់នឹងបញ្ញត្តដ៏ត្រឹមត្រូវ ឲ្យដូចជាក្រិត្យព្រះវិន័យនេះ» (ចោទិយកថា ៤:៨) រីឯជនជាតិរ៉ូម៉ាំងបានចម្លងយកក្រិត្យវិន័យពីជនជាតិយូដាហើយផ្ដល់វាឲ្យទៅពិភពលោកទាំងមូល។ ទោះជាយ៉ាងណា ព្រះអម្ចាស់នៃយើងមិនទទួលនូវការកាត់ក្តីដោយភាពយុត្តិធម៌ ឬក៏ស្របតាមនិតិវិធីឡើយ។ សូមអានដំណឹងល្អទាំងបួននិមួយៗដើម្បីទទួលបាននូវរូបភាពនៃពត៌មានទាំងស្រុង។ សូមកាត់ក្តីសម្រាប់ខ្លួនអ្នកផ្ទាល់ក្នុងពន្លឺនិតិសាស្ត្រនៃសម័យទំនើបទោះបីបុគ្គលម្នាក់ត្រូវគេចោទប្រកាន់នៅចំពោះអង្គជំនុំជំរះតាមតែចិត្តមនុស្សដូចជាព្រះអម្ចាស់នៃយើងឡើយ។ ព្រះអង្គត្រូវបានគេអូសពីកន្លែងមួយទៅកន្លែងមួយ គឺពីលោកអាណាទៅលោកកៃផា ពីកៃផាទៅលោកពីឡាត់ ពីលោកពីឡាត់ទៅ ស្ដេចហេរ៉ូឌ ពីស្ដេចហេរ៉ូឌត្រឡប់ទៅពីឡាត់វិញដើម្បីទទួលកាត់ទោសដោយតុលាការប្រជាជន។ ការនោះមិនរួមអំពីការទទួលជំនួយខាងផ្លូវច្បាប់ផ្ដល់ជាសម្បទានពីព្រះមហាក្សត្រនិងសិទ្ធិស្របច្បាប់ឯទៀតផង!

«ទ្រង់ត្រូវគេសង្កត់សង្កិន ហើយធ្វើទុក្ខ តែទ្រង់មិនបានហើបព្រះឱស្ឋសោះ គឺដូចជាកូនចៀមដែលគេដឹកទៅសំឡាប់ ហើយដូចជាចៀមដែលគនៅចំពោះពួកអ្នកកាត់រោមយ៉ាងណា ទ្រង់ក៏មិនបានហើបព្រះឱស្ឋសោះយ៉ាងនោះដែរ» (អេសាយ ៥៣៧)។ ហេតុអ្វី? ហេតុអ្វីបានជាទ្រង់ត្រូវគេបណ្តើរអូសពីកន្លែងមួយទៅកន្លែងមួយក្នុងទីជំនុំជំរះប្រមាថមើលងាយ ហើយទីបំផុតសម្រេចកាត់ទោសប្រហារជីវិត? ដើម្បីរូបអ្នក! ដើម្បីរូបខ្ញុំ!

**ការពិចារណា៖** ព្រះយេស៊ូវគ្រីស្ទជាជង្វាយលោះបាបតែ១សម្រាប់អ្នកនិងខ្ញុំ។
**ការអធិស្ឋាន៖** ឱព្រះអម្ចាសព្រះអើយ សូមអរព្រះគុណសម្រាប់ជង្វាយដ៏ធួននឹងបាបខ្ញុំ។

ថ្ងៃទី ១ សីហា

យ៉ូហាន ១៨:១៥-១៨, ២៤-២៧ *« ខ្ញុំបានអធិស្ឋានឲ្យអ្នក.. »*

## «បរាជ័យជាបទពិសោធន៍នៃភាពជោគជ័យ»

ដំណឹងល្អទាំងបួនសុទ្ធតែបានកត់ត្រានូវឧបកថានៃបដិសេធន៍របស់សាវ័កពេត្រុស។ ដូច្នេះ ការបដិសេធនេះប្រាកដជាមេរៀនដ៏សំខាន់មួយសម្រាប់យើងទាំងអស់គ្នា។ តើអ្នកអាចរកឃើញនៅក្នុងកំណត់ត្រាដំណើររឿងទាំងបីផ្សេងទៀតដែរឬទេ? សូមស្វែងរកវាទៅ! នៃបណ្ដាដំណឹងល្អទាំងបួន យ៉ូហានជាដំណឹងល្អសម្ដែងប្រាប់នូវ «ផ្ទៃខាងក្នុង» របស់ដំណើររឿង។ គាត់បានបរិយាយប្រាប់ពីសិស្សម្នាក់ដែលសម្ដេចសង្ឃស្គាល់ហើយតាមរយៈគាត់ ខ្លួនគាត់ផ្ទាល់និងសិស្សម្នាក់ទៀតមានឱកាសចូលទៅក្នុងព្រះលានសម្ដេចសង្ឃ។ ជាទូទៅ មតិសន្មត់ជាច្រើនគិតថាសិស្សម្នាក់នោះគឺជាសាវ័កយ៉ូហាន។ តើធ្វើដូចម្ដេចឲ្យអ្នកទេសាទជនបទម្នាក់ក្លាយជាមិត្តភក្ដិរបស់សម្ដេចសង្ឃ? ដំណាលរឿងពីសតវត្សទីបួនបានពិពណ៌នាប្រាប់ថាយ៉ូហានគឺជាអ្នកធ្លាប់លក់ត្រីនៅមុខមាត់ផ្ទះរបស់សម្ដេចសង្ឃមុនពេលគាត់លះបង់មុខរបរនេសាទត្រី។

បើពិតជាដូច្នោះក៏ដោយ វាគឺជាភក្ដីភាពដ៏ស្មោះស្ម័គ្រមួយរបស់ពេត្រុសឃើញនៅក្នុងកំណត់ត្រានេះដែលត្រូវបានសាកល្បងនៅក្បែរភ្នក់ភ្លើង។ តើលោកពេត្រុសដឹងជាមុននូវសំណួរដែលបាវស្រី ចាំទ្វារសួរគាត់ថានោះគាត់នឹងមិនទទួលស្គាល់ព្រះអម្ចាស់ចំនួនបីដង «មុនដែលមាន់រងាវ ២ដង» (ម៉ាកុស ១៤:៣០)។ តើពាក្យរបស់ព្រះអម្ចាស់នៅតែនឹកចាំក្នុងត្រចៀករបស់គាត់ជានិច្ច?

*គ្រីស្ទាន ចូរកុំនៅស្ងៀមឡើយ!*
*ស្ដាប់ចម្លើយទេវតានាំផ្លូវ*
*អ្នកកំពុងក្នុងខ្មាំងសត្រូវ*
*ត្រូវប្រយ័ត្នដោយការអធិស្ឋាន!*

សំណួរទីពីរគឺមកពីពួកអ្នកកំពុងអង្គុយក្បែរភ្នក់ភ្លើង បើតាមដំណឹងល្អយ៉ូហាន ហើយចំណែកឯសំណួរទីបីវិញសួរដោយអ្នកសាក្សី ជាអ្នកបម្រើរបស់សម្ដេចសង្ឃ ដែលត្រូវជាញាតិរបស់ម៉ាលកុស!

នេះគឺជាការប្រឡងមូលដ្ឋានមួយដែលបានដាក់ឲ្យពេត្រុសនិងពួកយើង ជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ។ ពេត្រុសធ្លាក់ការប្រឡងយ៉ាងអាណោចអធមនាពេលនេះ តែបានជាប់ ប្រកបដោយកិត្តិយសនាពេលចុងក្រោយនៃជីវិតរបស់គាត់។ ការបរាជ័យរបស់គាត់គឺជាបទពិសោធន៍ នៃភាពជោគជ័យ មិនត្រឹមតែសម្រាប់រូបគាត់ទេ តែសម្រាប់មិត្តសំឡាញ់ទាំងឡាយរបស់គាត់ផងដែរ។

ចូរយើងកុំឆាប់នឹងបិទសៀវភៅនេះដោយមិនបានសូត្រពាក្យដាស់តឿនពីដំបូងដល់ពេត្រុសឡើយ «..ស៊ីម៉ូនៗអើយ មើលសាតាំងបានសូមចង់បានអ្នករាល់គ្នា ប្រយោជន៍នឹងរែងអ្នករាល់គ្នា ដូចជារែងអង្ករ ប៉ុន្តែ ខ្ញុំបានអធិស្ឋានឲ្យអ្នក ដើម្បីមិនឲ្យសេចក្ដីជំនឿរបស់អ្នកវិនាសបាត់ឡើយ កាលណាអ្នកបានប្រែចិត្តវិលមកវិញ នោះចូរចំរើនឲ្យបងប្អូនអ្នកបានខ្ជាប់ខ្ជួនឡើង» (លូកា ២២:៣១-៣២)។

តើអ្នកធ្លាប់បានធ្វើឲ្យព្រះសង្គ្រោះខកព្រះទ័យដែរឬទេ? សូមឲ្យមានកម្លាំងចិត្តឡើង! ព្រះអង្គជ្រាបនូវរាល់ភាពកំសោយរបស់យើង។ ទ្រង់បានអត់ទោសឲ្យយើងរួចហើយ។ ព្រះអង្គមានបំណងចង់ឲ្យយើងក្រោកឈរឡើងដើម្បីបម្រើទ្រង់រហូតដល់ទីបំផុត។

**ការពិចារណា៖** ខ្ញុំបដិសេធព្រះយេស៊ូវគ្រីស្ទដែរ?

**ការអធិស្ឋាន៖** សូមឲ្យខ្ញុំរក្សាទីបន្ទាល់ជាគ្រីស្ទាននៅគ្រប់ទីកន្លែងផង ព្រះអម្ចាស់អើយ!

ថ្ងៃទី ២ សីហា
យ៉ូហាន ១៨:១០-២៣

*«...ចូរនៅជាស្មោះត្រង់ដរាបដល់ស្លាប់ចុះ នោះអញនឹងឲ្យមកុដនៃជីវិតដល់ឯង» ។*

# ពេលមិនត្រូវបែរកំផ្លៀងម្ខាងទៀត

«បើអ្នកណាទះកំផ្លៀងស្តាំនៃអ្នក នោះត្រូវតែបែរកំផ្លៀងម្ខាងទៅឲ្យទៀត» (ម៉ាថាយ ៥:៣៩)។ នេះជាសេចក្តីបង្រៀនដ៏ល្បីល្បាញមួយរបស់ព្រះយេស៊ូវដែលអ្នកនយោបាយបានដកស្រង់ក្នុងជម្លោះតស៊ូមតិរបស់គេ គឺលោក រ៉ាចារ៉ាតណាម (Mr. Rajaratnam) នាយករដ្ឋមន្ត្រីស្តីទីទីពីរនៃប្រទេសសឹង្ហបុរី។ ក៏ប៉ុន្តែព្រះយេស៊ូវមិនបានបង្រៀនដល់សិស្សទ្រង់ ឲ្យបែរកំផ្លៀងម្ខាងទៀតដោយងងឹតងងល់ឡើយ។ សេចក្តីបង្រៀនដែលទ្រង់បានមានបន្ទូលក្នុងការអធិប្បាយនៅលើភ្នំគឺស្តីអំពីភាពអយុត្តិធម៌ជាលក្ខណៈបុគ្គលវិញទេតើ។ គ្រីស្ទបរិស័ទនឹងស៊ូខាតបង់ជាជាងទាមទារនូវមោទនភាពផ្នែកសាច់ឈាមនៅក្នុងលោកីយដែលតែងតែគិតនឹងសងសឹកមកជំនួស។

នៅអត្ថបទនេះ(យើង) ឃើញថាព្រះយេស៊ូវត្រូវបានពួកអាជ្ញារបស់តុលាការសម្តេចសង្ឃទះកំផ្លៀង។ តើហេតុអ្វីបានជាទ្រង់មិនព្រមឲ្យគេទះម្ខាងទៀត? ព្រះអង្គបែរជាបន្តប្រកាន់គោលជំហររបស់ទ្រង់៖ «បើខ្ញុំបាននិយាយអាក្រក់ នោះចូរធ្វើបន្ទាល់ពីសេចក្តីអាក្រក់នោះចុះ តែបើខ្ញុំបាននិយាយល្អវិញ ហេតុអ្វីបានជាវាយខ្ញុំ» (ខ ២៣)។ ឥឡូវនេះ ព្រះយេស៊ូវកំពុងធ្វើទីបន្ទាល់អំពីសេចក្តីពិត នៅពេលកំពុងទទួលការជំនុំជំរះ។ ការសួរចម្លើយដល់ទ្រង់គឺត្រូវបានធ្វើឡើងជាសាធារណៈ ហើយដោយនូវក្នុងអត្ថប្រយោជន៍នៃសេចក្តីពិត និងសេចក្តីយុត្តិធម៌ ព្រះអង្គត្រូវតែជំទាស់។ នៅក្នុងឧបត្តិហេតុនេះគួរតែបានសិក្សាដោយអ្នកនយោបាយគ្រប់រូប ជាពិសេសអ្នកដឹកនាំជាគ្រីស្ទបរិស័ទក្នុងជួររដ្ឋាភិបាល។

សាវ័កប៉ុលក៏បានប្រកាន់គោលជំហររបស់គាត់ដែរនៅពេលពួកក្រុមជំនុំសែនហិដ្រិន (Sanhedrin) ទះមាត់គាត់៖ «ឱកំផែងលាបសអើយ ព្រះទ្រង់នឹងវាយលោកវិញ លោកអង្គុយជំនុំជំរះខ្ញុំតាមក្រិត្យវិន័យ ចុះដូចម្តេចបានជាហ៊ានបង្គាប់ឲ្យគេវាយខ្ញុំ ខុសនឹងក្រិត្យវិន័យដូច្នេះ?» (កិច្ចការ ២៣:៣)។

ពេលទទួលការកាត់ក្តីព្រោះតែសេចក្តីពិតសូមឲ្យកំផ្លៀងរបស់អ្នកម្ខាងទៀតប្រកាន់គោលជំហរហើយនិយាយការពារខ្លួន! ហើយសូមឲ្យកំផ្លៀងនោះភ្លឺចែងចាំងដោយសេចក្តីក្លាហាននៃព្រះជាម្ចាស់ជាងឈ្មោះរបស់មនុស្សទាំងអស់ផ្គុំគ្នា។ «ដូច្នេះ ចូរនៅជាស្មោះត្រង់ដរាបដល់ស្លាប់ចុះ នោះអញនឹងឲ្យមកុដនៃជីវិតដល់ឯង» (វិវរណៈ ២"១០)។

«កុំឲ្យខ្លាចចំពោះពួកអ្នកដែលសំឡាប់បានតែរូបកាយ
តែពុំអាចនឹងសំឡាប់ដល់ព្រលឹងបាននោះឡើយ
ស៊ូឲ្យខ្លាចព្រះអង្គវិញជាជាង ដែលទ្រង់អាចនឹង
ធ្វើឲ្យទាំងព្រលឹង នឹងរូបកាយវិនាសទៅក្នុងនរកផង» (ម៉ាថាយ ១០:២៨)។

**ការពិចារណា៖** តើអ្នកនឹងក្រោកឈរដើម្បីសេចក្តីពិត។
**ការអធិស្ឋាន៖** ព្រះវរបិតាអើយ សូមឲ្យខ្ញុំស្មោះត្រង់ដរាបដល់ស្លាប់ចុះ..!

ថ្ងៃទី ៣ សីហា
យ៉ូហាន ១៨:២៨-៤០

*«..អស់អ្នកណាដែលកើតពីសេចក្ដីពិត នោះនឹងឮសំឡេងខ្ញុំ»*

**«ព្រះអង្គរងទុក្ខវេទនាជាប់នាឈើឆ្កាង ក្រោមអំណាចប៉ុនទាស-ពីឡាត់»**

ថ្វីត្បិតពួកក្រុមជំនុំសែនហិដ្រិនរកឃើញព្រះយេស៊ូវមានទោសនៃការប្រមាថ ជាទោស ប្រហារជីវិត ក្រោមច្បាប់របស់ជនជាតិជ្វីប(យូដា) ដោយការគប់នឹងដុំថ្ម ក៏ពួកគេគ្មានអំណាចអ្វីដើម្បីប្រហារជីវិតនៅ ក្រោមអំណាចអាព្យាបាលរបស់ជនជាតិរ៉ូម៉ាំងដែរ។ និតិវិធីតម្រូវឲ្យពួកគេចោទប្រកាន់ទ្រង់នៅចំពោះវត្តមានលោកពីឡាត់ជារាជអាជ្ញា (Procurator) ព្រះចៅអធិរាជ។ សាលាជំនុំគឺជាសាលា (Praetorium) ជាអាគារស្នាក់នៅជាផ្លូវការរបស់លោកក្នុងទីក្រុងយេរ៉ូសាឡឹម។

សូមចាំថាសាវ័កយ៉ូហានបានមានប្រសាសន៍ថា «ពេលនោះព្រលឹមស្រាងហើយ» (ខ ២៨) ជាសញ្ញាបញ្ជាក់ប្រាប់ពីភាពគ្មានក្ដីមេត្តានៃការព្យាយាមប៉ុនប៉ងរបស់ពួកសាសន៍យូដាដើម្បីឲ្យមានទោសប្រហារជីវិត។ ពួកគេបានដាស់លោកអភិបាលក្រុងពីដំណេក។ ពួកគេអាចធ្វើដូចបានដោយសារការគ្រប់គ្រងមិនត្រឹមត្រូវនិងតម្រូវការផ្សះផ្សាគ្នារបស់គាត់ (សូមអាន លូកា ២៣:១២)។ នយោបាយគឺជាទូទៅជ្រៀតជ្រែកក្នុងបញ្ហារបស់មនុស្ស! ហេតុផលមួយទៀតចំពោះការទាញយកវត្តមានលោកអភិបាលមកគឺដោយសារជនជ្វីបមិនអាចចូលទៅក្នុង «សាលាជំនុំ» នាខណៈពេលនោះបាន ព្រោះបើគេចូលទៅ គេនឹងទៅជាសៅហ្មង (មិនស្អាត) ហើយបុណ្យរំលងក៏កំពុងប្រព្រឹត្តនៅឡើយដែរ។

ដោយសារតែភាពក្ដៅក្រហាយនឹងការអាប់ឱនកិត្តិយសនាពេលបែបនេះ លោកពីឡាត់បានព្យាយាមច្រានសំណុំក្ដីឲ្យទៅតុលាការសាសន៍យូដាវិញ។ ពួកសាសន៍យូដាបានស្រែកឡូឡាឲ្យចាប់អារម្មណ៍និងសូមឲ្យមានសច្ចានុមតិ ពីព្រោះនៅពេលពួកគេបានរកឃើញព្រះយេស៊ូវមានទោស ពួកគេត្រូវការការកាត់ក្ដីរបស់លោកអភិបាល «ដើម្បីព្យួរលើឈើ»។ សាវ័កយ៉ូហាននឹកចាំពីចំណុចនេះអំពីការព្យាករណ៍របស់ព្រះយេស៊ូវមួយរយៈពេលមុនសប្ដាហ៍ដង្ហែរស្លឹកដូង (Palm Sunday) ពីពិធីនៃការជំនុំជំរះនិងការកាត់ទោសប្រហារជីវិត(ម៉ាថាយ ២០:១៨,១៩)។ «អ្នកត្រៀមខ្លួនដើម្បីស្លាប់នោះនឹងមិនខ្លាចស្លាប់ឡើយ»។

ដោយសារតែច្បាប់ជម្រុញឲ្យកាត់ក្ដី លោកពីឡាត់បានសួរចម្លើយព្រះយេស៊ូវនៅក្នុងសាលាជំនុំ។ ការចោទប្រកាន់ទាស់នឹងព្រះយេស៊ូវនៅចំពោះវត្តមានរបស់លោកអភិបាលសាសន៍រ៉ូម៉ាំងត្រូវមូលបង្កាច់ឡើងដើម្បីឲ្យស្របនឹងគោលបំណង ដោយការបញ្ចូលនូវការចោទប្រកាន់ (ទ្រង់) ជា «ស្ដេចសាសន៍យូដា» ជាបញ្ហាបះបោរប្រឆាំងរដ្ឋាភិបាលរ៉ូម។ ក្នុងសំណួរឆ្លើយតបរបស់ព្រះយេស៊ូវបើសិនជាការចោទប្រកាន់របស់ពីឡាត់ ឬរបស់សាសន៍យូដា លោកពីឡាត់បានព្យាយាមបង្វែរសំណួរ ដោយដឹងថាគាត់នឹងធ្វើតាមបំណងបែបកលល្បិចរបស់សាសន៍យូដា។

ការធ្វើទីបន្ទាល់ដោយក្លាហានដើម្បីបេសកកម្មនិងធាតុពិតនៃនគររបស់ទ្រង់ ព្រះយេស៊ូវបានថ្លែងប្រាប់ថា ព្រះអង្គគឺពិតជាស្ដេចមែន ជាព្រះរាជសាក្សីដើម្បីសេចក្ដីពិត។ អ្នកស្រឡាញ់សេចក្ដីពិតទាំងអស់គឺជាអ្នកនៅក្រោមអំណាចរបស់ទ្រង់។ លោកពីឡាត់យល់ដឹងពីភាសាបែបទស្សនៈវិជ្ជា ដែលតាមទស្សនៈលោកសេណុងគឺថាមនុស្សឆ្លាតគឺជាស្ដេច ឯទស្សនៈផ្លាតូបង្រៀនថាទស្សនៈវិទូគឺជាស្ដេច ហើយស្ដេចគួរតែជាទស្សនៈវិទូ។ ដោយការចំអកដាក់សេចក្ដីពិតនិងព្រះមហាក្សត្រនៃសេចក្ដីពិត លោកពីឡាត់បានបែរទៅរកកំហុសឆ្គងនៃការនៅស្ងៀមមិននិយាយស្ដី។

**ការពិចារណា៖** ទ្រង់រងទុក្ខព្រោះអ្នកនិងខ្ញុំ។
**ការអធិស្ឋាន៖** សូមទ្រង់ជាកម្លាំងឲ្យខ្ញុំក្រោកឈរព្រោះបុព្វហេតុដំណឹងល្អដល់ទីបញ្ចប់នៃជីវិត។

## ជំពូកទី ១៩
## នៅចំពោះអភិបាលនៃអធិរាជសេសាដែលកាត់ក្ដីទ្រង់
## ព្រះយេស៊ូវមានជំហរជាព្រះមហាក្សត្រនៃជីវិត

ដោយការភ្ជាប់នូវកំណត់ត្រានៃដំណឹងល្អម៉ាថាយនិងម៉ាកុស សាវ៉កយ៉ូហានបានរៀបរាប់ប្រាប់ពីទារុណកម្មរបស់ព្រះយេស៊ូវនិងពីរឿងរ៉ាវដែលទ្រង់ត្រូវបានគេចំអកដាក់ថាជាស្ដេចជនជាតិយូដាដោយការបំពាក់អាវព័ណស្វាយនិងកួងបន្លាដល់ទ្រង់។

ខណៈសាវ៉កឯទៀតបានគេចខ្លួន ហើយពេត្រុសគាត់កំពុងលាក់ខ្លួនពោរពេញដោយវិប្បដិសារីពីក្ដីអាម៉ាស់ដោយសារការបដិសេធន៍របស់គាត់ យ៉ូហានជាអ្នកបន្ដកំដរតាមមើលដំណើររបស់ព្រះអម្ចាស់រហូតដល់ទីបំផុត។ ហើយដោយហេតុថាគោលបំណងរបស់គាត់ គឺដើម្បីបន្ថែមនូវអ្វីដែលគ្រូផ្សាយដំណឹងល្អឯទៀតមិនបានប្រាប់ ជា ពិសេសនូវកំណត់ត្រាសាក្សីរបស់ខ្លួនគាត់ផ្ទាល់ ដូចនេះគាត់ផ្ដល់ឲ្យយើងនូវជំទាស់ខ្លីមួយរបស់លោកពីឡាត់ជា មួយនឹងជនជាតិយូដានៅខាងក្រៅសាលាជំនុំនៅឯទីក្រាលថ្ម ដែលភាសាហេព្រើរហៅថា*កាបាថា*។ តើអ្នកនៅទី នោះ ឬទេពេលពួកគេស្រែកសូមឲ្យមានទោសប្រហារជីវិតព្រះយេស៊ូវ?

រួមជាមួយនឹងគ្រូផ្សាយដំណឹល្អឯទៀត សាវ៉កយ៉ូហាននាំយើងទៅឯភ្នំគាល់កូថា (ក្នុងភាសាហេព្រើរ ហៅថាភ្នំរលាក្បាល) ភ្នំកាល់វ៉ារី នៅក្នុងភាសាឡាទីន (លូកា ២៣:៣៣)។ ខណៈយ៉ូហានលុបសេចក្ដីដែលគ្រូផ្សាយដំណឹងល្អឯទៀតបានលើកមកសង្កត់ធ្ងន់ គាត់ប្រាប់រឿងផ្ទាល់ខ្លួនរបស់គាត់យ៉ាងទន់ភ្លន់ពីទំនាក់ទំនងថ្មីប្រគល់ជូនទៅនាងម៉ារា ជាព្រះមាតានៃព្រះអម្ចាស់។ យ៉ូហាននៅរហូតដល់ពេលចុងក្រោយ ជាពេលគាត់ស្ដាប់ ឮពាក្យជ័យជំនះរបស់ព្រះសង្គ្រោះ «ការស្រេចហើយ!» (១៩:៣០)។

សាវ៉កយ៉ូហានបន្ដនឹងកំណត់ត្រារបស់គាត់អំពីព្រះយេស៊ូវដែលត្រូវបានគេចាក់នៅត្រង់ចំហៀងខ្លួន។ ការដ៏អស្ចារ្យមួយបានកើតឡើងខណៈពេលនោះគឺជាការហូរនូវឈាមនិងទឹក! យ៉ូហានបានដំណាលប្រាប់ពីភាពជាក់ស្ដែងនៃអាថ៌កំបាំងដ៏អស្ចារ្យនេះចំនួនបីដង។

*សូមឱ្យទឹកនឹងឈាមដែលហូរ ពីឫស.. ទ្រង់ជាបរិបូរ..*
*មកលាងចិត្ត ខ្ញុំស្អាតជ្រះថ្លា ប្រោសឱ្យរួចហើយ ថែរក្សា..។*

ព្រះយេស៊ូវបានសុគតយ៉ាងឆាប់រហ័ស ដោយពុំចាំបាច់អនុវត្តន៍ការវាយបំបាក់ជើងនោះឡើយ។

យ៉ូហានបញ្ចប់ការរៀបរាប់ត្រង់ចំណុចដែលព្រះយេស៊ូវត្រូវបានគេបញ្ចុះក្នុងផ្នូរថ្មីរបស់លោកយ៉ូសែបជាអ្នកស្រុកអើរីម៉ាថេ ជាសិស្សរបស់ព្រះយេស៊ូវជាសម្ងាត់ និងដោយការបន្ថែមពីសន្ដានចិត្តសប្បុរសនៃលោកនីកូដេម។ ដំណឹងល្អយ៉ូហានបញ្ចប់យ៉ាងល្អជាមួយនឹងមនុស្សដែលបានមកជួបព្រះយេស៊ូវនាពេលយប់។ អ្នកនឹងមិនអាចថ្លែងពីផលផ្លែបង្កើតឡើងពីការធ្វើបន្ទាល់រយៈពេលមួយម៉ោងបានឡើយ! «ហើយក្នុងកាលដែលទ្រង់ សុគតនោះគេក៏បញ្ចុះសពទ្រង់នៅជាមួយនឹងពួកអាក្រក់ ហើយនៅក្នុងផ្នូររបស់អ្នកមានម្នាក់ ទោះបើទ្រង់មិន ដែលធ្វើអំពើទុច្ចរិតណាមួយក៏ដោយ ក៏មិនដែលមានការបញ្ឆោតនៅក្នុងព្រះឱស្ឋទ្រង់ឡើយផង» (អេសាយ ៥៣:៩)។

**ការពិចារណា៖** ការសង្គ្រោះមនុស្សមានបាបស្រេចហើយ!

**ការអធិស្ឋាន៖** សូមអរគុណព្រះអង្គជាមហាក្សត្រនៃជីវិតរបស់យើង។

# « ខ្ញុំមិនឃើញជាមានទោសអ្វីទេ»

ក្នុងការជួបជុំដំបូងជាមួយនឹងសាសន៍យូដាក្រោយពីសួរចម្លើយព្រះយេស៊ូវនៅសាលាជំនុំ ជាចាំបាច់យើងសម្គាល់ពីភាពកំសោយរបស់លោកពីឡាត់ដែលមានទំនោរចិត្តតាមសម្រេកសូមឲ្យដោះលែងបារ៉ាបាស ដោយលោកប្រកាសថា «ខ្ញុំមិនឃើញជាអ្នកនោះ មានទោសខុសអ្វីសោះ» (យ៉ូហាន ១៨:៣៨)។

ព្រោះតែមនសិការមានទោសក្រោយពីការយល់ស្របតាមពួកអ្នកបះបោរដោយអំពើហឹង្សា លោកពីឡាត់បានធ្វើទារុណកម្មព្រះយេស៊ូវ។ ថៅក្រមញញើតញញើមរូបនេះបានធ្វើដូច្នោះដើម្បីឲ្យពួកអ្នកចោទប្រកាន់ព្រះគ្រីស្ទស្ងប់ស្ងាត់តាមរយៈការចាត់វិធានការធ្វើទារុណកម្ម៖ «មើល ខ្ញុំនាំអ្នកនេះចេញមកឯអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាដឹងថា ខ្ញុំមិនឃើញជាគាត់មានទោសយ៉ាងណាសោះ» (យ៉ូហាន ១៩:៤)។ នេះបណ្ដាលឲ្យកំហឹងរបស់សម្ដេចសង្ឃនិងពួកអាជ្ញារឹតតែឆេះក្ដៅឡើងថែមទៀត។ «ឆ្កាងវា ឆ្កាងវាទៅ» (ខ ៦) គឺជាពាក្យទទូចចង់បានដ៏គួរឲ្យរន្ធត់របស់ពួកគេ។

លោកកាល់វីនបានអត្ថាធិប្បាយថា៖ «នៅពេលគាត់ព្យាយាមយ៉ាងស្វិតស្វាញហើយមិនបានសម្រេចជោគជ័យ យើងត្រូវសម្លឹងមើលនៅក្នុងឧបត្ថិហេតុនេះដោយនូវបញ្ញាតិនៃឋានសួគ៌ពីព្រោះតាមរយៈឧបត្ថិហេតុនេះហើយដែលតម្រូវឲ្យព្រះគ្រីស្ទសុគត។ តែទោសរបស់ទ្រង់គឺជារឿយៗត្រូវបានគេបញ្ជាក់អះអាងការជំនុំជំរះរបស់ថៅក្រម ដើម្បីបង្រៀនយើងថា ការរួចពីអស់ទាំងទោស ព្រះអង្គបានរងទោសជំនួសអ្នកដទៃ ហើយរងទណ្ឌកម្មព្រោះតែអំពើបាបរបស់អ្នកដទៃដែរ។ ចំណុចនេះគឺបានសម្ដែងនូវគោលលទ្ធិនៃដង្វាយធួននឹងបាបដែលព្រះគ្រីស្ទបានសុគត ជាព្រះដ៏សុចរិត ទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិត សម្រាប់នឹងសងថ្លៃទណ្ឌកម្មនៃអំពើបាបរបស់យើង។ ទីបំផុត លោកពីឡាត់បានអនុញ្ញាតឲ្យពួកសាសន៍យូដាយកទ្រង់ទៅឆ្កាង ដោយលោកបានប្រកាសជាលើកទីបីថា៖ «ដ្បិត ខ្ញុំមិនឃើញជាមានទោសអ្វីទេ» (យ៉ូហាន ១៩:៦)។

ដោយសារសម្ពាធអំណាចនៃមនសិការមានទោសនោះលោកពីឡាត់បានតយុទ្ធនឹងការពន្យានូវទង្វើចុងក្រោយ។ លោកចង់ដឹងបន្ថែមពីការចោទប្រកាន់របស់សាសន៍យូដាពីដំណើរទ្រង់បានតាំងអង្គទ្រង់ជាព្រះរាជបុត្រានៃព្រះ។ ពីឡាត់បានគិតថាលោកនឹងនៅតែអាចរំដោះមនុស្សគ្មានទោសបាន ហើយគំនិតនោះចាក់ដោតយ៉ាងជាប់មុតមាំនៅក្នុងចិត្តរបស់គាត់ថាគាត់ត្រូវតែរំដោះព្រះយេស៊ូវ។ ដោយការជានារហ័សគាត់បានសួរអ្នកជាប់ទោសថា៖ «អ្នកមិនដឹងទេឬថា ខ្ញុំមានអំណាចនឹងឆ្កាងអ្នកឬលែងអ្នកបាន?» (ខ ១០)។ យ៉ាងណាក៏ដោយអ្នកទេវសាស្ត្រដ៏ជាព្រះក្នុងស្ថានភាពវិបត្តិ បានឃើញអំណាចកំពូលមួយ៖ «បើមិនបានប្រទាន មកពីស្ថានលើ នោះលោកឥតមានអំណាចលើខ្ញុំសោះ ហេតុនោះបានជាអ្នកដែលបញ្ជូនខ្ញុំមកលោកអ្នកនោះមានបាបធ្ងន់ជាង» (ខ ១១)។ ថ្វីត្បិតព្រឹត្តិការណ៍នាំទៅរកការសុគតរបស់ព្រះគ្រីស្ទគឺព្រះជាម្ចាស់ជាអ្នកចេញបញ្ញាតិ ក៏តួអង្គនិមួយៗនៅលើឆាកនៃជោគវាសនាគឺត្រូវទទួលខុសត្រូវសម្រាប់ទង្វើរបស់ខ្លួនដែរ ទោះបីល្អឬអាក្រក់ក្ដី។ នេះគឺជាអាថ៌កំបាំងដ៏ជ្រាលជ្រៅមួយនៃគោលលទ្ធិនៃការកំណត់ទុកជាមុនបង្រៀនដោយព្រះអម្ចាស់ផ្ទាល់ (សូមអាន ម៉ាកុស ១៤:២១)។

ទោះបីលោកពីឡាត់បានលាងសម្អាតដៃរបស់គាត់ពីឈាមរបស់មនុស្សសុចរិត (ម៉ាថាយ ២៧:២៤) នៅថ្ងៃណាមួយត្រូវតែឈរទទួលការជំនុំជំរះទោសនៅចំពោះព្រះអង្គដែលបានប្រគល់ទៅសាសន៍យូដាព្រោះតែទង្វើញញើតញញើមរបស់គាត់។ សុភាសិតចិនផ្ដល់យោបលដ៏ល្អថា ខ្លួនមួយកុំជិះទូកពីរ!

**ការពិចារណា៖** ព្រះយេស៊ូវគ្មានទោស តែរងទោសជំនួសអ្នកមានទោសដូចជារូបអ្នកនិងខ្ញុំ។

**ការអធិស្ឋាន៖** ឱព្រះអង្គដ៏លោះបាបអើយ យើងខ្ញុំសូមអរព្រះគុណនូវដង្វាយផ្ដាច់បាបរបស់ទ្រង់។

ថ្ងៃទី ៦ សីហា
យ៉ូហាន ១៩:១៤-១៦ *« ដូច្នេះលោកក៏បញ្ជូនទ្រង់ទៅឲ្យគេឆ្កាង ហើយគេនាំទ្រង់យកទៅ»*

## តាមវេលាអ្វី?

នាអំឡុងសម័យជនជាតិជប៉ុនគ្រប់គ្រងប្រទេសសឹង្ហបុរី ទីក្រុងសឹង្ហត្រូវបានហៅថាស៊ីយ៉ូណាន (Syonan)។ ក្រោមការរាជរដ្ឋាភិបាលចក្រភពថ្មីប្រជាជនត្រូវរក្សាវេលាពីរគឺ ម៉ោងតាមស៊ីយ៉ូណាន និង ម៉ោងតាមទីក្រុងតូក្យូ!

នៅអំឡុងសម័យព្រះគ្រីស្ទ ជនជាតិយូដានៅក្រោមការគ្រប់គ្រងនៃជនជាតិរ៉ូម៉ាំង។ សម័យនោះមាន របៀបរក្សាតាមវេលារបស់ជនជាតិយូដានិងវេលារបស់ជនជាតិរ៉ូម៉ាំង។

ជនជាតិយូដារាប់វេលារបស់គេពីម៉ោង៦ព្រឹកដល់៦ល្ងាចដូចជាពួកគេរាប់នាបច្ចុប្បន្ននេះដរាបណាថ្ងៃ សប្ប័ទយកជាគោលដែរ។ ឯជនជាតិរ៉ូម៉ាំងវិញរាប់វេលាចាប់ពីកណ្តាលអាធ្រាតដល់ពេលរសៀល។

ឥឡូវនេះបើយើងអានម៉ោងក្នុងសេចក្តីសង្ខេបនៃដំណឹងល្អទាំងបី (Synoptic Gospels) និងម៉ោង ក្នុងដំណឹងល្អយ៉ូហាន យើងនឹងឃើញថាដំណឹងល្អទាំងបីរាប់តាមវេលារបស់ជនជាតិយូដា ហើយ ដំណឹងល្អ យ៉ូហានរាប់តាមវេលារបស់ជនជាតិរ៉ូម៉ាំង។ ដូច្នេះយ៉ូហាន ១៩:១៤ ចែងប្រាប់វេលាដល់យើង ប្រហែល ជា ម៉ោងទីប្រាំមួយដែលលោកពីឡាត់បាននិយាយទៅកាន់សាសន៍យូដាថា «នេះស្តេចនៃអ្នករាល់ គ្នា» ។ ម៉ោងទីប្រាំមួយនៅក្នុងខនេះគឺម៉ោង៦ព្រឹក។ ឯប្រហែលជាម៉ោង ៦ល្ងាចអាចជាម៉ោង ៦:១០ នាទី ឬ ៦:១៥ នាទីព្រឹក។ នេះគឺផ្ទៀងផ្ទាត់ត្រូវ នឹងកំណត់ត្រា នៃដំណឹងល្អម៉ាកុសដែលចែងថាព្រះយេស៊ូវត្រូវបាន ជាប់ឆ្កាងនៅវេលាម៉ោងទីបី (តាមវេលានៃជនជាតិយូដា) ឬ ម៉ោង ៩ព្រឹក។

ចំណុចលំបាកមួយទៀតអំពីគោលការណ៍គ្រឹះនៃវេលាគឺឃ្លា «រៀបចំបុណ្យរំលង» ក្នុងយ៉ូហាន ១៩: ១៤ និង «បរិភោគបុណ្យរំលង» ក្នុងយ៉ូហាន ១៨:២៨។ តើព្រះអម្ចាស់នៃយើងនិងបណ្តាសាវ័កមិនបាន រក្សាពិធីបុណ្យរំលងកាលពីយប់មុននោះ? បើតាមខគម្ពីរទាំងនេះយ៉ូហានបានធ្វើខុសដ៏ធ្ងន់ធ្ងរ។ ទេ ដូច្នោះ ឡើយ! បណ្ឌិតដេវីឌ ស្មីត មានប្រសាសន៍ថា៖ «ឃ្លា «បរិភោគបុណ្យរំលង» មិនត្រឹមសំដៅតែពីការចូលរួម ក្នុងការបរិភោគអាហារបុណ្យរំលងនាពេលល្ងាច (អាហារបុណ្យរំលង) ដែលពួកគេបានប្រារព្ធធ្វើរួចហើយ កាលពីយប់មុននោះទេ តែជាការចូលរួមក្នុងកម្មវិធីផ្សេងៗនៅសប្តាហ៍ពិសិដ្ឋ ជាពិសេសពិធីបុណ្យអរព្រះ គុណ (ភាសាហេព្រើរ «ឆាហ្គីហ្គា (*chagigah*) ភាសាអង់គ្លេស «*feast of thanksgiving*») នារសៀលថ្ងៃ បន្ទាប់ពីអាហារពេលល្ងាចវិញ។ មូលហេតុនេះទើបមានការបដិសេធន៍របស់ពួកគេមិនចូលទៅក្នុងសាលាជំនុំ នាវេលាព្រឹកនោះ។ ភាពសៅហ្មងនឹងជាប់មាននៅរហូតដល់ពេលល្ងាច ហើយពួកគេនឹងមិនត្រូវបានអនុញ្ញាត ឲ្យចូលរួមពិធីបុណ្យអរព្រះគុណនាពេលរសៀលឡើយ។

ឯចំពោះឃ្លា «រៀបចំបុណ្យរំលង» ពាក្យ «រៀបចំ» នៅក្នុងខនេះមិនមានន័យថា «ត្រៀមលក្ខណៈ ជាស្រេច សម្រាប់ពិធីបុណ្យរំលងទេ តែជាការរៀបចំសម្រាប់ថ្ងៃសប្ប័ទដែលចាប់ផ្តើមនៅថ្ងៃសុក្រម៉ោង៦ ល្ងាច (នៃសប្តាហ៍បុណ្យរំលង) វិញ។ ដូច្នេះទីបំផុតនៃដំណើររៀបរាប់ពីការជាប់ឆ្កាង លោកម៉ាថាយប្រាប់ពី ថ្ងៃបន្ទាប់ពីការរៀបចំបុណ្យរំលងគឺជាថ្ងៃសៅរ៍ ឬជាវេលាដ៏សំខាន់នៃថ្ងៃសប្ប័ទរបស់ជនជាតិយូដា។ ម៉ាកុស

លោកប្រើពាក្យច្បាស់ជាងនៅក្នុងជំពូក ១៥:៤៣ «ដោយព្រោះជាថ្ងៃរៀបចំ ហើយគឺជាថ្ងៃមុនថ្ងៃឈប់សំរាក ហើយក៏ល្ងាចណាស់ផង» ។ នេះគឺជារយៈកាលមួយពេលមុនថ្ងៃសុក្រ ម៉ោង ៦ល្ងាច។ វាគ្មានអ្វីទាក់ទងនឹងការត្រៀមលក្ខណៈជាស្រេចសម្រាប់អាហារបុណ្យរំលងដែលបានកើតឡើងរួចហើយនោះឡើយ។

**ការពិចារណា៖** លុះវេលាមកដល់ព្រះយេស៊ូវសុគតជួសខ្ញុំ។

**ការអធិស្ឋាន៖** អរព្រះគុណព្រះសម្រាប់កូនចៀមនៃពិធីបុណ្យរំលង គឺជាព្រះយេស៊ូវ។

## ស្តេចនៃសាសន៍យូដា

ខណៈការសង្ខេបដំណឹងល្អទាំងបីជាទូទៅសម្តែងប្រាប់ពីពាក្យចារខាងលើព្រះសិរសារព្រះយេស៊ូវ អ្នកដែលប្រាប់យើងពីខ្លឹមសារទាំងស្រុងនៃពាក្យនោះគឺជាសាវ័កយ៉ូហាន។ ចំណុចដ៏សំខាន់នៃសេចក្តីប្រកាសគឺ «ស្តេចនៃសាសន៍យូដា» (ខ១៩)។

តើអង្គណាជាស្តេចនៃសាសន៍យូដា? ពិតជាមិនមែនយេស៊ូវជាអ្នកស្រុកណាសារ៉ែតដែលសាសន៍យូដាបានយកទៅប្រហារជីវិត! សាសន៍យូដាគឺកំពុងតែរង់ចាំព្រះមែស៊ី ជាស្តេចចាក់ប្រេងតាំងជាបំណងប្រាថ្នាចង់បានរបស់គេ ជាស្តេចដែលនឹងរំដោះគេចេញពីសាសន៍រ៉ូម៉ាំង។ ការសរសេរពាក្យ «ឈ្មោះយេស៊ូវជាអ្នកស្រុកណាសារ៉ែតស្តេចនៃសាសន៍យូដា» គឺជាការប្រមាថដល់ស្មារតីស្នេហាជាតិនៃសាសន៍យូដាដ៏ខ្លាំងក្លាបំផុត។ ប៉ុន្តែនេះមិនមែនជាពាក្យចោទប្រកាន់ដែលសាសន៍យូដាបានប្តឹងដើម្បីទទួលនូវក្តីអាណិតមេត្តាពីសាសន៍រ៉ូម៉ាំង? នៅក្នុងអត្ថន័យោងនៃពាក្យប្រកាសខាងលើ យើងឃើញថាលោកពីឡាត់បានធ្វើតបវិញឲ្យដូចជាគេបានធ្វើមកលើខ្លួនឯងគេដែរ។ ពេលស្នើសុំឲ្យកែប្រែឃ្លា «នេះឈ្មោះយេស៊ូវជាអ្នកស្រុកណាសារ៉ែតស្តេចនៃសាសន៍យូដា» លោកពីឡាត់ញញឹមដ៏រីករាយអស់ពីចិត្ត បដិសេធយ៉ាងដាច់អហង្ការ! សងសឹកយ៉ាងស្រួលតែម្តង! ទោះបីការបដិសេធនោះធ្វើឲ្យទាស់ចិត្តសាសន៍យូដា ពាក្យប្រកាសដែលលោកពីឡាត់បានសរសេរពិតជាគាប់ព្រះហឫទ័យដល់ ព្រះជាម្ចាស់ខ្លាំងណាស់! លោកពីឡាត់គឺគ្រាន់តែថ្លែងពីសេចក្តីពិតដែលបានជ្រាបពីទីបន្ទាល់ផ្ទាល់របស់ព្រះយេស៊ូវប៉ុណ្ណោះ។ តើព្រះអង្គឥតបានឈរយ៉ាងស្មោះត្រង់ចំពោះលោកជាស្តេច ហើយថែមទាំងប្រកាសប្រាប់លោកថាទ្រង់គឺជាស្តេច? ស្តេចលើអស់ទាំងស្តេច និងជាស្តេចសាសន៍យូដា ជាព្រះបុត្រានៃស្តេចដាវីឌ ហើយនឹងមានថ្ងៃមកដល់ទ្រង់នឹងយាងមកជំនុំជំរះពិភពលោកនេះដោយគង់លើបល្ល័ង្កព្រះវរបិតាទ្រង់? ពិតណាស់ព្រះយេស៊ូវគឺជាស្តេចសាសន៍យូដា! យើងពិតជាប្រាថ្នាចង់ឲ្យមិត្តជនជាតិជ្វីបរបស់យើងនឹងរកឃើញនូវសេចក្តីពិតនិងមកក្រាបថ្វាយបង្គំទ្រង់ ហើយនិងបានសង្គ្រោះ!

រាល់ព្រះរាជសារថ្ងៃបុណ្យណូអែល គឺជាព្រះរាជសារដ៏ពិសេសមួយចំពោះជនជាតិជ្វីប (យូដា) ចំពោះប្រទេសអ៊ីស្រាអែលក្នុងដំណើរតយុទ្ធដើម្បីរស់រានមានជីវិតក្នុងភាពឈឺចាប់ក្នុងពិភពសត្រូវអារ៉ាប់។

> «ដ្បិតមានបុត្រ១កើតដល់យើង ព្រះទ្រង់ប្រទានបុត្រា១មកយើងហើយ ឯការគ្រប់គ្រងនឹង នៅលើស្មារបស់បុត្រានោះ ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ ព្រះដ៏មានព្រះចេស្តា ព្រះវរបិតាដ៏គង់នៅអស់កល្ប នឹងជាម្ចាស់នៃមេត្រីភាព។ ឯសេចក្តី ចំរើននៃរដ្ឋបាលទ្រង់ នឹងសេចក្តីសុខសាន្តរបស់ទ្រង់នោះនឹងមិនចេះផុតពី**បល្ល័ង្ករបស់ដាវីឌ នឹងនគរនៃទ្រង់ឡើយ** ដើម្បីនឹងតាំងឡើង ហើយទប់ទល់ដោយសេចក្តីយុត្តិធម៌ និងសេចក្តី សុចរិត ចាប់តាំងពីឥឡូវនេះជារៀងរាបដរាបទៅ គឺសេចក្តីឧស្សាហ៍របស់ព្រះយេហូវ៉ានៃពលបរិវារនឹងសំរេចការនេះ» (អេសាយ ៩:៦-៧)។

អង្គបុគ្គលដែលគេប្រមាថនឹងគ្មានឋានៈពីស្រុកណាសារ៉ែតនេះ ថ្ងៃណាមួយនឹងធ្វើឲ្យសាសន៍យូដានិងពិភពលោកភ្ញាក់ផ្អើលក្នុងនាមជាស្តេចនិងជាចៅក្រមរបស់ពួកគេជាពុំខាន។ ដរាបណាព្រះមហាក្សត្រ

សាសន៍យូដាជាព្រះអម្ចាស់នៃសន្តិភាពពុំទាន់យាងមកផែនដី នោះនឹងគ្មានសន្តិភាពពិតប្រាកដឡើយ។ សូមលោកប្រធានាធិបតីនិងនាយករដ្ឋមន្ត្រីទាំងឡាយសម្គាល់មើលចុះ!

**ការពិចារណា៖** ឱក្សត្រនៃជីវិតខ្ញុំអើយ ខ្ញុំសូមលើកដំកើងទ្រង់ហើយ..!
**ការអធិស្ឋាន៖** ឱសូមឲ្យមហាក្សត្រនៃសន្តិភាពប្រទានសន្តិភាពដល់គ្រីស្ទានគ្រប់ប្រាណ។

## សម្រេចតាមបទទំនាយ សម្រេចទេវសាស្ត្រ

ទាហានបួននាក់ (កិច្ចការ ១២:៤) ត្រូវបានគេចាត់ឲ្យទទួលខុសត្រូវនឹងភារៈកិច្ចដ៏លំបាកនៃការឆ្កាងអ្នកទោសបីនាក់។ ជាទម្លាប់សំលៀកបំពាក់របស់អ្នកជាប់ទោសប្រហារជីវិតពាក់នឹងក្លាយជារបស់ពិជឃាត។ ពេលនេះព្រះអម្ចាស់នៃយើង ដូចជាសាសន៍យូដាឯទៀតដែរ ព្រះអង្គមានគ្រឿងប្រដាប់កាយចំនួនប្រាំ គឺឈ្នួត (ក្បាល) អាវធំក្រៅ ខ្សែក្រវ៉ាត់ ស្បែកជើងសង្រែក និងទីប្រាំគឺជាអាវផាយក្នុង។ ទោះបីពួកទាហានយកគ្រឿងប្រដាប់កាយបួនដំបូងមកចែកគ្នាតាមរយៈការចាប់ឆ្នោត ឬក៏យ៉ាងណា យើងមិនដឹងទេ តែពួកគេពិតជាបានយកគ្រឿងប្រដាប់កាយទីប្រាំមកចាប់ជាឆ្នោតមែន។ មូលហេតុដោយសារអាវផាយក្នុងជាអាវត្បាញគ្មានថ្នេរ។ បើចែកគ្នាវានឹងខូចអស់។ ដូច្នេះពួកគេបានធ្វើការចាប់ឆ្នោតសម្រាប់ «អាវ» នេះ។ ការធ្វើដូច្នោះពួកគេបានសម្រេចនូវបទទំនាយមួយទៀតអំពីព្រះមែស៊ី (ទំនុកដំកើង ២២:១៨) ពីការសរសេររបស់ស្ដេចដាវីឌ។

ស្ដេចដាវីឌ ជាបុព្វការីជនខាងផ្នែកសាច់ឈាមរបស់ព្រះអម្ចាស់នៃយើង ព្រះអង្គជាគំរូនៃព្រះរាជបុត្រាដ៏អស្ចារ្យរបស់ទ្រង់។ មានព្រឹត្តិការណ៍ជាច្រើននៅក្នុងជីវិតរបស់ទ្រង់ជាព្រាងទុកជាហេតុការណ៍ដែលនឹងត្រូវបានកើតឡើងចំពោះព្រះអម្ចាស់នៃយើង។ ពាក្យថ្លែងនេះ «គេបានយកសំលៀកបំពាក់ទូលបង្គំចែកគ្នាឯអាវវែងរបស់ទូលបង្គំគេយកដោយចាប់ជាឆ្នោត» (ខ ២៤) គឺជាពាក្យព្រះវិញ្ញាណបរិសុទ្ធបណ្ដាលឱ្យតែងដើម្បីជាឧយោងពីអង្គព្រះគ្រីស្ទ។ តាមការប៉ាន់ស្មានគឺមាន៣៣២ បទទំនាយខុសៗគ្នានៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែលត្រូវបានសម្រេចក្នុងអង្គព្រះគ្រីស្ទ។ ព្រះអង្គគឺជាមនុស្សព្រះបានបញ្ជូនមក ជាអង្គព្រះសង្គ្រោះដែលព្រះជាម្ចាស់បានកំណត់ទុក។

ពេលនេះសេចក្ដីពិតដ៏ជ្រាលជ្រៅអំពីការសម្រេចនូវបទទំនាយរបស់ស្ដេចដាវីឌនៅក្នុងទំនុកដំកើង ២២:១៨ ដូចជាលោកហិនឌ្រិសិន (Hendriksen) ចង្អុលប្រាប់ គឺដូចនេះ ៖ តាមរយៈការដោះសំលៀកបំពាក់ ជនរងគ្រោះរហូតដល់អាវក្នុង ព្រះអម្ចាស់នៃយើងបានត្រឡប់ទៅជានៅរូបអង្គទទេ។ តែទង្វើនោះបានធ្វើឲ្យសព្វព្រះហឫទ័យដល់ព្រះអម្ចាស់ ដែលការប្រមាថនោះជារបួសថែមទៅលើព្រះរាជ បុត្រារបស់ទ្រង់ (« ដូចជាអ្នកណាដែលមនុស្សគេចមុខចេញ ហើយយើងរាល់គ្នាមិនបានរាប់អានទ្រង់សោះ» អេសាយ ៥៣:៣) ជាប្រយោជន៍ឲ្យភាពអាក្រាតបានបំពាក់ដោយសេចក្ដីសុចរិតរបស់ទ្រង់វិញ។ យើងត្រូវតែឈប់បង្អង់ក្នុងការដឹងគុណព្រះអង្គសង្គ្រោះដែលត្រូវគេធ្វើទារុណកម្ម ជាអង្គបុគ្គលមិនត្រឹមតែបានប្រទាននូវព្រះលោហិតរបស់ទ្រង់ដល់យើងនោះទេ តែថែមទាំងសំលៀកបំពាក់របស់ទ្រង់ផងដែរ។ សូមអរព្រះគុណដល់ព្រះដោយសារព្រះយេហូវ៉ាដ៏ជាសេចក្ដីសុចរិតនៃយើងរាល់គ្នា (យេរេមា ២៣:៦) ជាអង្គបុគ្គលដែលមិនត្រឹមតែបានដកទោសរបស់យើងចេញទេ តែថែមទាំងគ្របបាំងនូវក្ដីអាម៉ាស់របស់យើងផងដែរ។ ព្រះអង្គបានសម្រេចនូវបទទំនាយដើម្បីឲ្យបានសម្រេចតាមបទទេវសាស្ត្រ។

**ការពិចារណា៖** ព្រះយេហូវ៉ាជាសេចក្ដីសុចរិតនៃយើង។

**ការអធិស្ឋាន៖** សូមអរព្រះគុណ ឱព្រះអម្ចាស់សម្រាប់សេចក្ដីសុចរិតដែលទ្រង់ប្រទានដល់យើងខ្ញុំ។

ថ្ងៃទី ៩ សីហា
យ៉ូហាន ១៩:២៥-២៧

«...ប្រជុំជាមួយគ្នាដោយនូវឈ្មោះខ្ញុំ នោះខ្ញុំក៏នៅកណ្ដាលចំណោមអ្នកទាំងនោះដែរ»

**«ដែលទ្រង់បានស្រឡាញ់ដល់ពួកទ្រង់នៅក្នុងលោកីយនេះ នោះទ្រង់ក៏ចេះ តែស្រឡាញ់គេ ដរាបដល់ចុងបំផុត»**
(យ៉ូហាន ១៣:១)

« ដ្បិតសេចក្ដីស្រឡាញ់មានកំឡាំងដូចជាសេចក្ដីស្លាប់» (បទចំរៀងនៃសាឡូម៉ូន ៨:៦)។ ដូច្នេះនៅពេលសិស្សទាំងដប់នាក់បានរត់គេចចេញពីព្រះរាជគ្រូ លោកយ៉ូហានជាសិស្សទីដប់មួយ ជាសិស្សដែលព្រះយេស៊ូវ ស្រឡាញ់ និងពួកស្ត្រីដែលស្រឡាញ់ព្រះយេស៊ូវដែរ បានធ្វើពិធីទុកដាក់សពនាទីតាំងឈើឆ្កាង។ ក្រុមស្ត្រីស្រឡាញ់ព្រះយេស៊ូវជាធម្មតាគឺមានមាតាបង្កើតរបស់ទ្រង់ ប្អូនស្រីរបស់មាតាទ្រង់ គឺនាងម៉ារាភរិយាក្លូប៉ាស និងនាងម៉ារាជាអ្នកស្រុកម៉ាក់ដាឡា។ ស្ត្រីទីបីក្នុងចំណោមទាំងបីនាក់ ស្ត្រីដែលត្រូវបានគេស្គាល់ច្បាស់ជាងគេគឺនាងម៉ារាជាអ្នកស្រុកម៉ាក់ដាឡា ជាអ្នកដែលព្រះយេស៊ូវបានបណ្ដេញអារក្សអាសោចចំនួនប្រាំពីរចេញ។ នាងជាស្ត្រីដែលត្រូវបានអត់ទោសច្រើន ក៏បានស្រឡាញ់ (ទ្រង់)ខ្លាំងដែរ។ ប្រាកដណាស់ការស្រឡាញ់អាណិតអាសូរត្រូវបានបង្ហាញឲ្យឃើញច្បាស់តាមរយៈសិស្សសំណព្វរបស់ព្រះយេស៊ូវនិងតាមរយៈពួកស្ត្រីដែលបានលើកទឹកចិត្ត ព្រះសង្គ្រោះនៃយើងឲ្យបន្តទ្រាំទ្រនឹងឈើឆ្កាង។ «តើអ្នកនៅទីនោះពេលគេដុំដែកគោលទ្រង់ជាប់ឈើឆ្កាង ... ពេល ខ្លះវាធ្វើឱ្យខ្ញុំស្លុតភ័យ ស្លុតភ័យ ស្លុតភ័យ...។

សេចក្ដីស្រឡាញ់ដ៏សប្បុរសរបស់នាងម៉ារាចំពោះព្រះអម្ចាស់ ជាបុត្ររបស់នាង រហូតដល់បំផុតរំឭកពីករណីយកិច្ចដ៏ស្មោះត្រង់ទៅវិញទៅមកមួយ។ ដោយមានសិស្សសំណព្វនៅក្បែរទ្រង់ ព្រះអង្គប្រទានកិត្តិយសដល់យ៉ូហានតាមរយៈការប្រទានមាតារបស់ទ្រង់នៅក្នុងការថែរក្សារបស់គាត់។ ឧទាហរណ៍ថាបើនាងម៉ារា និងសាវ័ក យ៉ូហានមិនបានមកវិញ? តើព្រះពរច្រើនប៉ុណ្ណាដែលយើងបានបាត់បង់ដោយសារតែមិនបានមកព្រះវិហារ មិន បានចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ មិនបានចូលរួមប្រជុំអធិស្ឋាន មិនបានចូលរួមការបោះជំរុំព្រះវិហារ ឬ សន្និបាត ជាទីកន្លែងព្រះអម្ចាស់នៃយើងមានព្រះវត្តមានប្រទានពរ។ ព្រោះ «ដ្បិតកន្លែងណាដែលមាន២ឬ៣នាក់ប្រជុំជាមួយគ្នាដោយនូវឈ្មោះខ្ញុំ នោះខ្ញុំក៏នៅកណ្ដាលចំណោមអ្នកទាំងនោះដែរ» ម៉ាថាយ ១៨:២០)។ ក៏ប៉ុន្តែលុះត្រាចូលរួមរបស់យើងគឺ ជម្រុញដោយសារសេចក្ដីស្រឡាញ់ដូចគ្នាដែលបណ្ដាលឱ្យសាវ័កយ៉ូហាននិងក្រុមស្ត្រីឈរនៅទៀបឈើឆ្កាងទេ ទើបកិច្ចបំរើរបស់យើងសម្រាប់ព្រះអម្ចាស់នឹងមិនក្លាយជាប្រយោជន៍។

អ្នកបម្រើជនជាតិចិនម្នាក់បានប្រាប់ពីដំណើររឿងរបស់នាងបានបម្រើការឲ្យថៅកែជាជនជាតិអឺរ៉ុបនៅភូមិគ្រឹះក្បែរមាត់សមុទ្ររបស់គាត់មួយនាជីវិតឯកកោចុងក្រោយរបស់គាត់។ ប៉ុន្តែ នៅពេលគាត់ស្លាប់ ទ្រព្យសម្បត្តិដែលនាងទទួលបានពីគាត់គឺជាទូរទស្សន៍មួយគ្រឿង។ សំណួរចោទសួរនៅក្នុងចិត្តរបស់ខ្ញុំគឺថា៖ បើនាងពិតជាបានបម្រើគាត់យ៉ាងយកចិត្តទុកដាក់ជាច្រើនឆ្នាំមុននេះ នាងនឹងមិនអាចទទួលបានរង្វាន់ជាផ្ទះ? របៀបយើងបម្រើព្រះអម្ចាស់នៃយើងគឺសំខាន់ណាស់។

ព្រះគ្រីស្ទជាចៅហ្វាយដ៏ល្អបំផុតដែលត្រូវបម្រើ។ ព្រោះទ្រង់ស្រឡាញ់អ្នកបម្រើរបស់ទ្រង់និងលើកដំកើងគេជាមិត្តរបស់ទ្រង់ពិតមែនហើយ ជាពួកទ្រង់ «នោះទ្រង់ក៏ចេះតែស្រឡាញ់គេដរាបដល់ចុងបំផុតជារបស់ទ្រង់» ។

**ការពិចារណា៖** តើខ្ញុំបម្រើព្រះយេស៊ូវដោយរបៀបណា?

**ការអធិស្ឋាន៖** សូមព្រះអម្ចាស់ជួយឲ្យយើងខ្ញុំបម្រើព្រះអង្គដោយសេចក្ដីស្រឡាញ់ផង។

ថ្ងៃទី ១០ សីហា
យ៉ូហាន ១៩:២៥-៤២ « ការស្រេច

**«វេទនាជាប់នាឈើឆ្កាង.. ព្រះបរមសពបានទទួលទីបញ្ចុះ»** (ជំនឿនៃក្រុមសាវ័ក)

ពាក្យពីគោលជំនឿនៃក្រុមសាវ័កនេះគឺផ្អែកលើនិយមន័យដំណឹងល្អរបស់សាវ័កប៉ុលក្នុង ១ កូរិនថូស ១៥:១-៤ «… គឺថាព្រះគ្រីស្ទបានសុគត ដោយព្រោះបាបរបស់យើងរាល់គ្នា តាមបទគម្ពីរ ថាទ្រង់ ត្រូវគេបញ្ចុះក្នុងផ្នូរ..» ។

សម្រាប់សាវ័កយ៉ូហាន គាត់ពិពណ៌នាក្នុងនាមជាសាក្សីពីទុក្ខវេទនាខាងផ្នែករូបកាយរបស់ព្រះអម្ចាស់នៃយើង ពីព្រះលោហិតរបស់ទ្រង់ហូរព្រិចៗ ទ្រង់ស្រេកទឹក។ ហើយពីដំណើរពេល ព្រះអង្គ បានសម្រាលពីការស្រេកទឹកដោយសារទឹកខ្មេះ ទ្រង់មានកំឡាំងដើម្បីស្រែកបន្លឺជ័យជំនះថា «ការស្រេចហើយ»(ខ ៣០) មុនពេលទ្រង់ឱនព្រះសិរប្រគល់វិញ្ញាណទ្រង់ទៅ។

ដូចជាការស្លាប់ដោយការប្រហារជីវិតត្រូវតែបញ្ជាក់បែបវិជ្ជសាស្ត្រតាមរដ្ឋបាលតុលាការសម័យទំនើប ការបញ្ជាក់បែបនោះក៏តម្រូវឱ្យធ្វើនៅក្រោមច្បាប់សាសន៍រ៉ូម៉ាំងដែរ។ នៅក្នុងករណីព្រះអម្ចាស់នៃយើង ការសុគតរបស់ទ្រង់ត្រូវយ៉ូហានភ្ជាប់នូវពាក្យសង្កត់ប្រាប់ថាឈាមនិងទឹកហូរបានចេញពីរបួសនៃចំហៀងរូបកាយទ្រង់។ ព្រឹត្តិការណ៍នោះបាននាំទៅការសម្រេចនូវបទទំនាយពីព្រះមែស៊ីចំនួនជាទ្វេរដង។

ទោះបីព្រះយេស៊ូវបានសុគតព្រោះតែគ្រាំគ្រាចិត្តឬយ៉ាងណាវាគ្រាន់ជាបញ្ហាដដែកវែកញែកគ្នាមួយតែប៉ុណ្ណោះ។ ការពិតបានកត់ត្រានៅក្នុងបទគម្ពីរគឺថាព្រះអង្គបានសុគត។ ទ្រង់បានសុគតជាលទ្ធផលពីទុក្ខវេទនានៃសេចក្តីស្លាប់ដ៏សែនឈឺចាប់លើឈើឆ្កាងជំនួសអំពើបាបរបស់យើង។ ការពិតនេះគឺសំខាន់ព្រោះបើទ្រង់មិនបានសុគតទេ ទណ្ឌកម្មរបស់យើងក៏មិនបានសងយ៉ាងពេញថ្លៃឡើយ។ សេចក្តីសង្គ្រោះរបស់យើងនឹងមិនបានគ្រប់លក្ខណៈដែរ។

ការពិតដែលទ្រង់បានសុគតប្រានចេញនូវការវាយប្រហារបែបខុសឆ្គង ដោយពួកសត្រូវនៃដំណឹងល្អ ៖ ទី ១. កំហុសឆ្គងពីបុរាណនាសតវត្សទីពីរហៅថា ដកស៊ីទីស (Docetists) ដែលបានប្រកាន់ជឿថាព្រះគ្រីស្ទឥតមានរូបអង្គពិតប្រាដ ឬក៏ព្រលឹងមនុស្សឡើយ។ ហេតុនេះពួកអ្នកបង្រៀនខុសឆ្គងទាំងនេះត្រូវបានហៅ ថាពួក ដកស៊ីទីស ពីកិរិយាសព្ទ័ភាសាក្រិចដែលមានន័យថា «លេចជា» ។ បើតាមពួកដកស៊ីទីស ជីវភាពបែប លោកីយរបស់ព្រះគ្រីស្ទគឺជាការការស្រមើស្រម័យមួយ។ ការបដិសេធន៍និស្ស័យជាមនុស្សត្រូវបានសាវ័កយ៉ូហានថ្កោលទោសនៅក្នុង ១ យ៉ូហាន ៤:១-៣។

ទី២. ការសុគតរបស់ព្រះគ្រីស្ទបដិសេធពួកអ្នកសម័យនិយមដែលហៅថាទ្រឹស្តីសន្លប់និយម។ ទ្រឹស្តីនេះបង្រៀនថាព្រះគ្រីស្ទមិនបានសុគតយ៉ាងពិតប្រាកដទេ តែគ្រាន់តែសន្លប់ប៉ុណ្ណោះ។ ក្នុងបរិយាកាសដ៏ត្រជាក់នៅក្នុងផ្នូរទ្រង់បានដឹងខ្លួនឡើងវិញ! (វចនានុក្រមព្រះគម្ពីរថ្មី «New Bible Dictionary»)។ ក៏ប៉ុន្តែភស្តុតាងពីសាវ័កសំណព្វគឺថាព្រះគ្រីស្ទពិតជាបានសុគតមែន។ ព្រោះឈាមនឹងទឹកហូរចេញពីចំហៀងនៃរូបកាយទ្រង់។ មនុស្សស្លាប់បានសន្លប់លើសជាងពីមួយរយដង!

ការបញ្ចុះសពព្រះយេស៊ូវគឺត្រូវបានសង្កត់ធ្ងន់ជាថ្មីម្តងទៀត ឈ្មោះមនុស្សជាអ្នកមានស្តុកស្តម្ភដែលបានចូលរួមត្រូវបានបរិយាយប្រាប់ សោភណ្ឌភាពទីកន្លែងក៏ត្រូវបានប្រាប់ ហើយវេលាក៏បានកត់ត្រាប្រាប់ដែរ។ តើធ្វើដូចម្តេចនឹងមានព្រឹត្តិការណ៍មានព្រះជន្មរស់ឡើងវិញ បើព្រះគ្រីស្ទឥតបានសុគតនិងបានបញ្ចុះ? ដូចនេះទើបកំណត់ត្រាពីការជាប់ឆ្កាង ការសុគត និងការបញ្ចុះរបស់ទ្រង់គឺត្រូវបានសូត្រនៅក្នុងជំនឿក្រុមនៃក្រុមសាវ័កសម្រាប់សេចក្តីសង្គ្រោះរបស់យើង។

តើអ្នកនៅទីនោះពេលគេបញ្ចុះសពទ្រង់ក្នុងផ្នូរ? ... ពេលខ្លះនាំឱ្យខ្ញុំភ័យញ័រ ភ័យញ័រ ភ័យញ័រ..» ។

**ការពិចារណា៖** គ្មានការសុគត គ្មានការរស់ឡើងវិញពីស្លាប់របស់ព្រះយេស៊ូវ។

**ការអធិស្ឋាន៖** ខ្ញុំជឿលើការសុគត ការបញ្ចុះសពទ្រង់ និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ដែរ។

**« ..លុះថ្ងៃទីបី ព្រះអង្គមានព្រះជន្មរស់ឡើងវិញ»** (ជំនឿនៃក្រុមសាវ័ក)

ភស្តុតាងពីការឆ្កាងការសុគតនិងការបញ្ចុះសពព្រះអម្ចាស់នៃយើង មានជាច្រើនដើម្បីធ្វើបន្ទាល់ប្រាប់ពីការមានព្រះជន្មរស់របស់ទ្រង់! ការអស្ចារ្យអំពីការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់គឺជាទីសម្គាល់មួយក្នុងបណ្ដា «ទីសំគាល់ជាច្រើនទៀតនៅចំពោះពួកសិស្សទ្រង់» ដែលព្រះយេស៊ូវធ្វើ ហើយបានចែងមក «ដើម្បីឲ្យអ្នករាល់គ្នាបានជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត ហើយឲ្យអ្នករាល់គ្នាបានជីវិតដោយសារព្រះនាមទ្រង់ ដោយមានសេចក្ដីជំនឿ» (យ៉ូហាន ២០:៣១)។

យ៉ូហានផ្ដល់នូវកំណត់ត្រាពិស្ដារអំពីការលេចដំបូងនៃព្រះយេស៊ូវគ្រីស្ទនាព្រឹកថ្ងៃអាទិត្យព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញដល់យើងជាងគ្រូផ្សាយដំណឹងល្អឯទៀតពីព្រោះគាត់ជាសិស្សម្នាក់ក្នុងចំណោមសិស្សពីរក្រុមដែលបានទៅទីកន្លែងផ្នូរទទេ។

សាវ័កយ៉ូហាននេះហើយជាអ្នករៀបរាប់ប្រាប់ពីទីបន្ទាល់របស់នាងម៉ារា-ម៉ាក់ដាឡាឡើងវិញ។ ទោះបីស្ត្រីឯទៀតដែលនៅជាមួយនាងម៉ារា-ម៉ាក់ដាឡានាឈើឆ្កាងក៏បានទៅដែរក៏ដោយ ក៏ក្រុមស្ត្រីទាំងនេះមិនត្រូវបានបរិយាយប្រាប់យ៉ាងដោយឡែកនៅក្នុងដំណឹងល្អយ៉ូហានលើកលែងតែនៅក្នុងស័ព្ទនាម «យើងខ្ញុំ» នៃយ៉ូហាន ២០:២ ប៉ុណ្ណោះ។ ខនេះសម្ដែងប្រាប់ផងដែរពីដំណើររត់យ៉ាង លឿន របស់យ៉ូហានជាមួយនឹងសាវ័កពេត្រុសទៅឯផ្នូរនិងពីការដែលទោះបើគាត់រត់បានលឿនជាងមនុស្សចាស់យ៉ាងណាក៏ដោយ គឺពេត្រុសទេជាអ្នកបានចូលទៅក្នុងផ្នូរដើម្បីពិនិត្យ «ទិដ្ឋភាព» (ក្នុងផ្នូរ)។

យ៉ូហានបន្ថែមលើកំណត់ត្រារបស់លោកលូកាអំពីការលេចឡើងនៃព្រះយេស៊ូវគ្រីស្ទដល់សាវ័កនាក់។ ថូម៉ាសដែលបានអវត្តមាន ហើយមានតែយ៉ូហានម្នាក់គត់ដែលបានប្រាប់បង្គ្រប់ពីការលេចឡើងនៃទ្រង់ដល់សាវ័កទាំងដប់មួយនាក់នាថ្ងៃព្រះអម្ចាស់បន្ទាប់ទៀត ដែលពេលនោះលោកថូម៉ាសមានវត្តមាន។ អាស្រ័យតាមការរាប់បញ្ចូលគ្នារបស់ជនជាតិជ្វីប (យូដា) ដូចជារបៀបជនជាតិចិនដែរ ដល់ប្រាំបីថ្ងៃក្រោយមកមានន័យថាប្រាំពីរថ្ងៃបន្ទាប់នៅក្នុងរបៀបរាប់របស់ជនជាតិអង់គ្លេស។

«សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត» (សាឡូម) ជាពាក្យគារវៈកិច្ចរបស់ ជនជាតិហេព្រើរដែលមានអត្ថន័យយ៉ាងជ្រាលជ្រៅនៅពេលព្រះសង្គ្រោះដ៏មានព្រះជន្មរស់ប្រើសម្រាប់បងប្អូនទ្រង់ (យ៉ូហាន ២០:១៧)។ ហើយនៅពេលពាក្យនេះត្រូវបានប្រើជាលើកទីពីរ (យ៉ូហាន ២០:២៦) វិធីប្រើនៃពាក្យនេះត្រូវបានបញ្ជាក់ដោយពួកជំនុំគ្រីស្ទបរិស័ទទាំងមូល! «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត» គឺរបៀបគារវៈកិច្ចថ្មីដែលក្រុមបេសកជនបំរើការនៅប្រទេសចិនសម័យមុនបានបង្រៀនដល់អ្នកបានកើតជាថ្មី (អ្នកជឿព្រះយេស៊ូវ)។ វាបានក្លាយទៅពាក្យសួរសុខទុក្ខរវាងគ្រីស្ទបរិស័ទក្នុងពាក្យនិយាយនិងសរសេរឆ្លងឆ្លើយគ្នា។ នៅក្នុងបណ្ដាប្រទេសដែលបានពិសោធន៍នូវសន្តិភាពបន្តិចបន្តួច ជាពិសេសប្រទេសចិនដែលតែងជួបនឹងភាពជ្រួលច្របល់នៃការធ្វើបដិវត្តន៍។ ពេលពោលពាក្យ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត» ជាគារវកិច្ចវាបាននាំមកនូវភាពកក់ក្ដៅនិងក្ដីសង្ឃឹមហើយនឹងក្ដី

អំណររីករាយពីព្រះអង្គដែលបានឈ្នះលើសេចក្តីស្លាប់និងបានរស់ឡើងវិញយ៉ាងជោគជ័យពីផ្នូរ។ មិត្តអ្នកអានអើយ សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត ទោះបីលោកអ្នកមានបញ្ហាអ្វីក៏ដោយចុះ! នាថ្ងៃព្រះអម្ចាស់ សូមកុំអាក់ខានជួបព្រះសង្គ្រោះដ៏មានព្រះជន្មរស់ជាមួយនឹងបងប្អូនប្រុសស្រីរបស់អ្នកនៅក្នុងព្រះវិហារ!

**ការពិចារណា៖** *សាឡូម!*
**ការអធិស្ឋាន៖** សូមឲ្យសេចក្តីសុខសាន្តរបស់កើតមានឡើងក្នុងរង្វង់យើងខ្ញុំផង។

យ៉ូហាន ២០:១,២, ១១-១៦ *«...ដើម្បីនឹងបណ្ដាលឲ្យមានសេចក្ដីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អ*

## ហេតុអ្វីទៅជានាងម៉ារាម៉ាក់ដាឡាមុនគេ?

មានសាវ័កពីរក្រុមធ្វើដំណើរសំដៅទៅរកឈាបនដ្ឋាន (*the Garden Tomb*) ក្នុងពេលតែមួយដូចគ្នានាថ្ងៃដំបូងនៃការមានព្រះជន្មរស់ឡើងវិញនៅព្រឹកថ្ងៃព្រះអម្ចាស់ គឺៈ (១) ក្រុមស្ត្រី ដឹកនាំដោយនាងម៉ារា-ម៉ាក់ដាឡា (២) ក្រុមពេត្រុសនិងយ៉ូហាន។ ហេតុតែគ្មានចំណេះដឹងពីបទគម្ពីរថាយេស៊ូវត្រូវមានព្រះជន្មរស់ឡើងវិញ (ទំនុក.១៦:១០) ទើបក្រុមស្ត្រីនេះយកគ្រឿងក្រអូបនឹងប្រេងអប់(លូកា ២៣:៥៦) ជាការសម្ដែងនូវក្ដីស្រឡាញ់នៃភាពជាស្ត្រីរបស់ពួកគាត់។ ពេត្រុសនិងយ៉ូហានប្រាកដជាមិនបានធ្វើដូច្នោះឡើយ។

ចំពោះពួកសិស្សដែលមកមើលព្រះយេស៊ូវ គឺនាងម៉ារា-ម៉ាក់ដាឡាជាសិស្សដែលព្រះអម្ចាស់នៃយើងប្រទានកិត្តិយសឲ្យបានឃើញនូវការលេចឡើងដំបូងរបស់ទ្រង់។ ហេតុអ្វី? តើហេតុអ្វីបានជាមនុស្សមានបាបដ៏អាក្រក់ម្នាក់ ដែលមានអារក្ស៧ ចេញពីនាង (លូកា ៨:២) គួរទទួលនូវព្រះពរបែបនេះ? នេះហើយគឺជាការសម្ដែងនូវព្រះគុណនៃព្រះជាម្ចាស់ដ៏ពុំអាចថ្លែងបាន! ដូចជាបទសរសើរខ្លីៗច្រៀងថាៈ «ទ្រង់អត់ទោសបាបពីអតីតធំ ខ្ញុំមានសេរី!» នាងជំពាក់ព្រះអម្ចាស់របស់នាងចំនួនប្រាំពីរផ្នែក សេចក្ដីស្រឡាញ់តបស្នងទៅវិញរបស់នាងចំពោះព្រះយេស៊ូវច្រើនអនេកជាងអ្នកឯដទៃទៀតទាំងអស់។ ក្នុងបណ្ដាពួកសិស្សរបស់ព្រះអម្ចាស់នៃយើងទាំងអស់ ហាក់ដូចជាគ្មានអ្នកម្នាក់ សូម្បីសាវ័កយ៉ូហាន មានសេចក្ដីស្រឡាញ់ចំពោះព្រះយេស៊ូវច្រើនដូចជានាង ម៉ារា-ម៉ាក់ដាឡាឡើយ។ លោកប៊ីហ្សប អនទ្រេ ផ្ដល់ចំណាប់អារម្មណ៍ថា «នាងនៅទៀបឈើឆ្កាងរបស់ទ្រង់ក្រោយគេ ហើយ (នាង) នៅផ្នូររបស់ទ្រង់មុនគេ។ នាងបាននៅទីនោះយូរជាងគេបង្អស់ ហើយឆាប់មក (កន្លែងបញ្ចុះព្រះសព)លឿនជាងគេបង្អស់ដែរ។

ស្ដេចសាឡូម៉ូនថ្លែងថា «ដ្បិតសេចក្ដីស្រឡាញ់មានកំឡាំងដូចជាសេចក្ដីស្លាប់» (បទចំរៀងនៃសាឡូម៉ូន ៨:៦)។ សេចក្ដីស្រឡាញ់គឺជាអំណាចនៃការជម្រុញទឹកចិត្តដ៏ចម្បង! សេចក្ដីស្រឡាញ់ក៏ជាអំណាចនៃការគាំទ្រដែរ។ សេចក្ដីស្រឡាញ់គឺជាអំណាចនៃព្រះជាម្ចាស់ ពីព្រោះព្រះទ្រង់ជាសេចក្ដីស្រឡាញ់ (១ យ៉ូហាន ៤:៨)។ ដូច្នេះនៅពេលបានឃើញថាផ្នូរនៅទទេ ពួកអ្នកដែលមកជាមួយនាងម៉ារាបានចាកចេញពីកន្លែងនោះម្ដងម្នាក់ៗ។ ដំណើរបោះជំហានរបស់នាងម៉ារា-ម៉ាក់ដាឡាជាស់ដែលជម្រុញដោយក្ដីស្រឡាញ់នៅពេលនេះសេចក្ដីដដែលក៏បណ្ដាលឲ្យនាងនៅទីនោះយូរជាងគេដែរ។ ប្រដូចជាថា «ព្រះអម្ចាស់អើយ ខ្ញុំម្ចាស់នឹងមិនចាកចេញពីទ្រង់ទេ គឺនៅជាមួយនឹងទ្រង់ជានិច្ច»។ ភក្ដីភាពនិងការស្វែងរកដ៏សង្វាតបែបនោះគឺជាសេចក្ដីដែលពួកជំនុំមិនក្ដៅមិនត្រជាក់ក្រុងឡៅឌីសេសព្វថ្ងៃនេះកំពុងខ្វះខាត។ អ្វីដែលយើងត្រូវការគឺជាសេចក្ដីស្រឡាញ់នៃនាងម៉ារា គឺដូចជាសេចក្ដីស្រឡាញ់ដំបូងរបស់ពួកជំនុំក្រុងអេភេសូរដែរ។

នៅក្នុងសាកលវិទ្យាល័យរបស់ព្រះគ្រីស្ទ ចំណេះដឹងឃើញថាជារឿយៗអួតអាង តែសេចក្ដីស្រឡាញ់វិញមិនចេះអួតអាងហើយទទួលសញ្ញាប័ត្រពីព្រះគ្រីស្ទ។ តើហេតុអ្វីមិនលេចទៅនាងម៉ារា-ម៉ាក់ដាឡាមុនគេ? «ហើយត្រូវឲ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្ដាលឲ្យមានសេចក្ដីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អផង» (ហេព្រើរ ១០:២៤)។

**ការពិចារណា៖** ទង្វើគឺជាសាក្ខីភាពនៃសេចក្ដីស្រឡាញ់។

**ការអធិស្ឋាន៖** សូមឲ្យសេចក្ដីស្រឡាញ់របស់យើងខ្ញុំនៅថ្មីចំពោះទ្រង់ផង ឱព្រះអម្ចាស់អើយ។

ថ្ងៃទី ១៣ សីហា
យ៉ូហាន ២០:២-១០ « ..កាលណាអ្នកបានប្រែចិត្តវិលមកវិញ នោះចូរចំរើនឲ្យបងប្អូនអ្នកបានខ្ជាប់ខ្លួន

## សាវ័កពេត្រុសនិងសាវ័កយ៉ូហាន

បើនាងម៉ារា-ម៉ាកដាឡាត្រូវទទួលបានការកោតសរសើរសម្រាប់សេចក្ដីស្រឡាញ់ប្រាំពីរដងរបស់នាងចំពោះព្រះយេស៊ូវ សាវ័កពេត្រុសក៏ត្រូវតែទទួលបាននូវការកោតសរសើរសម្រាប់ភាពស្មោះត្រង់ដ៏ជ្រាលជ្រៅចំពោះព្រះរាជគ្រូរបស់គាត់ដែរ។ ថ្វីដ្បិតបើគាត់បានក្បត់ទ្រង់ខណៈពេលកំសោយ ជាពេលស្ថិតវេងសម្ពាធដ៏ធ្ងន់ធ្ងរ ទឹកភ្នែកហូរជោគជាំនៃការប្រែចិត្តរបស់គាត់បានលាងសម្អាតចេញនូវរាល់ស្នាមប្រឡាក់ដែលហាក់ដូចជាការគ្មានភក្ដី។ ដំណើរដែលព្រះអម្ចាស់នៃយើងទតមើលទៅរូបគាត់បានរំឭកពីពាក្យព្រមានដោយក្ដីស្រឡាញ់និងការយកព្រះទ័យទុកដាក់របស់ទ្រង់កាលពីមួយរយៈកាលមុន៖ «ស៊ីម៉ូនៗអើយ មើល សាតាំងបានសូមចង់បានអ្នករាល់គ្នា ប្រយោជន៍នឹងរែងអ្នករាល់គ្នាដូចជារែងអង្ករ ប៉ុន្តែខ្ញុំបានអធិស្ឋានឲ្យអ្នក ដើម្បីមិនឲ្យសេចក្ដីជំនឿរបស់អ្នកវិនាសបាត់ឡើយ កាលណាអ្នកបានប្រែចិត្តវិលមកវិញ នោះចូរចំរើនឲ្យបងប្អូនអ្នកបានខ្ជាប់ខ្លួនឡើង» (លូកា ២២:៣១-៣២)។

ហេតុនោះទើបពេត្រុសនៅពីខាងក្រោយវត្តមានសិស្សដទៃនាព្រឹកព្រលឹមព្រះយេស៊ូវមានព្រះ ជន្មរស់ដំបូងបញ្ជាក់យ៉ាងច្បាស់អំពីចិត្តគំនិតដែលបានស្ដារឡើងវិញ។ គាត់អាចនឹងបានស្បថស្រឡាញ់ព្រះគ្រីស្ទឲ្យបានច្រើនជាងបីដងទៀត! នៅក្នុងការស្ដារឡើងវិញរបស់ពេត្រុសគឺផ្ទុយពីយូដាសជាអ្នកដែលបានតម្រូវឲ្យត្រូវវិនាស។ តើធ្វើដូចម្ដេចយើងដឹងថាយូដាជាអ្នកបាត់បង់? ការបំផ្លាញខ្លួនឯងគឺសាក្ខីភាពបញ្ជាក់ពីការនោះ។ ក៏ប៉ុន្តែមិនមែនករណីពេត្រុសទេ! គ្រីស្ទបរិស័ទអើយ ទោះជាបាបអ្វីរបស់អ្នកក៏ដោយ ឬទោះបីជាការបរាជ័យអ្វីរបស់អ្នកក៏ដោយ សូមកុំនិយាយថាចប់សោះឡើយ គឺត្រូវធ្វើដូចជាពេត្រុសវិញ។ ចូរប្រែចិត្តហើយត្រឡប់មកវិញ ព្រោះព្រះអម្ចាស់ទ្រង់នៅតែយុត្តិធ៌ម ដែលពេលនេះទ្រង់កំពុងទតមើលមកកាន់រូបអ្នក។

ហេតុតែយ៉ូហានជាសិស្សសំណព្វចាប់តាំងពីដំបូងរហូតដល់ចុងបំផុត គាត់ត្រូវបានទទួលនូវការកោតសរសើរមិនត្រឹមតែសម្រាប់ការថែរក្សាមាតារបស់ព្រះអម្ចាស់ទេ តែក៏សម្រាប់ការយកចិត្តទុកដាក់ចំពោះបងប្រុសធំរបស់គាត់ផងដែរ។ ប្រាកដណាស់ គាត់គឺជាអ្នកថែរក្សាពេត្រុស ហើយនិយាយប្រាប់ពួកសិស្សពីទីកន្លែងពួកគេបានបញ្ចុះសពទ្រង់។ តើនឹងអាចជាអ្នកណា? គាត់គឺជាអ្នកបានដឹងពីនាងម៉ារាជាការជួបជាលក្ខណៈផ្ទាល់ខ្លួនរវាងនាងនឹងព្រះសង្គ្រោះដ៏មានជន្មរស់។

ចរិករបស់សិស្សប្រុសទាំងពីរនាក់ជាថ្មីម្ដងទៀតបើកសម្ដែងឲ្យឃើញពីលក្ខណៈផ្ទាល់ខ្លួន របស់គេរៀងៗខ្លួន។ ពេត្រុសជាមនុស្សធ្វើការតាមចិត្តរបស់ខ្លួនឯង ទោះបីរត់យឺតជាងយ៉ូហានដែលមនុស្សវ័យក្មេងជាងគាត់ ក៏គាត់នៅបន្តចូលទៅខាងក្នុងផ្នូរដែរ។ ក៏ប៉ុន្តែ យ៉ូហានបានសម្លឹងទៅខាងក្នុង ហើយជញ្ជឹងគិតប៉ុណ្ណោះ។ ការសំខាន់គឺទាំងពីរនាក់បានជឿថាព្រះគ្រីស្ទបានរស់ឡើងវិញ ហើយភស្តុតាងដ៏អស្ចារ្យពីការពិតនេះចំពោះពួកគេគឺជាផ្នូរទទេរជាមួយនឹងសំពត់ស្នបនិងកន្សែងដែលគ្របព្រះសិរទ្រង់នៅត្រង់កន្លែងដាក់ព្រះសពទ្រង់។ យ៉ាងហោចណាស់នោះគឺជាទីបន្ទាល់របស់យ៉ូហាន (យ៉ូហាន ២០:៨)។ បច្ចុប្បន្ន ព្រះជាម្ចាស់មានសិស្សដូចជាពេត្រុសនិងយ៉ូហាន អ្នកនិមួយៗមានចរិកលក្ខណៈដោយឡែកពីគ្នា ខ្លះលឿន ខ្លះ

ទៀតឃើត។ ការសំខាន់គឺថាយើងជឿលើព្រះបុត្រាដ៏មានព្រះជន្មរស់របស់ទ្រង់ ហើយស្រឡាញ់ទ្រង់ទោះបីយើងមិនបានឃើញព្រះអង្គ។

នេះគឺជារាជសារថ្ងៃព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញរបស់ពេត្រុស៖ «ដែលអ្នករាល់គ្នា មិនបានឃើញទ្រង់ទេ តែបានស្រឡាញ់ទ្រង់ ហើយទោះបើនៅជាន់ឥឡូវនេះ អ្នករាល់គ្នានៅតែមិនឃើញ ទ្រង់ទៀត គង់តែមានចិត្តជឿដែរ ហើយក៏ត្រេកអរសោទរក្នុងទ្រង់ ដោយសេចក្ដីអំណរ ដ៏ប្រសើរដែលរកថ្លែងមិនបាន» (១ ពេត្រុស ១:៨)។

**ការពិចារណា៖** ភក្ដីភាព ចំពោះបងប្អូនរួមជំនឿ គឺជាផលផ្លែនៃភក្ដីភាពចំពោះព្រះជាម្ចាស់។

**ការអធិស្ឋាន៖** ឪសូមឲ្យសេចក្ដីស្រឡាញ់របស់ខ្ញុំចំពោះព្រះយេស៊ូវជាដរាបផង។

ថ្ងៃទី ១៤ សីហា
យ៉ូហាន ២០:១១-១៦

*« នាងអើយ ហេតុអ្វីបានជាយំ»*

## មិនមែនតាមរយៈទស្សនៈនៃទេវសាស្ត្រទេ តែតាមរយៈទឹកភ្នែកនៃក្ដីស្រឡាញ់វិញ

អ្នកអត្ថាធិប្បាយខ្លះអង្កេតមើលលក្ខណៈស្រពិចស្រពិលក្នុងចិត្តអំពីនាងម៉ារា-ម៉ាក់ដាឡាតាមរយៈទស្សនៈនៃទេវសាស្ត្រដុះស្នឹមរបស់គេ តែពួកគេមិនធ្លាប់មានកិត្តិយសនៃការជួបផ្ទាល់ជាមួយនឹងព្រះសង្គ្រោះដ៏មានព្រះជន្មឡើយ។ ពួកគេពោលពាក្យគ្រោតគ្រាតអំពីភាពអវិជ្ជានិងជំនឿស៊ប់ជ្រុលរបស់នាងម៉ារា ដែលយើងមិនយល់ស្របតាម។

វាគឺដោយតាមរយៈទឹកភ្នែករបស់នាងម៉ារាដែលបណ្ដាលឲ្យព្រះសង្គ្រោះដ៏មានព្រះជន្មរស់យាងមកក្បែរនាង។ វាគឺក៏ដោយតាមរយៈទំនួញយំចេញពីការទទួចចង់បាននិងចិត្តស្រឡាញ់របស់នាងផងដែរដែលនាំឲ្យព្រះអម្ចាស់នៃយើងបញ្ជូនទេវតាមក។ បើតាមការអត្ថាធិប្បាយរបស់បណ្ឌិតកាល់វិន នៅពេលវាជាការពិតដែលថាព្រះគ្រីស្ទបានចាប់ផ្ដើមសិរីរុងរឿងនៃនគររបស់ទ្រង់តាមរយៈទេវតាមកជំកើងផ្នូរទ្រង់ហើយដកនូវក្ដីអាម៉ាស់នៃឈើឆ្កាងចេញ យើងជឿថាទេវតាត្រូវបានបញ្ជូនមកដោយយល់នាងម៉ាថា។ ទឹកភ្នែកនៃក្ដីស្រឡាញ់របស់នាងម៉ារា។

ឃ្លា *« នាងអើយ ហេតុអ្វីបានជាយំ»* (ខ ១៣) មិនមែនសំណួរក្នុងការដាស់តឿនទេ តែក្នុងការអាណិតអាសូរវិញ។ បើស្ដាប់កាសែតថតពាក្យទាំងនេះនោះនឹងឮសំឡេងបញ្ជាក់យ៉ាងច្បាស់មិនខានឡើយ! នៅពេលព្រះយេស៊ូវគង់ឈររយៈពេលដ៏ខ្លីពីក្រោយខ្នងនាងហើយសួរសំណួរដដែល ព្រមទាំងបានសួរបន្ថែមថា «នាងរកអ្នកណា?» (ខ ១៥) ពាក្យនោះគឺជាពាក្យនៃក្ដីស្រឡាញ់របស់អ្នកគង្វាលឆ្លើយតបដល់កូនចៀមដែលបានវង្វេងផ្លូវ។ យើងក៏មិនអាចស្ដីបន្ទោសដល់នាងម៉ារានៅពេលនាងស្ថិតក្នុងអារម្មណ៍ងោកងុយចង់អប់ព្រះអម្ចាស់ដោយគ្រឿងក្រអូបដែលនាងបានយកមកបានដែរ។ ឱកាសកម្សរបស់យើងគឺជាឱកាសល្អរបស់ព្រះជាម្ចាស់។

ដោយតាមរយៈស្នាមប្រឡាក់ទឹកភ្នែកនេះហើយដែលព្រះយេស៊ូវបានសម្ដែងអង្គទ្រង់ដល់នាងម៉ារា ហៅនាងដោយការសង្កត់សម្លេងនៃក្ដីស្រឡាញ់នោះហើយ ទើបនាងបានឮពាក្យ «ម៉ារា (ម៉ារាមនៅក្នុងភាសាហេព្រើរ) ម៉ារាអើយ! ហេតុអ្វី? នោះជាសម្លេងព្រះរាជគ្រូ! «រ៉ាបូនី» បណ្ដាលឲ្យភ្នែករបស់នាងបើកឡើងភ្លាមមួយរំពេច។ ការលេចឡើងជាលើកទី១ដល់ពួកសិស្សបានកើតឡើង!

*ពេលរួមជាសម្លេងឆ្លងតែមួយ*
*ជួយឲ្យភ្នែកនាងឃើញព្រះភក្ត្រ័ទ្រង់!*

វាជាចាំបាច់បំផុតដែលព្រះបន្ទូលនៃព្រះត្រូវបានសិក្សាដោយការសង្ឃឹមចង់បាននិងប្រកបដោយក្ដីស្រឡាញ់។ និម្មិតនៃសេចក្ដីស្រឡាញ់ សេចក្ដីអាណិតអាសូរ ព្រះចេស្ដាអនុភាពដ៏អស្ចារ្យជាច្រើនត្រូវបានបាត់បង់នៅពេលពួកសាស្ត្រាចារ្យរកដើមឈើតែរកឈើមិនឃើញ។ ចំណុចក្បៀសនិងចុចដ៏តូចក្នុងភាសាក្រិចនិងហេព្រើរចង្អុលបញ្ជាក់ពីចំណុចលម្អិតតូចៗយ៉ាងជាក់ច្បាស់ តែគ្មាននិម្មិតឡើយ! ហេតុដែលព្រះ

យេស៊ូវលេចមកឯនាងម៉ារា-ម៉ាក់ដាឡា តែទ្រង់មិនលេចមកលោកគ្រូគង្វាលពេត្រុស ឬ លោកចាស់ទុំយ៉ូហាន គឺជាមេរៀនមួយសម្រាប់អ្នកដឹកនាំពួកជំនុំត្រូវតែចាប់អារម្មណ៍។

ផ្ទុយទៅវិញ សូមឲ្យអ្នកគ្មានអំណាចឬទ្រព្យសម្បត្តិ ហើយមានតែសេចក្តីស្រឡាញ់ចិញ្ចឹមទុកក្នុងចិត្តរក្សាសម្រាប់ព្រះអម្ចាស់របស់គាត់ឬរបស់នាងក្លាហានជាមួយនឹងនាងម៉ារាចុះ។ មិនមែនតាមរយៈទស្សនៈនៃទេវសាស្ត្រទេ តែតាមរយៈទឹកភ្នែកនៃក្តីស្រឡាញ់វិញ។

**ការពិចារណា៖** បើគ្មានវែនតានៃសេចក្តីជំនឿគ្មានអ្នកណាអាចឃើញព្រះបានឡើយ។

**ការអធិស្ឋាន៖** សូមទ្រង់បើកភ្នែកនៃសេចក្តីជំនឿឲ្យយើងខ្ញុំបានឃើញព្រះអម្ចាស់យេស៊ូវផង។

ថ្ងៃទី ១៥ សីហា
យ៉ូហាន ២០:១៧-១៨

«...នាងបានឃើញព្រះអម្ចាស់ ហើយទ្រង់បានមានបន្ទូលសេចក្ដីទាំងនេះមកនាង» ។

## តាមរយៈទឹកភ្នែកនៃក្ដីស្រឡាញ់និងក្ដីអំណរ

នៅពេលដែលនាងម៉ារាបានឃើញព្រះអម្ចាស់របស់នាងមានព្រះជន្មរស់និងបានបំផ្លាស់ប្រែរូបកាយនៅក្នុងសិរីរុងរឿងនៃការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ប្រតិកម្មដំបូងរបស់នាងគឺការឱបព្រះបាទថ្វាយទ្រង់(សូមមើល ម៉ាថាយ ២៨:៩)។ នៅក្នុងហេតុការណ៍នេះ ព្រះអង្គបានបោះជំហានថយក្រោយ៖ «កុំពាល់ខ្ញុំ» (ឬ «កុំមកជិតខ្ញុំអី» ជាឃ្លាស៊ីម៉ូនជាគណៈផារីស៊ីប្រើនៅពេលគាត់បានឃើញនាងជាស្ត្រីមានបាប កំពុងថើបព្រះបាទដោយស្រឡាញ់នាគុបរិភោគអាហារ ហើយបានជំទាស់ថាទ្រង់ជាហោរា ទ្រង់ប្រាកដជាជ្រាបដឹងថានាងជាស្ត្រីបែបណាហើយដែលកំពុង «ពាល់» ទ្រង់ លូកា ៧:៣៩។ (ដេវីឌ ស្មីត)។

បើតាមសាវ័កម៉ាថាយ ឥឡូវនេះហេតុតែទ្រង់បានអនុញ្ញាតឲ្យពួកសិស្សរបស់ព្រះអង្គប៉ះទ្រង់(សូមមើល យ៉ូហាន ២០:៣៧) តើសំអាងលើអ្វីបានជាទ្រង់ថយចេញមិនឲ្យនាងបានធ្វើដូច្នោះដែរ? លោកកាល់វិន មានប្រសាសន៍ថា ចម្លើយគឺងាយស្រួលរកទេដរាបណាយើងយល់ស្ត្រីគឺមិនបានប្រានចេញពីការពាល់ព្រះគ្រីស្ទព្រោះតែពួកគេប៉ះពាល់ទ្រង់ច្រើនហួសពេក។ ហើយដរាបណាទុកជាការដេកក្ដីមន្ទិលសង្ស័យចេញ ទ្រង់ប្រាកដជាមិនហាមពួកគេពាល់ទ្រង់ទេ តែនៅពេលទ្រង់ទតឃើញពួកគេរវល់ជាមួយនឹងការឱបព្រះបាទទ្រង់ពេក ទ្រង់ខ្វាល់ហើយកែតម្រូវភាពឧស្សាហ៍ដោយឥតពិចារណារបស់ពួកគេ ដែលហាក់ដូចជាការសម្ដែងថាវាជាបំណងរបស់គេដើម្បីរក្សាទ្រង់ទុកនៅក្នុងពិភពលោក។

នៅក្នុងពាក្យ «ព្រោះខ្ញុំមិនទាន់ឡើងទៅឯព្រះវរបិតាខ្ញុំនៅឡើយ»។ ព្រះគ្រីស្ទបានបង្ហាញពីគោលបំណងនៃការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់។ វាមិនដូចជាអ្វីដែលគេធ្លាប់បានគិតនោះទេថាពេលព្រះអង្គមានព្រះជន្មឡើងវិញ ទ្រង់នឹងមានព្រះជន្មរស់នៅជាមួយពួកគេដូចជាគ្រាមុន ប៉ុន្តែការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់នឹងនាំទ្រង់ទៅរកការយាងឡើងទៅស្ថានសួគ៌របស់ទ្រង់វិញ។ ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់បានយកទ្រង់ទៅរកទីដ៏សំខាន់ថ្មីមួយដែលពីទីនោះទ្រង់នឹងគង់នៅជាមួយរាស្ត្ររបស់ទ្រង់ដោយសារព្រះវិញ្ញាណបរិសុទ្ធជាអង្គបុគ្គលដែលព្រះវរបិតានឹងបញ្ជូនមក។

បន្ទាប់ពីបានយល់ពីសេចក្ដីពិតនៃទំនាក់ទំនងថ្មីនេះរវាងសាវ័កនឹងព្រះរាជគ្រូ នាងម៉ារា-ម៉ាកដាឡាទទួលបង្គាប់ឲ្យទៅប្រាប់ «ពួកបងប្អូន» ដោយទឹកភ្នែកនៃក្ដីអំណរ។ ទំនាក់ទំនងដ៏អស្ចារ្យអ្វីម្ល៉េះទេរវាងយើងនឹងព្រះអម្ចាស់នៃយើងរាល់គ្នា! ព្រះអង្គគឺមិនត្រឹមជាព្រះសង្គ្រោះដែលប្រោសយើងពីបាបរបស់យើងប៉ុណ្ណោះទេ តែជាព្រះអម្ចាស់ដែលយាងឡើងទៅស្ថានសួគ៌ពីទីកន្លែងទ្រង់គ្រប់គ្រង លោកីយនាបច្ចុប្បន្ន គង់នៅខាងឯព្រះហស្តស្តាំនៃព្រះវរបិតាទៀតផងដែរ។ «គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ហើយលើផែនដីផង» ជាមួយនឹងការយាងឡើងទៅស្ថានសួគ៌របស់ទ្រង់។ ហើយព្រោះតែព្រះគ្រីស្ទបានយាងឡើងទៅស្ថានដ៏ខ្ពស់ទើបទ្រង់ទទួលតួនាទីដ៏ប្រសើរនិងឮហើយស្តាប់ការអធិស្ឋាននៃកូនទាំងឡាយរបស់ទ្រង់ដ៏មានប្រសិទ្ធិភាព។ ជាមួយនឹងសេចក្ដីអំណរចូរយើងចេញទៅក្រៅធ្វើទីបន្ទាល់ថ្វាយព្រះដ៏មានព្រះជន្មរស់និងព្រះសង្គ្រោះដែលបានយាងឡើងទៅស្ថានសួគ៌ ជាកន្លែងទ្រង់នឹងយាងមកឆាប់ៗដើម្បីជំនុំជំរះលោកីយ។

**ការពិចារណា៖** អំណរតែងមានក្នុងព្រះវត្តមាននៃព្រះ។

**ការអធិស្ឋាន៖** សូមឲ្យយើងខ្ញុំមានចិត្តក្លាហានថ្លែងប្រាប់ពីក្ដីអំណរនៃសេចក្ដីសង្គ្រោះ។

ថ្ងៃទី ១៦ សីហា
យ៉ូហាន ២០:១៩-២៣

*«សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខចុះ!»*

## ល្ងាចដំបូងនៃថ្ងៃព្រះអម្ចាស់ជាមួយនឹងព្រះអម្ចាស់ដ៏មានព្រះជន្មរស់

អត្ថបទនេះជាចាំបាច់ត្រូវតែអានរួមគ្នានឹងលូកា ២៤:១៣-៤៥។ ព្រះសង្គ្រោះដ៏មានព្រះជន្មរស់ជាដំបូងបានសម្ដែងអង្គទ្រង់ដល់នាងម៉ារា-ម៉ាកដាឡា (យ៉ូហាន ២០:១៤-១៨)ទីពីរដល់ក្រុមស្ដ្រីដែលធ្វើដំណើរត្រឡប់ពីផ្នូរជាមួយនឹងរាជសាររបស់ទេវតា (ម៉ាថាយ ២៨:៨-១៩)ទីបីដល់សាវ័កពេត្រុស (លូកា ២៤:៣៤) ទីបួនដល់សិស្សដែលធ្វើដំណើរលើដងផ្លូវអេម៉ោសនាជិតពេលយប់ (លូកា ២៤:១៣-៣១)។ នេះគឺជាការលេចឡើងរបស់ទ្រង់លើកទីប្រាំ។ ឱពិតជាក្ដីអំណរបន្ថែមលើក្ដីអំណរមួយទៀតមែន!

តាមរយៈកំណត់ត្រារបស់លូកានិងយ៉ូហានយើងឃើញថាពួកសិស្សបានប្រជុំគ្នានៅក្នុងបន្ទប់សម្ងាត់ដោយដាក់គន្លឹះទ្វារ។ មានដំណឹងរៀបរាប់ប្រាប់របស់នាងម៉ារា-ម៉ាកដាឡានិងរបស់ស្ដ្រីឯទៀតពីការលេចឡើងរបស់ព្រះគ្រីស្ទពីនាព្រឹកព្រលឹមនៃថ្ងៃដដែលនោះ។ ពេត្រុសបានប្រាប់ពីបទពិសោធន៍ដែលព្រះអម្ចាស់បានយាងមកដើម្បីបញ្ជាក់រូបគាត់អំពីការអត់ទោសបាប។ ក្រោយមកមានសិស្សពីរនាក់រត់ប្រាំពីរឬប្រាំបីម៉ៃ (ប្រហែលជាង ១២ គ.ម)ត្រឡប់ពីដងផ្លូវអេម៉ោសរហើយរ៉ាយរ៉ាប់ប្រាប់ពីមិត្តរួមដំណើររបស់ពួកគេ។ នៅក្នុងទំហំនៃសេចក្ដីអំណរពាក្យសម្ដីនិងភ្នែកបើកធំៗ រំពេចភ្លាមនោះព្រះយេស៊ូវបានឈរនៅក្នុងចំណោមពួកគេហើយសួរសុខទុក្ខដល់ពួកថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខចុះ!» (ខ ១៩)។ លោកលូកា បរិយាយប្រាប់យើងថាពួកសិស្សបានភ័យញ័រ ទាំងមានសេចក្ដីស្ញែងខ្លាចជាខ្លាំង ដោយស្មានថាជាខ្មោចលង។ ដើម្បីបង្ហាញភស្តុតាងពីអង្គទ្រង់ផ្ទាល់ ព្រះយេស៊ូវបានបង្ហាញព្រះហស្តនិងព្រះបាទឲ្យពួកគេស្ទាប ខណៈពេលទ្រង់សោយត្រីអាំងមួយដុំនិងសំណុំទឹកឃ្មុំសម្រាប់បង្កើនពីក្ដីទំនុកចិត្តរបស់ទ្រង់។ សាវ័កយ៉ូហានជាអ្នកបានឃើញព្រះលោហិតនិងទឹកហូរចេញពីចំហៀងនៃទ្រង់បន្ថែមថាព្រះយេស៊ូវក៏បានបង្ហាញចំហៀងរបស់ទ្រង់ផងដែរ។ ការនេះបាននាំមកនូវក្ដីអំណរក្នុងចិត្តពួកសិស្សដែលតែងតែសង្ស័យ។

កិច្ចការដ៏ចាំបាច់ជាងពីការបញ្ជាក់ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ (ដែលឥឡូវនេះគឺបានបញ្ជាក់ច្បាស់) គឺមហាបេសកកម្មដើម្បីបញ្ជូនពួកគេជាមួយនឹងព្រះរាជសារនៃសេចក្ដីសង្គ្រោះទៅទូទាំងពិភពលោក។ ព្រះអង្គក៏បានប្រទានព្រះវិញ្ញាណបរិសុទ្ធនិងអំណាចដើម្បីអត់ទោសបាបដែរ។ អំណាចដើម្បីអត់ទោសបាបគឺមិនមែនប្រទានទៅឲ្យពួកសង្ឃឬសម្ដេចសង្ឃនោះទេ តែនៅក្នុងការប្រកាសដំណឹងល្អ ជាពេលព្រះវិញ្ញាណបរិសុទ្ធប្រទានពរលើការប្រកាសដំណឹងនោះវិញ។ វាមិនមែនខាងការប្រតិបត្តិ តែជាពន្ធ័កិច្ចនៃការប្រកាសប្រាប់។ ហើយពន្ធ័កិច្ចនេះគឺមិនមែនប្រទានឲ្យសាវ័កពេត្រុសតែម្នាក់ ដូចជាព្រះវិហាររ៉ូម៉ាំងកាតូលិកអះអាងនោះទេ តែប្រទានឲ្យគ្រប់ពួកសាវ័កទាំងអស់។ នៅល្ងាចដំបូងនៃការមានព្រះជន្មរស់ឡើងវិញគឺជាការចាប់ផ្ដើមនៃរបៀបរៀបរយសម្រាប់ពួកជំនុំគ្រីស្ទបរិស័ទ ដែលឥឡូវនេះត្រូវតែប្រកាសព្រះរាជសារទៅទូទាំងពិភពលោក។ ហើយរបៀបរៀបរយថ្មីនោះគឺបានប្រគល់ឲ្យដល់ពួកជំនុំគ្រប់ៗរូប ទោះចាស់ឬក្មេងក្ដី។ តើយើងបានបំពេញបេសកកម្មនេះបានប៉ុន្មានដែរ?

**ការពិចារណា៖** តើខ្ញុំមានចំណែកក្នុងមហាបេសកកម្មដំណឹងល្អ?

**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ សូមទ្រង់ប្រើខ្ញុំជាអ្នកសាបព្រោះគ្រាប់ដំណឹងល្អផង។

ថ្ងៃទី ១៧ សីហា
យ៉ូហាន ២០:២៤-៣១ «នេះ អ្នករាល់គ្នានៅតែមិនឃើញទ្រង់ទៀត គង់តែមានចិត្តជឿដែរ»

# ថ្ងៃទីពីរនៃថ្ងៃព្រះអម្ចាស់ជាមួយសាវ័កថូម៉ាស

មូលហេតុដែលថូម៉ាសអវត្តមានជាមួយនឹងសាវ័កឯទៀតនាល្ងាចថ្ងៃដំបូងនៃថ្ងៃព្រះអម្ចាស់គឺមិនបានប្រាប់ដល់យើងទេ។ ប៉ុន្តែប្រតិកម្មរបស់គាត់ចំពោះដំណឹងនៃការមានព្រះជន្មរស់ឡើងវិញគឺបានប្រាប់យ៉ាងច្បាស់លាស់។ សាវ័កថូម៉ាសបានសង្ស័យ។ គាត់ប្រកាសពីគោលជំនឿរបស់គាត់ «ឃើញទើបជឿ បើបានប៉ះទៀតនោះនឹងជឿទ្វេរដង»។ ជំនឿរបស់គាត់ ជាជំនឿគ្មានបទពិសោធន៍ ហើយនៅក្នុងស្ថានភាពសង្ស័យបែបនេះគឺត្រូវបានថយចុះ។ បណ្ឌិតកាល់វិន មានប្រសាសន៍ថាភាពមានះរឹងរូសមិនព្រមទទួលពាក្យរបស់សាវ័កបែបនេះជាភស្តុតាងបញ្ជាក់ថាសេចក្តីអាក្រក់នេះគឺភ្ជាប់មកពីកំណើតក្នុងចិត្តមនុស្សភាគច្រើន។ តើលោកអ្នកគឺជាប្រភេទមនុស្សសង្ស័យ? ជាមនុស្សដ៏ឈ្លាសវៃ? នោះនឹងធ្វើការវាយតម្លៃនៅក្នុងពន្លឺនៃការបង្រៀនដែលព្រះគ្រីស្ទជាព្រះដ៏មានព្រះជន្មរស់ទ្រង់នឹងមានបន្ទូលជាបន្តបន្ទាប់ទៀត។

ដើម្បីជួយសាវ័កថូម៉ាសឲ្យរួចផុតចេញពីការគ្មានជំនឿនេះ ព្រះគ្រីស្ទបានយាងមកនៅថ្ងៃព្រះអម្ចាស់ទីពីរ។ ទ្រង់សម្របសម្រួលអង្គទ្រង់នឹងភាពល្ងីល្ងើជាមនុស្សរបស់យើងជាច្រើនដង។ សណ្ឋាននៃការសង្គ្រោះដែលសាវ័កថូម៉ាសបានបើកសម្តែងគឺថានៅពេលព្រះអម្ចាស់នឹងជាព្រះរបស់គាត់បានលេចឡើងគឺគាត់ឈប់មានពាក្យជំទាស់តវ៉ាទៀតហើយ។ ភ្លាមៗនោះ គាត់ប្រាកដជាបានលុតជង្គង់ចុះក្រាបថ្វាយបង្គំចំពោះព្រះអង្គដែលត្រូវបានទទួលស្គាល់ជាព្រះសង្គ្រោះដ៏អស់កល្ប។ ឱអ្នកប្រកាន់តាមទំនៀមទម្លាប់ជាអ្នកបានគ្រាប់តាមសាវ័កថូម៉ាសអើយ សូមកុំឲ្យមានការសង្ស័យនៅក្នុងចិត្តរបស់អ្នកទៀតឡើយ!

ដំណោះស្រាយរបស់ថូម៉ាសពីការគ្មានជំនឿគឺបានគូសបង្ហាញនូវគោលការណ៍ដ៏អស្ចារ្យមួយសម្រាប់ការរៀនសូត្រនិងការប្រសិទ្ធិពរជ័យរបស់យើង។ វាគឺជាព្រះពរយ៉ាងពិសេសដើម្បីជឿដោយពុំចាំបាច់ឃើញ។ ដូច្នេះយើងជាអ្នកឥតបានឃើញព្រះអម្ចាស់ដោយផ្ទាល់ភ្នែកតាមបែបបសាច់ឈាម របស់យើងតែបានជឿក៏មិនអន់នោះដែរ ពោលគឺជាព្រះពរច្រើនជាងពួកអ្នកបានឃើញផ្ទាល់ភ្នែកទៅទៀត។ បើគ្រាន់តែជឿតាមពាក្យបន្ទូលរបស់ទ្រង់ យើងនឹងដំកើងទ្រង់ទ្វេរដង ហើយក៏ទទួលនូវប្រសិទ្ធិពរជ័យទ្វេរដងដែរ។ ឱព្រះអម្ចាស់អើយ សូមប្រទានជំនឿដល់យើងខ្ញុំផង ប្រយោជន៍ឲ្យបានជឿលើអង្គទ្រង់និងលើព្រះចេស្តាដ៏ខ្លាំងវិសេសរបស់ព្រះអង្គ។ គ្មានការអ្វីដែលទ្រង់ធ្វើបានឡើយ។ សូមឲ្យយើងខ្ញុំស្តាប់ឮម្តងទៀតនូវព្រះពររបស់ពេត្រុសដល់គ្រីស្ទបរិស័ទក្នុងស្ថានភាពល្បួងល្បងជាអ្នកឈររឹងមាំព្រោះតែគេបន្តជឿទុកចិត្តលើព្រះសង្គ្រោះដ៏មានព្រះជន្មរស់។ «ដែលអ្នករាល់គ្នាមិនបានឃើញទ្រង់ទេ តែបានស្រឡាញ់ទ្រង់ ហើយទោះបើនៅជាន់ឥឡូវនេះអ្នករាល់គ្នានៅតែមិនឃើញទ្រង់ទៀត គង់តែមានចិត្តជឿដែរ ហើយក៏ត្រេកអរសោទរក្នុងទ្រង់ ដោយសេចក្តីអំណរដ៏ប្រសើរ ដែលរកថ្លែងមិនបាន» (១ ពេត្រុស ១:៨)។

សាវ័កថូម៉ាសដែលមានចិត្តសង្ស័យ គាត់បានក្លាយជាថូម៉ាសដ៏មានចិត្តក្លាហាន ជាសាវ័កទៅប្រទេសឥណ្ឌា។ បើតាមការនិយាយតៗគ្នា គាត់បានបង្កើតព្រះវិហារចំនួនប្រាំពីរនៅភាគខាងត្បូងនៃប្រទេសឥណ្ឌានិងបានស្លាប់ជាមរណៈស្មរបន្ទាល់នៅជិតស្រុកម៉ាដ្រាស (Madras)។ ទំនៀមទម្លាប់មួយទៀតបាន

និយាយថាគាត់ក៏បានទៅប្រទេសចិនផងដែរ។ ចំនួនគ្រីស្ទបរិស័ទដែលមានឈ្មោះថូម៉ាសដ៏ច្រើននាក់នៅប្រទេសឥណ្ឌាចង្អុលភស្តុតាងពីការអះអាងរបស់ទំនៀមទម្លាប់។

**ការពិចារណា៖** តើខ្ញុំជាថូម៉ាសដែរ?

**ការអធិស្ឋាន៖** ព្រះអម្ចាស់ សូមជម្រះចិត្តដែលតែងតែសង្ស័យរបស់ខ្ញុំ។

ថ្ងៃទី ១៨ សីហា
យ៉ូហាន ២១

*" ចូរឲ្យចំណីដល់ហ្វូងចៀមខ្ញុំស៊ីផង"*

**ចំពោះហ្វូងចៀមនិងអ្នកគង្វាលក្រោមឱវាទរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទគឺជាមេអ្នកគង្វាល នៃកូនចៀមតាម រយៈព្រះលោហិតនៃសេចក្ដីតាំងសញ្ញាដ៏អស់កល្ប។ អាម៉ែន**

ជំពូកចុងបង្អស់នៅក្នុងដំណឹងល្អយ៉ូហាននេះគឺជាអវសានកថា។ យោងទៅតាមវចនានុក្រមវេបស៊្ទើរ (Webster) អវសានកថា (an epilogue) ជា «វគ្គបញ្ចប់ដែលត្រូវបានបន្ថែមទៅលើរឿងប្រលោមលោក រឿងល្ខោន ។ល។ ទុកជាការផ្ដល់នូវការវិចារណ៍ ការបកស្រាយ ឬ ជាព័ត៌មាន» ជាដើម។ ក៏ប៉ុន្តែតើហេតុអ្វីបានជាអវសានកថាត្រូវបានបន្ថែមបន្ទាប់ពីដំណឹងល្អយ៉ូហានបានបញ្ចប់ដោយបរិបូរនិងដ៏ល្អប្រពៃនៅយ៉ូហាន ២០: ៣០-៣១?

បើតាមលោកហិនឌ្រិកសិន (Hendriksen) មានគោលបំណងប្រាំពីរផ្នែកគឺ៖

(១). ដើម្បីបញ្ជាក់ថាព្រះគ្រីស្ទជាព្រះដ៏មានព្រះជន្មនៅមានព្រះហឫទ័យទុកដាក់ក្នុងពួកជំនុំរបស់ទ្រង់ ហើយថាព្រះចេស្ដានិងសេចក្ដីស្រឡាញ់មិនបានដកចេញនៅឡើយទេ។

(២). ដើម្បីដាស់រំឭកបណ្ដាសាវ័កអោយបានធ្វើជាអ្នកនេសាទមនុស្សជារៀងរហូត។

(៣). ដើម្បីសម្ដែងប្រាប់ពេត្រុសថាគាត់ត្រូវបានតាំងជាសាវ័កឡើងវិញ ទោះបីជាអំពើបាបដ៏ធ្ងន់ធ្ងរនៃការបដិសេធន៍ព្រះសង្គ្រោះរបស់គាត់ក៏ដោយ។ សេចក្ដីដែលមនុស្សបានចងចាំគឺព្រះម្ចាស់បានបំភ្លេចរួចស្រេចហើយ ព្រោះការអត់ទោសរបស់គឺល្អឥតខ្ចោះ។

(៤). ដើម្បីបញ្ជាក់ជាថ្មីម្ដងទៀតពីសេចក្ដីពិតដ៏លើកទឹកចិត្តនៃការកំណត់ទុក ។ ដោយហេតុថាការស្លាប់ដ៏កិត្តិយសរបស់ពេត្រុសត្រូវបានដឹងនឹងព្យាករណ៍ជាមុន (សូមអាន ២:១៨-១៩)។

(៥). ដើម្បីដកចេញនូវការយល់ច្រឡំទាក់ទិនទៅនឹងពាក្យបន្ទូលរបស់ព្រះយេស៊ូវអំពីសាវ័កយ៉ូហានដែលយល់ថាគាត់នឹងត្រូវស្លាប់ (២១:២៣)។

(៦).ដើម្បីអនុញ្ញតឲ្យចាស់ទុំពួកជំនុំអេភេសូរធ្វើបទបង្ហាញពីទីបន្ទាល់រួមគ្នាបញ្ជាក់ពីការជឿជាក់លើកំណត់ត្រានៃដំណឹងល្អរបស់សាវ័កយ៉ូហាន។

(៧). ដើម្បីពន្យល់ពីហេតុផលដែលព្រឹត្តិការណ៍ជាច្រើននៃជីវភាពរបស់ព្រះគ្រីស្ទមិនត្រូវបានកត់ត្រា (២១:២៥)។

ទោះបីជាគោលបំណងអ្វីផ្សេងទៀតក្នុងការសរសេរអវសានកថានេះក៏ដោយ ជាក់ស្ដែងវាគឺជាបទពិសោធន៍ផ្ទាល់ខ្លួនរបស់យ៉ូហាន ហើយជាទីបន្ទាល់បញ្ជាក់បន្ថែមលើការសរសេរនេះដោយជីវិត។ តើធ្វើដូចម្ដេចទើបអ្នកអាចដឹងថាយ៉ូហានមានវត្តមាននៅទីនោះនាពេលព្រឹក«ទីបី»នៃការមានព្រះជន្មរស់ឡើងវិញ?

**ការពិចារណា៖** " ..យើងខ្ញុំដឹងថាសេចក្ដីបន្ទាល់របស់គាត់ នោះពិតហើយ" (យ៉ូហាន ២១:២៤)។
**ការអធិស្ឋាន៖** ឱសូមឲ្យខ្ញុំធ្វើជាទីបន្ទាល់រស់ថ្វាយព្រះអង្គសង្គ្រោះផង។

ថ្ងៃទី ១៩ សីហា

យ៉ូហាន ២១:១-៣ *«...បើអ្នកណាមិនចង់ធ្វើការ មិនត្រូវទាំងឲ្យអ្នកនោះបរិភោគផង»*

## បើគ្មានព្រះគ្រីស្ទ សហគ្រាសគ្មានភាពជោគជ័យ

សមុទ្រទីបេរាសគឺជាសមុទ្រកាលីឡេ អតីតជាកន្លែងប្រជុំគ្នានៃក្រុមសាវ័ក។ ពួកសាវ័កបានត្រឡប់មកស្រុកកំណើតរបស់គេវិញនៅស្រុកកាលីឡេវិញដើម្បីរក្សាការណាត់ជួបជាមួយនឹងព្រះអម្ចាស់ (ម៉ាថាយ ២៨:១០)។ ដូចជាគេត្រូវបានកោះហៅដំបូងក្នុងស្រុកកាលីឡេ ដូចនេះពួកគេក៏ត្រូវទទួលបាននូវការចាត់តាំងពីស្រុកកាលីឡេយ៉ាងដូច្នោះដែរ។

ខណៈពេលពួកគេរង់ចាំព្រះអម្ចាស់ ពេត្រុសជាមេក្រុមសាវ័ក បានបបួលពួកគេទៅនេសាទត្រី។ មិនមែនជាការនេសាទដើម្បីកំសាន្តទេ តែដើម្បីចិញ្ចឹមជីវិត។ «...បើអ្នកណាមិនចង់ធ្វើការ មិនត្រូវទាំងឲ្យអ្នកនោះបរិភោគផង» (២ ថែស្សាឡូនីច ៣:១០)។ បើសិនសាវ័កជាកសិករ ពួកគេប្រាកដជាជីកកោះកាយដីនៅក្នុងវាលស្រែ(ឬចំការ) ជាមិនខាន។ គេមិនមែនអង្គុយរង់ខ្ជិលច្រអូសរង់ចាំគេចិញ្ចឹមដូចជាពួកសង្ឃទ្បើយ។ ពួកគេមិនជាអ្នកបរិភោគអាហារដែលបានមកដោយឥតធ្វើការដែរ។ ការងារគឺជាកិច្ចការពិសិដ្ឋនិងជាកិត្តិយស។

ទោះបីជាអ្វីក៏ដោយចុះ សហគ្រាសផ្ទាល់ខ្លួនត្រូវការជំនួយរបស់ព្រះជាម្ចាស់ដើម្បីជោគជ័យ។ ដូចជាព្រះអម្ចាស់អវត្តមាន ហើយដំណើរនេសាទនេះចាប់ផ្តើមឡើងដោយការគំនិតផ្តួចផ្តើមរបស់ពេត្រុសផ្ទាល់ ព្រះអម្ចាស់មានព្រះទ័យចង់ឲ្យពួកគេរៀននូវមេរៀនកាលពីមុនម្តងទៀត (លូកា ៥) អំពីភាពគ្មានផលផ្លែតាមរយៈការខិតខំដោយផ្ទាល់ខ្លួនឯង។ ព្រះអម្ចាស់ក៏មានព្រះទ័យចង់ធានាបញ្ជាក់ដល់សិស្សរបស់ទ្រង់ពីវត្តមានដ៏ជាជំនួយរបស់ទ្រង់នាពេលត្រូវការចាំបាច់ផងដែរ។ ព្រោះមិនជាយូរប៉ុន្មានព្រះអង្គនឹងយាងត្រឡប់ខាងផ្នែករូបកាយទៅស្ថានសួគ៌ តែទ្រង់នឹងបន្តគង់ជាមួយគេធ្វើជាព្រះដ៏ជួយផ្គត់ផ្គង់របស់គេដដែល។ មានគោលបំណងដ៏ខ្ពស់របស់ព្រះក្នុងដំណើរជីវិតនៃកូនទាំងឡាយរបស់ទ្រង់ទោះបីស្ថិតក្នុងការដកចេញ ឬផ្តល់ឲ្យ។ ដូច្នេះកំណត់ត្រានេះគឺត្រូវបានដំណាលប្រាប់ជាសង្ខេបនៅក្នុងតែមួយខ ជាមួយនឹងសេចក្តីបញ្ចប់ដ៏ខ្លី «តែយប់នោះគេចាប់មិនបានអ្វីសោះ» (ខ ៣)។ តើនោះគឺជាបទពិសោធន៍របស់អ្នកដែរ?

នៅក្នុងការងារព្រះវិហារមានពួកអ្នកដែលចូលចិត្តមាញឹកនឹងការលក់ដូរ ដើររែអង្គាសប្រាក់ ពិធីប្រគុំតន្ត្រីនិងភ្លេងផ្សេងៗ។ តែនៅពេលព្រះអម្ចាស់លើកតម្កើងកិច្ចការរបស់ទ្រង់ នោះទ្រង់នឹងមិនត្រូវនូវការខិតខំផ្ទាល់ខ្លួនរបស់យើងឡើយ ដើម្បីឲ្យសិរីល្អទាំងអស់ត្រូវថ្វាយទៅព្រះអង្គផ្ទាល់។

*ព្រះយេស៊ូវ ទ្រង់ហៅយើងខ្ញុំមក*
*ឲ្យលែងការល្បែងនាំវឹកវរ*
*រាល់តែថ្ងៃទ្រង់មានបន្ទូល..រក*
*ថាចូរ អ្នកមកឲ្យបានពរ។* (ទំនុកដំកើង ២៩៖ ព្រះយេស៊ូវទ្រង់ហៅយើងខ្ញុំ)

**ការពិចារណា៖** ព្រះពរនៃព្រះគឺគ្មានទុក្ខភ័យឡើយ!

**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមទ្រង់ប្រទានព្រះពរទាំងមេៗដល់យើងខ្ញុំផង។

# ការបម្រើប្រកបដោយផលផ្លែក្រោមការដឹកនាំរបស់ព្រះគ្រីស្ទ

«ដល់ព្រលឹមឡើង ព្រះយេស៊ូវទ្រង់ឈរនៅឆ្នេរសមុទ្រ តែពួកសិស្សមិនដឹងជាព្រះយេស៊ូវទេ» (ខ ៤) ។ ពិតណាស់ ជារឿយៗនៅក្នុងការតស៊ូដ៏ងងឹតងងល់របស់យើង យើងម្នាក់ៗមិនបានដឹងថាទ្រង់កំពុងតែទតមើលយើងនោះទេ ពោលគឺទោះបីជាយើងស្ថិតនៅក្រោមការថែរក្សារបស់ព្រះសង្គ្រោះនៃយើងក៏ដោយ។ នៅពេលយើងស្ថិតក្នុងភាពទល់ច្រកគ្មានទីពឹងពំនាក់ នោះជំនួយពីព្រះសង្គ្រោះក៏បានមកដល់ទាន់ពេលវេលា។ ពួកសាវ័កបានទទឹកជោគជាំនិងរងារដោយភាពស្រេកឃ្លានអាហារតែព្រះអម្ចាស់មានអាហារក្តៅៗរង់ចាំទទួលគេ។ ព្រះអង្គជ្រាបជាមុននូវតម្រូវការជាក់ស្តែងរបស់យើង។ ទ្រង់ផ្គត់ផ្គង់ដូចជាម្តាយផ្គត់ផ្គង់កូនៗមុនពេលគេសូមដូច្នោះដែរ។

ប៉ុន្តែព្រះអង្គមានព្រះពរដ៏ច្រើនលើសលប់ស្តុកក្នុងឃ្លាំងសម្រាប់គេបើពួកគេនឹងធ្វើតាមការណែកនាំរបស់ទ្រង់។ «ចូរទំលាក់អួនទៅខាងស្តាំទូក»។ គេធ្វើតាមទ្រង់បន្ទាប់ពីបរាជ័យនេសាទត្រីមិនបានដោយសារតែទំលាក់អួនចុះខុសទិសដៅ។ ហើយនេសាទត្រីដោយវិធីណាក៏បានច្រើនម្ល៉េះ គឺ ១៥៣ កន្ទុយ! ។ ចំនួនត្រី «ច្រើនសន្ធឹកណាស់» គឺមិនបានប្រាប់យើងទេ តែបើពី ១០ ទៅ ២០ គីឡូក្រាម ដែលជាមធ្យមត្រីមួយទំងន់ ១៥ ផោន (៦.៨០ គ.ក) នោះការប្រមូលត្រីពីការនេសាទដ៏ច្រើនសន្ធឹកបែបនេះនឹងលើសជាង ២០០ ផោន ឬ១០០ គីឡូក្រាម។ បើមួយគីឡូក្រាមតម្លៃ ៣ដុល្លាអាមេរិក ត្រីដែលនេសាទបានភ្លាមៗនេះនឹងបានកម្រៃលើសជាង ៣,០០០ ដុល្លាជាមិនខានឡើយ។ តើប្រាក់ចំនួន៣,០០០ ដុល្លានឹងអាចទិញអាហារសម្រាប់សិស្សប្រាំពីនាក់បានប៉ុន្មានដង?

នៅពេលព្រះជាម្ចាស់ប្រទានពរជាច្រើនដល់ការងារដោយដៃរបស់គេ ភ្នែករបស់សាវ័កក៏បានបើកឡើង៖ «នេះគឺជាព្រះអម្ចាស់ហើយ»។ ពេលព្រះទ្រង់ប្រទានពរការងារដោយដៃរបស់យើង ជាក្រុមជំនុំរបស់យើង តើពួកយើងថ្វាយសិរីល្អដល់ទ្រង់ហើយបន្លឺសំឡេងថា «នេះគឺជាព្រះអម្ចាស់ហើយ» ដែរឬទេ? ហើយពេលយើងនិយាយឃ្លានេះ វាជាពាក្យថ្លែងអំណរគុណដល់ព្រះអង្គដ៏ប្រទានពរជាក្តីអំណរនឹងអំណោយទាន។ វានឹងញែកយើងជាបរិសុទ្ធឲ្យនៅតែឆេះឆួលស្រឡាញ់កិច្ចបម្រើដល់ទ្រង់ជាដរាប ហើយមិនធ្វើតាមគំនិតផ្ទាល់ខ្លួនយើង ឬកំឡាំងនិងជំនាញរបស់យើងឡើយ។ ចូរប្រៀបធៀបជំពូកនេះជាមួយលូកា ៥ ដែលសាវ័កពេត្រុសបានឆេះឆួលដោយសារសេចក្តីស្រឡាញ់និងព្រះចេស្តារបស់ព្រះអម្ចាស់របស់គាត់។ អាស្រ័យតាមការសារភាពផ្ទាល់ខ្លួនគាត់ កិច្ចបម្រើផ្ទាល់ខ្លួនរបស់គាត់គឺពោរពេញដោយបាបព្រោះតែគ្មានការដឹកនាំនៃព្រះអម្ចាស់។ តើយើងមិនគួរពិចារណាមើលខ្លួនឯងយើងជាថ្មីដែលកំពុងព្យាយាមបម្រើព្រះតាមវិធីតាំងចិត្តផ្ទាល់ខ្លួន? នេះជាលើកទីបីដែលព្រះយេស៊ូវបានសម្តែងអង្គទ្រង់ដល់សាវ័ក ពីរលើកដំបូងនៅយេរូសាឡឹម គឺនៅល្ងាចថ្ងៃអាទិត្យដំបូង អវត្តមានលោកថូម៉ាស និងល្ងាចថ្ងៃអាទិត្យទីពីរ មានវត្តមានរបស់លោកថូម៉ាស។

**ការពិចារណា៖** មានព្រះជាដៃគូការងារ ទោះបីរងារក៏ជោគជ័យដល់ត្រើយដែរ។

**ការអធិស្ឋាន៖** សូមព្រះអម្ចាស់ ជាម្ចាស់លើរាល់ទាំងកិច្ចការដែលយើងខ្ញុំប្រកបធ្វើ។

# វាងពេត្រុសនិងយ៉ូហាន

លោក ចេ ស៊ី រ៉ាយល៍(J . C. Ryl e ) អត្ថាធិប្បាយថា៖ «យើងគួរកត់សម្គាល់ សម្រាប់មេរៀនមួយទៀត នៅក្នុងខទាំងនេះ វាងអាកប្បកិរិយាខុសប្លែកគ្នានៃសាវ័ករបស់ព្រះគ្រីស្ទ។ មួយវិញទៀត នាឱកាសដ៏គួរឲ្យចាប់អារម្មណ៍នេះ យើងឃើញថាពេត្រុសនិងយ៉ូហាននៅជិតគ្នាក្នុងទូកតែមួយ ហើយម្យ៉ាងទៀតដូចជានៅឯផ្ទះដែរ យើងឃើញថាមនុស្សល្អទាំងពីរនាក់នេះកំពុងប្រព្រឹត្តក្នុងរបៀបខុសៗគ្នា។ នៅពេលព្រះយេស៊ូវគង់ឈរនៅមាត់សមុទ្រ ក្នុងពន្លឺព្រឹងៗនាពេលព្រឹក យ៉ូហានគឺជាមនុស្សដំបូងដែលដឹងថាទ្រង់ជាអ្នកណា ហើយនិយាយថា «នេះគឺជាព្រះអម្ចាស់ហើយ» តែពេត្រុសជាអ្នកលោតចុះទៅក្នុងទឹកហើយព្យាយាមចូលទៅជិតព្រះរាជគ្រូរបស់គាត់។ ពោលយ៉ូហានគឺជាអ្នកឃើញមុនគេ តែពេត្រុសគឺជាអ្នកធ្វើសកម្មភាពមុន។ ទឹកចិត្តស្រឡាញ់ដ៏ទន់ភ្លន់របស់យ៉ូហានគឺឆាប់នឹងយល់ តែទឹកចិត្តរបស់ពេត្រុសគឺឆាបឆេះដូចជាភ្លើង និស្ស័យពុះកញ្ជ្រោលរបស់គាត់គឺងាយនឹងជម្រុញឲ្យធ្វើសកម្មភាពឡើង។ យ៉ាងណាក៏ដោយទាំងពីរនាក់គឺជាអ្នកជឿ អ្នកដូចគ្នា ជាសាវ័កមានចិត្តកក្តី សិស្សទាំងពីរស្រឡាញ់ព្រះអម្ចាស់ស្មើនឹងជីវិត ហើយស្មោះត្រង់រហូតដល់មរណៈ។ ប៉ុន្តែនិស្ស័យពីកំណើតរបស់ពួកគេគឺមិនដូចគ្នាឡើយ។

ចូរយើងកុំភ្លេចយកមេរៀននេះមកអនុវត្តចំពោះខ្លួនយើងឡើយ។ ដរាបណាយើងនៅមានជីវិតរស់នៅចូរយើងអនុវត្តមេរៀននេះដ៏ខ្ជាតខ្ជីនៅក្នុងចំណោមនៃបណ្តាពួកជំនុំដែលយើងបង្កើត។ ចូរយើងកុំថ្កោលទោសអ្នកដទៃថាគ្មានគុណបំណាច់និងមិនបានកើតជាថ្មី ពីព្រោះពួកមិនឃើញពីច្រកនៃភារកិច្ចពីទស្សនៈរបស់យើង ឬមានអារម្មណ៍ចំពោះកិច្ចការដូចជាយើងមានអារម្មណ៍ចំពោះកិច្ចការទាំងនោះឡើយ។ «រីឯអំណោយទាន នោះមានផ្សេងៗពីគ្នា តែគឺជាព្រះវិញ្ញាណដដែលទេ» (១ កូរិនថូស ១២:៤)។ អំណោយទាននៃកូនៗរបស់ព្រះគឺមិនត្រូវបានប្រទានមកក្នុងទំហំនិងកម្រិតជាក់លាក់ស្មើគ្នានោះឡើយ។ អ្នកខ្លះមានអំណោយទានច្រើនជាងមួយ ឯអ្នកខ្លះទៀតមានច្រើនជាងគេ។ អ្នកខ្លះមានអំណោទានដែលលេចធ្លោខ្លាំងក្នុងទីសាធារណៈ និងអ្នកខ្លះទៀតលេចធ្លោខ្លាំងក្នុងទីឯកជន។ អ្នកខ្លះឈ្លាសវៃខ្លាំងក្នុងជីវភាពអកម្ម ឯអ្នកខ្លះទៀតវិញឈ្លាសវៃយខ្លាំងជីវភាពដ៏សកម្ម។ តែសមាជិកម្នាក់ៗនៃគ្រួសាររបស់ព្រះជាម្ចាស់ ទោះបីស្ថិតក្នុងមធ្យោបាយនិងមូលហេតុផ្ទាល់ខ្លួនរបស់ពួកយ៉ាងក៏ដោយ សុទ្ធតែនាំមកនូវសិរីល្អថ្វាយដល់ទ្រង់។ នាងម៉ាថា «មានការរវល់ជាច្រើន» ឯម៉ារាជាប្អូនស្រី «នាងនោះបានអង្គុយស្តាប់ព្រះបន្ទូល នៅទៀបព្រះបាទព្រះអម្ចាស់» ។ ក៏ប៉ុន្តែមានថ្ងៃមួយនៅឯភូមិបេថានីជាពេលនាងម៉ារាងទុក្ខជាទម្ងន់ ហើយជំនឿរបស់នាងម៉ាថាបានភ្លឺឡើងខ្លាំងជាងជំនឿរបស់ប្អូនស្រីនាង។ (លូកា ១០:៣៩-៤០ យ៉ូហាន ១១:២០-២១)។ យ៉ាងណាក៏ដោយទាំងពីរនាក់បងប្អូនស្រីបានស្រឡាញ់ព្រះអម្ចាស់នៃយើង។ សេចក្តីតែ១ទេដែលត្រូវការគឺត្រូវមានព្រះគុណនៃព្រះវិញ្ញាណហើយនឹងត្រូវស្រឡាញ់ព្រះគ្រីស្ទ។ ចូរឱ្យយើងស្រឡាញ់មនុស្សគ្រប់រូបទាំងអស់ដូចជាពាក្យថ្លែងនេះ ទោះបីជាពួកគេមិនអាចឃើញដូចជាយើងយល់ឃើញនូវរាល់កិច្ចការទាំងឡាយ។ ពួកជំនុំរបស់ព្រះគ្រីស្ទត្រូវការអ្នកបម្រើគ្រប់ប្រភេទ និងរាល់ឧបករណ៍ ទាំងកូនបិតទាំង ដាវ ពូថៅនិងញញួរ ពន្លាកនិងរណារ ទាំងម៉ាថាទាំងម៉ារា ទាំងពេត្រុសនិង យ៉ូហាន ផងដែរ។ ចូរឱ្យ សុភាសិតនៃការដឹកនាំរបស់យើងដូចនេះ « សូមឲ្យ

ព្រះគុណ បានសណ្ឋិតនៅជាមួយនឹងអស់អ្នកណា ដែលស្រឡាញ់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង រាល់គ្នាដោយស្មោះត្រង់» (អេភេសូរ ៦:២៤)។

**ការពិចារណា៖** តើខ្ញុំមានអំណោយទាននៃព្រះគុណអ្វីដែលខ្ញុំមាន?

**ការអធិស្ឋាន៖** ឪ សូមឲ្យខ្ញុំប្រើអំណោយទានទាំងឡាយសម្រាប់ថ្វាយសិរីល្អដល់ទ្រង់ផង។

ថ្ងៃទី ២២ សីហា
យ៉ូហាន ២១:១៥-១៧ « ..គឺទ្រង់ជ្រាបថា ទូលបង្គំពេញចិត្តនឹងទ្រង់ហើយ..

# រវាងព្រះយេស៊ូវនិងពេត្រុស

មានអ្នកអត្ថាធិប្បាយជាច្រើនអះអាងពីមូលហេតុព្រះយេស៊ូវសួរពេត្រុសចំនួនបីដងបើគាត់ស្រឡាញ់ទ្រង់គឺជាការឆ្លើយតបទៅការបដិសេធន៍ចំនួនបីដងរបស់គាត់។ ហើយមូលហេតុដែលព្រះយេស៊ូវចង់បានចម្លើយសម្រាប់សំណួរនិមួយៗគឺដើម្បីស្វែងរកពីរបៀបពេត្រុសស្រឡាញ់ព្រះអម្ចាស់របស់ខ្លួន។

លោកចេមស៍ ស្តកខឺ (James Stalker) នៅក្នុងព័ន្ធកិច្ចគ្រីស្ទាន វើល ពុពីត (Christian World Pulpit) មានប្រសាសន៍អំពីសេចក្តីស្រឡាញ់របស់ពេត្រុសចំពោះព្រះសង្រ្គោះរបស់គាត់ថាមានបី «ជាន់»។ នៅក្នុងរូបកាយនៃជីវិតរបស់យើងម្នាក់ៗមានបីជាន់ គឺជាន់ក្រោម ជាន់កណ្តាល និងជាន់លើ។

ជាន់ក្រោមតំណាងឱ្យអារម្មណ៍របស់យើង។ នៅក្នុងខ្លួនយើងមានអារម្មណ៍ជាច្រើនបែបខុសៗគ្នាៗឆ្លងកាត់បណ្តាញមួយដែលជាទូទៅឈ្មោះថាសេចក្តីស្រឡាញ់។ ក្នុងបណ្តានៃ សេចក្តីស្រឡាញ់ទាំងអស់ដែលចិត្តរបស់អ្នកស្គាល់ តើមានសេចក្តីស្រឡាញ់ចំពោះព្រះគ្រីស្ទដែរឬទេ?

ពីជាន់ក្រោម ព្រះគ្រីស្ទយាងមកខាងលើជាន់កណ្តាលដែលជាផ្នែកបញ្ញា (Intelligence)។ ព្រះអង្គចង់បាននូវជម្រើសរបស់យើងសម្រាប់ទ្រង់មិនត្រឹមតែផុសចេញពីអារម្មណ៍របស់យើងនោះទេ តែចេញមកពីការវិនិច្ឆ័យរបស់យើងផងដែរ។ ចំណេះដឹងនឹងបង្កើនជម្រៅនៃក្តីស្រឡាញ់របស់យើងចំពោះព្រះគ្រីស្ទ។ ចំណេះដឹងក៏បង្កើននូវការដឹងគុណចំពោះទ្រង់ដែរ។

ពីជាន់កណ្តាលនៃចំណេះដឹង ទ្រង់យាងទៅជាន់លើជាផ្នែកឆន្ទះ(Will)។ មានសេចក្តីស្រឡាញ់ពីរប្រភេទនៅក្នុងពិភពលោកនេះ គឺសេចក្តីស្រឡាញ់ដែលទទួលនិងសេចក្តីស្រឡាញ់ចែករំលែក។ សេចក្តីស្រឡាញ់ដែលទទួលយកកម្មវត្ថុនៃក្តីស្រឡាញ់របស់វារួចហើយមានអំណររីករាយនឹងសេចក្តីស្រឡាញ់នោះ។ សេចក្តីស្រឡាញ់ចែករំលែកគឺត្រូវបានកម្មវត្ថុនៃក្តីស្រឡាញ់របស់វាស្រូបយករួចហើយបំភ្លេចខ្លួនឯងរបស់វា។ សេចក្តីស្រឡាញ់របស់យើងចំពោះព្រះគ្រីស្ទត្រូវតែស្ថិតនៅក្រោមការសាកល្បង។ តើសេចក្តីស្រឡាញ់របស់យើងចំពោះព្រះគ្រីស្ទតម្រូវនូវការបាត់បង់គុណប្រយោជន៍និងការលះកាត់ចិត្តខ្លួនឯង? បើយើងស្រឡាញ់ទ្រង់ តើយើងព្រមលីឈើឆ្កាងហើយដើរតាមទ្រង់ដែរទេ? ក្លាយជាគ្មានអ្វីដើម្បីឱ្យទ្រង់ជាពោរពេញទាំងអស់?

តើហេតុអ្វីបានជាព្រះអម្ចាស់នៃយើងតម្រូវឱ្យមានសេចក្តីស្រឡាញ់បែបនេះ? ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន រហូតទ្រង់បានសុគតនៅលើឈើឆ្កាងជំនួសបាបរបស់យើង។ ការទាមទារដ៏ចម្បងពីព្រះអម្ចាស់នៃយើងចំពោះសាវ័កពេត្រុសឆ្លុះបញ្ចាំងពីសេចក្តីស្រឡាញ់ដ៏មហិមាចំពោះរូបគាត់និងចំពោះពួកយើង។ ហើយបើយើងពិតជាស្រឡាញ់ទ្រង់មែន យើងត្រូវតែឱ្យចំណីដល់កូនចៀម និងឃ្វាលហ្វូងចៀមរបស់ទ្រង់ដូចជាព្រះអង្គបានបង្គាប់។ បើយើងស្រឡាញ់ទ្រង់ យើងត្រូវបម្រើព្រះ អង្គនៅក្នុងពួកជំនុំរបស់ទ្រង់។ លោក ចេ ស៊ី រ៉ាយល៍ (J.C. Ryle) មានប្រសាសន៍ថា៖ «សេចក្តីស្រឡាញ់ពិតចំពោះព្រះគ្រីស្ទជាចម្បងដើម្បីបង្ហាញឱ្យឃើញក្នុងភាព (មនុស្ស)ដ៏មានប្រយោជន៍ដល់អ្នកដទៃ គឺការធ្វើកិច្ចការដូចជាព្រះគ្រីស្ទទ្រង់បានសម្តែងធ្វើជាការដើរក្នុងជំហានរបស់ទ្រង់ ក្នុងការប្រកបការល្អនៅក្នុងពិភពលោកដ៏អាក្រក់នេះ។ អ្នក

ដែលនិយាយអំពីការស្រឡាញ់ព្រះគ្រីស្ទ ហើយខ្ជិលច្រអូសក្នុងជីវិត មិនដែលព្យាយាមធ្វើការល្អដល់អ្នកដទៃ គឺកំពុងតែបោកបញ្ឆោតខ្លួនឯង ហើយនិងជាការល្អបើបុគ្គលនោះមិនបានកើតមក» ។

*ព្រះយេស៊ូវទ្រង់ហៅយើងខ្ញុំចេញ ពីការស្វែងរកទ្រព្យ សម្បត្តិ*
*ទ្រង់ ចង់ធ្វើ ម្ចាស់សព្វគ្រប់ពោរពេញ ចូរស្រឡាញ់.. ទ្រង់ទុកជាក្សត្រ។*
(«**ព្រះយេស៊ូវទ្រង់ហៅយើងខ្ញុំ**» ទំនុកដំកើង ២៩ ៩៣)

**ការពិចារណា៖** សេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណ៍គឺទាំងពាក្យសម្តីនិងការប្រព្រឹត្តផងដែរ ។
**ការអធិស្ឋាន៖** សូមឲ្យស្រឡាញ់របស់យើងខ្ញុំបានគ្រប់លក្ខណ៍ចំពោះទ្រង់ផង ឱព្រះអម្ចាស់អើយ ។

## «លោហិតនៃមរណៈស្មរបន្ទាល់គឺជាគ្រាប់ពូជនៃពួកជំនុំ»

ខ ១៨ គឺជាព្យាករណ៍របស់ព្រះអម្ចាស់នៃយើងអំពីលក្ខណៈមរណភាពរបស់សាវ័ក។ បទទំនាយនេះបានសម្រេចនៅពេលពេត្រុសត្រូវបានជាប់ឆ្កាងជាមរណៈស្មរបន្ទាល់ដោយបុព្វហេតុនៃព្រះគ្រីស្ទ។

ជាធម្មតាមានរនាំងបាំងរវាងយើងនិងអនាគត។ ដើម្បីទទួលបាននូវចំណេះដឹងជាមុនអំពីព្រឹត្តិការណ៍ដែលនឹងមកដល់ នៅក្នុងករណីភាគច្រើន លោក ចេ ស៊ី រ៉ាយល៍ មានប្រសាសន៍ថានឹងក្លាយជាចំណេះពោរពេញដោយទុក្ខព្រួយ។ ការដឹងអំពីការអាក្រក់ដែលកើតមានឡើងចំពោះរូបយើង ក៏ប៉ុន្តែមិនសមត្ថភាពដើម្បីទប់ស្កាត់វា នោះជាក់ស្តែងនឹងធ្វើឱ្យយើងវេទនា។ ដូច្នេះទើបព្រះជាម្ចាស់ទ្រង់មិនត្រឹមតែដកចំណេះដឹងអំពីអនាគតចេញពីយើងទេ តែក៏បានហាមកុំឱ្យយើងព្យាយាមដោះស្រាយវាតាមរយៈជំនួយរបស់គ្រូទស្សន៍ទាយផងដែរ (ចោទិយកថា ១៨:៩-១៤)។

ប៉ុន្តែចំពោះសាវ័កពេត្រុសវិញ ព្រះគ្រីស្ទបានបើកសម្តែងដល់គាត់ពីរបៀបដែលគាត់នឹងត្រូវស្លាប់ដើម្បីបុព្វហេតុទ្រង់។ កិច្ចការនេះនេះព្រះអង្គបានសម្តែងដល់គាត់ពីព្រោះទ្រង់ជ្រាបថាគាត់នឹងអាចទទួលនូវការនេះបាន។ ជាប្រយោជន៍ឱ្យគាត់នឹងពួកយើងនឹងដឹងថាអនាគតទាំងមូលរបស់យើងគឺព្រះជាម្ចាស់ទ្រង់ជ្រាបនិងបានរៀបចំទុកជាស្រេច។ គ្មានការអ្វីដែលហៅថាជាសំណាង វាសនា ឬជាការចៃដន្យនៅក្នុងដំណើរជីវិតឡើយ។ រាល់ហេតុការណ៍ទាំងអស់ពីដើមដល់ចប់គឺត្រូវបានអង្គបុគ្គលដ៏វៃឆ្លាតឥតមានកំហុសនិងជាទីស្រឡាញ់ទ្រង់ជ្រាបដឹងនឹងកំណត់ទុកជាស្រេចដើម្បីបញ្ចៀសគ្រោះថ្នាក់ចេញពីយើង។

លោក ចេ ស៊ី រ៉ាយល៍ មានប្រសាសន៍ទៀតថា៖ ចូរឱ្យយើងរក្សាទុកសេចក្តីពិតនេះនៅក្នុងចិត្តគំនិតរបស់យើង ហើយប្រើប្រាស់វាដោយឧស្សាហ៍ព្យាយាមនាវេលាសេចក្តីងងឹតជាពេលដែលយើងនឹងត្រូវឆ្លង។ នាគ្រាបែបនេះយើងគួរពឹងផ្អែកលើទំនុកចិត្តថា «ព្រះគ្រីស្ទបានជ្រាបនូវថ្ងៃនោះ ហើយទ្រង់បានដឹងពីវេលានៅពេលទ្រង់ហៅរូបខ្ញុំដើម្បីឱ្យបានធ្វើជាសិស្សរបស់ទ្រង់»។ វាគឺជាភាពឆ្កួតលីលាក្នុងការកើតមានទុក្ខព្រួយនិងគ្នាញគ្នេរនឹងបញ្ហាទុក្ខលំបាករបស់ពួកអ្នកដែលយើងស្រឡាញ់។ យើងគួរតែត្រឡប់មកឯគំនិតដែលគ្រប់យ៉ាងគឺជាការល្អប្រពៃ។ វាគឺជាការឥតប្រយោជន៍ក្នុងការមួម៉ៅនិងមានៈបះបោរនៅពេលខ្លួនយើងផ្ទាល់មានពែងល្វីងដូចត់ត្រូវផឹក។ យើងគួរតែនិយាយថា «នេះគឺក៏មកពីព្រះអម្ចាស់ដែរ ទ្រង់បានជ្រាបដឹងវាជាមុនហើយនឹងបង្ខាំងវា ប្រសិនបើមិនវាមិនមែនជាសម្រាប់ការល្អដល់យើង»។ «យើងដឹងជាលើកទីពីរទៀតថាមរណៈភាពរបស់អ្នកជឿគឺតម្រូវទុកដើម្បីថ្វាយសិរីរុងរឿងដល់ព្រះ...។ យើងអាចស្លាប់ដើម្បីព្រះអម្ចាស់និងមានជីវិតដើម្បីព្រះអម្ចាស់ផងដែរ។ ដូចជាលោកសាំសុនយើងនឹងបម្រើព្រះជាម្ចាស់ក្នុងសេចក្តីស្លាប់របស់យើងបានច្រើនជាងនៅពេលយើងបម្រើទ្រង់ក្នុងជីវិតរស់នៅរបស់យើង..។

ពាក្យរបស់លោក ធើទូលាន (Tertullians) គឺពិតជាត្រឹមត្រូវ «លោហិតនៃមរណៈស្មរបន្ទាល់គឺជាគ្រាប់ពូជរបស់ពួកជំនុំ»។

**ការពិចារណា៖** តើខ្ញុំស្មោះត្រង់ចំពោះបុព្វហេតុនៃឈើឆ្កាងព្រះយេស៊ូវគ្រីស្ទដែរឬទេ?

**ការអធិស្ឋាន៖** ឱព្រះអម្ចាស់ សូមឲ្យយើងខ្ញុំស្មោះត្រង់ចំពោះទ្រង់រហូតដល់មរណាចុះ!

# លោកយ៉ូហានគ្មានជីវិតដ៏អស់កល្បទេ តែជាព្រះយេស៊ូវិញ!

បន្ទាប់ពីព្រះអម្ចាស់នៃយើងទ្រង់បានប្រទានមកុដមរណៈស្មរបន្ទាល់ដល់សាវ័កពេត្រុស ជាប្រធានក្រុមសាវ័ក ទើបគាត់ទទួចចង់ដឹងអំពីអនាគតរបស់យ៉ូហាន។ លោកកាល់វិនបានមានប្រសាសន៍ថា៖ «យើងមិនត្រឹមតែមានសំណួរបន្តិចបន្តួចរបស់យើងដូចជាពេត្រុសនោះទេ ប៉ុន្តែថែមទាំងមានការទទួចចង់ដឹងដ៏គ្រោះថ្នាក់ដែលនាំឱ្យយើងប្រាសចាកពីភារៈកិច្ចរបស់យើងរវល់ដេញដោលនឹងបញ្ហាអ្នកដទៃផងដែរ»។ ដូចមានសុភាសិតមួយពោលថា៖ «ការប្រៀបធៀបគឺប្រៀបដូចជាក្លិនដ៏ស្អុយអាសោចមួយ» យើងគួរតែយកចិត្តទុកដាក់នឹងពាក្យទូន្មានដ៏ទន់ភ្លន់ដែលព្រះអម្ចាស់នៃយើងមានបន្ទូលឆ្លើយតបដល់ពេត្រុស។ «បើសិនជាខ្ញុំចង់ឲ្យអ្នកនោះនៅ ទាល់តែខ្ញុំមក នោះតើអំពល់អ្វីដល់អ្នក ចូរឲ្យអ្នកមកតាមខ្ញុំចុះ» (ខ ២២)។ តើអ្វីជាផែនការនៃព្រះសម្រាប់ជីវិតរបស់អ្នក? តើបំណងព្រះហឫទ័យដ៏បរិសុទ្ធរបស់ទ្រង់ដែលបញ្ជេះរូបអ្នកដូចជាធ្យូងជាអ្វី? សូមលះបង់ខ្លួនអ្នកទាំងមូលទុកជាការប្រតិបត្តិតាមបង្គាប់ទ្រង់ចុះ។ សាវ័កប៉ុលនៅក្នុងសេចក្តីបង្រៀនរបស់គាត់មានប្រសាសន៍ថា «តែខ្ញុំកំពុងតែដេញតាម សង្ឃាតនឹងចាប់ឲ្យបានសេចក្តីដែលព្រះគ្រីស្ទយេស៊ូវបានចាប់ខ្ញុំឲ្យបាននោះដែរ» (ភីលីព ៣:១២)។ ចូរឱ្យយើងរៀនពីប៉ុលក្នុងការ «ដេញតាម» ព្រះគ្រីស្ទ។

ចេញពីបណ្តៅនៃពាក្យបន្ទូលរបស់ព្រះគ្រីស្ទ «បើសិនជាខ្ញុំចង់ឲ្យអ្នកនោះនៅ ទាល់តែខ្ញុំមក» ជាពាក្យបង្កប់ន័យដែលគេជឿថាយ៉ូហានជាសិស្សម្នាក់ព្រះអម្ចាស់នៃយើងសន្យាប្រទានជីវិតអមតៈដល់គាត់។ នេះជាគំនិតយល់ខុសដ៏ធំមួយ ប្រហែលជាពាក្យដំណាលតៗគ្នានៃពួកជំនុំស្រុកអេភេសូរជាពួកជំនុំរបស់សាវ័កយ៉ូហានប៉ុណ្ណោះ។ រឿងមួយទៀតដំណាលប្រាប់ពីសាវ័កយ៉ូហាន អំពីការដែលលោកបង្គាប់ឱ្យគេជីករណ្តៅសពមួយសម្រាប់គាត់ ហើយគាត់បានចូលទៅក្នុងរណ្តៅបញ្ចុះសពនោះ ស្រាប់តែនៅថ្ងៃបន្ទាប់គេមិនឃើញអ្វីនៅក្នុងផ្នូរនោះសោះឡើយ! នៅក្នុងអវសានក្តកថានេះសាវ័កយ៉ូហានលើកយកព្រេងកថាដែលបម្រុងនឹងផ្សព្វផ្សាយអំពីរូបគាត់មកបំភ្លឺ។

មានបុគ្គលម្នាក់ដែលមានជីវិតអមតៈ គឺជាព្រះសង្គ្រោះដ៏មានព្រះជន្មរស់ដែលបានសោយអាហារជាមួយក្រុមសាវ័កនាព្រឹកព្រលឹមស្រាងៗនោះ។ ជីវិតអមតៈរបស់ទ្រង់បានបញ្ជាក់កាន់តែច្បាស់តាមរយៈកំណត់ត្រាអំពីជីវភាពរបស់ទ្រង់ «បើនឹងសរសេរទុក ដោយលំដាប់តមក នោះលោកីយទាំងមូលក៏មិនល្មមគ្រាន់ដើម្បីនឹងដាក់អស់ទាំងសៀវភៅដែលត្រូវសរសេរនោះផង។ អាម៉ែន»។ មិត្តអ្នកអានជាទីស្រឡាញ់ សូមឱ្យអ្នករកឃើញជីវិត ជាជីវិតដ៏អស់កលក្បជានិច្ច ជាជីវិតមួយដ៏ពេញបរិបូរតាមរយៈការអានម្តងហើយម្តងទៀតនៅក្នុងដំណឹងល្អនៃជីវិតនេះ។

**ការពិចារណា៖** ជីវិតអមតៈគឺជាជីវិតដ៏អស់កល្បដែលព្រះយេស៊ូវប្រទានដល់អ្នកជឿដល់ទ្រង់។

**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមកុំឲ្យយើងខ្ញុំឃ្លាតឆ្ងាយពីជីវិតដែលទ្រង់ប្រទានឡើយ!

# សំបុត្រនៃជីវិត

ថ្វីត្បិតឈ្មោះយ៉ូហានមិនបានបញ្ជាក់នៅក្នុងសំបុត្រទាំងនេះដែលជាសំបុត្រត្រូវបានគេសន្មត់ថាជាស្នាដៃរបស់គាត់ក៏ «មានភាពស្និតរមួតជាមួយនឹងដំណឹងល្អទីបួនទាំងរចនាបថនិងប្រធានបទដែលអ្នកប្រាជ្ញភាគច្រើនយល់ស្របថាជាសំណេរទាំងបួនគឺមកពីអ្នកសរសេរតែម្នាក់ដែរ» (ការអត្ថាធិប្បាយព្រះគម្ពីរថ្មី « New Bible Commentary» )។

ហើយដរាបណាដំណឹងល្អទីបួនត្រូវបានថែងមកថា «ដើម្បីឲ្យអ្នករាល់គ្នាបានជឿថាព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត ហើយឲ្យអ្នករាល់គ្នាបានជីវិត ដោយសារព្រះនាមទ្រង់ ដោយមានសេចក្តីជំនឿ» (យ៉ូហាន ២០:៣១) សំបុត្រទាំងនេះគឺត្រូវបានសរសេរមកសម្រាប់អ្នក «ដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ» (១ យ៉ូហាន ៥:១៣)។ ដូចជាយើងហៅដំណឹងល្អយ៉ូហានជាដំណឹងល្អនៃជីវិត ដូចនេះក៏បណ្តាលឲ្យយើងហៅសំណេរអមនេះថាជាសំបុត្រនៃជីវិតផងដែរ។ តើនឹងអាចយកអ្វីនៅក្នុងលោកនេះមកប្រៀបស្មើនឹងជីវិត? «ដ្បិតបើសិនជាមនុស្សណានឹងបានលោកីយទាំងមូល ប៉ុន្តែធ្វើឲ្យខ្លួនឯង ឬបាត់បង់ នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ?» (លូកា ៩:២៥)។ ដំណឹងល្អនៃជីវិតគឺដើម្បីនាំអ្នកឆ្ពោះទៅរកជីវិត។ សំបុត្រនៃជីវិតគឺដើម្បីកសាងរូបអ្នកឡើងនៅក្នុងជីវិត ជាប្រយោជន៍កុំឲ្យអ្នកគ្រាន់តែសង្ឃឹមថានឹងបានសេចក្តីសង្គ្រោះនោះឡើយ តែក៏នាំឲ្យអ្នកមានទំនុកចិត្តថែមទៀតផងដែរ។ សំបុត្រទាំងនេះគឺជាគោលលទ្ធិនៃជីវិតដ៏អស់កល្បជានិច្ច។

សំបុត្រទាំងបីនេះគឺជាការបន្ថែមនៃដំណឹងល្អដែលតាមរយៈសំណេរបន្ថែមនេះវាជាការអត្ថាធិប្បាយបំភ្លឺពីដំណឹងល្អនិងការពារដំណឹងល្អផងដែរ។ ពីព្រោះពួកជំនុំសម័យដើមរងការវាយប្រហារពីសំណាក់បុគ្គលអាក្រក់ ជាវិញ្ញាណរបស់អាប្រឆាំងនឹងព្រះគ្រីស្ទ តាមរយៈអញ្ញមតិ (លទ្ធិខុសឆ្គង) និងទស្សនវិជ្ជាបែបលោកីយ ហេតុនេះបក្សពួកនិយមបានបង្កជារបួសស្នាមដល់សាមគ្គីភាពរបស់ពួកជំនុំរួចមកហើយដែរ (១ យ៉ូហាន ២:១៩)។ ខណៈពេលសំបុត្រទាំងនេះគឺជាបំណកស្រាយយ៉ាងម៉ឺងម៉ាត់ទប់ទល់នឹងការអះអាងដ៏ខុសឆ្គងនៃសេចក្តីបង្រៀនពីការស្គាល់ព្រះជាម្ចាស់តាមរយៈចំណេះដឹងអាថ៌កំបាំង (Gnosticism) ដែលបង្រៀនថាសេចក្តីសង្គ្រោះទទួលបានមកដោយសារការចាប់ផ្តើមទៅក្នុងប្រព័ន្ធ «ចំណេះដឹង» នៃការបដិសេធន៍កំណើតជាមនុស្សរបស់ព្រះគ្រីស្ទ ពោលជាវិជ្ជមាន ពួកគេបង្រៀនពីជីវិតសុចរិត សេចក្តីស្រឡាញ់ជាបងប្អូននិងជំនឿលើព្រះយេស៊ូវ ជាព្រះនៅក្នុងសាច់ឈាម។ ព្រះជាម្ចាស់គឺជាសេចក្តីស្រឡាញ់ហើយព្រះគឺជាពន្លឺ តែលើសជាងនោះទៅទៀតព្រះជាម្ចាស់ទ្រង់គឺជាព្រះវរបិតាដែលគង់នៅឯនគរស្ថានសួគ៌នៃយើង ហើយពួកយើងគឺជាកូនតូចៗរបស់ទ្រង់។ ហេតុនេះយើងគួរស្វែងរកទ្រង់ហើយរក្សាខ្លួនយើងពីរូបព្រះ!

**ការពិចារណា៖** តើខ្ញុំស្វែងរកជីវិតក្នុងព្រះគ្រីស្ទ?

**ការអធិស្ឋាន៖** យើងខ្ញុំសូមអរព្រះគុណសម្រាប់ជីវិតដែលទ្រង់ប្រទានតាមរយៈព្រះយេស៊ូវគ្រីស្ទ។

## ជីវិតដ៏អស់កល្បនៅក្នុងព្រះជាម្ចាស់បានបើកសម្តែងដល់មនុស្ស

ភាពប្រហាក់ប្រហែលគ្នាដែលសាវ័កធ្វើសេចក្តីអត្ថាធិប្បាយនៅសំបុត្រនេះគឺពិតជាដូចគ្នានឹងអ្វីគាត់បានធ្វើនៅក្នុងដំណឹងល្អខ្លាំងណាស់។ ឃ្លា «តាំងពីដើមមក» ដែលបានចែងនៅខនេះគឺដូចគ្នានឹងឃ្លា «កាលដើមដំបូង» នៃដំណឹងល្អ យ៉ូហាន ១:១ ពោលគឺពីមួយជំនាន់ទៅជំនាន់មួយមុន «កាលដើមដំបូង« នៃលោកុប្បត្តិ ១:១ ជាពេលព្រះទ្រង់បានបង្កើតពិភពលោក។

ឯសេចក្តីដែលមានតាំងពីដើមមក លោកកាល់វិនមានប្រសាសន៍គឺសំដៅចំពោះនិស្ស័យជាព្រះរបស់ព្រះគ្រីស្ទ និស្ស័យរបស់ទ្រង់ដែលគង់នៅជាមួយនឹងព្រះជាម្ចាស់។ ចាប់តាំងពីអស់កល្បរៀងមក សេចក្តីដែលមានតាំងពីដើមមកនោះគ្មានពេលចាប់ផ្តើមឡើយ!

យ៉ូហានលោកធ្វើទីបន្ទាល់ពីខ្លួនគាត់នឹងសាវ័កដទៃទៀតជាអ្នកបានចូលមកក្នុងទំនាក់ទំនងនឹងព្រះជាម្ចាស់ ជាអង្គបុគ្គលដែលបានមកក្នុងសាច់ឈាម (១ យ៉ូហាន ៤:២) ហេតុនេះទើបយើងខ្ញុំ «បានឮហើយភ្នែកបានឃើញ ក៏បានមើល ហើយដៃបានប៉ះពាល់» (ខ ១។ ពាក្យនេះឆ្លុះបញ្ចាំងពីសេចក្តីដែលយ៉ូហានបានសរសេរកាលពីមុនមក «ព្រះបន្ទូលក៏ត្រឡប់ជាសាច់ ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណនឹងសេចក្តីពិត» (យ៉ូហាន ១:១៤)។

សម្រាប់រយៈពេលបីឆ្នាំកន្លះ សាវ័កយ៉ូហានក៏ដូចជាសាវ័កឯទៀតបានរស់នៅជាមួយនឹងព្រះអម្ចាស់នៃយើង និងបានដើរហើយប្រកបគ្នានៅពេលពួកគេធ្វើដំណើរគ្រប់ទីកន្លែងប្រកាសនិងបង្រៀនពាក្យបន្ទូលហើយនិងប្រោសជម្ងឺក្នុងស្រុកយូដា។ ពួកគេជឿអស់អំពីចិត្តរបស់គេថាព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះ ជាព្រះសង្គ្រោះនៃពិភពលោក។ នៅពេលទស្សនិកជនមួយភាគធំរបស់ព្រះយេស៊ូវបានចាកចេញពីទ្រង់ព្រោះតែគ្មានជំនឿ ពួកសាវ័កបានបន្តនៅជាប់នឹងទ្រង់ដោយឆ្លងកាត់រាល់ឧបសគ្គ។ នៅគ្រាព្រះយេស៊ូវសាកចិត្តពួកគេបន្ទាប់ពីបានផ្គត់ផ្គង់អាហារដល់មនុស្សប្រាំពាន់នាក់ ប្រសិនបើគេនឹងចាក់ចេញទៅដែរ ពេត្រុសបានឆ្លើយទូលថា «ព្រះអម្ចាស់អើយ តើយើងខ្ញុំនឹងទៅឯអ្នកណាវិញ? គឺទ្រង់ហើយ ដែលមានព្រះបន្ទូលនៃជីវិតដ៏នៅអស់កល្បជានិច្ច។ យើងខ្ញុំក៏បានជឿ ហើយដឹងថា ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ពិត» (យ៉ូហាន ៦:៦៨-៦៩)។ តើអ្នកអាចថ្លែងដូច្នោះអំពីព្រះយេស៊ូវគ្រីស្ទដែរឬទេ?

នៅក្នុងដំណឹងល្អព្រះគ្រីស្ទត្រូវបានហៅថាជាព្រះបន្ទូល។ នៅក្នុងសំបុត្រនេះទ្រង់ត្រូវបានហៅថាជាព្រះបន្ទូលនៃជីវិត ឬជាព្រះបន្ទូលដ៏រស់ ដោយផ្អែកលើការប្រកាសប្រាប់ពីមុនថា «នៅក្នុងទ្រង់មានជីវិត» (យ៉ូហាន ១:៤)។ ព្រះយេស៊ូវជាព្រះបន្ទូលនៃជីវិតព្រោះទ្រង់បានចាក់ប្រទានជីវិតរបស់ទ្រង់ដល់មនុស្សជាតិទាំងមូល ហើយពេលនេះព្រះអង្គតាំងជីវិតឡើងវិញនៅក្នុងយើងដែលជាអ្នកធ្លាប់បានបាត់បង់ហើយស្លាប់ក្នុងក្នុងបាបរបស់លោកអ័ដាម(កាល់វិន)។

**ការពិចារណា៖** បាបជានាំងបិទបាំងមិនឲ្យមនុស្សជាតិរកជីវិតក្នុងព្រះជាម្ចាស់។

**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ នៅក្នុងទ្រង់ហើយមានជីវិតដ៏នៅអស់កល្បជានិច្ច!

## ជីវិតក្នុងការប្រកបគ្នានៃគ្រីស្ទបរិស័ទ

នៅក្នុងដំណឹងល្អ យ៉ូហាន ១:១២,១៣ សាវ័កមានបង្រៀនថា «ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឲ្យត្រឡប់ជាកូនព្រះ គឺជាកូនដែលមិនមែនកើតមកពីឈាម ឬតាមប្រាថ្នាខាងរូបសាច់ ឬតាមចំណង់នៃមនុស្សឡើយ គឺកើតមកអំពីព្រះវិញ» ។

នោះគឺជាពួកអ្នកបានកើតជាថ្មី ជាអ្នកបានទទួលព្រះគ្រីស្ទជាព្រះសង្គ្រោះនិងបានត្រឡប់ជាកូនព្រះដែលចាប់ផ្តើមរស់នៅជីវិតថ្មី។ ជីវិតថ្មីនេះ នៅក្នុងវាមានទំនាក់ទំនងគ្នាទៅវិញទៅមក គឺរវាងព្រះជាម្ចាស់និងមនុស្ស រវាងគ្រីស្ទបរិស័ទនិងគ្រីស្ទបរិស័ទដទៃទៀត ហើយជីវិតនេះត្រូវបានហៅថាជាការប្រកបគ្នា។ ការប្រកបគ្នាមានលក្ខណៈពិសេសចំពោះជំនឿគ្រីស្ទបរិស័ទ។ វាគឺលើសជាងមិត្តភាពដែលពួកអ្នកប្រកាន់លទ្ធិកុម្មុយនីស្តនិងអ្នកសង្គមនិយមបង្រៀនអំពីមិត្តភាពនៃការប្រមូលផ្តុំប្រជាជនឲ្យមានគំនិតជាធ្លុងតែមួយដើម្បីផែនការដ៏កំពូលរបស់លទ្ធិទាំងនោះទៅទៀត។

ចំពោះការប្រកបគ្នានៃគ្រីស្ទបរិស័ទជាចាំបាច់ត្រូវតែទាក់ទងនឹងព្រះវរបិតាហើយនឹងព្រះរាជបុត្រា គឺតាមរយៈព្រះរាជបុត្រានៃព្រះដ៏ជាព្រះវរបិតា។ ជាបឋមត្រូវតែមានទំនាក់ទំនងបែបរយៈកំពស់មុនពេលនឹងអាចមានទំនាក់ទំនងបែបរាបស្មើ។ វាគឺជាជីវិត និងជាប្រពន្ធ័សរីរាង្គ មិនមែនលក្ខណៈជាអង្គការទេ គឺដូចជាដើមឈើនិងមិនមែនទ្រង់ទ្រាយដូចជាឈើឡើយ។

នៅក្នុងសំបុត្រនេះសាវ័កគឺកំពុងបើកសម្តែងដល់ពួកអ្នកជឿថ្មោងថ្មីនូវកំណប់នៃការប្រកបគ្នារបស់គ្រីស្ទបរិស័ទ។ «យើងខ្ញុំក៏សរសេរសេចក្តីទាំងនេះ ផ្ញើមកអ្នករាល់គ្នា ដើម្បីឲ្យសេចក្តីអំណររបស់អ្នករាល់គ្នាបានពោរពេញឡើង» (១ យ៉ូហាន ១:៤)។ គាត់កំពុងប្រាប់យើងថា «តើវាមិនមែនអស្ចារ្យទេថាយើងបានត្រឡប់ជាកូនប្រុសនិងកូនស្រីរបស់ព្រះជាម្ចាស់ ជាសមាជិកតែមួយរបស់គ្រួសារព្រះ ហើយយើងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងព្រះដ៏ជាព្រះវរបិតាតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើង?» ។ យ៉ូហានចង់បញ្ជាក់ប្រាប់ដល់គ្រីស្ទបរិស័ទថ្មោងថ្មីបន្ថែមទៀតអំពីការប្រកបគ្នាដែលពួកជំនុំនឹងបង្កើននូវវិសាលភាពដល់ពួកគេនៅពេលគេបានជឿពិតប្រាកដដែរ។

តើអ្នកមិនធ្លាប់មានបទពិសោធន៍នូវទំនាក់ទំនងបែបព្រលឹងវិញ្ញាណថ្មីនេះដែលមានលក្ខណៈស៊ីជម្រៅហើយផ្អែមល្ហែមជាងទំនាក់ទំនងដ៏ខ្ពង់ខ្ពស់នៃមិត្តភាពធម្មតា? បងប្អូនប្រុសស្រីផ្នែកព្រលឹងវិញ្ញាណគឺជិតស្និទ្ធជាងបងប្អូនប្រុសស្រីផ្នែកសាច់ឈាមទៅទៀត «ប៉ុន្តែមានមិត្រសំឡាញ់ម្យ៉ាង ដែលនៅជាប់ជាងបងប្អូនទៅទៀត» (សុភាសិត ១៨:២៤)។

**ការពិចារណា៖** ព្រះយេស៊ូវជាមិត្តសម្លាញ់ពិត!
**ការអធិស្ឋាន៖** សូមឲ្យយើងខ្ញុំប្រកបគ្នានឹងទ្រង់ជាប្រចាំថ្ងៃផង ឱព្រះអម្ចាស់អើយ!

ថ្ងៃទី ២៨ សីហា

១ យ៉ូហាន ១:៥-៧ «ព្រះទ្រង់ជាពន្លឺភ្លឺ»

## ពន្លឺនៅក្នុងការប្រកបគ្នានៃគ្រីស្ទបរិស័ទ

ដូចជានៅក្នុងយ៉ូហានជំពូកទី១ត្រង់ចំណុចដែលសម្តែងថាព្រះយេស៊ូវគ្រីស្ទជាពន្លឺបន្ទាប់ពីព្រះអង្គត្រូវបានប្រកាសថាជាប្រភពនៃជីវិត សាវ័កបង្ហាញប្រាប់ពីអង្គទ្រង់តាមបែបដូច្នោះដែរ។ ព្រះបន្ទូលនៃជីវិតគឺមានរយៈកាលយូរដូចជា «ព្រះទ្រង់ជាពន្លឺភ្លឺ» ដែរ។

ដោយហេតុតែព្រះទ្រង់ជាពន្លឺ ការប្រកបគ្នានៃគ្រីស្ទបរិស័ទទោះបីបែបជាខ្សែបន្ទាត់ឈរឬខ្សែបន្ទាត់ផ្តេកក៏ត្រូវតែប្រព្រឹត្តធ្វើឡើងនៅក្នុងពន្លឺដែរ។ ការប្រកបគ្នានៃគ្រីស្ទបរិស័ទមិនអាចប្រព្រឹត្តឡើងនៅក្នុងសេចក្តីងងឹតបានទេពីព្រោះបែបនោះគឺជាការមិនអាចធ្វើបាន។ បញ្ចាំងពន្លឺភ្លើងពិលទៅក្នុងរូងងងឹត ហើយតើនឹងមានអ្វីកើតឡើង? ស្បែងងងឹតនឹងរលាយបាតអស់! បើសិនសេចក្តីដែលហៅថាការប្រកបគ្នានៃគ្រីស្ទបរិស័ទគឺប្រព្រឹត្តឡើងនៅក្នុងសេចក្តីងងឹត ឬក្នុងស្រមោលនៃសេចក្តីងងឹតទេ ដូច្នោះវាគឺមិនមែនជាការប្រកបគ្នានៃគ្រីស្ទបរិស័ទឡើយ។ វាគឺជាការភូតកុហក។ វាគឺមិនមែនជាសេចក្តីពិត។ ចំណុចនេះពិតជាមេរៀនសម្រាបពួកជំនុំទាំងមូល គឺពីគ្រូគង្វាលរហូតដល់ចាស់ទុំ ដល់គ្រូជំនួយ និងដល់សមាជិកព្រះវិហារដែរ។

ខណៈពេលពួកជំនុំគឺជាអង្គការដែលអាចមើលឃើញនឹងភ្នែក វាមានវិបត្តិច្រើនជាទម្ងន់។ ជារឿយៗការនិយាយដើមគ្នាកើតឡើងជំនួសដំណឹងល្អ។ ពាក្យពេចន៍មិនល្អសាយភាយជាលទ្ធផល។ ពន្លឺគឺត្រូវបានគ្របបាំងដោយសេចក្តីងងឹត គឺដោយសារតែអ័ក្រនិងព្រិល។

ប៉ុន្តែពួកជំនុំមិនត្រូវប្រឡូកប្រឡាក់នឹងស្ថានភាពបែបនោះឡើយ។ បើសេចក្តីងងឹតចាប់ផ្តើមរាលដាលមកពួកជំនុំ គឺមានដំណោះស្រាយពីការជំពាក់ជំពិនគ្នាបើយើងប្រើដំណាក់ការនៃការផ្សះផ្សាគ្នាដែលបានបង្កើតឡើងដោយព្រះអម្ចាស់នៃយើងនៅក្នុងដំណឹងល្អម៉ាថាយ ១៨:១៥-១៧។ ទាំងអស់មានបួនដំណាក់ការដើម្បីរំដោះយើងចេញពីសេចក្តីងងឹត៖

(១) ការជួបគ្នាជាឯកជនរវាងរូបអ្នកនឹងបងប្អូនប្រុសឬស្រីតែពីរនាក់។

(២) បើការនេះបរាជ័យ សូមនាំមួយនាក់ឬពីរនាក់ទៅជាមួយធ្វើជាសាក្សី។

(៣) បើបរាជ័យតទៅទៀតសូមលើកបញ្ហានោះចំពោះមុខគ្រូគង្វាល ឬថ្នាក់ដឹកនាំព្រះវិហារ។

(៤) បើសិនជានៅតែមិនអាចជោគជ័យទៀត សូមចាត់ទុកបងប្អូនប្រុសឬស្រីនោះដូចជាអ្នកមិនជឿព្រះ។ ការប្រកបគ្នានឹងត្រូវបានរក្សាយ៉ាងល្អ។ កណ្តុំខ្សែដែលមិនអាចតភ្ជាប់បានត្រូវតែកាត់វាចោល។

ប្រសិនបើវាបានជោគជ័យ នៅក្នុងដំណាការទាំងបី ការប្រកបគ្នាគឺនឹងត្រូវតាំងឡើងវិញដោយនូវក្នុងការអត់ទោសគ្នាទៅវិញទៅមកក្នុងព្រះយេស៊ូវគ្រីស្ទ (ខ ៧)។

**ការពិចារណា៖** ដើរ ដើរ ដើរ ដើរក្នុងពន្លឺ!

**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ សូមសម្អាតចិត្តយើងខ្ញុំឲ្យមានសេចក្តីស្រឡាញ់ដ៏បរិសុទ្ធផង។

ថ្ងៃទី ២៩ សីហា
១ យ៉ូហាន ១:៨-១០

*« បើសិនជាយើងថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន..»*

## ចិត្តដែលមិនផ្លាស់ប្រែគឺជាចិត្តខ្មៅ

នៅក្រោមចំណាំងភ្លើងនៃព្រះដ៏ជាពន្លឺ ទោះបីជីវិតស្អាតស្អំនិងបរិសុទ្ធយ៉ាងណាដែលយើងមានជីវភាពរស់នៅ យើងគឺគ្រាន់តែអាចនិយាយដូចជាពាក្យរបស់ហោរាអេសាយប៉ុណ្ណោះ «វរហើយខ្ញុំ ខ្ញុំត្រូវវិនាសជាពិត ដ្បិតខ្ញុំជាមនុស្សមានបបូរមាត់មិនស្អាត ហើយខ្ញុំនៅកណ្តាលបណ្តាមនុស្សដែលមានបបូរមាត់មិនស្អាតដែរ ពីព្រោះភ្នែកខ្ញុំបានឃើញមហាក្សត្រ គឺជាព្រះយេហូវ៉ានៃពួកពលបរិវារ» (អេសាយ ៦:៥)។ ចុះទំរាំនៅពេលយើងពាក់ព័ន្ធនឹងបងប្អូនក្នុងជម្លោះទាស់ទែងគ្នា នោះមិនថ្វីថាជារឿងរ៉ាវបន្តិចបន្តួចឡើយ។

វានឹងមិនធ្វើឡើងដើម្បីបំប៉ោងសេចក្តីសុចរិតផ្ទាល់ខ្លួននៃបុគ្គលណាម្នាក់ទេ។ យើងមិនគួរដះកំហឹងដាក់អ្នកដទៃទេ គឺចំពោះបងប្អូនដែលយើងមានវិវាទជាមួយយើងឡើយ។ នេះគឺជាសេចក្តីដែលសាវ័កចង់ដាស់តឿននៅពេលគាត់បង្រៀនថា «បើសិនជាយើងថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្តីពិតមិនស្ថិតនៅក្នុងយើងទេ» (ខ ៨)។

ប៉ុន្តែចិត្តដែលផ្លាស់ប្រែគឺតែងតែជាទីគាប់ព្រះទ័យចំពោះព្រះជាម្ចាស់ «ឯយញ្ញបូជាដែល គួរថ្វាយដល់ព្រះនោះគឺជាវិញ្ញាណខ្ទេចខ្ទាំ ឱព្រះអម្ចាស់អើយ ទ្រង់មិនមើលងាយចំពោះចិត្តខ្ទេចខ្ទាំ ហើយទន់ទាបឡើយ» (ទំនុក. ៥១:១៧)។ «បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ហើយសុចរិតប្រយោជន៍នឹងអត់ទោសបាបឲ្យយើងហើយនឹងសំអាតយើងពីគ្រប់អំពើទុច្ចរិតទាំងអស់ផង» (១ យ៉ូហាន១:៩)។

ដូច្នេះបងប្អូនដែលបន្តមិនព្រមផ្សះផ្សាគ្នារហូតដល់ «ដំណាក់កាលទីបួន» ព្រោះតែគាត់គិតថាខ្លួនស្អាតស្អំគឺប្រៀបដូចជានិយាយថា ព្រះគឺជាអ្នកកុហក! ប៉ុន្តែពាក្យបន្ទូលទ្រង់គឺមិននៅស្ថិតក្នុងបុគ្គលម្នាក់នោះឡើយ។ តាមពិតគាត់បានបដិសេធព្រះជាម្ចាស់ មិនមែនបដិសេធមនុស្សទេ! ចិត្តដ៏រឹងរូសរបស់គាត់បានប្រែជាចិត្តបិទគឺជាចិត្តខ្មៅ។

តើការប្រកបគ្នានៃគ្រីស្ទបរិស័ទរបស់យើងជ្រះថ្លាដែរទេ? តើយើងហ៊ាននិយាយពាក្យដែលយើងបាននិយាយដើមអ្នកដទៃនៅចំពោះមុខពួកគាត់ដែរទេ? មេរៀនមួយពីស្តេចសាឡូម៉ូនគឺ «របួសដែលមិត្រសំឡាញ់ធ្វើដល់យើង នោះតែងធ្វើដោយស្មោះត្រង់ទេ តែឯការថើបរបស់ខ្មាំងសត្រូវ នោះជាសេចក្តីបញ្ឆោតវិញ» (សុភាសិត ២៧:៦)។ សូមទន្ទេញឲ្យចាំមាត់!

ក្នុងចំណុមក្រុមសាវ័កទាំងដប់ពីនាក់ តើអ្នកណាម្នាក់មានចិត្តខ្មៅ?

**ការពិចារណា៖** តើមានអ្វីអាចលាងបាបបាន មានតែឈាមវិសេសព្រះយេស៊ូវ!

**ការអធិស្ឋាន៖** សូមឲ្យការប្រកបគ្នាជាបងប្អូនរបស់យើងខ្ញុំប្រកបដោយភាពស្មោះត្រង់។

# ១ យ៉ូហាន ២

## ច្បាប់នៃការប្រកបគ្នា

ដូចជាយើងបានឃើញរួចមកហើយថានៅក្នុងជំពូកមុន ការប្រកបគ្នានៃគ្រីស្ទបរិស័ទអាចនឹងខូចបង់ដោយសារអំពើបាបរបស់សមាជិកណាម្នាក់នៃក្រុមប្រកបគ្នានោះ។ ដើម្បីរក្សាការប្រកបគ្នានេះគោលការណ៍មួយចំនួនត្រូវតែបង្កើតឡើងដែលយើងសង្ខេបមកនៅក្រោមពាក្យថា « ច្បាប់» ។

(១). រវាងសមាជិកនៃពួកជំនុំហើយនិងថ្នាក់ដឹកនាំនៃពួកជំនុំ ដែលមានព្រះយេស៊ូវគ្រីស្ទ ជាអ្នកជួយការពារ ដើម្បីទូលអង្វរជំនួសបុព្វហេតុរបស់យើង ជាអង្គបុគ្គលដែលក្លាយជាដង្វាយធួននឹងបាបរបស់យើង។

(២). រវាងសមាជិកផ្ទាល់ខ្លួនដែលពួកគេត្រូវតែរក្សាតាមបញ្ញត្តិដែលត្រូវបានសង្ខេបថា «គឺឲ្យអ្នករាល់គ្នាស្រឡាញ់ដល់គ្នាទៅវិញទៅមក» ។

(៣). ចំពោះលោកីយយើងត្រូវរក្សាពីការស្រឡាញ់ដល់វា ឬសេចក្ដីប៉ងប្រាថ្នារបស់វា។ ការស្រឡាញ់លោកីយហើយនិងការស្រឡាញ់ព្រះជាម្ចាស់គឺវាផ្ទុយគ្នាស្រឡះ។

(៤). ចំពោះអាទទឹងនឹងព្រះគ្រីស្ទដែលបានក្លែងខ្លួនបន្លំជាបងប្អូននៅក្នុងព្រះគ្រីស្ទ ជាចាំបាច់យើងត្រូវដកវាចេញពីការប្រកបគ្នា។

(៥). នៅក្នុងបញ្ហានៃការថ្កោលទោស ការប្រកបគ្នាមានព្រះដ៏បរិសុទ្ធចាក់លាបឲ្យដើម្បីជួយពួកគេវិនិច្ឆ័យរវាងកំហុសនិងសេចក្ដីពិត។ ការចាក់លាបនេះបំភ្លឺយើងឲ្យចៀសចេញពីការវង្វេង។

(៦). ការនៅជាប់នឹងព្រះគ្រីស្ទគឺជាការធានាពីសេចក្ដីសង្គ្រោះរបស់យើងរហូតដល់ព្រះគ្រីស្ទទ្រង់យាងមកម្ដងទៀត។

ចូរយើងល្បងលខ្លួនឯងយើងប្រសិនបើយើងពិតជាកំពុងរក្សាតាមច្បាប់នៃការប្រកបគ្នាទាំងនេះ មិនមែនតាមរយៈការរក្សាច្បាប់នេះយើងនឹងបានសង្គ្រោះទេ តែការបានសង្គ្រោះការរក្សាច្បាប់នេះ ក្លាយជាការប្រតិបត្តិរបស់យើងវិញ។ ទំនុកដំកើង ១១៩:៩៧-៩៩ « ឱទូលបង្គំស្រឡាញ់ក្រិត្យវិន័យរបស់ទ្រង់ណាស់ហ្ន៎ទូលបង្គំរំពឹងគិតពីក្រិត្យវិន័យនោះជាដរាបរាល់ថ្ងៃ។ សេចក្ដីបង្គាប់របស់ទ្រង់ ក៏ធ្វើឲ្យទូលបង្គំមានប្រាជ្ញាលើសជាងខ្មាំងសត្រូវ ដ្បិតបាននៅជាប់ជាមួយនឹងទូលបង្គំជាដរាប។ ទូលបង្គំមានយោបលជាងអស់ទាំងគ្រូរបស់ទូលបង្គំទៅទៀត ដ្បិតសេក្ដីបន្ទាល់ទ្រង់ជាទីនឹករំពឹងរបស់ទូលបង្គំ» ។ សូមទន្ទេញឲ្យចាំមាត់!

**ការពិចារណា៖** ការប្រតិបត្តិចេញពីសេចក្ដីស្រឡាញ់ទើបជាព្រះពរ។
**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមបំពេញយើងខ្ញុំដោយក្ដីស្រឡាញ់នៃការប្រតិបត្តិដល់ទ្រង់ផង!

## អ្នកការពារសម្រាប់សមាជិកដែលធ្វើអំពើបាប

នៅពេលសមាជិកពួកជំនុំធ្លាក់ទៅក្នុងអំពើបាប ពួកគេជាចាំបាច់ត្រូវតែត្រឡប់មកឯព្រះវរបិតាវិញ។ ប៉ុន្តែត្រូវតាមរយៈអ្នកការពារតែម្នាក់គត់ជាអ្នកអាចទូលដល់ព្រះវរបិតាជំនួសយើង។ អ្នកការពារ បើតាមភាសាឡាទីន ជាអ្នកដែលអាចអញ្ជើញមកអង្វរជំនួសបុគ្គលណាម្នាក់។ នៅក្នុងភាសាក្រេកពាក្យនេះគឺ *ប៉ារ៉ាក្លែតូស* (*paraketos*) ដែលត្រូវបានបកប្រែថាជាអ្នកជំនួយ (*Comforter*) នៅក្នុងយ៉ូហាន ១៥:១៦, ២៥។ អ្នកការពារ (*advocate*) គឺពាក្យក្លាយនៅក្នុងខនេះ។ ព្រះយេស៊ូវគ្រីស្ទគឺមានតួនាទីដូចជាមេធាវីការពារក្ដីដែលកំពុងធ្វើជាអ្នកតំណាងឲ្យយើងក្នុងអង្គជំនុំជំរះនៃព្រះវរបិតាដ៏ជាចៅក្រម ហើយទ្រង់គង់នៅក្នុងតួនាទីនោះដើម្បីទូលអង្វរជំនួសយើងរាល់គ្នា។

ប៉ុន្តែអ្នកការពារនៅក្នុងព្រះសង្គ្រោះនៃយើងគឺប្រសើរជាជាងអ្នកការពារជាមនុស្ស។ អ្នកការពារជាមនុស្សអាចនឹងជោគជ័យឬក៏បរាជ័យក្នុងតួនាទីនៃកិច្ចការពាររបស់គាត់។ ព្រះអម្ចាស់នៃយើងទទួលបានជោគជ័យជានិច្ចព្រោះទ្រង់គឺក៏ជាដង្វាយធួននឹងបាប និងជាសំណាង ហើយជាយញ្ញបូជាដែលជាដង្វាយដ៏សព្វព្រះហឫទ័យដោយវិធីរបស់ទ្រង់ផ្ទាល់ជំនួសបាបរបស់យើង។ ព្រះអង្គមិនត្រឹមតែទូលអង្វរនឹងព្រះវរបិតាសូមឲ្យទ្រង់អត់ទោសដល់យើងប៉ុណ្ណោះទេ តែក៏បានលោះទណ្ឌកម្មនៃអំពីបាបរបស់យើងផងដែរ។ តើមានមេធាវីណាម្នាក់ដែលទៅតុលាការហើយបង់ថ្លៃការផាកពិន័យ ឬទទួលរងនូវការផ្ដន្ទាទោស ក៏ដូចជាព្រមទទួលនូវការផ្ដន្ទាទោសប្រហារជីវិតជំនួសកូនក្ដីរបស់ខ្លួនដែរទេ?

វាគឺជាការមួយដ៏គួរឲ្យចាប់អារម្មណ៍ក្នុងការសម្គាល់ពីការផ្ដត់ផ្ដង់នូវដង្វាយធួននឹងបាបជំនួសបាបនៃលោកីយទាំងមូល។ ថ្វីដ្បិតតែដង្វាយធួននឹងបាបមានសម្រាប់គ្រីស្ទបរិស័ទគឺវាមានប្រសិទ្ធិភាពសម្រាប់តែអ្នកជ្រើសតាំងទេ ហើយដង្វាយនេះក៏គ្រប់គ្រាន់សម្រាប់ពិភពលោកទាំងមូលដែរ។ ការផ្ដល់ឲ្យនូវដង្វាយធួននឹងបាបសម្រាប់របស់បាបលោកីយគឺជាបំណងព្រះហឫទ័យចង់បានដោយចេតនានៃព្រះជាម្ចាស់ (*desiderative will of God*) ដែលទ្រង់ «មានព្រះហឫទ័យអត់ធ្មត់នឹងយើងរាល់គ្នាវិញ ដោយមិនចង់ឲ្យអ្នកណាមួយវិនាសឡើយ គឺចង់ឲ្យមនុស្សទាំងអស់បានប្រែចិត្តវិញ» (២ ពេត្រុស ៣:៩)។ នោះគឺជាដំណឹងល្អយ៉ូហាន ៣:១៦ នៃសំបុត្រយ៉ូហាន។ សូមកុំបោះបង់ចោលឲ្យសោះទោះបីជានៅពេលអ្នកមានអារម្មណ៍ហាក់ដូចជាគ្មានក្ដីសង្ឃឹម ដូចជាវង្វេងឆ្ងាយពីព្រះជាម្ចាស់ជាដើម។ សាតាំងដែលច្រណែនឈ្នានីសនឹងជ័យជំនះរបស់យើងតែងព្យាយាមដឹកនាំយើងឲ្យធ្វើអត្តឃាត។ តែព្រះជាម្ចាស់នៃយើងជានិច្ចកាលគឺពេញដោយក្ដីសន្ដោសប្រណីវិញ។ ទ្រង់មានបន្ទូលថា «អស់អ្នកដែលនឿយព្រួយហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សំរាក» (ម៉ាថាយ ១១:២៨) «...ហើយអ្នកណាដែលមកឯខ្ញុំ ខ្ញុំក៏មិនដែលចោលទៅក្រៅឡើយ» (យ៉ូហាន ៦:៣៧)។ ខព្រះគម្ពីរបន្ថែមសម្រាប់អ្នកអានកាន់សាសនាកាតូលិក៖ «ពីព្រោះមានព្រះតែ១ ហើយមានអ្នកសង្រួបសង្រួមតែ១ នៅកណ្ដាលព្រះនឹងមនុស្ស» (១ ធីម៉ូថេ ២:៥)។

**ការពិចារណា៖** ប៉ារ៉ាក្លែតូស ព្រះដ៏ជាជំនួយ។

**ការអធិស្ឋាន៖** ឳព្រះអង្គអើយ សូមនាំជិត ជិត ឈើឆ្កាងទ្រង់ផង..!

ថ្ងៃទី ១ កញ្ញា
១ យ៉ូហាន ២:៣-១៤

*« អ្នកណាដែលស្អប់ដល់បងប្អូន នោះឈ្មោះថានៅក្នុងសេចក្តីងងឹត ?»*

# ការប្រកបគ្នា = ការស្តាប់បង្គាប់និងសេចក្តីស្រឡាញ់

តើធ្វើដូចម្តេចទើបអ្នកដឹងថាអ្នកបានសង្រ្គោះ? រួចហើយរីករាយនឹងការប្រកបគ្នាជាគ្រីស្ទបរិស័ទ? បើអ្នកស្រឡាញ់ព្រះអង្គនិងរក្សាបញ្ញត្តិរបស់ទ្រង់!នេះបញ្ជាក់នូវសេចក្តីដែលព្រះអម្ចាស់នៃយើងបានបង្រៀនដល់ពួកសិស្សក្នុងយ៉ូហាន ១៥ នៅក្នុងសេចក្តីអធិប្បាយអំពីដើមទំពាំងបាយជូរពិត។

នៅក្នុងពាក្យទូន្មានដល់គ្រីស្ទបរិស័ទឲ្យរក្សាបញ្ញត្តិរបស់ព្រះទុកជាសាក្ខីភាពអំពីចំណេះដឹងនិងពីការប្រកបគ្នាជាមួយនឹងព្រះជាម្ចាស់ យ៉ូហានបានលើកឡើងពីសារៈសំខាន់នៃការរក្សាតាមពាក្យបន្ទូលរបស់ទ្រង់ «បញ្ញត្តិចាស់» ដែលបានប្រទានមកដល់យើង តាមរយៈលោកម៉ូសេ និង ពួកហោរា។ នេះគឺជាព្រះគម្ពីរសញ្ញាចាស់ ពាក្យបន្ទូលពីបុរាណ។ អញ្ចឹងតើហេតុអ្វីបានជាបញ្ញត្តិថ្មី? យ៉ូហានបានប្រមូលផ្តុំនូវអ្វីដែលព្រះអម្ចាស់នៃយើងបានផ្តល់នៅក្នុងយ៉ូហាន ១៣:៣៤។ បញ្ញត្តិថ្មីគឺជាការអនុវត្តន៍សេចក្តីស្រឡាញ់ ជាផ្នែកម្ខាងទៀតនៃបញ្ញត្តិចាស់។ វាគឺជាក្រិត្យវិន័យរបស់ព្រះបានចែងជាវិជ្ជមានដើម្បីបំពេញឃ្លា «មិនត្រូវឲ្យឯង» របស់បញ្ញត្តិចាស់។ បញ្ញត្តិថ្មី ដែលផ្តោតលើការសម្តែងធ្វើនៃសេចក្តីស្រឡាញ់នៅក្នុងរង្វង់ការប្រកបគ្នានៃគ្រីស្ទបរិស័ទមិនផ្ទុយគ្នានឹងបញ្ញត្តិចាស់ទេ តែអនុវត្តវានៅក្នុងបរិបទថ្មី។ ដើម្បីសាកល្បងថាបុគ្គលម្នាក់រស់នៅក្នុងការប្រកបគ្នាពិតប្រាកដ ដែលត្រូវបានហៅថាពន្លឺ យ៉ូហានសួរថា «តើអ្នកស្រឡាញ់បងប្អូនរបស់អ្នកដែរឬទេ?» នេះគឺជាសំណួរអនុវត្តន៍ដ៏សមស្របមួយ ព្រោះវាគឺងាយស្រួលនឹងឃើញបងប្អូនប្រុសស្រីនៅក្នុងការប្រកបគ្នាដដែលបានចាកចេញទៅ។ ពេលនេះ អ្វីដែលយ៉ូហានសង្កត់ធ្ងន់ត្រង់ចំណុចនេះគឺចំពោះពួកជំនុំទាំងមូល ពីមនុស្សវ័យក្មេងរហូតដល់វ័យចំណាស់ ពីការប្របគ្នានៃក្រុមយុវជនរហូតដល់គណៈកម្មការនិងក្រុមប្រឹក្សាភិបាល។

ប្រសិនបើពួកជំនុំនឹងទៅជារឹងមាំ យើងត្រូវអនុវត្តភាពបរិសុទ្ធនិងសេចក្តីស្រឡាញ់នៅក្នុងការប្រកបគ្នា។ ហេតុនេះ ចូរយើងកុំធ្វើជាអ្នកនិយាយដើមគេឯង តែធ្វើជាអ្នកប្រាប់ពីដំណឹងល្អវិញ!

**ការពិចារណា៖** ហេតុអ្វីបានជាការប្រកបគ្នានៃពួកជំនុំសំខាន់សម្រាប់គ្រីស្ទបរិស័ទគ្រប់រូប?
**ការអធិស្ឋាន៖** សូមព្រះអង្គប្រទានពរដល់ការប្រកបគ្នានៃយើងខ្ញុំផង។

ថ្ងៃទី ២ កញ្ញា
១ យ៉ូហាន ២:១៥-១៧

*« ដ្បិតសេចក្តីស្រឡាញ់ប្រចណ្ឌក៏សាហាវ ដូចជាស្ថានឃុំព្រលឹងមនុស្ស*

## ការស្រឡាញ់លោកីយនិងការស្រឡាញ់ព្រះជាម្ចាស់គឺជាច់ស្រឡះពីគ្នា

នៅក្នុងការអនុវត្តន៍ការប្រកបគ្នានៃគ្រីស្ទបរិស័ទតម្រូវទុកជាមុនគឺការស្រឡាញ់ព្រះវរបិតាផ្ទុយពីនឹងការស្រឡាញ់លោកីយ។ នៅពេលគ្រីស្ទបរិស័ទចាប់ផ្តើមស្រឡាញ់លោកីយជាសេចក្តីដែលគាត់បានរំដោះចេញមក គាត់នឹងចាប់ផ្តើមត្រឡប់ទៅជីវិតចាស់របស់គាត់វិញ។ សេចក្តីស្រឡាញ់របស់គាត់ចំពោះព្រះវរបិតានឹងថយចុះជាលំដាប់។

«ដ្បិតសេចក្តីស្រឡាញ់ប្រចណ្ឌក៏សាហាវ ដូចជាស្ថានឃុំព្រលឹងមនុស្សស្លាប់» (បទចំរៀងសាឡូម៉ូន ៨:៦)។ នៅពេលយើងងាកចេញមិនស្រឡាញ់បងប្អូនដូចជាយើងត្រូវស្រឡាញ់ សេចក្តីស្រឡាញ់បែបនោះនឹងប្រែទៅជាការច្រណែននឹងបុគ្គលដែលយើងស្រឡាញ់កាលពីដើមដំបូង ហើយមិនជាយូរប៉ុន្មាននឹងក្លាយទៅជាសេចក្តីសំអប់។ ព្រះជាម្ចាស់និងលោកីយគឺនៅទីទៃពីគ្នា ហើយយើងអាចស្រឡាញ់មួយឬស្អប់មួយ តែមិនអាចស្រឡាញ់ទាំងពីរបានឡើយ។

ពាក្យថា «លោកីយ៍» យើងចង់មានន័យថាជាប្រពន្ធ័នៃពិភពលោក គឺទ្រព្យនិយម។ លោកីយនៅចំណុចនេះគឺត្រូវបានធ្វើការវិភាគថាជាសេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម និងសេចក្តីប៉ងប្រាថ្នារបស់ភ្នែក ហើយនិងសេចក្តីអំណួតរបស់ជីវិត។ តើនាងអេវ៉ាមិនបានធ្លាក់ទៅអន្ទាក់របស់សាតាំងនៅពេលវាល្បួងនាងដោយប្រើសេចក្តីល្បួងទាំងបីនេះក្នុងករណីផ្លែឈើហាមឃាត់? ផ្លែឈើនោះបរិភោគបាន (សេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម) ក៏ជាទីគាប់ដល់ភ្នែក (សេចក្តីប៉ងប្រាថ្នារបស់ភ្នែក) ហើយ «ជាដើមដែលល្មមគួរនឹងចង់បានដើម្បីឲ្យបានប្រាជ្ញា» (សេចក្តីអំណួតរបស់ជីវិត) លោកុប្បត្តិ ៣:៦។

ថ្វីដ្បិតដើមឈើនោះបានបាត់វត្តមានចាប់តាំងពីសម័យដើម ក៏អំណាចនៃសេចក្តីល្បួងរបស់សាច់ឈាម និងសេចក្តីល្បួងរបស់ភ្នែក ហើយនិងសេចក្តីអំណួតរបស់ជីវិតបានអូសទាញគ្រីស្ទបរិស័ទមិនតិចឲ្យវិលត្រឡប់ទៅក្នុងលោកីយដែរ។ តើហេតុអ្វីបានជាអ្នកនេះឬអ្នកនោះឈប់នៅក្នុងពួកជំនុំ? ពីព្រោះគាត់រវល់រកប្រាក់នៅថ្ងៃព្រះអម្ចាស់។ ព្រោះគាត់រត់ចោលភរិយារបស់គាត់ទៅជាមួយស្ត្រីម្នាក់ផ្សេងទៀត។ ទាំងនេះគឺសុទ្ធតែជារឿងរ៉ាវដ៏សោកស្តាយតែជារឿងពិត។ ហេតុនេះ សូមរត់ចេញពីសេចក្តីប៉ងប្រាថ្នាទាំងអស់ទោះជាវាហាក់ដូចជាតូចប៉ុណ្ណាក៏ដោយ។ តែសូមឲ្យស្រឡាញ់ព្រះអម្ចាស់ដ៏អស់ពីចិត្តនិងកំឡាំងរបស់អ្នកវិញ។

*សូមញែកពេលវេលាអោយបរិសុទ្ធ ថ្លែងជាប់ពីព្រះអម្ចាស់អ្នក*
*ចូរនៅជាប់នឹងទ្រង់ជានិច្ច ក្រេបយកពាក្យបន្ទូលនៃទ្រង់*
*ធ្វើមិត្តនឹងពួកកូនព្រះ ជួយដល់អ្នកទន់ខ្សោយ*
*បំភ្លេចអ្វីគ្រប់ទាំងអស់ ស្វែងរកតែព្រះពរទ្រង់។*

**ការពិចារណា៖** ចូររត់ឲ្យឆ្ងាយពីសេចក្តីល្បួងដូចលោកយ៉ូសែបជាគំរូ។
**ការអធិស្ឋាន៖** សូមរំដោះយើងខ្ញុំពីការអាក្រក់។

## អ្នកប្រឆាំងព្រះគ្រីស្ទបានមកដល់ហើយ!

សាវ័កយ៉ូហានបានប្រើពាក្យ «ពួកទទឹងនឹងព្រះគ្រីស្ទ (*Antichrist*)» នៅក្នុងសំបុត្រទាំងអស់ តែគំនិតពីខាងក្រោយនៃការប្រើពាក្យនេះគឺត្រូវបានទទួលស្គាល់គ្រប់គ្នា។ យ៉ូហានសន្មត់ថាអ្នកអានសំបុត្ររបស់គាត់ដឹងពីការមកដល់របស់អ្នកប្រឆាំងព្រះគ្រីស្ទនាពេលម៉ោងក្រោយបង្អស់ តែដោយព្រោះកើតមានពួកអ្នកទទឹងនឹងព្រះគ្រីស្ទនៅក្នុងការប្រកបគ្នារបស់គាត់ គឺមានមនុស្សជាច្រើនអ្នកបដិសេធគោលលទ្ធិអំពីព្រះគ្រីស្ទ គាត់បានសម្គាល់ឃើញពួកអ្នកប្រាសចាកពីជំនឿធ្វើជាអ្នកត្រួសត្រាយផ្លូវឲ្យអ្នកដែលនឹងត្រូវមកដល់។ ពាក្យ «ទទឹង (*anti*)» ត្រូវបានប្រែមកថាជា «សត្រូវ» នៅក្នុងភាសាចិន គឺជាពាក្យមានអត្ថន័យធ្ងន់ជាង «ក្លែងក្លាយ»។ វាសំដៅទៅសេចក្តីដែលសាវ័កប៉ុលចាត់ទុកថា មនុស្សអាក្រក់ (*Wicked)* មនុស្សមានបាប (*Man of Sin)* កូននៃពួកទាស់ទទឹង។ នៅក្នុងកណ្ឌវិវរណៈជននេះត្រូវបានហៅថាជាសត្វ។

តើអ្វីខ្លះជាចរិកលក្ខណៈរបស់អ្នកប្រឆាំងព្រះគ្រីស្ទ? ចរិកលក្ខណៈទាំងនេះត្រូវបានសម្តែងប្រាប់ឲ្យដឹងបន្ថែមក្នុង ១ យ៉ូហាន ៤:៣, ២ យ៉ូហាន ៧។

ដូចជាប្រេងនឹងទឹកមិនអាចលាយចូលគ្នាបាន ពួកអ្នកនៅក្នុងការប្រកបគ្នានៃគ្រីស្ទបរិស័ទដែលគ្មានព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ តែជាវិញ្ញាណរបស់អាទទឹងនឹងព្រះគ្រីស្ទ មិនជាយូរប៉ុន្មាននឹងចូលមកបង្ខូចការប្រកបគ្នា។ «អ្នកណាដែលមិននៅខាងខ្ញុំ អ្នកនោះគឺទាស់នឹងខ្ញុំ ហើយអ្នកណា ដែល មិនប្រមូលមកខាងខ្ញុំ អ្នកនោះឈ្មោះថាជាអ្នកកំចាត់កំចាយវិញ» (លូកា ១១:២៣)។

ពាក្យដាស់រំឭកហ្មងចៀមឲ្យប្រឆាំងនឹងសត្រូវរបស់អ្នកគង្វាលល្អគឺជាផ្នែកមួយនៃព័ន្ធកិច្ចសាវ័ក។ នៅពេលយ៉ូហានចង្អុលបង្ហាញពីពួកអ្នកប្រឆាំងព្រះគ្រីស្ទដែលបានសម្ងំលាក់ខ្លួននៅក្នុងការប្រកបគ្នា សាវ័កពេត្រុសប្រកាសប្រឆាំងយ៉ាងក្លៀវក្លាថា «តែកាលពីដើម មានហោរាក្លែងក្លាយ នៅក្នុងពួកជន ដូចជានឹងមានគ្រូក្លែងក្លាយក្នុងពួកអ្នករាល់គ្នាដែរ គេនឹងលួចនាំបញ្ចូលបក្សពួកដែលបង្ខូចបំផ្លាញ គេមិនព្រមស្គាល់ព្រះដ៏ជាម្ចាស់ ដែលបានលោះគេនោះឡើយ ក៏នាំសេចក្តីវិនាសដ៏ឆាប់រហ័សឲ្យមកលើខ្លួនផង» (២ ពេត្រុស ២:១)។ សាវ័កប៉ុលចាត់ទុកពួកគេជា «ខ្មាំងសត្រូវនឹងឈើឆ្កាងព្រះគ្រីស្ទទេ...គេយកពោះគេទុកជាព្រះ» (ភីលីព ៣:១៨-១៩)។ កាល់វិនបន្ថែមលើការថ្កោលទោសនេះថា «សាសនារបស់គេគឺជាផ្ទះបាយ របស់គេ»។

តើហេតុអ្វីបានជាសត្រូវរបស់ព្រះគ្រីស្ទព្យាយាមបម្រើព្រះគ្រីស្ទនៅក្នុងពួកជំនុំ? ដើម្បីផលប្រយោជន៍ និងអំណាច ហើយនិងកេរ្តិ៍ឈ្មោះផ្ទាល់ខ្លួន។ បណ្ឌិត រុនស៊ី (Dr. Runcie) ជាអគ្គប៊ីស្សព នៃក្រុងខិនធើប៊ើរី (*archbishop of Canterbery*) ដែលមានទស្សនៈប្រឆាំងនឹងព្រះគ្រីស្ទ គាត់ជាមនុស្សល្បីល្បាញចំពោះពិភពលោក ជាអ្នកបដិសេធផ្លូវតែមួយនៃសេចក្តីសង្គ្រោះតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើង គឺជាអ្នកប្រាជ្ញសម័យនិយមនៃវិញ្ញាណរបស់អ្នកប្រឆាំងនឹងព្រះគ្រីស្ទ។ បើតាមអ្នកកែទម្រង់ សម្តេចប៉ាបគឺអ្នកប្រឆាំងម្នាក់ទៀត។ សូមប្រយ័ត្ននឹងពួកអាទទឹងនឹងព្រះគ្រីស្ទ!

**ការពិចារណា៖** តើខ្ញុំស្ថិតនៅក្នុងក្រុមអ្នកប្រឆាំងនឹងព្រះគ្រីស្ទ?

**ការអធិស្ឋាន៖** ព្រះជាម្ចាស់អើយសូមរក្សាយើងខ្ញុំពីវិញ្ញាណណាដែលប្រឆាំងនឹងព្រះគ្រីស្ទផង។

ថ្ងៃទី ៤ កញ្ញា
១ យ៉ូហាន ២:២០,២៩ «...បានព្រះដ៏បរិសុទ្ធចាក់លាបឲ្យហើយ ក៏ចេះគ្រប់ទាំងអស់ផង»

## ការត្រិះរិះពិចារណាតាមរយៈការចាក់លាបដ៏បរិសុទ្ធ (១)

ដើម្បីដឹកនាំពួកជំនុំទៅក្នុងអស់ទាំងសេចក្តីពិត ព្រះគ្រីស្ទបានសន្យានឹងបញ្ជូនព្រះវិញ្ញាណនៃ សេចក្តីពិត (យ៉ូហាន ១៦:១៣)។ នៅក្នុងខនេះព្រះវិញ្ញាណដដែលនេះត្រូវបានហៅថាជាព្រះដ៏បរិសុទ្ធដែលប្រទានដល់យើងនូវ «ចាក់លាបឲ្យ» (ខ ២០) ឬ «ដំណើរចាក់លាប» (ខ ២៧) ដែលនៅក្នុងផ្នែកទេវសាស្ត្រហៅថា «ការបំភ្លឺគំនិត»។ តាមរយៈការចាក់លាបនៃព្រះវិញ្ញាណបរិសុទ្ធយើងមានពន្លឺពីស្ថានសួគ៌ដែលជួយឲ្យយើងអាចយល់ដឹងអំពីវិញ្ញាណក្លែងក្លាយ ពីកំហុសនិងអញ្ញទិដ្ឋិ (អញ្ញមតិ)។ តាមរយៈការចាក់លាបនេះ យើងស្គាល់អ្នកដែលមានវិញ្ញាណនៃអាទទឹងព្រះគ្រីស្ទ គឺរួមទាំងអ្នកបដិសេធព្រះរាជបុត្រា និងការបដិសេធទាំងព្រះវរបិតានិងព្រះរាជបុត្រាផងដែរ។

ជំនឿលើព្រះយេស៊ូវគ្រីស្ទគឺប្រកាសយ៉ាងច្បាស់លាស់នៅក្នុងព្រះបន្ទូលនៃព្រះដើម្បីរួមបញ្ចូលនូវគោលលទ្ធិនៃព្រះយេស៊ូវគ្រីស្ទ (២ យ៉ូហាន ៩)។ កំណើតពីស្ត្រីព្រហ្មចារីរបស់ព្រះគ្រីស្ទនិងនិស្ស័យជាមនុស្សដ៏ឥតមានបាបរបស់ទ្រង់គឺជាគ្រឹះចម្បងនៃគោលលទ្ធិនៃព្រះគ្រីស្ទ។ ចំណុចផ្សេងទៀតដែលសំខាន់ដូចគ្នានៃសេចក្តីបង្រៀននៅក្នុងគោលលទ្ធិនៃព្រះគ្រីស្ទគឺដង្វាយធួននឹងបាបរបស់ទ្រង់ (ទ្រង់បានសុគតដើម្បីសងថ្លៃទណ្ឌកម្មនៃអំពើបាបរបស់យើង) ការអស្ចារ្យរបស់ទ្រង់ ការមានព្រះជន្មរស់ឡើងវិញខាងផ្នែករូបកាយនិងបុគ្គលភាពរបស់ទ្រង់ ការយាងមកជាថ្មីម្តងទៀតរបស់ទ្រង់ក្នុងលក្ខណៈអាចឃើញនឹងភ្នែក។ នៅពេលគ្រូគង្វាលជាង១០០០នាក់នៃពួកជំនុំប្រេស្ប៊ីស្ប៊ីធើរានក្នុងសហរដ្ឋអាមេរិចនាអំឡុងឆ្នាំ១៩២៣បានបដិសេធគោលលទ្ធិសំខាន់ៗនៃព្រះគ្រីស្ទដូចបានលើកឡើងខាងលើ តើអ្វីទៅជាការថ្កោលទោសរបស់អ្នកពីបញ្ហានេះ? តើអ្នកមានការត្រិះរិះពិចារណាតាមរយៈការចាក់លាបដ៏បរិសុទ្ធដើម្បីប្រកាសថ្កោលទោសដែរឬទេ។

ដោយសារការប្រទាននូវចំណេះដឹងខុសត្រូវនេះពីការចាក់លាបនៃព្រះវិញ្ញាណបរិសុទ្ធយើងអាចដឹងនូវរាល់ភាពពុតត្បុត់នៃការបង្រៀនរបស់ពីអារក្ស។ ផ្អែកលើសេចក្តីបង្រៀនរបស់យ៉ូហាន យើងនឹងគ្មានភាពស្ទាក់ស្ទើរអ្វីនឹងចាត់ទុកពួកអ្នកបដិសេធព្រះគ្រីស្ទថាជាមនុស្សកុហក់ឡើយ (ខ ២២)។ ម៉្យាងវិញទៀត ពួកអ្នកដែលប្រតិបត្តិតាមសេចក្តីពិតដែលពួកបានទទួលចាប់តាំងពីដើមដំបូងរៀងមក (ព្រះ)បានសន្យានឹងប្រទាននូវជីវិតអស់កល្បដល់គេ។ ពួកគេក៏នឹងបានរក្សាឲ្យរួចពីពួកអ្នកលួងលោម ដូចជាការដឹកនាំឲ្យវង្វេងពីព្រះជាដើម។ ការសិក្សាពីគោលលទ្ធិគឺជាការចាំបាច់បំផុតសម្រាប់សមាជិកពួកជំនុំ។

**ការពិចារណា៖** បើស្គាល់សេចក្តីពិត សេចក្តីពិតនឹងផ្តល់ឲ្យមានសេរីភាព។

**ការអធិស្ឋាន៖** សូមព្រះអម្ចាស់ប្រទាននូវអំណោយទាននៃការត្រិះរិះពិចារណាដឹងខុសត្រូវ។

## ការត្រិះរិះពិចារណាតាមរយៈការចាក់លាបដ៏បរិសុទ្ធ (២)

### ការនៅជាប់ក្នុងព្រះគ្រីស្ទគឺជាការធានា

មូលដ្ឋានគ្រឹះនៃគោលលទ្ធិដ៏សំខាន់មួយនៃសេចក្ដីសង្គ្រោះរបស់យើងគឺជាសន្តិសុខដ៏អស់កល្ប នោះមានន័យថា បើកាលណាអ្នកបានសង្គ្រោះគឺអ្នកនឹងបន្តបានសង្គ្រោះរហូតដល់ទីបំផុត។ សាវ័កយ៉ូហានបានដឹងពីគោលលទ្ធិនេះនៅក្នុងយ៉ូហានជំពូកទី១០ ជាជំពូកព្រះយេស៊ូវបង្រៀនអំពីការប្រទាននូវជីវិតអស់កល្បដល់ហ្វូងចៀម (យ៉ូហាន ១០:២៨, ២៩)។ ប៉ុន្តែសន្តិសុខដ៏អស់កល្បគឺមិនមែនជាវិធីទោលនោះឡើយ។ មានផ្នែកដទៃទៀតអំពីអ្នកដែលបានសង្គ្រោះគឺការ «នៅជាប់ក្នុងព្រះគ្រីស្ទ»។ បន្ទាប់ពីយើងបានសង្គ្រោះ យើងមិនមានអត្តចរឹកព្រងើយកន្តើយនឹងជីវភាពសុចរិតឡើយ។ យើងទទួលបាននូវការលើកទឹកចិត្តពីពេលនេះទៅមុខឲ្យរស់នៅដូចជាព្រះជាម្ចាស់មានបំណងព្រះហឫទ័យចង់ឲ្យយើងរស់នៅ ពោលគឺជាជីវភាពដ៏សុចរិត ជីវភាពបរិសុទ្ធ ជាជីវភាពលើសពីជីវិតដ៏ពេញបរិបូរ (យ៉ូហាន ១០:១០)។ ប៉ុន្តែការនេះមិនអាចធ្វើបានដោយកំឡាំងរបស់យើងផ្ទាល់ខ្លួនឡើយ។ យើងត្រូវតែ «នៅជាប់ក្នុងទ្រង់» (១ យ៉ូហាន ២:២៨) ដែលជាចំណាំងមួយទៀតពីសេចក្ដីអធិប្បាយ លើភ្នំអំពី ដើមទំពាំងបាយជូរពិត។ ហើយថា «បើអ្នកណាមិននៅជាប់នឹងខ្ញុំ អ្នកនោះត្រូវបោះចោលទៅខាងក្រៅ ហើយក៏ក្រៀមទៅដូចជាខ្នែងដែរ រួចគេប្រមូលបោះទៅក្នុងភ្លើងឆេះអស់ទៅ» (យ៉ូហាន ១០:៦)។

សន្តិសុខដ៏អស់កល្បមិនមែនផ្ដល់សិទ្ធិដើម្បីរស់នៅជីវភាពរីករាយពោរពេញដោយអំពើបាបឡើយ។ ជីវភាពបែបនោះគឺត្រូវបានហៅថា «លទ្ធិប្រឆាំងនឹងច្បាប់» ដែលព្រះជាម្ចាស់ទ្រង់ស្អប់។ អ្នកដែលរស់ជីវភាពបរិសុទ្ធអាចមានអារម្មណ៍សុវត្ថិភាពនាពេលព្រះគ្រីស្ទយាងមក។ បើសង្ខេបយ៉ាងខ្លី ចំពោះអ្នកផ្ដាច់ខ្លួនឯងចេញពីព្រះអម្ចាស់ គឺពីពួកជំនុំគឺអាចត្រឹមបំពេញខ្លួនឯងនូវអសុវត្ថិភាពនាគ្រាយាងមករបស់ទ្រង់ប៉ុណ្ណោះ។ តើអ្នករស់នៅដើម្បីព្រះគ្រីស្ទឬដើម្បីខ្លួនឯង?

**ការពិចារណា៖** តើអ្នកបានសង្គ្រោះហើយឬនៅ?
**ការអធិស្ឋាន៖** សូមអរព្រះគុណព្រះអង្គហើយដែលបានសង្គ្រោះយើងខ្ញុំជារៀងរហូត។

១ យ៉ូហាន ៣:១-១០ *« ..លើកតែអ្នករាល់គ្នាត្រូវកាត់ចោលចេញប៉ុណ្ណោះ ?»*

## កូនព្រះជាម្ចាស់គួរតែរស់នៅដូចជាកូនរបស់ព្រះជាម្ចាស់

លោកកាល់វីនប្រើពាក្យបែបក្រាហ្វិកអំពីទំនាក់ទំនងថ្មីរបស់យើងនឹងព្រះតាមរយៈកិច្ចការប្រោសលោះនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទរបស់យើងថា៖ «ព្រះរាជបុត្រានៃព្រះបានក្លាយជាកូនមនុស្សដើម្បីឲ្យកូនមនុស្សនឹងអាចក្លាយជាកូនព្រះ»។ ពិតមែនហើយ ដោយយល់ដល់ព្រះគ្រីស្ទ មើល សេចក្តីស្រឡាញ់យ៉ាងណាហ្ន៎ ដែលព្រះវរបិតាបានផ្តល់មកយើងរាល់គ្នា ឲ្យយើងបានហៅថាជាកូនរបស់ព្រះដូច្នេះ! លោកីយមិនស្គាល់នូវកិត្តយសដ៏ខ្ពង់ខ្ពស់របស់យើងនៅក្នុងព្រះគ្រីស្ទទឡើយ។

ប៉ុន្តែយើងគួរស្គាល់ខ្លួនឯង! យើងនឹងផ្លាស់ប្រែដូចជាព្រះគ្រីស្ទនាពេលយាងមកជាលើកទីពីររបស់ទ្រង់។ ហើយយើងជាអ្នកដែលមានក្តីសង្ឃឹមដ៏មានពរនៃការឃើញទ្រង់ត្រូវតែរស់នៅជីវភាពបរិសុទ្ធពីព្រោះនោះគឺជាខ្លឹមសារនៃជីវិតថ្មីក្នុងព្រះគ្រីស្ទ ក្នុងនាមជាកូនព្រះ។ តើអ្នកជាកូនព្រះ? ដោយសារមានក្តីសង្ឃឹមនេះនៅក្នុងទ្រង់ យើង «ត្រូវនៅជាប់នឹងទ្រង់»។ ការ «នៅជាប់នឹងទ្រង់» នេះផ្តល់ឲ្យយើងនូវអំណាចដើម្បីរស់នៅជីវិតឃ្លាតចេញពីអំពើបាប។ យើងមានអំណាចនៅក្នុងជីវិតយើងដើម្បីមិនធ្វើបាប។ ផ្ទុយពីអ្នកដែលគិតថាខ្លួនជាគ្រីស្ទបរិស័ទដែលមិនធ្លាប់ក្លាយជាកូនព្រះ ជាអ្នករស់នៅក្នុងអំពើបាប។ ពួកគេជាកូនអារក្សជាជាង។

ដូច្នេះការល្បងបើអ្នកជាកូនប្រុសឬកូនស្រីរបស់ព្រះ ឬជាកូនរបស់អារក្សគឺបើអ្នកបានកើតជាថ្មី គឺការកើតក្នុងគ្រួសាររបស់ព្រះ គឺថាបើអ្នកបានទទួលនូវកិត្តិយសដ៏ខ្ពង់ខ្ពស់នៃភាពជាបុត្រា (ឬបុត្រី) របស់ព្រះមហាក្សត្រនៃព្រះជាម្ចាស់តាមរយៈទំនាក់ទំនងថ្មីដែលបានបង្កើតឡើងក្នុងជីវិតយើងដោយអង្គព្រះគ្រីស្ទ។

ផ្នែកទីមួយនៃជាជំពូកទី៣នេះពិតជាឆ្លុះបញ្ចាំងពីផ្នែកដំបូងនៃជំពូកទី៣នៃដំណឹងល្អយ៉ូហានជាជំពូកដែលព្រះអម្ចាស់នៃយើងបានមានបន្ទូលយ៉ាងម៉ឺងម៉ាត់ដល់លោកនីកូដេមអំពីតម្រូវការកំណើតថ្មី។ វាគឺមិនទាន់គ្រប់គ្រាន់ក្នុងការកើតក្នុងគ្រួសារគ្រីស្ទបរិស័ទ ការទទួលអប់រំក្នុងថ្នាក់ថ្ងៃអាទិត្យនិងនៅក្នុងពួកជំនុំ ការចូលរួមក្នុងការប្រកបគ្នានៃពួកយុវជន ការបញ្ជាក់ក្តីជំនឿនៃបុគ្គលណាម្នាក់និងការទទួលពិធីលៀងព្រះអម្ចាស់នោះឡើយ។ នៅក្នុងពាក្យរបស់សាវ័កប៉ុល «ចូរអ្នករាល់គ្នាពិចារណាខ្លួនឯងមើល តើស្ថិតនៅក្នុងសេចក្តីជំនឿឬទេ ចូរល្បងខ្លួនមើលចុះ តើអ្នករាល់គ្នាមិនយល់ឃើញថា ព្រះយេស៊ូវគ្រីស្ទគង់ក្នុងអ្នករាល់គ្នាទេឬអី លើកតែអ្នករាល់គ្នាត្រូវកាត់ចោលចេញប៉ុណ្ណោះ?» (២ កូរិនថូស ១៣:៥)។ បើអ្នកបានកើតជាថ្មី គឺបានក្លាយកូនប្រុសឬកូនស្រីរបស់ព្រះ អ្នកនឹងដឹងពីការនោះ។ បើអ្នកមិនបានកើតជាថ្មី តើវាមិនមែនដោយសារតែអ្នកជាមនុស្សបាត់បង់ ជាអ្នកចិត្តរឹងមានះក្នុងអំពើបាប ជាអ្នកព្រះកាត់ចោល?

**ការពិចារណា៖** «ព្រះរាជបុត្រានៃព្រះបានក្លាយជាកូនមនុស្សដើម្បីឲ្យកូនមនុស្សនឹងអាចក្លាយជាកូនព្រះ»។

**ការអធិស្ឋាន៖** ព្រះអម្ចាស់ សូមឲ្យយើងខ្ញុំពិចារណាខ្លួនឯង តើស្ថិតនៅក្នុងសេចក្តីជំនឿឬទេ។

ថ្ងៃទី ៧ កញ្ញា

១ យ៉ូហាន ៣:១១-២៤ «...គឺដោយការប្រព្រឹត្ត នឹងសេចក្ដីពិត

## វិធីកូនព្រះប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក

នៅពេលយើងបានកើតក្នុងគ្រួសាររបស់ព្រះជាម្ចាស់ យើងមិនត្រឹមបានមានទំនាក់ទំនងជាលក្ខណៈបញ្ឈរជាមួយនឹងព្រះវរបិតានានគរស្ថានសួគ៌ទេ តែក៏មានលក្ខណៈផ្ដេកជាមួយនឹងអ្នកឯទៀតដែលបានកើតជាថ្មីដូចគ្នាផងដែរ។ គ្រីស្ទបរិស័ទមិនអាចរស់នៅតែម្នាក់ឯងដូចជាតាបសឡើយ! គ្រីស្ទបរិស័ទគឺជាសមាជិកនៃសមាជិកឯទៀតបីដូចជាមែកឈើដូច្នោះដែរ។

គ្រីស្ទបរិស័ទត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ សមាជិកពួកជំនុំម្នាក់មិនអាចស្អប់ម្នាក់ទៀតឡើយ។ បើគាត់ធ្វើដូច្នោះគាត់គឺដូចជាកាអ៊ីនដែលបានសម្លាប់អេបិលជាប្អូន។ ការស្អប់បងឬប្អូនប្រុសនៅក្នុងព្រះអម្ចាស់គឺបានប្រព្រឹត្តអំពើបាបនៃមនុស្សឃាត គឺជាប្រព្រឹត្តអំពើដែលបំផ្លាញអាយុជីវិតរបស់គាត់! បើព្រះបានស្រឡាញ់យើងរហូតដល់បញ្ជូនព្រះរាជបុត្រារបស់ទ្រង់មកសុគតជំនួសយើងរាល់គ្នា យើងមានភារៈកិច្ចដើម្បីលះបង់ជំនួសបងឬប្អូនប្រុសរបស់យើងដែរ។ ដោយវិធីណា? ក្នុងលក្ខណៈជាអនុវត្តន៍ ដើម្បីជួយអ្នកខ្វះខាតតាមរយៈទង្វើករុណានានា។ ជាថវិការ ជាអាហារនិងសម្លៀកបំពាក់ជាដើម។ ជាញឹកញាប់ប៉ុន្មានដងដែលយើងដេញពួកអ្នកដែលយើងគួរជួយចេញដោយព្រោះតែភាពអាត្មានិយម ហើយតើចិត្តរបស់យើងមិនបានថ្កោលទោសយើង?

ប៉ុន្តែបើយើងមានចិត្តចំពោះតម្រូវការរបស់អ្នកក្រីក្រ ហើយយើងអនុវត្តក្ដីសប្បុរសជានិរន្តរ៍ នោះនៅពេលខ្លួនយើងផ្ទាល់ជួបខ្វះខាត ព្រះជាម្ចាស់នឹងប្រព្រឹត្តនឹងយើងដូចជាយើងបានប្រព្រឹត្តចំពោះពួកគេជាមិនខាន។ ការចែកទានដល់អ្នកខ្វះខាតគឺជាការសព្វព្រះទ័យដល់ព្រះ។

ទោះជាយ៉ាងណាវាមិនមែនដោយសារការចែករំលែកទានដែលបុគ្គលម្នាក់ទទួលបានសេចក្ដីសង្គ្រោះដូចលោកីយជាញឹកញាប់គិតនោះឡើយ។ សេចក្ដីសង្គ្រោះរបស់យើងកើតឡើងដោយសារការជឿលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយភស្តុតាងនៃសេចក្ដីសង្គ្រោះនោះគឺការស្រឡាញ់គ្នាទៅវិញទៅមក។ នៅក្នុងស្រឡាញ់គ្រីស្ទបរិស័ទដទៃទៀតយើងទទួលបាននូវបទពិសេធន៍ព្រះគ្រីស្ទកំពុងគង់នៅក្នុងយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ។ ដូចជាមែកឈើល្អស្រស់បំព្រងទទួលជ័រដែលហូរតាមបណ្ដាមែកទាំងឡាយពីដើមឈើផ្ដល់ទៅឲ្យគ្រប់ផ្នែកនៃដើមឈើទាំងមូលដូច្នោះដែរ។ សូមចងចាំពីសេចក្ដីអធិប្បាយនៅលើភ្នំអំពីដើមទំពាំងបាយជូរពិត (យ៉ូហាន ១៥) តើអ្នកទទួលបាននូវបទពិសោធន៍ជាក្ដីអំណរនៃការប្រកបគ្នារបស់គ្រីស្ទបរិស័ទដែរឬទេ? ឬ តើអ្នកព្យាយាមគេចចេញពីបងប្អូនប្រុសស្រីរបស់អ្នក ដោយសារតែក្ដីសំអប់នៅក្នុងចិត្តរបស់អ្នក?

**ការពិចារណា៖** សេចក្ដីស្រឡាញ់ពិត គឺដោយក្នុងសេចក្ដីពិត។

**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមសេចក្ដីស្រឡាញ់របស់ទ្រង់ហូរហៀរចេញពីយើងខ្ញុំ។

## ចំណុចតភ្ជាប់មួយដែលបាត់នៅក្នុងការស្នងតំណែងពួកសាវ័ក

មានព្រះវិហារជាច្រើនអះអាងថាជាអ្នកស្នងតំណែងក្រុមសាវ័ក! ទី១គឺព្រះវិហាររ៉ូម៉ាំងកាតូលិក ដោយ ផ្អែកលើកូនសោរដែលបានប្រគល់ឲ្យសាវ័កពេត្រុស។ មានព្រះវិហារផិនធីកុស្ទ (*Pentecostal Churches*) ជាច្រើនដែលបានតាំងខ្លួនជាព្រះវិហារក្រុមសាវ័ក ហើយរួមទាំងព្រះវិហារនិកាយខុសឆ្គងជាច្រើនទៀតផងដែរ។

បើព្រះវិហារមួយអះអាងថាជាព្រះវិហារក្រុមសាវ័ក ព្រះវិហារនោះប្រាកដជាពួកជំនុំដ៏ពិត មិនមែនត្រឹមតែតាមគោលលទ្ធិនៃពួកសាវ័កប៉ុណ្ណោះទេ តែក៏នឹងស្របតាមការប្ដេជ្ញាចិត្តចំពោះព័ន្ធកិច្ចនៃការព្រមានដាស់តឿនរបស់ក្រុមសាវ័កផងដែរ។ ពន្ធ័កិច្ចការនៃការព្រមានដាស់តឿននោះគឺទាស់នឹងពួកគ្រូក្លែងក្លាយ ពួកហោរាក្លែងក្លាយ ព្រះគ្រីស្ទក្លែងក្លាយ ពួកបងប្អូនក្លែងក្លាយ ហើយនិងបណ្ដាវិញ្ញាណក្លែងក្លាយ។

ជាការពិតណាស់ ព្រះគ្រីស្ទជាព្រះអម្ចាស់នៃយើងមានពាក្យជាច្រើនដើម្បីមានបន្ទូលទាស់នឹងបណ្ដាពួកក្លែងបន្លំទាំងនេះ។ ប៉ុន្ដែបើអ្នកអានសំបុត្រទាំងឡាយ អ្នកនឹងឃើញថាទោះបីជាលោកប៉ុល ឬលោកពេត្រុស លោកយ៉ូហាន ឬលោកយូដាស ពួកគាត់សុទ្ធតែប្រកាសព្រមានដាស់តឿនទាស់នឹងពួកអ្នកក្លែងក្លាយទាំងនោះដែរ។

ដោយគិតត្រឹមតែសាវ័កយ៉ូហាន យើងសម្គាល់ឃើញថាគាត់បានស្គាល់ពួកទទឹងនឹងព្រះគ្រីស្ទនៅក្នុង ១ យ៉ូហាន ២:១៨-១៩។ នៅក្នុង ១ យ៉ូហាន ៤:១ គាត់បានដាស់តឿនពីទាស់នឹងហោរានិងវិញ្ញាណក្លែងក្លាយ។ ហោរាគឺជាអ្នកនាំពាក្យសម្រាប់អង្គបុគ្គលដែលបញ្ជូនគាត់ឲ្យទៅប្រកាសប្រាប់។ តើគាត់ប្រកាសពីវិញ្ញាណនៃសេចក្ដីពិតឬវិញ្ញាណនៃកំហុសឆ្គង។ អ្នកខ្លះអាចនឹងត្រូវបានគេដឹកនាំខុសដោយស្មោះត្រង់ ដូចជាក្មេងៗដែលត្រូវបានបោកបញ្ឆោតដោយពួកស្មរបន្ទាល់ព្រះយេហូវ៉ា (*J ehovah Witnesses*) ពួកម៉ម៉ុន (Mormons) និងពួកមូនី(Moonies)ជាដើម។ អាក្រក់លើសជាងនោះទៅទៀតគឺពួកបោកបញ្ឆោតខ្លួនឯងដែលជាសាស្ត្រាចារ្យសេរីនិយមនិងសម័យនិយមនៃបណ្ដាមហាវិទ្យាល័យនិងសិក្ខាសាលាព្រះគម្ពីរជាន់ខ្ពស់។ ការបង្រៀនរបស់គេមិនអាចនឹងទទួលជឿតាមបានទេ បើពួកគេមិនត្រាប់តាមបទគម្ពីរបរិសុទ្ធ។

ឧទាហរណ៍នៅពេលអ្នកដឹកនាំព្រះវិហារមូនីបានមកទស្សនៈកិច្ចពួកជំនុំរបស់យើងដើម្បីផ្សព្វផ្សាយស្លាកយីហោគ្រីស្ទាននៃព្រះវិហារយូនីហ្វិខេស្សិន (*the Unification Church*) ពួកយើងបានសួរសំណួរសាកល្បងគាត់ថា៖ «តើលោកជឿព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះគឺមានកំណើតដោយស្ត្រីព្រហ្មចារីដែរឬទេ?» នៅពេលចម្លើយគឺ «ទេ» នោះនឹងដឹងពីវិញ្ញាណក្លែងក្លាយ! ចូរល្បងសួរពួកគេដោយគោលលទ្ធិនៃព្រះយេស៊ូវគ្រីស្ទ! បញ្ហាជាមួយបណ្ដាព្រះវិហារជាច្រើននាពេលបច្ចុប្បន្ននេះគឺព្រះវិហារជាច្រើនមិនត្រឹមព្រមានដាស់តឿនទាស់នឹងហោរានិងវិញ្ញាណក្លែងក្លាយប៉ុណ្ណោះទេ ពួកគេបានវង្វេងតាមពួកខុសឆ្គងទាំងនោះទៀតផង! នោះហើយជាចំណុចតភ្ជាប់មួយដែលបាត់នៅក្នុងការស្នងតំណែងពួកសាវ័ក!

**ការពិចារណា៖** តើអ្នកស្គាល់ក្រុមនិកាយខុសឆ្គងណាខ្លះ?

**ការអធិស្ឋាន៖** យើងខ្ញុំសូមអរព្រះគុណទ្រង់ សម្រាប់ពាក្យបន្ទូលតែងតែរំឭកយើងខ្ញុំ។

ថ្ងៃទី ៩ កញ្ញា
១ យ៉ូហាន ៤:២-៦

*«..គឺអស់ទាំងវិញ្ញាណណាដែលថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទ បានមកក្នុងសាច់ឈាម គឺវិញ្ញាណនោះហើយដែលមកពីព្រះ»*

# តើនេះគឺជាអត្តសញ្ញាណនៃវិញ្ញាណក្លែងក្លាយ?

វិញ្ញាណក្លែងបន្លំដែលសាវ័កយ៉ូហានថ្កោលទោសនៅក្នុងបទគម្ពីរនេះបដិសេធនិស្ស័យជាមនុស្សរបស់ព្រះគ្រីស្ទ។ ព្រះគ្រីស្ទគឺពិតជាព្រះនិងពិតជាមនុស្សនៅក្នុងអង្គបុគ្គលតែមួយ ដែលជាព្រះនិងជាមនុស្ស ព្រះរាជបុត្រានៃព្រះជាម្ចាស់បានយកនិស្ស័យជាមនុស្សដើម្បីឲ្យទ្រង់អាចនាំមនុស្សទៅឯព្រះវរបិតា។ នោះហើយជាអត្ថន័យសម្រាប់ពាក្យដែលចែងថា «ព្រះយេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាម»។ ព្រះគ្រីស្ទជាមនុស្សគឺសំខាន់ដូចគ្នានឹងព្រះគ្រីស្ទទ្រង់ជាព្រះយ៉ាងដូច្នោះដែរ។

វិញ្ញាណក្លែងបន្លំដែលបានយកមកវែកញែកក្នុងខគម្ពីរនេះវាគឺជាវិញ្ញាណរបស់ក្រុមសាសនាខុសឆ្គងឈ្មោះថាដូស៊ីទីស្ទ (*Docetists*) ជាបណ្តាញមួយរបស់ក្រុមខុសឆ្គងណូស្ទិក (*Gnostics*) ដែលជឿថា «ព្រះគ្រីស្ទទ្រង់គ្មានរូបកាយឬព្រលឹងវិញ្ញាណជាមនុស្សជាក់ស្តែង»។ ការបើកសម្តែងអង្គទ្រង់ជាមនុស្សនៅលើផែនដីគឺជាគំនិតរវើរវាយ ជាការលេចឡើងដោយគ្មានរូបធាតុឬអវៈយវៈជាក់ស្តែងទេ។ ដូចនេះទើបក្រុមនេះត្រូវបានគេហៅថាជាក្រុមដូស៊ីទីស្ទ (*Docetists*) មកពីពាក្យកិរិយាស័ព្ទនៃភាសាក្រិកដូខេអូ (*dokeo*) មានន័យថាលេចឡើង ដែលហាក់ដូចជាមានទ្រង់ទ្រាយ។ ជីវភាពលើផែនដីដ៏ពេញលេញរបស់ព្រះគ្រីស្ទគឺជាការស្រមើស្រម៉ៃ។ ទ្រង់មិនបានប្រសូត្រជាមនុស្ស។ ហើយទ្រង់ក៏មិនបានរងការឈឺចាប់ដែរ (Hodge)។

វិញ្ញាណបែបនេះគឺមិនត្រឹមជាវិញ្ញាណក្លែងបន្លំទេ តែជាអាទទឹងនឹងព្រះគ្រីស្ទ (*antichrist*)ផងដែរ។ វាបានមកក្នុងលោកីយនៅសម័យលោកយ៉ូហាន។ ថ្វីដ្បិតអាទទឹងនឹងព្រះគ្រីស្ទគឺមានរូបកាយជាមនុស្សដ៏អាក្រក់ គ្រីស្ទបរិស័ទមិនត្រូវខ្លាចវាឡើយ «ពីព្រោះព្រះដែលគង់នៅក្នុងអ្នករាល់គ្នា នោះទ្រង់ធំជាអានោះដែលក្នុងលោកីយ៍ផង»។ យើងមានជ័យជំនះលើរាល់អំណាចនៃសេចក្តីអាក្រក់។ ដូចជាពន្លឺឈ្នះភាពងងឹតអញ្ចឹង!

តើអ្នកស្គាល់ពីអត្តសញ្ញាណនៃវិញ្ញាណក្លែងបន្លំដោយវិធីណា? ពួកអ្នកទាំងនោះគេអាចស្គាល់តាមរយៈការក្លែងបន្លំរស់គេ។ នៅពេលពួកគេនិយាយ ពួកគេព្យាយាមបកស្រាយយ៉ាងណាដើម្បីទទួលការទាក់ទាញពីលោកីយ។ ពួកគេប្រើវិធីចិត្តសាស្ត្រកេងប្រយោជន៍ពីមនុស្សទាំងឡាយ។ ឧទាហរណ៍ បណ្ឌិត រូនស៊ី (Dr. Runcie) ជាមហាព្រឹទ្ធាបូជាចារ្យខិនធឺប៊ីរី មានប្រសាសន៍នៅក្នុងសារព័ត៌មាន ស្ទ្រេត ថៃមស៍ (*the Straits Times*) ថាបើទ្រង់បានប្រសូត្រនៅទីក្រុងញូដាលី (*New Delhi*) ព្រះអង្គនឹងក្លាយសាសនិកព្រហ្មញ្ញ ហើយបើទ្រង់ប្រសូត្រនៅប្រទេសអ៊ីរ៉ង់ នោះទ្រង់ជាសាសនិកម៉ូស្លីម។ តាមរយៈការផ្គាប់ចិត្តតាមជំនឿក្រុមសាសនាផ្សេងៗ គាត់ទទួលបាននូវ «សម្លេងឆ្នោតគាំទ្រមួយភាគធំ» សម្រាប់ប្រជាប្រិយភាពផ្ទាល់ខ្លួន។ ប៉ុន្តែគាត់គឺជាហោរាក្លែងក្លាយ។ វិធីមួយទៀតដើម្បីស្គាល់វិញ្ញាណក្លែងបន្លំគឺពីប្រតិកម្មរបស់ពួកគេចំពោះការបង្រៀនពីសេចក្តីពិត។ គ្រូបង្រៀនក្លែងក្លាយនឹងមិនចុះចូលតាមសេចក្តីពិតឡើយ។

**ការពិចារណា៖** ចូរប្រយត្ន័នឹងពួកចចកពាក់ស្បែកចៀម។

**ការអធិស្ឋាន៖** សូមព្រះអង្គប្រទានចិត្តក្លាហានក្នុងការចង្អុលប្រាប់អត្តសញ្ញាណពួកគ្រូក្លែងក្លាយ។

ថ្ងៃទី ១០ កញ្ញា
១ យ៉ូហាន ៤:៧-២០

*« តែបើយើងស្រឡាញ់គ្នាទៅវិញទៅមក...ហើយសេចក្តីស្រឡាញ់របស់ទ្រង់បានពេញខ្នាតក្នុងយើងដែរ»*

## ឈើឆ្កាងជានិមិត្តសញ្ញានៃសេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណ៍

ចាប់ពី ខ៧ ដល់ ខ១០ ឃើញថាមានរយៈកំពស់នៃទំហំផ្ទៃទាំងមូល។ សេចក្តីស្រឡាញ់នៃព្រះដែលបានបញ្ជូនព្រះបុត្រាតែ១របស់ទ្រង់មកក្នុងពិភពលោកដើម្បីនាំយើងរួចពីសេចក្តីស្លាប់ឆ្ពោះទៅរកជីវិត។ រយៈកំពស់លាតពីលើចុះមកក្រោម «មិនមែនជាយើងបានស្រឡាញ់ព្រះនោះទេ គឺទ្រង់បានស្រឡាញ់យើងវិញទេតើ ហើយបានចាត់ព្រះរាជបុត្រាទ្រង់មកទុកជាដង្វាយឲ្យធួននឹងបាបយើងរាល់គ្នាផង» ។ (ខ ១០)។ តើអ្នកធ្លាប់បានពិសោធសេចក្តីស្រឡាញ់ពីស្ថានសួគ៌នេះដែរឬទេ?

ចាប់ពី ខ១១ ដល់ ខ២១ ឃើញថាមានរយៈបន្ទាត់ផ្តេកនៃទំហំផ្ទៃទាំងមូល។ សេចក្តីស្រឡាញ់របស់ព្រះដែលរត់កាត់ខ្សែបន្ទាត់ផ្តេកផ្ទេរសេចក្តីស្រឡាញ់នៅក្នុងនិងតាមរយៈយើងរាល់គ្នា។ បើព្រះស្រឡាញ់យើង ពួកយើងគួរតែស្រឡាញ់ដល់គ្នាទៅវិញទៅមក (ខ១១)។ សេចក្តីស្រឡាញ់លាតសន្ធឹងមកពីខ្សែបន្ទាត់បញ្ឈរមកខ្សែបន្ទាត់ផ្តេកគឺ «បានធ្វើឲ្យគ្រប់លក្ខណ៍» នៅក្នុងពួកយើង។ ដោយហេតុតែព្រះជាម្ចាស់គង់នៅក្នុងអស់អ្នកដែលស្រឡាញ់គ្នាទៅវិញទៅមក ហើយប្រកាសថ្លែងថាព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ ពីព្រោះដោយសារឈើឆ្កាងរបស់ទ្រង់ដែលយើងបានផ្សះផ្សានឹងព្រះជាម្ចាស់។ សេចក្តីស្រឡាញ់នៃព្រះនេះសណ្ឋិតនៅក្នុងយើង ការពារយើងពីសេចក្តីភិតភ័យនៃការជំនុំជំរះ។ សារៈសំខាន់នៃការស្រឡាញ់បងប្អូនមិនអាចពន្យល់សង្កត់ធ្ងន់ឲ្យបានប្រសើរជាងនេះទៀតឡើយ។ ពីព្រោះសេចក្តីស្រឡាញ់នេះត្រូវបានសាវ័កយ៉ូហានបង្រៀនម្តងហើយម្តងទៀតនៅក្នុងសំបុត្ររបស់គាត់។

ហេតុអី? ពីព្រោះសេចក្តីស្រឡាញ់ជាថាមពលជម្រុញទឹកចិត្តដ៏ខ្លាំងក្លាក្នុងព័ន្ធកិច្ចពួកជំនុំ។ សូមអានសំបុត្រកូរិនថូសខ្សែទី ជំពូកទី១៣។ ដូច្នេះ វាមិនមែនដោយសារការឫទ្ធិបារមី ទីសំគាល់ និងការអស្ចារ្យ ការយល់សប្តិ និមិត្តជាក់ស្តែង ហើយនិងព្រះអំណោយទាននៃការនិយាយភាសាដទៃ ហើយក៏មិនមែនដោយការអធិប្បាយនិងលក្ខណៈសម្បត្តិខាងផ្នែកទេវសាស្ត្រដ៏ខ្ពង់ខ្ពស់ដែរ។ល។ សេចក្តីស្រឡាញ់គឺសំខាន់បំផុតសេចក្តីស្រឡាញ់គឺសម្តែងឲ្យបានឃើញតាមរយៈឈើឆ្កាងរបស់ព្រះគ្រីស្ទ។

**ការពិចារណា៖** សូមទន្ទេញចងចាំ ១ យ៉ូហាន ៤:១០។
**ការអធិស្ឋាន៖** ឪសូមឲ្យសេចក្តីស្រឡាញ់ជាបងប្អូនរបស់យើងខ្ញុំបានពោរពេញផង!

*«..គឺព្រះវរបិតា១ ព្រះបន្ទូល១ និងព្រះវិញ្ញាណបរិសុទ្ធ១ តែទាំង៣អង្គនេះរួមមកតែ១ទេ»*

## ជ័យជំនះតាមរយៈសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ

សារ៉ៃនៃសេចក្ដីស្រឡាញ់ក៏ជាសារ៉ៃនៃសេចក្ដីជំនឿដែរ។ យ៉ូហានសរសេរដំណឹងល្អទីបួនដើម្បីឲ្យយើងជឿ ឯសំបុត្រនេះគាត់សរសេរសម្រាប់យើងជាអ្នកបានជឿ។ ..សេចក្ដីស្រឡាញ់ជាកូនស្រីនៃសេចក្ដីជំនឿ ព្រោះបើយើងមិនបានជឿព្រះយេស៊ូវគ្រីស្ទផង ធ្វើដូចម្ដេចឲ្យយើងអាចស្រឡាញ់ព្រះវរបិតានៃទ្រង់និងកូនៗរបស់ព្រះអង្គ ហើយឲ្យយើងអាចប្រតិបត្តិតាមបញ្ញតិទ្រង់ដោយក្ដីស្រឡាញ់បាន?

ប៉ុន្តែសេចក្ដីជំនឿដែលលោកីយប្រកាសជាសេចក្ដីជំនឿអវត្តមានអង្គព្រះគ្រីស្ទគឺមិនមែនជាជំនឿសោះឡើយ។ សេចក្ដីជំនឿនៃលោកីយគឺដូចជាយុថ្កាគ្មានចងច្រវ៉ាក់។ សេចក្ដីជំនឿយ៉ូហានថ្លែងប្រាប់គឺជាសេចក្ដីជំនឿដ៏មានជ័យ ដោយដាក់យុថ្កាជាប់នឹងអង្គព្រះយេស៊ូវគ្រីស្ទដែលមានច្រវ៉ាក់តភ្ជាប់ទៅដល់ទ្រង់ដ៏ជាថ្មដារ។ តើសេចក្ដីជំនឿបែបណាជារបស់លោកអ្នក?

នៅក្នុងបរិបទនៃការល្បួងលអស់ទាំងវិញ្ញាណដែលព្យាយាមបកស្រាយបដិសេធអង្គព្រះគ្រីស្ទ មានអ្នកខ្លះអះអាងថាទ្រង់មិនមែនជាមនុស្សទេតែជាមនុស្សបែបអរូបីក្នុងភាពស្រមើស្រម៉ៃ (គេបដិសេធកំណើតជាមនុស្សរបស់ទ្រង់) ត្រង់ចំណុចនេះបង្ខំឲ្យសាវ័កយ៉ូហានធ្វើបន្ទាល់ពីលក្ខណះជាព្រះសង្គ្រោះដ៏ពិតប្រាកដរបស់ព្រះយេស៊ូវ។ ដោយហេតុថាយ៉ូហានបានធ្វើសាក្សីពីលោហិតនិងទឹកដែលហូរពីចំហៀងនៃដងព្រះកាយព្រះយេស៊ូវ (យ៉ូហាន ១៩:៣៤, ៣៥) ឥឡូវនេះគាត់ប្រកាសថា «នៅចំហៀងនៃព្រះកាយព្រះយេស៊ូវមានប្រភពលោហិតនិងទឹក ប្រយោជន៍ដើម្បីឲ្យពួកអ្នកជឿអាចដឹងពីការលាងជំរះដ៏ពិតប្រាកដ ជាការដែលលាងសម្អាតនានាពីសម័យបុរាណគឺជាតំណាងឲ្យអង្គទ្រង់។ ហើយក៏ដើម្បីឲ្យពួកគេដឹងថានោះគឺបានសម្រេចគ្រប់យ៉ាងនៃការប្រស់លោហិតកាលពេលកន្លងមកផងដែរ» (កាល់វិន)។ ព្រះវិញ្ញាណនៃសេចក្ដីពិតជាអង្គបុគ្គលដែលបណ្ដាលឲ្យពួកអ្នកជឿដឹងពីអំណាចនៃការលាងជំរះរបស់ព្រះគ្រីស្ទ។ (យ៉ូហាន៣ ចែងពីលក្ខណះព្រះវិញ្ញាណបណ្ដាលឲ្យយើងកើតជាថ្មីតាមរយៈការរំពឹងមើលទៅកាន់ព្រះសង្គ្រោះដែលបានជាប់ឆ្កាង)។

ខ៧ ជាខត្រូវបានជាប់ជំទាស់ដោយសារកំណត់សម្គាល់នៅរឹមជើងទំព័រនិងជាខគម្ពីរមិនបញ្ចូលនៅក្នុងព្រះគម្ពីរភាសាអង់គ្លេស **អ អេស វី** (***RSV**: Revised Standard Version*) ប៉ុន្តែលោកកាល់វិនមិនហ៊ានសង្ស័យនឹងខនេះទេ ដោយសារខនេះឃើញមាន«នៅក្នុងកំណែព្រះគម្ពីរដ៏ល្អៗនិងកំណែព្រះគម្ពីរគេទទួលស្គាល់ជាច្រើនទៀត»។ ព្រះជាម្ចាស់ ដើម្បីបញ្ជាក់ច្បាស់នូវសេចក្ដីជំនឿរបស់យើងដ៏ពេញបរិបូរណ៍នៅក្នុងអង្គព្រះគ្រីស្ទ ទ្រង់បានធ្វើទីបន្ទាល់តាមរយៈវិធីបីផ្នែកដែលអាចឲ្យយើងមានទំនុកចិត្តលើទ្រង់។ ដូចដែលព្រះវិញ្ញាណបានធ្វើបន្ទាល់ពីអំណាចនៃទឹកនិងលោហិតដែលហូរនៅលើផែនដី នៅស្ថានសួគ៌យើងក៏មានទីបន្ទាល់បីផ្នែកទៀត គឺព្រះវរបិតា១ ព្រះបន្ទូល១ និងព្រះវិញ្ញាណបរិសុទ្ធ១ ផងដែរ។ (ព្រះត្រៃឯកគឺត្រូវបានបើកសម្ដែងឲ្យដឹងពីស្ថានសួគ៌នាពិធីបុណ្យជ្រមុជរបស់ព្រះយេស៊ូវ។ ម៉ាថាយ ៣:១៦, ១៧)។

ដូច្នេះ ការជជែកអំពីឃ្លាពីរជាប់គ្នាហើយមានចុងចួនដូចគ្នានៅខ១២នឹងបញ្ជាក់ប្រាប់ដោយខ្លួនឯង។

**ការពិចារណា៖** ១ ធីម៉ូថេ ៣:១៦។

**ការអធិស្ឋាន៖** សូមព្រះអង្គប្រទានសេចក្ដីជំនឿ ជឿថារាល់កំណត់ត្រានៃព្រះបន្ទូលគឺគ្មានកំហុស។

## អ្នកដែលជឿព្រះគ្រីស្ទក៏ដឹង (ចំណេះដឹងគឺជាអំណាច)

យើងបានអង្កេតឃើញពីពួកអ្នកនៃលោកីយដែលនិយាយគ្នាអំពីសេចក្តីជំនឿដ៏គ្មានមូលដ្ឋានគ្រឹះ តែជំនឿរបស់យើងគឺនៅជាប់ក្នុងព្រះគ្រីស្ទដ៏ជាថ្មដា។ ម្យ៉ាងវិញទៀត សេចក្តីជំនឿរបស់យើងគឺហ៊ុំព័ទ្ធដោយចំណេះដឹង។ តើអ្នកដឹងថាខ្លួនអ្នកបានសង្គ្រោះដែរឬទេ? បើអ្នកកំពុងទុកចិត្តលើព្រះគ្រីស្ទ អ្នកគួរតែឆ្លើយបាទឬចាំសដោយក្តីទំនុកចិត្ត។ នោះហើយគឺជាសេចក្តីដែលយ៉ូហានចង់មានន័យតាមរយៈ ខ១៣។

ចំណេះនោះក៏ផ្តល់នូវក្តីទំនុកចិត្តដល់យើងក្នុងការអធិស្ឋានរបស់យើងនិងការជានាពីការឆ្លើយតបនានារបស់ទ្រង់ដែរ។ ចំណេះដឹងនោះជួយកុំឲ្យយើងទូលសូម «សេចក្តីទាំងឡាយណាដែលយើងនឹងមិនទទួលបាន» (កាល់វិន) មានន័យថាយើងទូលសូមដោយនូវក្នុងបំណងព្រះរាជហឫទ័យទ្រង់។

ចំណេះដឹងនោះគួរដឹកនាំយើងទៅរកការយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក អំពីបងប្អូនប្រុសស្រីដែលបានប្រព្រឹត្តអំពើបាប។ ព្រះជាម្ចាស់ទ្រង់ស្តាប់នូវសេចក្តីអធិស្ឋានរបស់យើងសម្រាប់អ្នកដែលបានប្រព្រឹត្តខុសឆ្គងនៅក្នុងពួកជំនុំ ហើយទ្រង់នឹងលើកតាំងពួកគេឡើងវិញពីព្រោះគេបានកើតនៅក្នុងគ្រួសាររបស់ព្រះអង្គ ពួកគេនឹងមិនត្រូវវិនាសឡើយ។ នេះគឺជាព័ន្ធកិច្ចនៃការអធិស្ឋានជំនួស ដែលយើងខ្វះខាតយ៉ាងខ្លាំង។ ក៏ប៉ុន្តែទាក់ទិនទៅនឹងពួកអ្នកប្រាសចាកពីសេចក្តីជំនឿ និងពួកអ្នកមិនជឿ ហើយពួកខុសឆ្គងជា អ្នកស្គាល់សេចក្តីពិតហើយបដិសេធសេចក្តីពិត ពួកគេត្រូវបានកំណត់វាសនាសម្រាប់សេចក្តីអន្តរាយ។ លោកយ៉ូហានមិនតម្រូវឲ្យយើងអធិស្ឋានសម្រាប់ពួកគេទេ។ សាវ៉កប៉ុលបង្រៀនថា «ឯមនុស្សណាដែលបង្កើតបក្សពួក នោះត្រូវកាត់គេចោលចេញ ក្នុងពេលក្រោយដែលទូន្មានប្រដៅគេម្តងពីរហើយ» (ទីតុស ៣:១០)។ «រាល់ការប្រព្រឹត្តខុសឆ្គងទាំងអស់គឺជាអំពើបាប។ ពួកយើងមិនត្រូវចាត់អំពើបាបជាបញ្ហាតូចតាចឡើយ។ ប៉ុន្តែអ្នកជឿអាចនឹងធ្វើបាបនូវអំពើបាបណាមួយដែល នឹងមិនបានបណ្តាលឲ្យមានការដកហូតគាត់ចេញពីបណ្តាពួកអ្នកជឿ» (ព្រះគម្ពីរអត្ថាធិប្បាយថ្មី «*New Bible Commentary*»)។

ចំណេះដឹងនោះសម្តែងប្រាប់យើងកុំឲ្យប្រព្រឹត្តអំពើបាបក្លាយជាទម្លាប់ក្នុងនាមយើងជាអ្នកបានកើតជាថ្មី។ យើងមានអំណាចនឹងមិនប្រព្រឹត្តអំពើបាបពីព្រោះយើងជាកូនព្រះជាម្ចាស់។ ផ្ទុយទៅវិញ លោកីយទាំងមូលកំពុងស្ថិតនៅក្រោមអំណាចរបស់អារក្សសាតាំង។ ចំណេះដឹងនោះគឺក្នុងអង្គព្រះគ្រីស្ទដែលចាប់បដិសន្ធិជាមនុស្ស ជាព្រះសង្គ្រោះក្នុងទ្រង់ទ្រាយជាមនុស្ស ជាសេចក្តីពិត គឺជាជីវិតដ៏នៅអស់កល្បជានិច្ច។

ចំណេះដឹងនេះពិតជាផ្តល់ឲ្យយើងនូវអំណាចដើម្បីរស់នៅជីវភាពដែលកោតខ្លាចដល់ព្រះ។ ចំណេះដឹងបែបនេះក្លាយជាគ្រឹះដ៏រឹងមាំនៃសេចក្តីជំនឿរបស់យើង។ ចំណេះដឹងបែបនេះផ្តល់ឲ្យយើងនូវសន្តិសុខដ៏អស់កល្បជានិច្ចផងដែរ។

**ការពិចារណា៖** ព្រះគម្ពីរសម្រាប់អាននិងសិក្សាដើម្បីឲ្យបានស្គាល់ព្រះនិងស្គាល់ខ្លួនឯង។
**ការអធិស្ឋាន៖** សូមព្រះអង្គជួយឲ្យយើងខ្ញុំស្រឡាញ់ទ្រង់និងសិក្សាពាក្យបន្ទូលទ្រង់ផងដែរ។

*« ដ្បិតបើអ្នកណាជំរាបសួរ នោះក៏តែងមានសេចក្តីប្រកបគ្នា ក្នុងការអាក្រក់របស់អ្នកនោះ*

## សាវ័កនៃសេចក្តីស្រឡាញ់គឺក៏ជាចាស់ទុំនៃសេចក្តីពិតផងដែរ

ទោះបីជាឈ្មោះរបស់យ៉ូហានមិនបានលេចឡើងនៅក្នុងសំបុត្រនេះឬភាពជាសាវ័ករបស់គាត់មិនបានកត់ត្រា ក៏ខ្លឹមសារនៃសំបុត្រនេះនាំឲ្យពួកជំនុំជឿជាក់ថាមកពីសាវ័កដែរ។ សំបុត្រនេះត្រូវបានសរសេរ «ផ្ញើមកលោកស្រីរើសតាំង នឹងកូនចៅរបស់លោកស្រី» ហើយបញ្ជីនោះឆ្លុះបញ្ចាំងពីចំនួនស្ត្រីបរិសុទ្ធជាច្រើនទៀតដែលបានបម្រើព្រះអម្ចាស់ជាមួយនឹងក្រុមគ្រួសាររបស់ពួកគេ។ នៅក្នុងសញ្ញាថ្មី មាននាងលីឌា មាននាងព្រីស៊ីល ជាបណ្តាស្ត្រីដ៏មានកេរ្តិ៍ឈ្មោះល្បីល្បាញ។

ខណៈសេចក្តីស្រឡាញ់ក្នុងការប្រកបគ្នានៃគ្រីស្ទបរិស័ទគឺជាបាវចនារបស់សាវ័កយ៉ូហានដល់ពួកជំនុំដែលទាមទារឲ្យមានការប្រតិបត្តិរបស់ពួកយើងចំពោះព្រះជាម្ចាស់ ដូចនេះយើងត្រូវរក្សាក្នុងគោលជំហរនៃសេចក្តីពិត (ពាក្យសេចក្តីពិតលេចឡើងចំនួន ៥ដងនៅក្នុងបួនខដំបូង)។

សេចក្តីពិតដែលយ៉ូហានមានក្នុងចិត្តក្នុងខនេះគឺបើកសម្តែងនៅក្នុងខ៩ជាគោលលទ្ធិអំពីព្រះគ្រីស្ទ។ គោលជំនឿអំពីព្រះគ្រីស្ទមិនត្រឹមយល់តែពីនិស្ស័យជាព្រះរបស់ទ្រង់ទេ តែពីនិស្ស័យជាមនុស្សរបស់ទ្រង់ផងដែរ ព្រោះទ្រង់គឺជាព្រះនិងជាមនុស្ស ជាព្រះដ៏ជាមនុស្ស។ នាសម័យលោកយ៉ូហាន វិញ្ញាណរបស់អាទទឹងនឹងព្រះគ្រីស្ទបានបដិសេធនិស្ស័យជាមនុស្សពិតរបស់ទ្រង់ ដោយការប្រដូចទ្រង់ថាជាវិញ្ញាណប៉ិននភ្នែក (*illusive phantom*)។ ការបំពានលើគោលលទ្ធិនៃព្រះគ្រីស្ទនេះជាហេតុនាំឲ្យគ្រីស្ទបរិស័ទមិនអាចប្រកបគ្នានឹងពួកអ្នកជឿតាមអញ្ញមតិ (ជំនឿខុសឆ្គង) បានឡើយ។ ប្រកបគ្នាជាមួយនឹងមនុស្សបែបនេះនឹងមានចំណែកក្នុង «ការអាក្រក់» របស់ពួកគេ។

ជាមេរៀនអនុវត្ត ពាក្យបង្គាប់របស់លោកយ៉ូហាននេះត្រូវតែជួយរក្សាយើងកុំឲ្យមានការប្រកបគ្នាជាមួយនឹងពួកអ្នកបដិសេធកំណើតពីស្ត្រីព្រហ្មចារី ដង្វាយធួននឹងបាប ការឫទ្ធិបារមី និងការមានព្រះជន្មរស់ឡើង (នៃព្រះយេស៊ូវគ្រីស្ទ)។ នាឆ្នាំ ១៩២៣ មានគ្រូគង្វាលគណៈនិកាយប្រេ៍សប៊ីធីរានជនជាតិអាមេរិកចំនួន១២៩៤នាក់បានចុះហត្ថលេខាលើឯកសារមួយឈ្មោះថា អប៊ឺន អហ្វឺមេស្សិន (*Auburn Affirmation*) ដែលពួកគេបានបដិសេធគោលលទ្ធិទាំងបួនចំណុចដូចបានលើកឡើងខាងលើរួមទាំងសេចក្តីបង្រៀនពីការគ្មានកំហុស និងការផុតភាន់ច្រឡំនៃបទ គម្ពីរទៀតផងដែរ។ តើអ្នកយល់ថាពួកគេគួរតែនៅធ្វើជាអ្នកបម្រើព្រះគ្រីស្ទ ឬគួរតែបណ្តេញគេចេញ? បណ្ឌិត រ៉ាន់ស៊ី ជាអគ្គប៊ីហ្សប ខាន់ទេប៊ឺរី គឺប្រឆាំងនឹងអ្នកដែល «ធ្វើការអះអាងប្រកាន់យកសេចក្តីជំនឿតែមួយ» ។ ទង្វើរបស់គាត់ជាការប្រានចោលនូវការប្រកាសអះអាងរបស់ព្រះគ្រីស្ទថាជាផ្លូវតែមួយសម្រាប់សេចក្តីសង្គ្រោះ។ តើអ្នកគិតថាសមាជិកគណៈនិកាយអិងគ្លីខិន(*Anglicans*) គួរតែបម្រើការក្រោមការដឹកនាំរបស់គាត់ ឬក៏ប្រកាសប្រានចោលជំនឿអញ្ញមតិរបស់គាត់? សាវ័កយ៉ូហានបង្រៀនថា «ដ្បិតបើអ្នកណាជំរាបសួរ នោះក៏តែងមានសេចក្តីប្រកបគ្នា ក្នុងការអាក្រក់របស់អ្នកនោះដែរ» ។

បើអ្នកយល់ស្របតាមសាវ័កយ៉ូហាន តើហេតុអ្វីអ្នកមិនលើកឡើងពីជំនឿខុសឆ្គងទាំងនោះ?

**ការពិចារណា៖** សូមចៀសវាងការរួបរួមក្រោមពាក្យនៃសេចក្តីស្រឡាញ់តែមិនក្នុងសេចក្តីពិត។

**ការអធិស្ឋាន៖** សូមឲ្យសេចក្តីពិតរំដោះយើងខ្ញុំឲ្យនាមានសេរីភាពនៃកំហុសឆ្គងទាំងឡាយ។

« ដ្បិតយើងខ្ញុំពុំអាចនឹងធ្វើអ្វីទាស់នឹងសេចក្ដីពិតបាន
ទេ

## ចាស់ទុំនៃសេចក្ដីពិតកោតសរសើរអ្នកប្រកបគ្នានឹងសេចក្ដីពិត

នៅគ្រាភាពខុសឆ្គងឈានដល់កម្រិតខ្ពស់ និងសេចក្ដីបង្រៀនខុសប្រាសចាកបង្ខូចសេចក្ដីជំនឿគ្រីស្ទបរិស័ទដែលពុំបានរៀនសូត្រ នោះត្រូវតែមានការប្រជុំគ្នារបស់កូនៗនៃសេចក្ដីពិតសម្រាប់បុព្វហេតុរបស់សេចក្ដីពិត។

អ្នកចាស់ទុំនៃសេចក្ដីពិតកោតសរសើរលោកកៃយុសដោយសារគាត់ប្រកាន់ខ្ជាប់ខ្លួនតាមសេចក្ដីពិត ហេតុនេះទើបគាត់សរសើរថាជា «ពួកកូនខ្ញុំ» (ខ៤)។ ចាស់ទុំនៃសេចក្ដីពិតថ្លែងពីការការពារសេចក្ដីពិតឆ្ពោះទៅរកការកំពស់សេចក្ដីពិត។ យ៉ូហាន គាត់មានចិត្តរីករាយពីការឮថាលោកកៃយុសបានសម្ដែងនូវភាពទទួលរាក់ទាក់ដល់គ្រូប្រកាសដំណឹងល្អត្រាច់ចរ ទោះបីជាគាត់ស្គាល់ឬពុំបានស្គាល់ពួកគេក៏ដោយ។ ខណៈពេលគ្រូអធិប្បាយពាក្យបន្ទូលទាំងនេះធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយប្រកាសដំណឹងល្អដល់ពួកសាសន៍ដទៃ ពួកគេត្រូវការកន្លែងសម្រាក ហើយកៃយុសបានជួយទំនុកបម្រុងពួកគេប្រកបដោយសន្ដានចិត្តសប្បុរស។ ដោយសារចិត្តសប្បុរសបែបជាគ្រីស្ទបរិស័ទនេះកៃយុសត្រូវបានសរសើរថាជាអ្នកប្រកបគ្នានឹងសេចក្ដីពិត។ ពិតជាកិត្តិយសដ៏ខ្ពង់ខ្ពស់មែន! លោកកៃយុសមិនមែនជាមិត្តសម្លាញ់នឹងមហាវិទ្យាល័យនៃព្រះរាជាណាមួយឬនឹងបណ្ឌិតសភាណាមួយនោះទេ តែគាត់ជាអ្នកជួយគាំទ្រសេចក្ដីពិត ជាមនុស្សដ៏អស្ចារ្យម្នាក់នៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់។ ព័ន្ធកិច្ចនៃការទទួលឲ្យស្នាក់នៅដោយឥតគិតកម្រៃគឺកម្រណាស់នាបច្ចុប្បន្នជាសម័យដ៏មានការប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម។ ក៏ប៉ុន្តែបើយើងបម្រើព័ន្ធកិច្ចនេះដោយយល់ដល់សេចក្ដីពិតវិញ ព្រះជាម្ចាស់នឹងលើកតម្កើងពួកយើងជាមិនខាន តើអ្នកគឺជាកៃយុស ជានាងលីឌា ឬជានាព្រីស៊ីល?

ផ្ទុយទៅវិញ ចំពោះអ្នកមិនទទួលអ្នកនាំសារនៃសេចក្ដីពិត ករណីដូចជាឌីអូត្រេព ព្រមទាំងបានបណ្ដេញគ្រីស្ទបរិស័ទឯទៀតចេញដោយសារតែយកចិត្តទុកដាក់នឹងបងប្អូនប្រុសស្រី នៅក្នុងករណីនេះគឺរួមទាំងសាវ័កយ៉ូហានផងដែរនោះ ពួកគេនឹងត្រូវឆ្លើយតបនឹងទង្វើរបស់ពួកគេជាមិនខានឡើយ! ចូរយើងត្រាប់តាមសេចក្ដីល្អ តែកុំត្រាប់តាមសេចក្ដីអាក្រក់សោះឡើយ។

នៅពេលនិយាយចំៗពីឈ្មោះឌីអូត្រេព ឈ្មោះរបស់ដេមេទ្រាសក៏បានលើកមកដែរ តែអ្នកចាស់ទុំលើកមកនិយាយទុកជាការសរសើរវិញ។ តើអ្នកបម្រើរបស់ព្រះផ្ដល់ចំណាត់ថ្នាក់សម្រាប់ឈ្មោះរបស់យើងនៅក្នុងកម្រិតណាដែរ? តើកេរ្តិ៍ឈ្មោះរបស់យើងនៅក្នុងពួកជំនុំនៃព្រះជាម្ចាស់គឺជាអ្វី? តើមនុស្សស្គាល់ អ្នកដោយសារអំណាចនិងទ្រព្យសម្បត្តិ ឬឈ្មោះរបស់អ្នកល្បីឮក្នុងបុព្វហេតុនៃសេចក្ដីពិត?

«ដ្បិតយើងខ្ញុំពុំអាចនឹងធ្វើអ្វីទាស់នឹងសេចក្ដីពិតបានទេ ធ្វើបានតែអ្វីដែលសំរាប់សេចក្ដីពិតវិញ» (២ កូរិនថូស ១៣:៨)។ សូមទន្ទេញចងចាំខគម្ពីរនេះ!

**ការពិចារណា៖** ព្រះនឹងមិនភ្លេចកិច្ចបម្រើទាំងឡាយដោយនូវក្នុងនាមព្រះយេស៊ូវគ្រីស្ទឡើយ។
**ការអធិស្ឋាន៖** សូមឲ្យយើងខ្ញុំបានពាក្យការសរសើរពីព្រះជាជាងពីមនុស្ស។

# ដោយមូលហេតុតែ

*តើថ្ងៃនេះព្រលឹងវិញ្ញាណរបស់អ្នកដូចម្តេចដែរ?*

ឧទាហរណ៍បុរសវ័យក្មេងម្នាក់ធ្វើឲ្យគូដណ្តឹងរបស់គាត់ចិញ្ចៀនពេជ្រមួយវង់តម្លៃ១០,០០០ដុល្លា ដាក់វានៅក្នុងកូនប្រអប់តូចមួយដែលអ្នកលក់គ្រឿងអលង្ការថែមឲ្យដោយឥតគិតថ្លៃ។ តើគាត់នឹងអាក់អន់ចិត្តប៉ុណ្ណានៅពេលគាត់ជួបនាងពីបីថ្ងៃក្រោយមក នាងនិយាយថា៖ « *បងសម្លាញ់ ប្រអប់តូចដែលបងធ្វើជូនអូននោះគឺពិតជាស្អាតណាស់។ ដើម្បីរក្សាវាទុកឲ្យបានល្អ អូនសន្យាថានឹងទុកវានៅកន្លែងសុវត្ថិភាពកុំឲ្យមានអ្វីប៉ះខូចឡើយ*» ។

វាពិតជាអស់សំណើចណាស់មែនទេ? ប៉ុន្តែវារឿងរ៉ាវដ៏ល្ងង់ខ្លៅមួយសម្រាប់បុរសនិងស្ត្រីដែល បានចំណាយពេលវេលានិងចិត្តគំនិតនឹងរូបកាយរបស់ខ្លួន ដែលគ្រាន់តែជាសំបកក្រៅផ្ទុកអត្មាពិតប្រាកដ ជាព្រលឹង ដែលព្រះគម្ពីរប្រាប់យើងថា នឹងត្រូវពុករលួយបន្ទាប់ពីរូបកាយរបស់យើងខូចត្រឡប់ជាធូលី។ ព្រលឹងគឺថ្លៃមិនអាចកាត់ថ្លៃបានឡើយ។ លោក ឡុងហ្វិឡូ (Longf el l ow) បានបញ្ចេញមតិអំពីព្រលឹងដូច្នេះថា៖

*សូមកុំប្រាប់ខ្ញុំនូវចំនួនទុក្ខសោកសង្រេង*
*ជីវិតគឺគ្រាន់ជាសុបិន្តដ៏ឥតន័យ*
*ព្រោះព្រលឹងស្លាប់ទេដែលដេកលង់លក់*
*ហើយអ្វីៗមិនដូចជាពេលមានចលនាទេ។*
*ជីវិតគឺជាក់ស្តែង ហើយជីវិតគឺជាកស្តុតាង*
*ផ្នូរគឺមិនមែនជាទីបញ្ចប់នៃជីវិត។*
*ធូលីគឺជាអ្នក ហើយអ្នកនឹងត្រឡប់ទៅធូលីវិញ*
*តែនោះមិនមែននិយាយពីព្រលឹងឡើយ។*

សូមស្តាប់ពាក្យព្រះយេស៊ូវមានបន្ទូលអំពីព្រលឹង៖ « *ដ្បិតបើអ្នកណានឹងបានលោកីយ៍ទាំងមូលតែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ?*» ។ បើតាមការវាយតម្លៃរបស់ព្រះគ្រីស្ទ ព្រលឹងមនុស្សទើបជាសេចក្តីដែលមានតម្លៃជាងលោកីយ៍ទាំងមូល។ *សូមពិចារណានូវពាក្យនេះ។*

មានសេចក្តីដែលថ្លៃហើយថ្លៃជាងអ្វីៗដែលយើងអាចឃើញដោយសារភ្នែកទាក់ទងនឹងជីវិតទៅទៀតផង នោះគឺជាជីវិតបន្ទាប់ពីជីវិតនេះ ជាជីវិតដែលហួសដែននៃសេចក្តីស្លាប់។ ជីវិតនោះមិនអាចឃើញមាននៅក្នុងលោកីយ៍នេះទេ។ ជីវិតនេះគឺនៅក្នុងព្រះ ហើយយើងនឹងទៅឯទ្រង់។

**ការពិចារណា៖** ជីវិតគឺលើសពីការមានគ្រួសារដ៏ល្អនិងអាហារបីពេលក្នុងមួយថ្ងៃ។

**ការអធិស្ឋាន៖** ព្រះអម្ចាស់អើយ សូមកុំឲ្យខ្ញុំធ្វេសប្រហែសនឹង «គ្រាប់ពេជ្រ» ព្រោះតែ «ប្រអប់» វាឡើយ។

## សំណួរមូលដ្ឋានគ្រឹះមួយចំនួន

*ការយល់ដឹងគ្រប់ជ្រុងជ្រោយអំពីព្រះគឺនឹងគ្មានព្រះ*

ខ្ញុំចង់ពិភាក្សាជាមួយអ្នកអំពីបញ្ហាជាបឋមមួយចំនួនទាក់ទងនឹងកម្មសិទ្ធិដ៏មានតម្លៃរបស់អ្នកនោះគឺជាព្រលឹងវិញ្ញាណរបស់អ្នក។ ឧទាហរណ៍ដូចជា៖

*តើមានព្រះជាម្ចាស់?*

*តើព្រះគម្ពីរពិតប្រាកដ?*

*តើមនុស្សត្រូវទទួលខុសត្រូវ?*

*តើមានការអត់ទោសពីព្រះជាម្ចាស់?*

ទាំងអស់នេះជាបញ្ហាដែលរំខានដល់អ្នកដែលគិតល្អិតល្អន់អំពីអនាគត។ *តើធ្វើដូចម្តេចឲ្យខ្ញុំអាចដឹងថាពិតជាមានព្រះ?*

ខ្ញុំមានការជឿជាក់ពីកំណើតមកថាមានព្រះដ៏មានព្រះជន្មរស់។ ទោះបីចំណេះដឹងរបស់ខ្ញុំបានព្យាយាមពីអតីតកាលបង្កើតហេតុផលជាច្រើនដើម្បីបញ្ជាក់ថាទ្រង់មិនមានព្រះជន្មរស់ក៏ដោយ ឬខ្ញុំចង់ជឿជាក់ច្រើនប៉ុណ្ណាថាគ្មានព្រះ នោះនៅតែមាន «សម្លេងដ៏តូចមួយ» ប្រាប់ខ្ញុំម្តងហើយម្តងទៀត ដូចជាវាមកប្រាប់អ្នកនាពេលដ៏ស្ងៀមស្ងាត់នាវេលាជីវិតដ៏មធ្យ័តដែរ។ ជាការពិត សម្រាប់រូបខ្ញុំផ្ទាល់ ខ្ញុំបានដឹងថាមានព្រះ។ ហើយនៅពេលខ្ញុំសម្លឹងមើលទៅកាន់អ្នកដទៃ ខ្ញុំយល់ថាមានមនុស្សជាច្រើនអ្នកកំពុងតែស្វែងរកទ្រង់ តាមរយៈការសាកសួរក្នុង *«ជំនឿសាសនា»* ដើម្បីឲ្យសម្លេងដ៏តូចដូចគ្នាដែលបន្លឺនៅក្នុងជម្រៅចិត្តរបស់ខ្ញុំនាវេលាស្ងៀមស្ងាត់ដែរ។

ពិតមែនហើយ មានមនុស្សខ្លះមិនជឿលើព្រះជាម្ចាស់។ ប៉ុន្តែចំពោះរូបខ្ញុំ បញ្ហានៃការគ្មានជំនឿលើព្រះគឺធំមហិមាជាងបញ្ហានៃការគ្មានជំនឿ។ ការជឿថារូបធាតុគ្មានជីវិតដែលមិនត្រូវការជំនួយបានបង្កើតគំនិត និងគំនិតនោះបានបង្កើតសម្បជញ្ញៈ ហើយនិងភាពចៃដន្យដ៏ចលាចលបានបង្កើតក្នុងចក្រវាឡឲ្យមានលំដាប់ដោយដូចជាយើងឃើញមានក្នុងសភាពបែបធម្មជាតិនាសព្វថ្ងៃនេះ គឺហាក់ដូចជាមិនតម្រូវឲ្យមានជំនឿនោះទេ តែជាការងាយនឹងជឿបំផុតវិញ។

គ្មានកូនប្រុសពិតប្រាកដណាម្នាក់ដែលទាមទារឲ្យឪពុករបស់ខ្លួនបញ្ជាក់ពីអត្តសញ្ញាណគាត់ឡើយ។ ឯឪពុកក៏មិនត្រូវការឲ្យកូនធ្វើដូច្នោះដែរ ពីព្រោះតែគាត់បានបើកបង្ហាញខ្លួនគាត់តាមរយៈភ័ស្តុតាងនៃក្តីស្រឡាញ់ដែលមិនអាចបដិសេធជាច្រើន។ ចំពោះព្រះក៏ដូច្នោះដែរ។ ដូចនេះ នៅក្នុងព្រះគម្ពីរគ្មានពាក្យសូម្បីតែមួយដែលព្យាយាមពន្យល់ពីព្រះឡើយ។ ភ័ស្តុតាងអំពីព្រះនៅគ្រប់ទីកន្លែង មានតែមនុស្សខ្វាក់ទេដែលមិនធ្លាប់ឃើញ។

**ពិចារណា៖** *«មនុស្សល្ងង់ខ្លៅតែងគិតក្នុងចិត្តថា គ្មានព្រះទេ»* (ទំនុកដំកើង ១៤:១)

**អធិស្ឋាន៖** សូមបំភ្លឺភ្នែកទូលបង្គំ ឲ្យបានឃើញសេចក្តីអស្ចារ្យនៅក្នុងក្រឹត្យវិន័យរបស់ទ្រង់ (ទំនុកដំកើង១១៩:១៨)។

ថ្ងៃទី ១៧ កញ្ញា
ទំនុកដំកើង ១៣៩:១-១០ យ៉ូហាន ១:៦-១៤

*« ឱព្រះយេហូវ៉ា អើយ ទ្រង់បានពិនិត្យមើល ហើយបាន ស្គាល់ទូលបង្គំផង...»*

## ការបញ្ជាក់ពីព្រះ

*ព្រះជាម្ចាស់មិនមែនសម្រាប់ការពន្យល់បកស្រាយទេ តែសម្រាប់ប្រកាសវិញ*

នាយកសមាគមវិទ្យាសាស្ត្រក្រុងញូវយ៉ក (*New York Scientific Society*) មានពេលមួយគាត់បានផ្តល់ប្រាំបីមូលហេតុដែលគាត់ជឿថាមានព្រះ។ មូលេហេតុទីមួយគឺដូចនេះ៖ ចូរយកកាក់ចំនួនដប់ដូចៗគ្នារួចហើយគូសលេខចំណាំវាពីមួយដល់ដប់។ ដាក់វាទៅក្នុងហោរប៉ៅរបស់អ្នក។ ឥឡូវសូមមួយចេញមកក្រៅ។ នឹងមានសំណាងមួយក្នុងដប់ដែលអ្នកនឹងអាចយកចំកាក់មានសញ្ញាលេខមួយ។ បើប្តូរយកលេខផ្សេងហើយសំណាងយកចំកាក់លេខពីរជាលេខរៀងបន្ទាប់ពីលេខមួយគឺនឹងមិនមែនសំណាងមួយក្នុងដប់ទៀតទេតែ មួយ ក្នុងមួយរយវិញ។ នៅពេលយកកាក់ថ្មីនិមួយចេញមកក្រៅហានិភ័យនឹងកើនគុណនឹងដប់ ដូចនេះសំណាងដែលកាក់លេខដប់បន្ទាប់មកកាក់លេខប្រាំបួន គឺជាសំណាងមួយក្នុង ១០,០០០,០០០,០០០(ដប់កោដ)។ វាហាក់បីដូចជាមិនគួរឲ្យជឿដែលធ្វើឲ្យខ្ញុំចាប់យកខ្មៅដៃនិងក្រដាសមកគ្លាម ហើយរំពេចភ្លាមនោះបានរកឃើញថាគាត់ពិតជាត្រឹមត្រូវ។ *ចូរអ្នកសាកល្បងដោយខ្លួនឯងមើល!*

ហេតុនេះហើយទើបលោកចូជ ហ្គាលួប (Geor ge Gal l up) អ្នកស្ថិតិលេខជនជាតិអាមេរិកាំងមានប្រសាសន៍ថា *«ខ្ញុំអាចបញ្ជាក់ពីព្រះជាម្ចាស់តាមបែបស្ថិតិលេខបាន»។ ឧទាហរណ៍សារពាង្គកាយរបស់មនុស្ស ឱកាសនៃរាល់ប្រតិបត្តិការរបស់អវៈយវៈទាំងអស់នឹងដំណើរការគឺបែបស្ថិតិដ៏ច្រើនលើសលប់»*។

ពិតជាគ្មានមនុស្សចេះគិតល្អិតល្អន់ណាម្នាក់នឹងចង់ឲ្យអនាគតដ៏អស់កល្បរបស់ខ្លួនឈរលើ*«ចំនួនស្ថិតដ៏ច្រើនលើសលប់»* នោះឡើយ។ ប្រហែលជាបណ្តាលមកពីកត្តានោះហើយទើបព្រះគម្ពីរសម្តែងប្រាប់នៅក្នុងទំនុកដំកើង ១៤:១ ថា «មនុស្សល្ងង់ខ្លៅតែងគិតក្នុងចិត្តថាគ្មានព្រះទេ»។

មនុស្សអាចនឹងប្រើប្រាស់ម៉ាស៊ីនកុំព្យូទ័រនិងវិធីស្ថិតិលេខដ៏ស្មុគស្មាញ ជាការព្យាយាមបញ្ជាក់ពីព្រះជាម្ចាស់។ ប៉ុន្តែនោះមិនមែនជាការចាំបាច់ឡើយ។ ការជញ្ជឹងគិតដ៏តូចមួយដោយការបន្ទាបខ្លួននឹងបណ្តាលឲ្យយើងជឿពីព្រះអាទិករ។ បន្ទាប់មកយើងនឹងបន្លឺឡើងដូចជាអ្នកសរសេរទំនុកដំកើងថា៖ « ឱព្រះយេហូវ៉ាអើយ ទ្រង់បានពិនិត្យមើល ហើយបានស្គាល់ទូលបង្គំផង..រតើទូលបង្គំនឹងទៅឯណាឲ្យរួចពីព្រះវិញ្ញាណទ្រង់ តើនឹងរត់ទៅឯណា ឲ្យរួចពីព្រះភក្ត្រទ្រង់ ?» ។

ការពិតពីព្រះជាម្ចាស់គឺនៅគ្រប់ទីកន្លែងដែលមនុស្សមានចិត្តទន់ភ្លន់ទទួលយក។ សេចក្តីស្រឡាញ់និងសេចក្តីសប្បុរសរបស់ទ្រង់សម្តែងដល់មនុស្សទាំងអស់។ មានតែមនុស្សអកត្តញូទេបដិសេធនូវការពិតនោះ។ សូមកុំព្យាយាមបញ្ជាក់ពីព្រះអី! សូមប្រកាសពីព្រះនាមដ៏ជួយប្រោសលោះនៅគ្រប់ទីកន្លែងវិញ!

**ការពិចារណា៖** ព្រះជាម្ចាស់ទ្រង់គឺជាភស្តុតាងដ៏វិសេសផ្ទាល់ពីអង្គទ្រង់។
**ការអធិស្ឋាន៖** ឱព្រះអង្គអើយ សូមពិនិត្យមើលឲ្យបានស្គាល់ចិត្តទូលបង្គំផង» ។

## បុព្វហេតុដំបូង

*ព្រះគឺជាបុព្វហេតុនៃបុព្វហេតុទាំងអស់*

ឧទាហរណ៍ថាយើងកំពុងតែឈរនៅអាកាសយានដ្ឋានសម្លឹងមើលយន្តហោះដ៏ធំមួយគ្រឿងហោះចុះមកចត។ ខ្ញុំនិយាយទៅអ្នកថា *« មនុស្សភាគច្រើនយល់ថាយន្តហោះគឺជាស្នាដៃរៀបចំបង្កើតឡើងដ៏សម្រិតសម្រាំង តែខ្ញុំដឹងច្រើនជាងនោះ។ គ្មានការងារដើរើយឆ្លាតអ្វីចំពោះការបង្កើតវាឡើយ។ ដោយក្នុងវិធីដ៏ចម្លែកមួយ ដែកក៏កើតមានឡើងនៅលើដី ហើយកើតជាផ្ទាំងដែកសំប៉ែត។ បន្ទាប់មកផ្ទាំងដែកទាំងនេះចាប់ ផ្ដើមត ភ្ជាប់ គ្នាយឺតៗបន្តិចម្ដងៗហើយផ្គុំគ្នាជាទួនិងស្លាបហើយនិងកន្ទុយ។ បន្ទាប់ពីរយៈពេលដ៏យូរ ម៉ាស៊ីនក៏កើតឡើង បន្តិចម្ដងៗចំនឹងសំណុំរបស់វា ហើយចួនជាថ្ងៃមួយ មានមនុស្សមកក៏ឃើញយន្តហោះនោះ ជាសម្មិទ្ធិផល សម្រេចនិងរួចរាល់ដើម្បីហោះហើរ»* ។

អ្នកប្រាកដជានឹងចាត់ទុកខ្ញុំជាមនុស្សឆ្កួតហើយដើរចេញទៅមហាជនដើម្បីគេចពីពាក្យនិយាយឥតប្រយោជន៍របស់ខ្ញុំជាមិនខាន។ ហេតុអី? អ្នកដឹងថាបើមានការបង្កើត នោះប្រាកដជាមានអ្នកបង្កើត ហើយតាមរយៈការឃើញផលិតកម្មផ្សេងៗរបស់គំនិតមនុស្សដូចជាយន្តហោះនៅក្នុងសំណួរជាដើម អ្នកនឹង យល់ស្របថាវាគឺត្រូវបានរៀបចំឡើងដោយមនុស្សដ៏ឆ្លាតវៃនិងបង្កើតឡើងដោយមនុស្សដ៏ស្ទាត់ជំនាញ។

តែមានមនុស្សដ៏មានចំណេះដឹងជ្រាលជ្រៅ ជាមនុស្សប្រកបដោយវិជ្ជាជីវៈខ្ពស់ដែលប្រាប់យើងថាសាកលលោកទាំងមូលកកើតឡើងដោយចៃដន្ធ ដោយគ្មានអង្គអាទិទេពណាបង្កើតវាមកឡើយ។ អ្នកទាំងនោះអះអាងថាគ្មានព្រះ មានតែធម្មជាតិប៉ុណ្ណោះ។

ផ្ទុយទៅវិញ មានមនុស្សដ៏មានគំនិតជ្រាលជ្រៅជាច្រើននាក់ដែលជឿថាព្រះដ៏អស់កល្បជា៖ ខណៈបើកសម្ដែងអង្គទ្រង់ក្នុងធម្មជាតិ (ដែលនៅក្នុងនោះច្បាប់និងគោលការណ៍របស់វាគឺជាការសម្ដែងពីអំណាចនិងគតិបណ្ឌិតរបស់ទ្រង់) ជាព្រះអង្គទ្រង់ផ្ទាល់គឺធំជាងសាកលលោកទាំងមូល។ ប៉ុន្តែអ្វីទាំងអស់អ្នកមិនជឿថាមានព្រះអាចផ្ដល់ឲ្យយើងគឺប្រស្នាពីរចនាដែលគ្មានអ្នករចនា អំពីស្នាដៃបង្កបង្កើត ដែលគ្មានព្រះអាទិករ អំពីផលដែលគ្មានហេតុ។

អ្នកមានគំនិតពិចារណាគ្រប់រូបជឿលើលំដាប់នៃច្បាប់ហេតុនិងផលនៅក្នុងធម្មជាតិដែលផលនិមួយៗក្លាយជាហេតុនៃផលផ្សេងៗទៀត។ ការទទួលស្គាល់នូវការពិតនេះថាជាការជាក់ស្ដែងនឹងបណ្ដាលយ៉ាងសមហេតុផលឲ្យបុគ្គលម្នាក់ទទួលស្គាល់ថាប្រាកដជាមានការចាប់ផ្ដើមចំពោះអ្វីៗដែលមានលំដាប់លំដោយ។ ផលដំបូងនឹងមិនអាចកើតឡើងដរាបណាគ្មានហេតុពីដំបូង។ ហេតុដំបូលនេះ ចំពោះខ្ញុំគឺជាព្រះ។

**ការពិចារណា៖** «កាលពីដើមដំបូងមានព្រះ..» (លោកុប្បត្តិ ១១)។

**ការអធិស្ឋាន៖** ព្រះអង្គអើយ សូមប្រទានកែវភ្នែកនៃសេចក្ដីជំនឿ ឲ្យខ្ញុំអាចមើលឃើញទ្រង់ជាបុព្វហេតុនៃលទ្ធផលទាំងអស់ផង។

# បើជឿនិងឃើញ

*ដោយសារសេចក្តីជំនឿយើងមើលឃើញអ្វីៗដែលមើលនឹងភ្នែកមិនឃើញ*

ថ្វីដ្បិតមនុស្សបានរកឃើញច្បាប់ទាំងឡាយដែលគ្រប់ប្រពន្ធ័អគ្គីសនី អ្នកវិទ្យាសាស្ត្រដ៏ល្បីល្បាញជាច្រើននាក់ក៏មិនអាចផ្តល់និយមន័យឲ្យអគ្គីសនីបានឡើយ។ បើដូច្នោះ តើហេតុអ្វីបានជាយើងជឿថាមានអគ្គីសនី? ពីព្រោះយើងឃើញនូវការបញ្ចេញថាមពលរបស់វានៅក្នុងគេហដ្ឋានរបស់យើងនិងនៅក្នុងបណ្តារោងចក្រឧស្សាហកម្មនិងនៅតាមដងវិថី។ ទោះបីខ្ញុំមិនជឿពីទីកន្លែងដែលព្រះទ្រង់យាងមក ក៏ខ្ញុំជឿថាទ្រង់មានព្រះជន្មរស់ដែរ ព្រោះខ្ញុំឃើញការបើកសម្តែងពីអង្គទ្រង់មាននៅគ្រប់ទីកន្លែងជុំវិញខ្ញុំ។

បណ្ឌិត វ៉ែនហឺ វ៉ុន ប្រូន (Dr. Wernher von Braun) នាយកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កាំជ្រួចរបស់អង្គការណាសា (NASA) ជាអ្នកដែលបង្ហោះផ្កាយរណបអវកាសអាមេរិកដំបូងទៅក្នុងគន្លងគោចរមាន ប្រសាសន៍ថា៖

«នៅពិភពលោកដ៏ទាន់សម័យរបស់យើង មនុស្សជាច្រើនហាក់ដូចជាមានយក់ថាសន្ទុះនៃភាពជឿនលឿនក្នុងវិស័យវិទ្យាសាស្ត្របណ្តាលឲ្យបញ្ហាខ្លះដូចជាជំនឿសាសនាប្រែជាមិនស្របនឹងសម័យ កាល ឬហួសសម័យ។ ពួកគេងឿយឆ្ងល់ពីមូលហេតុយើងគួរស្តប់ចិត្តនឹង «ការជឿ» លើអ្វីមួយដែលវិទ្យាសាស្ត្រប្រាប់ថាយើង «ដឹង» នូវរឿងរ៉ាវជាច្រើន។ ចម្លើយដ៏សាមញ្ញនឹងការមិនស្រុះស្រួលគ្នានេះគឺថាយើងប្រឈមមុខនឹងអាថ៌កំបាំងនៃធម្មជាតិជាច្រើននាពេលបច្ចុប្បន្នជាងនាសម័យចាប់ផ្តើមយល់ដឹងពីវិទ្យាសាស្ត្រ។ ពេលចម្លើយថ្មីមួយបានឆ្លើយបំភ្លឺ វិទ្យាសាស្ត្របានរកឃើញយ៉ាងហោចណាស់បីចំណោទបញ្ហាដូចៗគ្នាថែមទៀត។

ចម្លើយជាច្រើនចង្អុលប្រាប់ថាគ្រប់យ៉ាងដូចដែលបានរក្សាតាមលំដាប់លំដោយនិងបានបង្កើតមកយ៉ាងល្អប្រពៃដូចមាននៅលើផែនដីនិងសាកលលោករបស់យើងជាចាំបាច់ត្រូវតែមានអ្នកបង្កើត ជាអ្នករចនាដ៏មហាកំពូល។ អ្វីៗដ៏មានលំដាប់លំដោយ ដ៏ល្អប្រពៃ ដ៏មានលំនឹង ដ៏ធំមហិមា ដូចជាការបង្កបង្កើតនេះគឺគ្មានអ្វីក្រៅពីស្នាព្រះហស្តនៃគំនិតរបស់ព្រះជាម្ចាស់ឡើយ..។

លោកសាស្ត្រចារ្យ អិដវិន ខនគ្លីន (Prof. Edwin Conklin) ដែលទើបបានទទួលមរណៈភាព ជាជីវវិទូដ៏ល្បីល្បាញម្នាក់មានប្រសាសន៍យ៉ាងខ្លីថា៖ «ការប៉ាន់ស្មានអំពីជីវិតមានដើមកំណើតមកពីភាពចៃដន្យ គឺប្រៀបបីដូចជាការស្មានអំពីវចនានុក្រមធំាបីរ ជាលទ្ធផលពីការបន្ទុះកើតឡើងក្នុងរោងពុម្ពដូច្នោះ ដែរ»។

ពាក្យបន្ទូលព្រះសម្តែងប្រាប់ថា៖ «យើងរាល់គ្នាក៏យល់ដោយសារសេចក្តីជំនឿនោះថា លោកីយបានកើតមកដោយសារបន្ទូលនៃព្រះ បានជារបស់ដែលមើលឃើញទាំងប៉ុន្មាន នោះមិនមែនកើតអំពីរបស់ដែលមើលឃើញទេ» (ហេព្រើរ ១១:៣)។

**ការពិចារណា៖** ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ!

**ការអធិស្ឋាន៖** ឱព្រះអើយ សូមប្រទានចិត្តនៃសេចក្តីជំនឿខ្ញុំ ដើម្បីឲ្យខ្ញុំជឿពាក្យបន្ទូលទ្រង់ផង។

## ការបើកសម្តែងរបស់ព្រះជាម្ចាស់

*នៅពេលព្រះមានបន្ទូល យើងត្រូវតែស្តាប់*

ព្រះជាម្ចាស់មានព្រះជន្មរស់នៅទោះបីមនុស្សជ្រើសរើសជឿឬមិនជឿលើទ្រង់ក៏ដោយ។ មូលហេតុមនុស្សជាច្រើនមិនជឿលើព្រះគឺពុំមែនព្រោះតែខាងឯចំណេះដឹងគេមិនអាចជឿព្រះបាននោះទេ តែពីព្រោះជំនឿលើព្រះបណ្តាលឲ្យមនុស្សដែលមានការពិចារណាគ្រប់ជ្រុងជ្រោយនឹងប្រឈមមុខនូវការពិតថាខ្លួនត្រូវទទួលខុសត្រូវចំពោះព្រះដ៏មានព្រះជន្មរស់។ មានមនុស្សជាច្រើនគ្មានឆន្ទៈនឹងប្រឈមមុខនឹងការទទួលខុសត្រូវបែបនេះ។ មនុស្សភាគច្រើនដែលជ្រកក្នុងលទ្ធិគ្មានព្រះនិយម ឬ លទ្ធិព្រះមិនអាចស្គាល់បានប្រកាន់ជំហរ បែបនោះដោយសារវាងាយស្រួល «គេចចេញ» ពីការពិតដ៏ច្បាស់លាស់ដែលមនុស្សត្រូវឆ្លើយតបចំពោះ ព្រះ អាទិកររបស់ខ្លួន។ វាក៏មិនមែនជាមូលហេតុទាក់ទងនឹង «ខ្ញុំមិនអាចជឿបាន» គឺដូចជានិយាយថា «ខ្ញុំមិនអាច ជឿបានទេ» ដូចជាករណីថា «ខ្ញុំមិនចង់ជឿ» ដូច្នេះដែរ។

ខ្ញុំដឹងវិធីពីរយ៉ាងជាវិធីដែលគេអាចស្គាល់ពីគោលបំណងរបស់ព្រះនិងមនុស្សរបស់ទ្រង់។ ទីមួយមានដំណើរនៃមូលហេតុ។ ឧទាហរណ៍ ដូចជាអ្នកស៊ើបអង្កេតដ៏ពូកែអាចប្រាប់អ្នកពីសំណុំរឿងជាច្រើនអំពីជំនាញអំពីទម្លាប់និងចរិកលក្ខណៈរបស់ខ្ញុំដោយគ្រាន់តែពិនិត្យទៅលើកិច្ចការណាមួយដែលខ្ញុំបានធ្វើឬដោះស្រាយ រហូតដល់អាចដឹងអំពីព្រះជាម្ចាស់តាមរយៈការពិនិត្យមើលយ៉ាងម៉ត់ចត់អំពីសាកលលោក ជាស្នាព្រះហស្តរបស់ទ្រង់។ ប៉ុន្តែអ្នកស៊ើបអង្កេតដែលពិនិត្យតែពីកិច្ចការដែលខ្ញុំធ្វើនឹងមិនអាចនិយាយអះអាងថាស្គាល់ខ្ញុំបានទេ។ គាត់អាចនឹងដឹងព័ត៌មានខ្លះៗពីខ្ញុំ តែមុននឹងគាត់អាចនិយាយថាស្គាល់ខ្ញុំ នោះជាចាំបាច់ត្រូវតែមានដំណើរការនៃការបើកសម្តែងថា **ខ្ញុំបានប្រស្រាយទាក់ទងនឹងគាត់**។ ខ្ញុំត្រូវតែប្រាប់គាត់ពីអ្វីដែលខ្ញុំគិត ពីអារម្មណ៍ដែលខ្ញុំមាន និងពីអ្វីដែលខ្ញុំចងធ្វើ។ ការសម្តែងប្រាប់ពីខ្លួនឯងអាចធ្វើឡើងតាមរយៈការសន្ទនាតាមរយៈការសរសេរ ឬដោយតាមវិធីផ្សេងៗទៀត។ មានតែវិធីទាំងឡាយនោះទេទើបអ្នកស៊ើបអង្កេតអាចស្គាល់ខ្ញុំ។ ហើយមានតែតាមរយៈវិធីនោះទេ ដែលគេអាចស្គាល់ព្រះជាម្ចាស់និងព្រះតំរិះ បំណងព្រះហឫទ័យនិងយល់ពីគោលបំណងទាំងឡាយរបស់ទ្រង់ ព្រះអង្គជាចាំបាច់ត្រូវតែផ្តួចផ្តើមនិងយ៉ាងហោចណាស់ធ្វើការបើកសម្តែងមួយផ្នែកណាមួយអំពីអង្គទ្រង់ដល់មនុស្ស។

យើងនឹកចាំជាថ្មីម្តងទៀតអំពីពាក្យដ៏ល្បីល្បាញរបស់សូផាដល់យ៉ូបជាសម្លាញ់របស់គាត់។ *«បើអ្នកខំស្វែងរក តើអាចនឹងស្គាល់សភាពនៃព្រះបាន ឬយល់ដល់សេចក្តីគ្រប់លក្ខណ៍របស់ព្រះដ៏មានគ្រប់ព្រះចេស្តាបានដែរឬ? នោះខ្ពស់ជាងស្ថានសួគ៌ទៅទៀត តើអ្នកអាចនឹងធ្វើយ៉ាងណាបាន ក៏ជ្រៅជាស្ថានឃុំព្រលឹងមនុស្សស្លាប់ផង ធ្វើដូចម្តេចឲ្យអ្នកយល់បាន?»* (យ៉ូប ១១៧-៨)។ តែយើងអរព្រះគុណដល់ព្រះ ព្រោះទ្រង់បានបើកសម្តែងអង្គទ្រង់។

**ការពិចារណា៖** តើអ្នកស្គាល់ព្រះច្បាស់ប៉ុណ្ណា? តើទ្រង់ស្គាល់អ្នកដែរទេ?

**ការអធិស្ឋាន៖** ឱព្រះជាម្ចាស់អើយ សូមជួយខ្ញុំឲ្យបានស្គាល់ព្រះអង្គដូចជាបានបើកសម្តែងនៅក្នុងព្រះបន្ទូលទ្រង់ផង។

## *សៀវភៅលើអស់ទាំងសៀវភៅ*

*« ចូរឲ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជាបរិសុទ្ធ»*

ក្នុងបណ្ដាសៀវភៅទាំងអស់នៅក្នុងពិភពលោកនេះ មានតែសៀវភៅមួយក្បាលគត់ដែលអះ អាងថាការបើកសម្ដែងផ្ទាល់ពីព្រះជាម្ចាស់ ប្រាប់យើងអំពីអង្គទ្រង់និងគោលបំណងទាំងឡាយរបស់ទ្រង់សម្រាប់យើង។ សៀវភៅនោះគឺជាព្រះគម្ពីរប៊ីប។ ព្រះគម្ពីរគឺជាសៀវភៅដ៏មានសារៈសំខាន់ដែលវាមានតម្លៃសាកសមក្នុងស៊ើបអង្កេតយ៉ាងម៉ត់ចត់។ ហេតុនេះ តាមរយៈពាក្យទូន្មានរបស់លោកហ្វ្រានស៊ីស បេខន (Francis Bacon) គឺ (យើង) មិនអាចថាមិនទទួលឬបដិសេធបានទេ តែត្រូវថ្លឹងថ្លែងនិងពិចារណា ហើយចូរយើងអានសៀវភៅជាមួយនឹងការអះអាងខុសពីធម្មតារបស់សៀវភៅនេះ។

ដើម្បីយុត្តិធម៌ចំពោះខ្លួនយើងនិងព្រះគម្ពីរ យើងគួរអោចវាឲ្យបានចប់។ ដូចជាចៅក្រមមិនត្រូវធ្វើការសម្រេចចិត្តនៅពេលបានស្ដាប់សំណុំរឿងត្រឹមតែពាក់កណ្ដាល យើងក៏មិនអះអាងបញ្ចប់ដែរ។ តែ ត្រូវធ្វើដូចជាចៅក្រម យើងត្រូវប្រៀបធៀបនូវភស្ដុតាងរបស់សាក្សីទាំងឡាយ ហើយថ្លឹងថ្លែងនិងពិចារណាលើកិច្ចការនិមួយៗ ដោយការស្វែងរកនូវខ្លឹមសារដ៏សំខាន់ៗជាជាងគ្រាន់តែទទួលយកអត្ថន័យមិនស៊ីជម្រៅ របស់ភស្ដុតាងនោះ។ ជាក់ស្ដែងសារៈសំខាន់នៃការអះអាងរបស់ព្រះគម្ពីរផ្ដល់ហេតុផលត្រឹមត្រូវនៃការ ចំណាយពេលវេលាចាំបាច់អំពីការសិក្សាសៀវភៅទាំងហុកសិបប្រាំមួយកណ្ឌដែលបានសរសេរដោយអ្នកនិពន្ធខុសគ្នាមិនតិចជាងសែសិបនាក់អស់រយៈកាលជាង ១៦០០ ឆ្នាំនៅក្នុងបណ្ដាទីកន្លែងឆ្ងាយពីគ្នាដូចជាពី ស្រុកបាប៊ីឡូននៃទ្វីបអាស៊ី និងរ៉ូមក្នុងទ្វីបអឺរ៉ុប។ ជាមួយនឹងភាពជាអ្នកនិពន្ធបែបនោះ បុគ្គលម្នាក់អាចនឹង សង្ឃឹមថានឹងរកឃើញនូវបណ្ដុំពាក្យខ្វែងគ្នាផ្សេងៗ។ ភាពស៊ីមេត្រីគ្នារបស់ព្រះគម្ពីរដូច្នេះគឺពិតជាគួរឲ្យ អស្ចារ្យណាស់ពីព្រោះសំណេររបស់អ្នកនិពន្ធនិមួយៗគឺបំពេញឲ្យគ្នាទៅវិញទៅមក។

នៅក្នុងការពិចារណារបស់ខ្ញុំអំពីបញ្ហាទាំងមូលនេះ សេចក្ដីពិតនៃ ២ ពេត្រុស ១:២១ បន្តិចម្ដងៗបានក្លាយទៅជាក់ច្បាស់ដល់ខ្ញុំ។ គ្មានការពន្យល់បកស្រាយដ៏សមហេតុផលណាផ្សេងទៀតឡើយ។ *« ដ្បិតសេចក្ដីទំនាយមិនដែលមក ដោយបំណងចិត្តមនុស្សទេ គឺជាមនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយដោយសារព្រះវិញ្ញាណបរិសុទ្ធទ្រង់បណ្ដាលវិញ»*។ ជំនឿនេះត្រូវបានបញ្ជាក់ច្បាស់នៅពេលខ្ញុំអានពីបទទំនាយមួយហើយមួយទៀតនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែលបានឃើញនូវសេចក្ដីសម្រេចឥតសេសសល់បន្ទាប់ពីជាច្រើនរយឆ្នាំក្រោយមក។ ឧ. អេសាយ ៥៣ បានព្យាករណ៍ទុកជាមុនអំពីការសុគតរបស់ ព្រះគ្រីស្ទយ៉ាងលម្អិតច្បាស់លាស់៧០០ឆ្នាំមុនការជាប់ឆ្កាងរបស់ទ្រង់។ ពិតមែនហើយ ការពិបាកក្នុងការសង្ស័យព្រះគម្ពីរចំពោះខ្ញុំគឺហាក់ដូចពិបាកច្រើនជាងក្នុងការជឿតាមព្រះគម្ពីរ។ បញ្ហាទាំងអស់គឺផ្នែកនៃការ មិនជឿ!

**ការពិចារណា៖** តើអ្នកអាចនិយាយថា «ខ្ញុំជឿព្រះគម្ពីរជាពាក្យបន្ទូលព្រះ ដែលព្រះវិញ្ញាណបណ្ដាលឲ្យតែង គ្មានកំហុស និងគ្មានការភាន់ច្រឡំ» ?

**ការអធិស្ឋាន៖** ឱព្រះជាម្ចាស់អើយ សូមជួយខ្ញុំឲ្យស្រឡាញ់ព្រះគម្ពីរជាពាក្យបន្ទូលទ្រង់ផង។

ថ្ងៃទី ២២ កញ្ញា

ទំនុកដំកើង ១១៩:៩៧-១០៤, ២ ពេត្រុស ១:១៣-១៦ *« គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មាន*

## ស្តង់ដាររបស់ព្រះ

*« ចូរបរិសុទ្ធ ដូចជាអញបរិសុទ្ធ»*

ទោះជាយ៉ាងណា ការទទួលស្គាល់ព្រះគម្ពីរបាននាំឲ្យខ្ញុំមកប្រឈមមុខផលលំបាកដ៏ធ្ងន់ធ្ងរមួយ ព្រោះព្រះគម្ពីរកំណត់ស្តង់ដារនៃសេចក្តីសុចរិតដែលខ្ញុំមិនអាចឈានយកបាន។ ព្រះគម្ពីរប្រកាសថាអ្វីៗដែលមិនត្រឹមត្រូវតាមស្តង់ដាររបស់វានោះគឺជាអំពើបាប។ សូមនឹកចាំថាព្រះទ្រង់ជ្រាបរាល់គំនិតខាងក្នុងចិត្តរបស់អ្នក ឧទាហរណ៍បើគ្រាន់តែសាកវាស់ខ្លួនអ្នកនឹងស្តង់ដារ៖ « *នោះព្រះយេស៊ូវឆ្លើយថា « ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង» ។ នេះជាបញ្ញត្តយ៉ាងសំខាន់ ទី១»* (ម៉ាថាយ ២២:៣៧-៣៨)។

ប្រឈមនឹងសេចក្តីបង្រៀងនៅខគម្ពីរខាងលើ តើអ្នកអាចអះអាងថាបានរស់នៅដូចបញ្ញតនោះក្នុងជីវិតរបស់អ្នកដែរទេ? គ្មានបុគ្គលណាម្នាក់អាចអះអាងដោយស្មោះត្រង់ថាបានឈានដល់កម្រិតល្អគ្រប់លក្ខណ៍នោះឡើយ។ ទឹកចិត្តស្មោះត្រង់នឹងថ្លែង រ៉ូម ៣:១០ និង ២៣ ឡើងវិញថា៖ *« គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង.. ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ»*។ គ្រប់គ្នាបរាជ័យ ឈានមិនដល់ស្តង់ដាររបស់ព្រះ។

មានបុរសវ័យក្មេងម្នាក់សួរខ្ញុំថា៖ *« តើលោកគិតថាវាជារឿងយុត្តិធម៌ដែរទេសម្រាប់ព្រះកំណត់ស្តង់ដារ ដ៏ខ្ពស់រហូតគ្មានអ្នកណាម្នាក់អាចទទួលយកបាន រួចហើយជំនុំជំរះព្រោះតែឈានមិនដល់ស្តង់ដារនោះ?»* ។

ខ្ញុំក៏ឆ្លើយថា៖ *« ព្រះជាម្ចាស់ឥតបានកំណត់ឲ្យមានស្តង់ដារកណ្តាលនៃភាពបរិសុទ្ធដូចជាមន្ត្រីផ្លូវការ កំណត់ស្តង់ដារកណ្តាលនៃកំពស់សម្រាប់អង្គរក្សរបស់គាត់ឡើយ។ នៅក្នុងករណីបែបនេះ មនុស្សម្នាក់អាច មានលក្ខណះសម្បត្តិផ្សេងៗទៀតទាំងអស់ តែបើគាត់នៅខ្វះមួយសង់ទីម៉ែត្រក៏គាត់មិនមានលក្ខណះសម្បត្តិ គ្រប់គ្រាន់ដែរ។*

*« ព្រះពិតជាមិនបានកំណត់ស្តង់ដារអ្វីសោះឡើយ ព្រោះទ្រង់គឺជាស្តង់ដារ។ ព្រះអង្គគឺជាព្រះដ៏បរិសុទ្ធ ហើយដើម្បីរក្សាបុគ្គលិកលក្ខណះរបស់ទ្រង់ ព្រះអង្គត្រូវបន្តនៅបរិសុទ្ធក្នុងទង្វើគ្រប់យ៉ាងជាមួយមនុស្ស ដោយការរក្សាស្តង់ដារមិនលំអៀងទៅលើការអនុវត្តន៍ជាច្រើនដែលត្រូវប្រតិបត្តិសម្រាប់ទ្រង់និងយើង»* ។

ហេតុនេះហើយទើបយើងឃើញថាព្រះមិនត្រឹមបានបើកសម្តែងនូវភាពដ៏បរិសុទ្ធរបស់ទ្រង់ទេ តែទ្រង់ក៏បានបង្ហាញប្រាប់ដល់យើងនូវស្ថានភាពបាត់បង់ដ៏វេទនារបស់យើង ហើយពីតម្រូវការដ៏ចាំបាច់នូវសេចក្តីសង្គ្រោះរបស់ទ្រង់ផងដែរ។

**ការពិចារណា៖** តើធ្វើដូចម្តេចឲ្យយើងបានបរិសុទ្ធដ៏ដូចជាទ្រង់បរិសុទ្ធ?

**ការអធិស្ឋាន៖** ព្រះជាម្ចាស់អើយ សូមបង្កើតចិត្តបរិសុទ្ធនៅក្នុងខ្ញុំផង។

 *«...ឯព្រលឹងណាដែលណាដែលធ្វើបាប គឺព្រលឹងនោះឯងនឹងត្រូវស្លាប់វិញ»*

## គ្រប់គ្នាបានធ្វើបាប

*ដ៏សាមញ្ញបំផុតបាបគឺជាការបះបោរប្រឆាំងនឹងព្រះជាម្ចាស់*

សតិសម្បជញ្ញៈនិងការសុភវិនិច្ឆ័យរបស់ខ្ញុំបណ្តាលឲ្យខ្ញុំទទួលស្គាល់ថាខ្ញុំបានខ្វះមិនដល់ស្តង់ដារបរិសុទ្ធសៅហ្មងរបស់ព្រះ ហើយដូច្នេះខ្ញុំជាអ្នកមានបាបនៅក្នុងព្រះនេត្ររបស់ទ្រង់។

ផ្អែកលើការទទួលស្គាល់របស់ខ្ញុំថាបានធ្វើបាប ការថ្កោលទោសនៃព្រះនៅក្នុងអេសេគាល ១៨:៤ ក៏បានប្រកាសមកថា៖ «...*ឯព្រលឹងណាដែលណាដែលធ្វើបាប គឺព្រលឹងនោះឯងនឹងត្រូវស្លាប់វិញ*»។

ខគម្ពីរនោះបានទទួចដល់ខ្ញុំយ៉ាងដូច្នេះ៖ ច្បាប់នៅក្នុងចក្រភពអង់គ្លេសចែងថាអ្នកបើកបរទាំងអស់ត្រូវប្រកាន់យកខាងឆ្វេងនៃដងផ្លូវ។ នៅក្នុងទីក្រុងញូវយ៉ក ច្បាប់ចរាចរណ៍លើដងផ្លូវតម្រូវឲ្យអ្នកបើកបរប្រកាន់ស្តាំ។ ឥឡូវ ឧទាហរណ៍ថា បើខ្ញុំកំពុងបើកបរនៅក្នុងទីក្រុងឡុងដុងហើយប្រកាន់យកខាងស្តាំ។ នៅពេលគេនាំទៅឈរនៅមុខចៅក្រម ខ្ញុំនិយាយថា *«នេះគឺពិតជាគួរឲ្យអស់សំណើច។ នៅក្នុងសហរដ្ឋអាមេរិកច្បាប់អនុញ្ញាតឲ្យពួកយើងបើកបរដោយប្រកាន់យកខាងស្តាំ»*។

*«លោកមិនមែនទទួលការជំនុំជំរះដោយច្បាប់របស់ប្រទេសអាមេរិកាំងទេ»* ចៅក្រមឆ្លើយតប។ *«វាមិនសំខាន់ពីច្បាប់ប្រទេសណាមួយទេ លោកគួរតែយកចិត្តទុកដាក់នឹងខ្លួនលោកជាមួយនឹងច្បាប់ប្រទេសនេះដែលជំនុំជំរះលោក ជាកន្លែងដែលលោកកំពុងមានវត្តមានវិញ»*។

ដូចគ្នាដែរ ហើយដរាបណាស្តង់ដាររបស់ព្រះជាចម្បង ខ្ញុំជាមនុស្សបាត់បង់ ពីព្រោះស្តង់ដាររបស់ព្រះគឺជាខ្នាតតែមួយគត់ដែលជំនុំជំរះខ្ញុំតាំងពីអស់កល្បមក។ ខ្ញុំជាមនុស្សបាត់បង់ដ៏គ្មានក្តីសង្ឃឹម។ ខ្ញុំបានចាប់ផ្តើមឃើញថាវាមិនសំខាន់អ្វីទាល់តែសោះនូវអ្វីដែលខ្ញុំបានគិត ឬអ្វីដែលមិត្តភក្តិរបស់ខ្ញុំបានប្រាប់ខ្ញុំដែរ។ ការជំនុំជំរះគឺអាស្រ័យតាមអ្វីដែលព្រះជាម្ចាស់បានមានបន្ទូល មិនផ្អែកលើអ្វីដែលមិត្តភក្តិខ្ញុំនិយាយដែរ។ ម៉្យាងវិញទៀត ពីព្រោះនៅក្នុងការជំនុំជំរះរបស់ព្រះយើងទាំងអស់គ្នាសុទ្ធតែបានធ្វើបាប វាគ្មានប្រយោជន៍អ្វីក្នុងការស្វែងរកអ្នកដទៃទៀតជំនួយទេ ពីព្រោះពួកគេក៏ស្ថិតនៅក្រោមការថ្កោលទោសដដែលដូចជាខ្ញុំដែរ។

អរគុណព្រះជាម្ចាស់សម្រាប់ការបើកសម្តែងដល់យើងនូវក្រិត្យវិន័យដ៏បរិសុទ្ធនិងតម្រូវការដ៏យុត្តិធម៌។ ក្រិត្យវិន័យបង្ហាញប្រាប់ខ្ញុំពីស្ថានភាពពិតរបស់ខ្ញុំ *«ដ្បិតក្រិត្យវិន័យគ្រាន់តែសម្តែងឲ្យស្គាល់អំពើបាបប៉ុណ្ណោះ»* (រ៉ូម ៣:២០)។ ក្រិតវិន័យជាស់ឲ្យយើងភ្ញាក់រឭកពីតម្រូវការនិងដឹកនាំយើងរាលើគ្នាទៅដល់ព្រះសង្គ្រោះតែមួយគត់ដែលបានលោះយើងរាល់គ្នាពីបណ្តាសារបស់ក្រិត្យវិន័យ (កាឡាទី ៣:១៣,២៤)។

**ការពិចារណា៖** សូមព្យាយាមទន្ទេញចងចាំ ២ កូរិនថូស ៥:២១។

**ការអធិស្ឋាន៖** ឱព្រះជាម្ចាស់អើយ ខ្ញុំបានធ្វើបាបទាស់នឹងទ្រង់។ សូមសន្តោសប្រណីដល់ខ្ញុំផង។

## ព្រះយេស៊ូវគ្រីស្ទ៖ ជាព្រះរាជបុត្រានៃព្រះ?

*ព្រះយេស៊ូវគ្រីស្ទជាអង្គចំណាំងនៃព្រះជាម្ចាស់*

ព្រះគម្ពីរដដែលបានសម្តែងប្រាប់ខ្ញុំថាជាអ្នកមានបាបក៏សម្តែងប្រាប់ខ្ញុំពីព្រះយេស៊ូវគ្រីស្ទដែលបានអះអាងថាទ្រង់ជាព្រះរាជបុត្រានៃព្រះផងដែរ។

បើព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះ ដូចនេះយើងអាចជឿជាក់ថាមានសេចក្តីសង្គ្រោះពិតប្រាកដ តែបញ្ហាលំបាកមួយដែលយើងត្រូវសួរ៖ តើព្រះយេស៊ូវពិតជាព្រះរាជបុត្រានៃព្រះមែន? ព្រះអង្គអាចស្ថិតក្នុងបុគ្គលបីប្រភេទគឺទ្រង់អាចជាព្រះរាជបុត្រានៃព្រះ ជាជនឆបោក និងជាមនុស្សសុចរិតដែលត្រូវបានការស្រមើស្រម៉ៃគ្រប់គ្រង។ តែយើងឃើញថាកាលគង់នៅលើផែនដី ព្រះយេស៊ូវបានប្រឈមមុខនឹងបណ្តាពួកអ្នកប្រាជ្ញជាច្រើននាក់ដែលត្រូវបានគេបញ្ជូនមកដើម្បីចាប់កំហុសទ្រង់ ក៏ប៉ុន្តែព្រះអង្គបានធ្វើឲ្យគេរកសំណួរបន្តសួរទ្រង់ទៀតមិនបាន (ម៉ាថាយ ២២:៤៦)។ ហើយនៅពេលយើងពិចារណាតាមចំណេះដឹងរបស់យើងអំពីសេចក្តីបង្រៀនប្រកបដោយគតិបណ្ឌិតរបស់ទ្រង់ នោះយើងយល់ឃើញយ៉ាងច្បាស់លាស់ថាការស្រមើស្រម៉ៃមិនបានគ្រប់គ្រងទ្រង់នោះឡើយ។ តើពីព្រោះតែគតិបណ្ឌិតរបស់ទ្រង់អស្ចារ្យពេកទើបទ្រង់អាចប្រើប្រាស់វាដើម្បីឆបោកមនុស្សទាំងឡាយ?

តើអ្នកធ្លាប់ឮគេនិយាយអំពីមនុស្សកម្លោះដែលសេពគប់នឹងអ្នកឆបោកនិងមនុស្សទុច្ចរិត ហើយព្រោះការសេពគប់នឹងពួកអ្នកទាំងនោះគាត់បានប្រែក្លាយទៅជាមនុស្សមានឋានៈខ្ពង់ខ្ពស់ ជាមនុស្សបរិសុទ្ធ និងទៀងត្រង់ដែរឬទេ? ចម្លើយគឺប្រាកដជាមិនអាចទៅរួចបានឡើយ។ ចំណែកអ្នកវិញក៏យល់ថាមិនធ្លាប់ឮករណីបែបនោះផងដែរ។ ប៉ុន្តែខ្ញុំបានស្គាល់មនុស្សវ័យក្មេងម្នាក់ដែលទទួលជឿព្រះគ្រីស្ទក្នុងជីវិតរបស់គាត់ក្រោយមកគាត់ត្រូវបានលើកពីបំណងប្រាថ្នាដ៏ថោកទាបទៅជាមនុស្សដ៏ថ្លៃថ្នូរម្នាក់។ ចំណែកខ្ញុំផ្ទាល់វិញក៏មិនអាចជឿថាការទទួលយកមនុស្សឆបោកមកក្នុងជីវិតអាចបំផ្លាស់ប្រែបុគ្គលណាម្នាក់ជាមនុស្សល្អបានដែរ។

ជួនជាមានថ្ងៃមួយខ្ញុំបានឮមនុស្សម្នាក់និយាយថា *«ខ្ញុំជំពាក់ព្រះយេស៊ូវគ្រីស្ទ ទើបខ្ញុំអាចដើរតាមដងផ្លូវដោយងើបមុខឡើងហើយអាចប្រឈមមុខនឹងស្ថានភាពលំបាកនៅក្នុងលោកីយ។ ខ្ញុំជំពាក់ព្រះអង្គដែលបានធ្វើឲ្យខ្ញុំអាចមើលទៅកាន់ស្ត្រីបរិសុទ្ធទល់នឹងមុខ និងកាន់ដៃមនុស្សទៀងត្រង់បាន»*។

ពាក្យសម្តីដែលមិនបានបញ្ជាក់ដោយទង្វើគឺគ្មានអត្ថន័យអ្វីឡើយ។ ព្រះយេស៊ូវបានប្រកាសថាទ្រង់ជាព្រះរាជបុត្រានៃព្រះ។ ព្រះអង្គបានបញ្ជាក់ពាក្យសម្តីរបស់ទ្រង់តាមរយៈការសម្តែងនូវការអស្ចារ្យរបស់ទ្រង់ជាច្រើន។ នៅចំពោះពួកអ្នកមិនជឿសាសន៍ជ្វីប ព្រះយេស៊ូវបន្លឺ ឡើងថា៖ *«... ទោះបើអ្នករាល់គ្នាមិនជឿខ្ញុំ គង់តែត្រូវជឿដល់ការទាំងនោះដែរ ដើម្បីឲ្យអ្នករាល់គ្នាបានដឹង ហើយជឿថាព្រះវរបិតាទ្រង់គង់នៅក្នុងខ្ញុំ ហើយខ្ញុំនៅក្នុងទ្រង់»* (យ៉ូហាន ១០:៣៧)។

**ការពិចារណា៖** ការអស្ចារ្យដ៏ធំជាងគេបង្អស់របស់ព្រះយេស៊ូវគឺជាការមានព្រះជន្មរស់ពីស្លាប់ឡើងវិញរបស់ទ្រង់។

**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមអរព្រះគុណដែលទ្រង់បានបញ្ជូនព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជ បុត្រារបស់ទ្រង់មកសុគត់ជំនួសខ្ញុំ។

ថ្ងៃទី ២៥ កញ្ញា
ទំនុកដំកើង ៥១:១-១៣, ២ កូរិនថូស ៥:១៧-១៩ *«មើល អញធ្វើទាំងអស់ឡើងជាថ្មី»*

## កើតជាថ្មីនៅក្នុងព្រះគ្រីស្ទ

ខ្ញុំហៅធ្វើទីបន្ទាល់ពីទស្សនៈនៃពិភពដ៏មានអារ្យធម៌ខ្ពង់ខ្ពស់ទាំងមូលដែលស្គាល់ថាព្រះយេស៊ូវគ្រីស្ទយ៉ាងហោចជាមនុស្សល្អមួយរូប។ ប្រសិនបើដូច្នោះមែន នោះជាមនុស្សស្មោះត្រង់ ហើយបើជាអ្នកស្មោះត្រង់ព្រះអង្គត្រូវតែមានបុគ្គលិកលក្ខណៈដូចជាទ្រង់បានអះអាងថាជាព្រះរាជបុត្រានៃព្រះ ដែលបានត្រូវបានបញ្ជូនមកដើម្បីថ្វាយជីវិតដ៏គ្មានបាបរបស់ទ្រង់ជំនួសជីវិតដ៏មានបាបរបស់អ្នកនិងខ្ញុំ។

អ្នកដឹកនាំពីបណ្តាអាជីពខុសៗគ្នាជាច្រើនមានពាក្យពេចន៍ដើម្បីបញ្ចេញពីទស្សនៈរបស់ខ្លួនអំពីព្រះយេស៊ូវគ្រីស្ទ៖

លោកព្រឹទ្ធសភាសហរដ្ឋអាមេរិក ម៉ាក អូ ហេតហ្វៀល (Mark O. Hatfield) បានធ្វើទីបន្ទាល់ថា៖ «*ខ្ញុំបានដឹងថារយៈពេល៣១ឆ្នាំ ខ្ញុំបានរស់នៅសម្រាប់ភាពអត្មានិយម ហើយបានសម្រេចចិត្តចង់រស់នៅជីវិតដែលនៅសល់ទាំងប៉ុន្មានរបស់ខ្ញុំសម្រាប់ថ្វាយតែព្រះយេស៊ូវគ្រីស្ទវិញម្តង។ ខ្ញុំបានទូលសូមឲ្យព្រះអត់ទោសនូវជីវិតអត្មានិយមជាស្ថូលហើយសូមឲ្យ (ព្រះអង្គ) ធ្វើជីវិតខ្ញុំឲ្យក្លាជារបស់ទ្រង់។ ការដើរតាមព្រះយេស៊ូវគ្រីស្ទជាបទពិសោធន៍នូវការប្រឈមមុខការលំបាក ការផ្សងព្រេង និងក្តីអំណររីករាយដែលនឹងកើតមានឡើងជាបន្តបន្ទាប់។ ការរស់នៅជីវិតជាគ្រីស្ទបរិស័ទដែលប្តេជ្ញាចិត្តគឺជានឹងស្កប់ស្កល់ចិត្តពីព្រោះជីវភាពនោះផ្តល់នូវគោលបំណងនិងគោលដៅពិតប្រាកដដល់ខ្ញុំតាមរយៈការដែលមិនបម្រើខ្លួនខ្ញុំតែបម្រើព្រះយេស៊ូវគ្រីស្ទ*»។

លោក រ៉ូបឹត អ៊ី (បុប) រីឆាដស៍ (Robert E. (Bob) Richards) អតីតកីឡាកររត់ប្រណាំងជើងឯកអូឡាំពិក បានមានប្រសាសន៍ថា៖ «*ហេតុផលតែមួយគត់របស់ខ្ញុំនៅក្នុងវិស័យកីឡាគឺដើម្បីផ្តល់ជាទីបន្ទាល់ដល់យុវជនទូទាំងពិភពលោកឲ្យដឹងថាព្រះយេស៊ូវគ្រីស្ទអាចសង្គ្រោះពីបាប ហើយថាមនុស្សម្នាក់អាចក្លាយជាគ្រីស្ទបរិស័ទនិងនៅតែអាចសម្រេចកិច្ចការទាំងឡាយនិងមានភាពថ្លៃប្រឌិតដ៏ល្អអស្ចារ្យផងដែរ។ មនុស្សវ័យក្មេងៗត្រូវតែដឹងថាព្រះជាម្ចាស់បញ្ចេញថាមពលផ្នែកព្រលឹងវិញ្ញាណយ៉ាងខ្លាំងមហិមានៅពេលព្រះយេស៊ូវគ្រីស្ទបានសុគត់នាភ្នំកាល់វ៉ារី*»។

លោកអគ្គមេបញ្ជាការ វីលៀម ខេ ហារីសុន (និវត្តជន) (Lt. Gen. William K. Harrison (Ret)) អតីតប្រតិភូជាន់ខ្ពស់នៃក្រុមអ្នកអង្កេតការឈប់បាញ់គ្នារបស់អង្គការសហប្រជាតិតនៅប្រទេសកូរ៉េ (UNCTT) និងក្រោយមកជាអគ្គមេបញ្ជាការនៃទីបញ្ជាការដ្ឋានការីបៀន (Caribbean Command) បានសរសេរថា៖ «*វាគឺពិតជាអស្ចារ្យណាស់ក្នុងការជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយខ្ញុំគឺពិតជាអរគុណយ៉ាងខ្លាំងដែលព្រះជាម្ចាស់បានដឹកនាំខ្ញុំប្រកបដោយក្តីសន្តោសប្រណីចូលទៅជំនឿដ៏ប្រោសលោះក្នុងព្រះគ្រីស្ទ។ ព្រះទ្រង់ប្រទានដល់យើង (អ្នកជឿលើព្រះគ្រីស្ទ) នូវបទពិសោធន៍ផ្ទាល់ខ្លួនប្រចាំថ្ងៃដែលជាភស្តុតាងដ៏គួរឲ្យជឿជាក់អំពីភាពប្រាកដនិយមអំពីជីវិតនៅក្នុងព្រះគ្រីស្ទ*»។

**ការពិចារណា៖** បើអ្នកណានៅក្នុងព្រះគ្រីស្ទ អ្នកនោះជាមនុស្សថ្មី។ វាគឺមិនត្រឹមតែជា «ការប្រែទៅជាមានស្លឹកថ្មីទេ តែគឺជាមនុស្សថ្មី»។

**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់សម្រាប់ការប្រទាននូវជីវិតថ្មីដល់ខ្ញុំ។

ថ្ងៃទី ២៦ កញ្ញា

សុភាសិត ១៤:១១-១៣ ម៉ាថាយ ៧:២១-២៩ *«...សេចក្តីពិតនោះនឹងប្រោសឲ្យអ្នករាល់គ្នាបានរួច...»*

## ភាពស្មោះត្រង់គឺមិនទាន់គ្រប់គ្រាន់ទេ

*យើងមិនបានសេចក្តីសង្គ្រោះដោយសារភាពស្មោះត្រង់ទេ តែយើងអាចនឹងជាមនុស្សបាត់បង់បើគ្មានភាពស្មោះត្រង់*

ខ្ញុំមិនបង្ខិតបង្ខំឲ្យអ្នកទទួលព្រះយេស៊ូវជាព្រះរបស់អ្នកទេ ពីព្រោះថាអ្នកប្រហែលអាចជាមានការជំទាស់នៅក្នុងចិត្ត។ ហើយថ្វីដ្បិតតែការអះអាងនៃព្រះគម្ពីរទំនងជាពិតត្រឹមត្រូវក៏ដោយ តើមិនមែនទស្សនៈផ្សេងទៀតទំនងជាពិតផងដែរ? តើហេតុអ្វីបានជាមិនព្រមស្វែងរកហេតុផលហើយធ្វើការសុកវិនិច្ឆ័យដោយទស្សនៈទាំងនោះដោយយុត្តិធម៌?

នៅខណៈពេលធ្វើទីបន្ទាល់ពីជំនឿរបស់ខ្ញុំដល់មិត្តភក្តិម្នាក់ មិត្តនោះបានឆ្លើយថា៖ *«សម្លាញ់ឯងមានប្រសាសន៍ត្រឹមត្រូវ ក៏ប៉ុន្តែខ្ញុំក៏ត្រឹមត្រូវផងដែរ ថ្វីដ្បិតខ្ញុំមិនយល់ដូចជាឯង។ ហើយវាហាក់ដូចគ្មានបញ្ហាអ្វីសោះចំពោះជំនឿលើអ្វីដែលមនុស្សម្នាក់ប្រកាន់ជឿតាម ដរាបណាគាត់ស្មោះត្រង់នឹងសេចក្តីជំនឿនោះ»*។

ចូរយើងវិភាគពាក្យសម្តីទាំងនោះ។ នាព្រឹកថ្ងៃអាទិត្យមួយ អ្នកជិតខាងរបស់ខ្ញុំបាននិយាយទៅកាន់ភរិយានិងសមាជិកគ្រួសារគាត់ថា៖ *«តោះ យើងជិះឡានដើរលេង»*។ ក្នុងដំណើរឆ្ពោះទៅភាគខាងជើង គាត់បានបើករថយន្តមកដល់ផ្លូវឆ្លងកាត់ផ្លូវរថភ្លើងមួយ។ មុនពេលឆ្លងកាត់ផ្លូវរថភ្លើងនោះ គាត់ជឿយ៉ាងស្មោះត្រង់ថានឹងគ្មានរថភ្លើងនឹងធ្វើចរាចរនាវេលាព្រឹកថ្ងៃអាទិត្យនោះឡើយ។ តែក្រោយមកគាត់ត្រូវបានរថភ្លើងបុកស្លាប់នៅនឹងកន្លែង។ កូនប្រុសគាត់បាក់ឆ្អឹងដៃ ហើយកូនស្រីពៅគាត់ប៉ង់ស៊ីម៉ងត៍អស់រយៈពេលជាច្រើនខែ។ តើការជឿដ៏ស្មោះត្រង់ឥតមន្ទិលសង្ស័យរបស់គាត់បានសង្គ្រោះគាត់ឲ្យរួចផុតពីគ្រោះថ្នាក់ចរាចរណ៍ដែរទេ? ខ្ញុំស្គាល់គិលានុបដ្ឋាយិកាម្នាក់ដែលត្រូវវេនយាមពេលយប់ នាងជឿដ៏ស្មោះត្រង់ថានាងមានឱសថដ៏ត្រឹមត្រូវតាមវេជ្ជបញ្ជានៅក្នុងដៃ ក៏ប៉ុន្តែនាងបានគិតខុសព្រោះអីក្នុងរយៈពេលត្រឹមតែម្ភៃនាទីអ្នកជម្ងឺរបស់នាងបានស្លាប់ទោះបីជាមានការខិតខំជួយសង្គ្រោះដ៏អស់ពីសមត្ថភាពបែបណាក៏ដោយ។

ជាការពិតណាស់ យើងត្រូវការភាពស្មោះត្រង់ តែជាចាំបាច់យើងត្រូវជឿលើសេចក្តីពិតដ៏ស្មោះត្រង់ដោយមិនមែនជឿលើសេចក្តីខុសឆ្គងដ៏ស្មោះត្រង់នោះឡើយ។ តាមពិត ការមានជំនឿលើសេចក្តីខុសឆ្គងអាចនឹងក្លាយជាមធ្យោបាយបោកបញ្ឆោតនិងទីបំផុតនឹងនាំមកនូវគ្រោះអន្តរាយដល់ខ្លួនឯងយើងថែមទៀតផង។ សេចក្តីបង្រៀននៃព្រះមហាក្សត្រដ៏ឆ្លាតវៃភ្ជាប់មកនូវអត្ថន័យដ៏ជ្រាលជ្រៅសម្រាប់យើង៖ *«មានផ្លូវមួយដែលមើលទៅដូចជាត្រឹមត្រូវល្អដល់មនុស្ស តែចុងបំផុតនៃផ្លូវនោះ គឺជាសេចក្តីស្លាប់វិញ»* (សុភាសិត ១៤:១២)។ ជំនឿដ៏ស្មោះត្រង់ជាក់លាក់របស់មនុស្សម្នាក់ ទោះបីវាពោះរពេញ ទៅដោយភាពស្មោះត្រង់ គង់តែទីបំផុតនឹងដឹកនាំគាត់ឆ្ពោះទៅរកសេចក្តីហិនវិនាស អន្តរាយផង ដែរ។

**ការពិចារណា៖** ព្រះយេស៊ូវមានបន្ទូលថា៖ *«អ្នករាល់គ្នានឹងស្គាល់សេចក្តីពិត ហើយសេចក្តីពិតនោះនឹងប្រោសឲ្យអ្នករាល់គ្នាបានរួច...ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត...»* (យ៉ូ. ៨:៣២,១៤:៦។

**ការអធិស្ឋាន៖** ឱព្រះជាម្ចាស់អើយ សូមទ្រង់បើកភ្នែកខ្ញុំប្រយោជន៍ឲ្យខ្ញុំបានយល់ដឹងពីសេចក្តីពិតនៃទ្រង់ផង។

## មាគ៌ាច្រើនទៅកាន់ព្រះជាម្ចាស់ ?

### *មានព្រះតែមួយ មានព្រះរាជបុត្រាតែមួយ មានផ្លូវតែមួយ*

ព្រះគម្ពីរមិនបានបន្សល់ទុកនូវភាពមន្ទិលសង្ស័យឡើយ។ នៅក្នុង យ៉ូហាន ១៤:៦ ព្រះគ្រីស្ទមានបន្ទូលថា៖ *«ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ»*។ កិច្ចការ ៤១២ ចែងថា៖ *«ហើយគ្មានសេចក្តីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ»*។ បើអ្នកអាចទៅស្ថានសួគ៌តាមរយៈផ្លូវណាមួយផ្សេងទៀត នោះអ្នកនឹងក្លាយជាអ្នកធ្វើទីបន្ទាល់ចាប់តាំងពីអស់កល្បចំពោះការពិតដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀនខុសឆ្គងនៅពេលទ្រង់បានមានបន្ទូលថាគ្មានផ្លូវណាផ្សេងទៀតជាមិនខានឡើយ។ ប៉ុន្តែចាប់តាំងពីទ្រង់ប្រទាននូវភស្តុតាងទាំងស្រុងអំពីសភាពជាព្រះរាជបុត្រានៃព្រះ តើវាមិនមែនជាការឆ្កួតលីលាដែលព្យាយាមចូលទៅកាន់ព្រះជាម្ចាស់តាមរយៈផ្លូវផ្សេងទៀតជាជាងតាមរយៈព្រះគ្រីស្ទផ្ទាល់ ជាអង្គបុគ្គលដែលបានប្រកាសអះអាងជាផ្លូវព្រះបានកំណត់?

ហេតុផលពិតប្រាកដដែលមនុស្សជាច្រើនចង់បានមធ្យោបាយផ្សេងគឺពីព្រោះតែផ្លូវនៃឈើឆ្កាងគឺជាផ្លូវដ៏បន្ទាបខ្លួនហើយមនុស្សគឺអំណួតនៅក្នុងចិត្ត។ ប៉ុន្តែចូរយើងនឹកចាំពីផ្លូវនៃឈើឆ្កាងគឺជាផ្លូវដ៏បន្ទាបខ្លួនសម្រាប់ទទួលបានព្រះគ្រីស្ទ ដូចជាយើងអាននៅក្នុងភីលីព ២:៥-៨ *«ត្រូវតែមានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង។ ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់ឈើឆ្កាងផង»*។

ការជជែកវែកញែកទាំងអស់អំពី «មាគ៌ាជាច្រើនទៅកាន់ព្រះជាម្ចាស់» នឹងមិនជាចាំបាច់ប្រសិនបើមានការទទួលស្គាល់ថាព្រះយេស៊ូវគឺជាព្រះ ដែលព្រះគម្ពីរបញ្ជាក់ម្តងហើយម្តងទៀត។ ព្រះយេស៊ូវបានមានបន្ទូលថា៖ *«អ្នកណាដែលឃើញខ្ញុំ នោះក៏បានឃើញព្រះវរបិតាដែរ... ខ្ញុំនៅក្នុងព្រះវរបិតា ហើយព្រះវរបិតាគង់នៅក្នុងខ្ញុំ...»* (យ៉ូហាន ១៤:៩,១០)។

*«ពីព្រោះមានព្រះតែ១ ហើយមានអ្នកសង្រួបសង្រួមតែ១ នៅកណ្តាលព្រះ និងមនុស្ស គឺជាមនុស្សដ៏ជាព្រះគ្រីស្ទយេស៊ូវ»* (១ ធីម៉ូថេ ២:៥)។

**ការពិចារណា៖** ការចូលមកឯព្រះយស៊ូវគឺជាការធ្វើឆ្ពោះទៅរកព្រះដ៏ជាព្រះវរបិតា។

**ការអធិស្ឋាន៖** ឱព្រះវរបិតាអើយ សូមអរព្រះគុណទ្រង់ ដែលខ្ញុំអាចចូលមកកាន់ទ្រង់បានតាមរយៈព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រារបស់ទ្រង់។

ថ្ងៃទី ២៨ កញ្ញា

អេសេគាល ១៨:១-៩, ១ ពេត្រុស ១:១៨-២១ *«...ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា...»*

## យើងមានបំណុលត្រូវសង

*យើងមិនអាចសងតាមរយៈមធ្យោបាយដែលយើងគ្មាននោះទេ*

មនុស្សខ្លះបានផ្ដល់មតិថាអ្វីៗទាំងអស់ដែលមនុស្សត្រូវការធ្វើគឺកែទម្រង់ដ៏ស្មោះត្រង់ ធ្វើការឲ្យបានល្អប្រសើរជាមុននាអនាគត ដូច្នេះហើយត្រូវបំភ្លេចនូវភាពកង្វះខាតពីអតីតកាល។ នេះគឺត្រូវបានសន្មត់ថានឹងធ្វើឲ្យបុគ្គលម្នាក់សាកសមសម្រាប់ស្ថានសួគ៌។ តើមតិនេះអាចមានប្រសិទ្ធិភាពដែរទេ?

ចូរយើងឧបមាថាអ្នកគ្រប់គ្រងនៃក្រុមហ៊ុនពាណិជ្ជកម្មទៅជួបគណនេយ្យកររបស់គាត់រួចក៏រកឃើញថាក្រុមហ៊ុនគាត់ជំពាក់បំណុលផលិតករ និងពាណិជ្ជករដទៃទៀតចំនួន ៥០,០០០$។ គាត់មានប្រសាសន៍ថា៖ *«ចូរសរសេរលិខិតទៅកាន់អ្នកទាំងនោះហើយជម្រាបពួកគាត់ថាពួកយើងមិនខ្វល់អំពីបញ្ហាអតីតកាលដែលពួកយើងបានចាប់ផ្ដើមធ្វើកត់បញ្ជីចេញចូលរបស់យើងទេ ប៉ុន្តែពួកយើងសន្យាថានឹងសងមិនឲ្យខ្វះមួយសេននូវគ្រប់ការធ្វើពាណិជ្ជកម្មនាពេលអនាគត ហើយចាប់ពេលនេះតទៅនឹងប្រតិបត្តិតាមស្តង់ដារសុច្ចរិតនៃធ្វើពាណិជ្ជកម្ម»*។

មន្ត្រីគណនេយ្យនឹងគិតថានិយោជករបស់គាត់ក្លាយជាមនុស្សឆ្កួត ហើយនឹងមិនព្រមសរសេរសំណើរបែបនោះផ្ញើទៅម្ចាស់បំណុលឡើយ។ ប៉ុន្តែផ្ទុយទៅវិញ មានមនុស្សដែលមានវិនិច្ឆ័យត្រឹមត្រូវជាច្រើនគឺកំពុងព្យាយាមទៅស្ថានសួគ៌តាមរយៈសំណើរបែបនេះ ដោយការផ្ដល់នូវអ្វីៗដែលឆ្លើយតបនឹងកាតព្វកិច្ចទាំងឡាយរបស់ពួកគេចំពោះព្រះសម្រាប់អនាគត តែមិនព្រមបារម្ភអំពីអតីតកាលសោះឡើយ។ តែនៅក្នុងសាស្ដា ៣:១៥ សម្ដែងប្រាប់យើងថា *«...ព្រះទ្រង់ស្វែងរកអ្វីៗដែលកន្លងបាត់ហើយឲ្យបានមកវិញ»*។ សូម្បីយើងសន្មត់ថាយើងអាចនឹងចាប់ផ្ដើមរស់នៅជីវិតដ៏ល្អសុក្រិតបែបណាមួយក៏ដោយ ជីវភាពនោះនឹងមិនអាចកើតមានឡើងបានឡើយ ព្រោះយើងនៅតែជាអ្នកមានបាប។

មានពាក្យថ្លែងមកថាព្រះយេស៊ូវបានយាងមកសងបំណុលជំនួសយើងដែលមិនបានជំពាក់ ជាបំណុលយើងសងមិនបាន។ ពាក្យបន្ទូលព្រះប្រកាសថា *« ឯព្រលឹងណាដែលធ្វើបាប គឺព្រលឹងនោះឯងនឹងត្រូវស្លាប់វិញ»* (អេសេគាល ១៨:៤)។ *«តែឯព្រះ ទ្រង់សំដែងសេចក្ដីស្រឡាញ់របស់ទ្រង់ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង»* (រ៉ូម ៥:៨)។ នៅក្នុងការសុគត់របស់ទ្រង់ ព្រះអង្គបានលះបង់ជីវភាពជាព្រះដ៏គ្មានបាបរបស់ទ្រង់ជំនួសយើង ដោយបញ្ចប់បំណុលដែលយើងជំពាក់មួយដងជាសម្រេច។

**ការពិចារណា៖** ព្រះយេស៊ូវបានមានបន្ទូលហៅថា៖ *«អស់ទាំងមនុស្សនៅចុងផែនដីអើយ ចូរមើលមកអញ ហើយទទួលសេចក្ដីសង្គ្រោះចុះ ដ្បិតអញនេះជាព្រះ ឥតមានណាទៀតឡើយ»*។ (អេសាយ ៤៥:២២)។

**ការអធិស្ឋាន៖** ឱព្រះយេស៊ូវអើយ ខ្ញុំសូមអរព្រះគុណ សម្រាប់ការសុគត់ជំនួសរូបខ្ញុំ ដើម្បីអត់ទោសបាបរបស់ខ្ញុំ។

## ព្រះយេស៊ូវសងថ្លៃដាច់ហើយ

### *យើងបានទទួលការប្រោសលោះដោយសារព្រះលោហិតទ្រង់*

សេចក្តីសុចរិតនៃព្រះជាម្ចាស់មិនអនុញ្ញាតឲ្យអំពើបាបពីអតីតកាលណាមួយគេចរួចដោយឥតបានទទួលការជំនុំជំរះដោយយុត្តិធម៌បានទេ។ ឃាតករនឹងអាចរស់នៅជីវភាពមួយធ្វើជាពលរដ្ឋគំរូរយៈកាលដប់ឆ្នាំបន្ទាប់ពីបានប្រព្រឹត្តឧក្រិដ្ឋកម្ម ក៏ប៉ុន្តែនៅពេលគេរកគាត់ឃើញ ច្បាប់មនុស្សជាតិនឹងផ្តន្ទាឲ្យគាត់ស្លាប់។ នោះទោះបីជាគាត់ឥតបានប្រព្រឹត្តបទមនុស្សឃាតក្នុងអំឡុងដប់ឆ្នាំ ក៏ច្បាប់នៅតែថ្កោលទោសគាត់ថាជាឃាតករដែរ។

ការបិទបាំងនូវអំពើបាបពីអតីតកាល ទោះជាបាបខាងផ្នែកចិត្តគំនិត ពាក្យសម្តី ឬផ្នែកកាយប្រព្រឹត្តដោយការធ្វើពុតជាមានជីវភាពដ៏ល្អត្រឹមត្រូវ ក៏យើងនៅជាអ្នកមានបាបនៅចំពោះព្រះជាម្ចាស់ដដែល ពីព្រោះទ្រង់ជាព្រះដែលជ្រាបគ្រប់ការទាំងអស់ ទោះជាការនោះនៅក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាលក៏ដោយ។ ស្របទៅតាមស្តង់ដារនៃសេចក្តីបរិសុទ្ធនៃព្រះ យើងគឺសុទ្ធតែជាអ្នកមានបាប ហើយយើងត្រូវតែបើកឲ្យដឹងពីអំពើបាបទាំងនោះដើម្បីដោះស្រាយនឹងព្រះជាម្ចាស់ដោយសុចរិតនិងយុត្តិធម៌។

យើងត្រូវការមនុស្សម្នាក់លុបអំពើបាបដែលបានកត់ត្រាក្នុងសៀវភៅ។ ព្រះគម្ពីរប្រកាស ប្រាប់ថាមានតែព្រះយេស៊ូវតែមួយគត់អាចលោះទណ្ឌកម្មនៃអំពើបាបរបស់យើងគ្រប់រូបបាន។ *«យើងបានជាមេត្រីនឹងព្រះវិញទៅហើយ ដោយព្រះរាជបុត្រាទ្រង់សុគត»* (រ៉ូម ៥:១០)។ ពិតមែនហើយ ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានលះបង់ជីវិតទ្រង់ជំនួសយើងរាល់គ្នាជាប្រយោជន៍ឲ្យយើងបានរួចពីសេចក្តីស្លាប់ក្នុងអំពើបាប។ អំពើបាបពីអតីតកាលរបស់យើងត្រូវបានសងថ្លៃដាច់ ដោយសារព្រះដែលយើងបានធ្វើបទាស់ប្រឆាំងនឹងទ្រង់បានផ្តល់បង្កាន់ដៃបង់លោះបាបដល់យើង ជាបង្កាន់ដៃបញ្ជាក់ថាទ្រង់បានសព្វព្រះហឫទ័យនឹងការបញ្ចប់កិច្ចការនៅលើឈើឆ្កាងរបស់ព្រះគ្រីស្ទ ដោយព្រះអង្គប្រោសទ្រង់ពីការសុគតឡើងវិញ។ ព្រះគ្រីស្ទបានជាប់ឆ្កាង តែទ្រង់ក៏បានមានព្រះជន្មរស់ឡើងវិញពីស្លាប់ធ្វើជាព្រះសង្គ្រោះដ៏មានព្រះជន្មរស់របស់យើង។ ព្រះអង្គបានសុគតជាប្រយោជន៍សង្គ្រោះយើងពីទណ្ឌកម្មនៃអំពើបាប ហើយពេលនេះទ្រង់មានព្រះជន្មរស់នៅដើម្បីលោះយើងពីអំណាចនៃអំពើបាប។

**ទំនុកដំកើង៖** *ខ្ញុំឮ ព្រះអង្គសង្គ្រោះ ទ្រង់មានបន្ទូលមកថា*
*កូនអើយ ចិត្តមិនមុតមោះ ចូរពឹងអញឲ្យខ្លាំងក្លា*
*ព្រះយេស៊ូវទ្រង់លោះ ទ្រង់សងថ្លៃដាច់ហើយ*
*ខ្ញុំជំពាក់គុណទ្រង់ជាធ្ងន់ រកតបស្នងមិនបានឡើយ។* (និពន្ធដោយ៖ Elvina M Hall)

**ការពិចារណា៖** នៅក្នុងអ័ដាម គ្រប់គ្នាស្លាប់... នៅក្នុងព្រះគ្រីស្ទគ្រប់គ្នានឹងមានជីវិតរស់នៅ។
**ការអធិស្ឋាន៖** ព្រះយេស៊ូវអើយ សូមអរព្រះគុណទ្រង់ជាខ្លាំងដែលទ្រង់មានជ័យជំនះលើ សេចក្តីស្លាប់ដើម្បីឲ្យយើងខ្ញុំមានជីវិតដ៏នៅអស់កល្បជានិច្ច។

# FEBC - បានបង្កើតឡើងដោយព្រះ



## សម្រាប់ពេលវេលាបែបនេះ

ពេលសាកលវិទ្យាល័យជាន់ខ្ពស់និងមហាវិទ្យាល័យព្រះគម្ពីរនៅគ្រប់ទីកន្លែងប្រាស់ចាកចេញពីសេចក្តីជំនឿនាសម័យចុងក្រោយនេះមហាវិទ្យាល័យព្រះគម្ពីរ ហ្វាអ៊ីស្ទឺន **(Far Eastern Bible College)** នៅតែបន្តឈររឹងមាំ ឥតរង្គើរ នៅលើថ្មដាជាគ្រឹះរឹងមាំ ដ៏ជាព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើង និងនៅ លើព្រះបន្ទូលដ៏បរិសុទ្ធ ជាពាក្យដែលព្រះវិញ្ញាណបណ្តាលឲ្យតែង ឥតភាន់ច្រឡំ ឥតកំហុស និងអភិរក្សទុកយ៉ាងល្អសុក្រិត។

អែហ្វ អ៊ី ប៊ី ស៊ី **(FEBC)** ប្រកាន់ជំហរតាម **«**ដំណឹងល្អបែបប្រវត្តិសាស្ត្រ**»** ជា **«**សេចក្តីជំនឿដែលបានប្រគល់មកពួកបរិសុទ្ធ១ដងជាសំរេច**»**តយុទ្ធនឹងគោល លទ្ធិសាតាំងដែលបច្ចុប្បន្នកំពុងជ្រាបហូរ ហៀរក្នុងបណ្តាពួកជំនុំ ជាលទ្ធិមានដូចជា៖ លទ្ធិសេរីនិយម លទ្ធិសម័យនីយម លទ្ធិដំណឹងល្អសម័យនិយម លទ្ធិការីស្មាទិក លទ្ធិពួកជំនុំរួបរួមនិយម លទ្ធិរ៉ូម៉ាំងកាតូលិក និងលទ្ធិអាថ៌កំបាំងសម័យទំនើបនិយម ជាដើម។ល។

តើអ្នកមិនអាចមកសិក្សានៅ អែហ្វ អ៊ី ប៊ី ស៊ី**?** អញ្ជើងសូមអនុញ្ញាតឲ្យ អែហ្វ អ៊ី ប៊ី ស៊ី មកឯលោកអ្នកវិញ**!** សិក្សាដើម្បីទទួលវិញ្ញាបនប័ត្រចំណេះដឹងផ្នែកសាសនា **(CertRK)** មិនថាអ្នករស់នៅទីណាឡើយ។ ទទួលបាននូវ វិញ្ញាបនប័ត្រនេះតាមប្រពន្ធ័សិក្សាតាមអ៊ីធីណែត**!** មុខវិជ្ជាជាច្រើនចាប់ផ្តើមបង្រៀននៅខែ មករានិងខែ កក្កដា ជារៀងរាល់ឆ្នាំ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅក្នុងគេហទំព័រមហាវិទ្យាល័យ។

ដើម្បីទទួលបាននូវការបង្ហាត់បង្រៀនដ៏ត្រឹមត្រូវតាមបទគម្ពីរ បែបប្រ៉ូតេស្តង់
និងវិជ្ជាខ្ពង់ខ្ពស់បែបចលនាកែទម្រង់ សូមចូលរួមសិក្សានៅ

## មហាវិទ្យាល័យព្រះគម្ពីរ ហ្វាអ៊ីស្ទឺន

**(FAR EASTERN BIBLE COLLEGE)**


អាស័យដ្ឋាន៖ **9A Gilstead Road, Singapore 309063**
**E-mail: febc@febc.edu.sg**
**Website: http://www.febc.edu.sg**
ទំនាក់ទំនងនៅកម្ពុជា **+85512383513**
**+85569567990**